ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## ថ្នាក់ទី ១០

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

**គណៈកម្មការនិពន្ធ** លោក ឃិន ធី លោកស្រី អៀ ចាន់នារី
លោកស្រី ម៉ៅ តាន់ណារី លោក ណាន ម៉ារ៉ាឌី
លោក ព្រៃ សំបូរ

**អ្នកវាយអត្ថបទ** លោក សេង តុងបុត្តា

**វិចិត្រករ** លោក ឃុន សុវណ្ណរិទ្ធី

**អ្នករៀបរៀង** លោកជំទាវ ទន់ សាអ៊ឹម

**អ្នករចនាទំព័រ** លោក គង់ ចិត្រា

**គណៈកម្មការពិនិត្យ** លោកស្រី ញេប ពិដោរ
លោក នៅ ស៊ុន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ១០៩៣ អយក.ប្រក. ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី១១ ឆ្នាំ២០២០ ចំនួន៣៦ ០០០ ច្បាប់

ISBN 9-789-995-000-967

youtube.com/moeys
kou.moeys.gov.kh
facebook.com/moeys.gov.kh

# អារម្ភកថា

សៀវភៅភាសាខ្មែរថ្នាក់ទី១០ នេះ បាននិពន្ធឡើងតាមកម្មវិធីសិក្សាថ្មី របស់ក្រសួងអប់រំ យុវជន និងកីឡា។ សៀវភៅនេះបន្តពង្រឹងនិងពង្រីកសមត្ថភាពអាន និយាយ ស្តាប់ និងសរសេរពីមធ្យមសិក្សាបឋមភូមិ ឱ្យកាន់តែប្រសើរឡើងថែមទៀត។

សៀវភៅនេះបង្ហាញអំពីប្រធានបទសំខាន់ៗស្តីពី មោទនភាពជាតិ អត្តសញ្ញាណជាតិ ការគោរពបូជា ការទទួលស្គាល់ការពិត ភាពជាពលរដ្ឋ។ល។ ដើម្បីរួមចំណែក អភិវឌ្ឍគំនិតប្រាជ្ញា ស្មារតី និងការទទួលខុសត្រូវរបស់កុលបុត្រ កុលធីតាខ្មែរចំពោះជាតិមាតុភូមិ។ មេរៀននៅក្នុងសៀវភៅនេះនឹងជួយអ្នកសិក្សា ឱ្យទទួលបានចំណេះដឹងនិងបំណិនកាន់តែស៊ីជម្រៅ និងច្បាស់លាស់ ទៅលើអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ បុរាណ ទំនើប អត្ថបទអត្ថាធិប្បាយ ល្ខោន ចម្រៀង របាំ វេយ្យាករណ៍ និងសំណេរជាច្រើនដូចជា បំពេញទម្រង់បែបបទផ្សេងៗ តាក់តែងរឿង តែងសេចក្តី អត្ថបទព័ត៌មាន វិភាគអត្ថបទជាដើម។ល។

តាមរយៈខ្លឹមសារ បំណិន សំណួរ លំហាត់ ការសិក្សាពាក្យគន្លឹះ នៅក្នុងសៀវភៅនេះ នឹងជំរុញឱ្យអ្នកមានការអភិវឌ្ឍនិងទទួលបានបំណិន ចំណេះដឹងកាន់តែស៊ីជម្រៅថែមទៀតលើផ្នែកភាសាខ្មែរ ដើម្បីតម្រង់ទិសការសិក្សានៅថ្នាក់បន្តទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី១០ ថ្មីនេះនឹងក្លាយជាមិត្តដ៏ល្អរបស់អ្នកជាពុំខាន។

សូមឱ្យការសិក្សារបស់ប្អូនៗទទួលបានជោគជ័យជានិច្ច។

**គណៈកម្មការនិពន្ធ**

facebook.com/moeys.gov.kh khmer.moeys.gov.kh youtube.com/moeys

# បញ្ជីអត្ថបទ

ទំព័រ

១. មោទនភាពជាតិ.......................................................១

២. អត្តសញ្ញាណជាតិ.....................................................៣៣

៣. ការគោរពបូជា.......................................................៥៧

៤. សប្បុរសធម៌.......................................................៨៧

៥. សោភ័ណភាសា.......................................................១១៣

៦. ការទទួលស្គាល់ការពិត.................................................១៣៥

៧. ភាពជាពលរដ្ឋ.......................................................១៥៧

៨. ការសម្រេចចិត្ត.....................................................១៨១

៩. សោភ័ណសិល្បៈ.......................................................១៩៧

១០. ជំនឿ.............................................................២១៧

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី ១

# មោទនភាពជាតិ



ប្រទេសយើងក្នុងសម័យបុរាណកាល ជារដ្ឋរុងរឿង ខ្ពង់ខ្ពស់ ថ្លៃថ្នូរ មានឈ្មោះល្បីជាងគេនៅអាស៊ីអាគ្នេយ៍យើងនេះ ។ ទឹកដីល្អផូរផង់ដោយសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ដ៏ថ្លៃថ្លានិងច្រើនមហិមា ជាកេរដំណែលមិនអាចកាត់ថ្លៃបាន ដែលដូនតាខ្មែរបន្សល់ទុកសម្រាប់កុលបុត្រ កុលធីតាខ្មែរគ្រប់ជំនាន់ ។ មរតកទាំងអស់នេះហើយ ដែលធ្វើឱ្យយើងជាកូនខ្មែរជំនាន់ក្រោយ មានមោទនភាពជាតិក្រៃលែង ។

សេចក្ដីស្រឡាញ់ ការពេញចិត្ត ការលើកតម្កើង ការឱ្យតម្លៃខ្ពស់ចំពោះជាតិខ្លួនត្រូវតែសម្ដែងចេញជាការចូលរួមយ៉ាងសកម្មក្នុងការកសាង ការពារ និងអភិវឌ្ឍជាតិ ។ ក្នុងមេរៀននេះអ្នកនឹងបានសិក្សាអំពីប្រវត្តិឈ្មោះភូមិ ស្រុកមួយចំនួនរបស់ខ្មែរ និងស្មារតីជម្នះការលំបាកគ្រប់បែបយ៉ាងក្នុងបុព្វហេតុជាតិ ទឹកដី ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបំណិនមួយចំនួនដូចជា កាលអាកាស លក្ខណៈតថៈរបស់រឿង ការសង្ខេប និងសំណេរបំពេញលិខិតឯកជនមួយចំនួន ។

# កាលអាកាស

នៅក្នុងរឿងនីមួយៗ យើងតែងសង្កេតឃើញមានការផ្លាស់ប្តូរ ប្រែប្រួលពេលវេលានិងទីកន្លែងនៃការប្រព្រឹត្តទៅនៃដំណើររឿង ។ ពេលវេលាអាចជា ពេលយប់ ពេលថ្ងៃ រដូវកាល ខែ ឆ្នាំ ...និងទីកន្លែងអាចជាកន្លែងដែលស្ថិតនៅក្នុងផ្ទះ ភូមិ ស្រុក ឬក្នុងព្រៃ លើអាកាស ស្ថានមនុស្ស ស្ថានសួគ៌ ស្ថាននរក ... ។ ដូចម្តេចហៅថា កាលអាកាស ?

ចូរពិនិត្យឧទាហរណ៍ខាងក្រោម :

សម័យទីក្រុង តាំងទីនៅឧត្តុង្គ នៅស្រុកសម្បូរ ខេត្តក្រចេះ មានចៅអធិការវត្តមួយអង្គ ជាអ្នកប្រព្រឹត្តរៀននូវវិជ្ជាវេទមន្តអាគម ហើយជាអ្នកចេះចិញ្ចឹមក្រពើ ។ លោកគ្រូចៅអធិការនោះ ចិញ្ចឹមក្រពើមួយ ទុកដូចជាកូនសិស្សរបស់លោក ។ ក្រពើនោះរស់នៅក្នុងទន្លេមេគង្គ ជាទន្លេដែលប្រកបដោយទឹកជ្រៅមានត្រីច្រើន ។ លោកឱ្យឈ្មោះក្រពើនោះ "អាធន" ។

សម័យមួយ កាលព្រះមហាក្សត្រទ្រង់គង់នៅក្រុងឧត្តុង្គ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គ ទ្រង់ប្រឈួនជាខ្លាំង ។ ព្រះអង្គស្រឡាញ់ព្រះរាជបុត្រីយ៉ាងខ្លាំងឥតឧបមា ព្រះអង្គទ្រង់ខ្វឹកខ្វួលតក់ស្លុតជាពន្លឹក ហើយទ្រង់ឱ្យជ្រើសរើសរកពេទ្យហ្ម ដែលពូកែមានឈ្មោះល្បីអស្ចារ្យមកព្យាបាលព្រះរាជបុត្រីព្រះអង្គ ក៏ប៉ុន្តែគ្មានគ្រូឯណាមួយអាចរំលែកទុក្ខព្រះរាជបុត្រីបានឡើយ ។ ហេតុនេះបានជាព្រះមហាក្សត្រទ្រង់ឱ្យនិមន្តចៅអធិការវត្តសម្បូរដែលមានឈ្មោះពូកែល្បីជាងគ្រូពេទ្យឯទៀតមកព្យាបាល ។

ការធ្វើដំណើរតាមទន្លេមេគង្គដោយកប៉ាល់ ពីស្រុកសម្បូរទៅឧត្តុង្គក្នុងសម័យនេះតែ ២ ថ្ងៃទេ តែក្នុងសម័យទីក្រុងតាំងនៅឧត្តុង្គនោះ គេធ្វើដំណើរដោយទូកជាយូរថ្ងៃ ព្រោះទន្លេនោះ មុនពេលទៅដល់ក្រចេះមានទឹកហូរស្រួលល្អទេ តែចាប់ពីក្រចេះទៅ ត្រូវឆ្លងទឹកហូរក្តួចខ្លាំងៗនិងមានថ្មស្រួចៗដុះនៅក្នុងទឹកដោយអន្លើៗ ។

លោកគ្រូចៅអធិការនិមន្តព្យាបាលព្រះរាជបុត្រី ព្រះរាជបុត្រីក៏បានស្រាកស្បើយជំងឺធូរគ្រាន់បើ ប៉ុន្តែព្រះមហាក្សត្រទ្រង់ពុំអនុញ្ញាតឱ្យលោកគ្រូចៅអធិការវិលទៅវិញភ្លាមទេ ទ្រង់ឱ្យលោកនៅរង់ចាំថែទាំជំងឺព្រះបុត្រី លុះត្រាតែជាស្រឡះមែនទែនសិន ។

និយាយអំពីអាធនដែលនៅស្រុកសម្បូរ វាទន្ទឹងមើលផ្លូវលោកគ្រូរបស់វាជាយូរខែថ្ងៃពុំឃើញវិលមកសោះ វាកើតមានសេចក្តីស្រងូតស្រងាត់នឹករលឹកដល់លោកគ្រូវាជាអនេក ។ ថ្ងៃមួយវាព្រួយខ្លាំងពេក វាក៏ហែលចេញពីទីលំនៅទៅតាមដងទន្លេមេគង្គឆ្ពោះត្រង់ទៅតាមលោកគ្រូវានៅឧត្តុង្គ ។ វាធ្វើដំណើរពីស្រុកសម្បូរទៅដល់ឆ្លងគ្មានជួបប្រទះនឹងសត្រូវ ឬគ្មានអន្តរាយអ្វីដល់ខ្លួនវាសោះ ប៉ុន្តែលុះវាទៅដល់ភ្នំមួយឈ្មោះ "ភ្នំសុពណ៌កាលី" វាបានជួបនឹងក្រពើមួយជាក្រពើសាហាវក្លាហាន

ឈ្លានពានណាស់ ដោយក្រពើនោះក្រេវក្រោធនឹងអាធនដែលហែលកាត់ទីលំនៅរបស់វា វាក៏រករឿងដាលវាលឈ្លោះ ប៉ុន្តែដោយអាធនមានកិច្ចរួសរាន់ចង់ជួបនឹងលោកគ្រូរបស់វាៗក៏ដោះដៃរត់អំពីក្រពើកំណាចនេះទៅ ។ [...]

*(ដកស្រង់ពីរឿងក្រពើឈ្មោះអាធន ប្រជុំរឿងព្រេងខ្មែរភាគ៥)*

តាមឧទាហរណ៍ខាងលើ ដំណើររឿងប្រព្រឹត្តទៅតាមពេលវេលានិងទីកន្លែងដូចខាងក្រោម ៖

**ពេលវេលា** : សម័យមួយ យូរថ្ងៃ យូរខែថ្ងៃ ថ្ងៃមួយ ... ។

ទីកន្លែង : រាជវាំងឧត្តុង្គ ស្រុកសម្បូរ ខេត្តក្រចេះ ទន្លេមេគង្គ ... ។

*កាលអាកាស គឺជាពេលវេលា និងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។ ពេលវេលានិងទីកន្លែងនៃរឿង ជួនកាលអ្នកនិពន្ធលើកឡើងតាមស្ថានភាពពិតជាក់ស្តែង ជួនប្រឌិតឡើងតាមមនោគតិរបស់ខ្លួន ។*

## លំហាត់

ចូរអ្នកបង្ហាញកាលអាកាសរបស់រឿងខាងក្រោម ៖

១. [...] បន្ទាប់ពីនេះ តាគហោពបក្សីចាំក្រុងរត់កាត់ព្រៃទៅដល់ទួលមួយមានដើមរលួសម្លប់ត្រឈៃល្អ ក៏ឈប់សម្រាកនៅទីនោះ បានជាទីនោះហៅ **ភូមិរលួស** នៅក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាបសព្វថ្ងៃនេះ ។ តពីនោះតាគហោនិងបក្សីចាំក្រុង បានសុំដោយសារទូកគេមកដល់ខេត្តជើងព្រៃ កងទ័ពបានតាមមកជិតទាន់ ក៏នាំបក្សីចាំក្រុងពួនក្នុងព្រៃមួយ ។ វេលាយប់នោះមានមូសច្រើន បក្សីចាំក្រុងបួងសួងថា "បើខ្ញុំមានបុណ្យ សុំកុំឱ្យមានមូសក្នុងទីនេះ" ។ ការបួងសួងនេះបានសម្រេចដូចបំណងមែន ។ ទីទួលដែលតាគហោពួននេះ មានឈ្មោះ **ទួលគហោ** នៅតំបន់រកាកោង ស្រុកមុខកំពូល ខេត្តកណ្តាលសព្វថ្ងៃនេះ ។

លុះព្រឹកឡើង តាគហោក៏នាំបក្សីចាំក្រុងរត់បន្តទៀតដល់មាត់ទន្លេ តែគ្មានទូកឆ្លងឡើយ បក្សីចាំក្រុងក៏អធិដ្ឋានថា បើខ្ញុំមានបុណ្យវាសនាត្រូវបានសោយរាជ្យ និងទំនុកបម្រុងព្រះពុទ្ធសាសនាមែន សូមឱ្យដើមរកានៅត្រើយខាងជើងកោងទៅ ឯដើមល្វាខាងត្បូងទេរមក ។ ដើមឈើទាំងពីរក៏ទេររកគ្នាដូចការអធិដ្ឋានមែន តាគហោក៏ពបក្សីចាំក្រុងឆ្លងតាមដើមឈើទាំងពីរនោះរួចទៅ ។ ដើមឈើទាំងពីរក៏ងើបឈរត្រង់ដូចដើមវិញ ទើបទីនោះនៅត្រើយខាងជើងមានឈ្មោះថា **រកាកោង** ស្ថិតនៅក្នុងទឹកដីស្រុកមុខកំពូល ឯត្រើយខាងត្បូងមានឈ្មោះថា **ល្វាទេរ** ស្ថិតក្នុងទឹកដីស្រុកស្រីសន្ធរសព្វថ្ងៃនេះ ។ [...]

*(ដកស្រង់ពីរឿង វត្តវិហារសួគ៌ ប្រជុំរឿងព្រេងខ្មែរ ភាគ៥)*

## ២. រឿងវត្តសំពៅប្រាំ

ក្នុងកាលកន្លងយូរមកហើយ មានស្តេចខ្មែរយើងមួយព្រះអង្គព្រះនាមព្រះថោង ។ រឿងដើមនៃក្សត្រអង្គនេះ គឺព្រះអង្គជាព្រះអង្គម្ចាស់ មានការតូចព្រះទ័យនឹងបិតា ដែលតម្រូវឱ្យព្រះអង្គគោរពបូជាព្រះអនុជពៅ ម៉្លោះហើយទ្រង់យាងចេញពីព្រះរាជវាំងជាមួយស្នំគ្របក្សព្ទពួកឆ្ងាយពីរាជវាំង ទៅដល់ឆ្នេរខ្សាច់មួយ ដែលមានដើមធ្លកមួយដើមដុះនៅកណ្តាលវាលខ្សាច់នោះ ។ ព្រះអង្គបញ្ឈប់ពលរេហ៍នៅទីនោះសម្រាកកាយក្រោមដើមធ្លក ។ ពេលព្រលឹមស្វាងឡើង ព្រះអង្គយាងមួយព្រះអង្គឯងលំហែកាយតាមសមុទ្រ ។ លុះធ្វើដំណើរកាន់តែឆ្ងាយទៅៗ ស្រាប់តែឮសូរសំឡេងមនុស្សអ៊ូអរព្រះអង្គក៏យាងទៅជិត ហើយបានជួបនឹងនាងនាគដែលកំពុងនាំភីលៀងមកកម្សាន្តឆ្នេរសមុទ្រនោះ ។ ព្រះអង្គបានលួងលោមប្រតិព័ទ្ធ នាងនាគក៏យល់ព្រម តែសុំឱ្យព្រះអង្គតោងកន្ទុយនាងនាគ ដើម្បីជ្រែកទឹកទៅកាន់ឋាននាគ ថ្វាយបង្គំព្រះបាទភុជង្គនាគជាព្រះវរបិតា ។ លុះព្រះអង្គតាមព្រះនាងទៅដល់ឋាននាគអស់រយៈប្រាំពីរថ្ងៃ ក៏សុំលាព្រះបិតាក្មេក នាំមហេសីវិលមកឋានមនុស្សវិញ ។ កាលនោះព្រះបាទភុជង្គនាគ ក៏បានរៀបចំប្រដាប់ប្រដាជាទ្រព្យមានតម្លៃចំនួនប្រាំសំពៅ ដើម្បីដង្ហែព្រះរាជបុត្រ មកគ្រប់គ្រងនៅឋានមនុស្សលោក ។ សំពៅទាំងប្រាំនេះបើកក្តោងសំដៅដល់មាត់សមុទ្រ ក៏ចូលចតតម្រៀបគ្នា រើប្រដាប់ប្រដាចេញពីសំពៅ ហើយដឹកជញ្ជូនយកទៅរកទីណាមួយមានដីទួលខ្ពស់រៀបចំកសាងជាទីក្រុង ។ ឯសំពៅទាំងប្រាំនោះ ក៏បញ្ញើរទុកសម្រាប់ព្រះអង្គមានដំណើរទៅណាមកណា ទ្រង់គង់ក្រសាលតាមព្រះចិន្តា ។ ពលរេហ៍ទាំង ៥០០នាក់ ក៏ដង្ហែព្រះថោងនិងនាងនាគទៅចាប់ស្តាបនាទីក្រុង រាជនិវេសន៍ទាំងអស់គ្នាបាត់ទៅ នៅសល់តែសំបកសំពៅ ។ លុះអស់កាលជាយូរលង់ក្រោយមក ឆ្នេរសមុទ្រក៏ចេះតែស្រុតស្រកឆ្ងាយទៅៗ ដីក៏កាន់តែដុះខ្ពស់ឡើងៗសំពៅទាំង ៥ នោះក៏កឿងនៅជាប់នឹងច្រាំងហើយយូរៗទៅក៏រឹងទៅជាថ្មលិចបាត់តួសំពៅទៅក្នុងដីនៅសល់តែក្តោងទាំង៥ ដែលគេឃើញសព្វថ្ងៃនេះ ។

*(ដកស្រង់ពីរឿងវត្តសំពៅប្រាំ ប្រជុំរឿងព្រេងខ្មែរភាគ ៦)*



# រឿង ភ្នំបាយ័ងកោរ នៅខេត្តតាកែវ



krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

## ក. សិក្សាពាក្យគន្លឹះ

- ឧបាយកល (ន) : កិច្ចការ ល្បិចល្បួងយ៉ាងល្អិតម៉ត់ចត់ ។
- ព្រះសិរសា (ន) : រ.ស ក្បាល ។
- នមស្ការ (ន) : កិរិយាថ្វាយបង្គំ ការក្រាបប្រណិប័តន៍ នឹកគុណ ... ។
- យុថ្កា (ន) : ឧបករណ៍ បោះទៅក្នុងទឹកសម្រាប់ចតនាវា សំពៅកុំឱ្យរសាត់ ។
- បព្វតា (ន) : ភ្នំ ។
- ព្រះពន្លា (ន) : រោង ឬសាលាដែលគេសង់សម្រាប់ថ្វាយព្រះរាជាគង់ប្រថាប់បណ្ដោះអាសន្ន ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកត្រូវយកចិត្តទុកដាក់កត់ចំណាំសេចក្តីលំអិតសំខាន់ៗ ដើម្បីត្រៀមឆ្លើយទៅនឹងសំណួរទាក់ទងនឹងកាលអាកាស លក្ខណតថៈនៃរឿង និងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ

ក្នុងសម័យព្រេងនាយ នៅប្រទេសខ្មែរមានស្តេចមួយព្រះអង្គព្រះនាមព្រះបាទបាយ៉ង់ មានព្រះដំណាក់នៅភ្នំដងរែក មានអគ្គមហេសីល្អណាស់ ព្រះនាមព្រះនាងសក់ក្រអូប ។ ព្រះនាងប្រកបដោយរូបឆោមនិងព្រះភក្រ្តល្អប្រិមប្រិយ សម្បុរភ្លឺថ្លាដូចនាងទេពធីតា ក្លិនក្រអូបសាយចេញជុំវិញព្រះកាយមួយយោជន៍ ល្បីកិត្តិយសសុសសាយទៅដល់ព្រះចៅសៀម ។ ព្រះចៅសៀមក៏ចាត់ឱ្យមនុស្សមកស៊ើបអង្កេតបានដឹងពិតថាព្រះនាងល្អឆើតមែនដាច់ស្រីទាំងឡាយ ជាស្រីបរិបូណ៌ដោយលក្ខណៈគ្រប់យ៉ាង ។

ស្តេចសៀមរកឧបាយកលចូលមកចាប់ព្រះនាងយកទៅ ដើម្បីជាកិត្តិយសប្រទេសខ្លួន ។ ស្តេចបាយ៉ង់ទ្រង់ជ្រាបការដូច្នោះ ក៏នាំព្រះអគ្គមហេសី ពួកស្រីស្នំក្រមការ និងពលសេនាទាំងឡាយចុះសំពៅភៀសព្រះអង្គរត់ចេញចោលព្រះដំណាក់ទាំងវេលាយប់ ដោយបើកសំពៅសំដៅទៅទិសអាគ្នេយ៍ ។ មុននឹងស្តេចយាងចេញ ទ្រង់លើកព្រះហស្តប្រណម្យដាក់លើព្រះសិរសាសច្ចាបន់ស្រន់ទេវតារក្សាទឹកថា សូមឱ្យបានសម្រេចសេចក្តីប្រាថ្នាបីប្រការគឺ

១. សូមឱ្យបានសេចក្តីសុខក្នុងដំណើរផ្លូវសាគរ

២. សូមកុំឱ្យពួកសៀមតាមទាន់

៣. សូមឱ្យជួបប្រទះកន្លែងជាទីគាប់ចិត្ត ។

បើបានសម្រេចដូចបំណង នឹងកោរព្រះកេសាថ្វាយ ។ ស្តេចទ្រង់ព្រួយព្រះទ័យជាខ្លាំង ទ្រង់បើកសំពៅទាំងយប់ទាំងថ្ងៃគ្មានឈប់ឈរ ។ លុះទ្រង់ប្រមើលមើលឃើញថា ចេញមកបានឆ្ងាយណាស់ហើយ ទើបទ្រង់ងាករេទៅរកតំបន់មួយដើម្បីចតសំពៅ ។ ជួនជាខណៈនោះ ខ្យល់ព្យុះមកដល់បក់បោកសំពៅឱ្យវិលវល់ចង្កូត ទើបទីត្រង់នោះមានឈ្មោះថា **ភូមិបាក់ចង្កូត** ជាប់មក តែសព្វថ្ងៃគេហៅក្លាយជា**ភូមិបាក់កូត** ។ ស្តេចទ្រង់ភ័យហើយលើកព្រះហស្តអំពាវនាវ "ឱ្យបាត់ខ្យល់ព្យុះទ្រង់នឹងសូមសែនថ្វាយដល់ពពួកអារក្សទឹកទាំងឡាយ" ។ គ្រានោះខ្យល់ព្យុះក៏សាបសូន្យអស់ សំពៅទៅបានបន្តិចទៀតឈប់បោះយុថ្កាចត ទើបទីនោះមានឈ្មោះថា **កន្លែងចត** ជាប់មក តែសព្វថ្ងៃនេះគេហៅថា **ភូមិកន្លែងចត** ហើយហៅក្លាយជា **ភូមិចត** ។ ការឈប់ចតនេះ ដើម្បីរៀបចំចំណីអាហារសែនព្រេនថ្វាយអារក្សទឹកនិងធ្វើចង្កូតសំពៅជាថ្មី ។ ត្រង់តំបន់ដែលថ្វាយអាហារនោះ មានឈ្មោះជាប់មកដល់សព្វថ្ងៃថា **ភូមិសែនបន់** ។ ទាំងបីកន្លែងនេះ ស្ថិតនៅក្នុងឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ។

លុះសម្រេចកិច្ចនៅកន្លែងនេះសព្វគ្រប់ហើយ ទ្រង់ក៏ចេញសំពៅទៅទៀតសំដៅទៅទិសអាគ្នេយ៍ដដែល ។ លុះដល់កន្លែងមួយសំពៅធ្លាយ ទ្រង់ក៏ចាប់ធ្វើសំពៅបណ្ដើរបើកទៅបណ្ដើរ ។ ត្រង់កន្លែងនោះជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃថា **សំពៅធ្លាយ** ។ សំពៅបើកបន្តិចទៀតទៅដល់កន្លែងមួយឃើញមានស្បូវដុះជាច្រើន ក៏បោចស្បូវនោះចុកសំពៅដែលធ្លាយ ។ កន្លែងនោះជាប់ឈ្មោះមកដល់សព្វថ្ងៃថា **ភូមិព្រែកស្បូវ** ហើយបើកសំពៅធ្វើដំណើរទៅទៀតដល់កន្លែងមួយទៀត ព្រះនាងសក់ក្រអូបទ្រង់កើតទុក្ខព្រួយព្រះហឫទ័យច្រើនប្រការ ណាមួយព្រួយអំពីសំពៅដែលចេះតែទៅរកទិសសំណាក់មិនឃើញ ណាមួយព្រួយអំពីពួកសៀមថា មុខជាគេនឹងតាមមកមិនខាន ។ ព្រះនាងទ្រង់អុជទៀននមស្ការបន់ស្រន់ដល់អារក្សទឹក អារក្សគោក អ្នកតាព្រៃភ្នំក្រំថ្ម សព្វទីកន្លែងថា សូមឱ្យបានជួបនឹងទីសុខប្រសើរ សូមឱ្យចោរសៀមចិត្តអប្រិយបរាជ័យវិនាសក្នុងសាគរ ។ ត្រង់កន្លែងដែលព្រះនាងអុជទៀនបន់នោះ នៅជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃហៅថា **ភូមិអន្លង់ទៀន** ។

ពិធីនមស្ការអំពាវនាវរបស់ព្រះនាងនោះ បានសម្រេចដូចសេចក្ដីប្រាថ្នាមែន គឺសំពៅស្ដេចសៀមដែលបានបញ្ជូនពលចំនួនមួយសែននាក់ឱ្យចេញទៅតាមស្កាត់រកព្រះនាងនោះ ជួសផ្លូវគ្នាដោយសំពៅស្ដេចបាយ៉ង់ ចេញផ្លូវក្រោមផ្នែកខាងកើត សំពៅសៀមចេញផ្លូវលើផ្នែកខាងលិច ។ ក្រោយពេលដែលព្រះនាងបន់ស្រន់រួចហើយ សំពៅស្ដេចបាយ៉ង់ក៏ងាកសំដៅទៅទិសនិរតីបន្តិច ។ បន្ទាប់ពីនោះស្រាប់តែមានខ្យល់ព្យុះយ៉ាងសម្បើមអស្ចារ្យ បក់បោកសំពៅសៀមខ្ទេចខ្ទីលិចលង់ងាប់អស់ពួកពលនៅក្នុងមហាសាគរ ។ ត្រង់កន្លែងនោះមានឈ្មោះថា **ភូមិសែនលង់** ជាប់មក តែសព្វថ្ងៃគេហៅក្លាយមកជា **ភូមិសន្លុង** វិញ ។

ចំណែកសំពៅស្ដេចបាយ៉ង់ កាលបើកលឿនត្រង់ទៅទិសនិរតី ស្ដេចទតឃើញកោះនិងភ្នំច្រើនត្រៀបត្រា ព្រះអង្គក៏ចូលទៅបោះយុថ្កាចតសំពៅនៅក្បែរកោះមួយ ស្ដេចយាងឡើងទៅលើកោះនោះដើម្បីរកកន្លែងសមគួរនឹងជ្រក ។ ព្រះអង្គបានទតឃើញកន្លែងដ៏ល្អៗជាច្រើន ប៉ុន្តែមិនសូវគាប់ព្រះទ័យក៏ឱ្យពួកពលជញ្ជូនអីវ៉ាន់ចេញពីសំពៅ នាំព្រះអគ្គមហេសីយាងចូលទៅក្នុងព្រៃច្រកបព្វតា ហើយចតសំពៅនៅត្រង់កន្លែងនោះ ។ គ្រាន់តែស្ដេចយាងចេញផុតភ្លាមមហាមេឃក៏ងងឹតបណ្ដាលឱ្យទៅជាមានភ្លៀងផ្គរយ៉ាងខ្លាំង ។ ក្រោយពីស្ដេចនិងព្រះនាងព្រមទាំងព្រះបរិពារឡើងគោកហើយ ស្រាប់តែរន្ទះបាញ់សំពៅក្រឡាប់លិចលង់នៅកំពង់នោះ ។ ត្រង់កន្លែងនោះជាប់ឈ្មោះថា **ភ្នំរន្ទះ** រហូតមកដល់សព្វថ្ងៃ ។

បន្ទាប់ពីនោះស្ដេចបាយ៉ង់ចេះតែខិតខំស្វែងរកទីភូមិឋាន ដើម្បីបានសង់ព្រះរាជដំណាក់ស្នាក់អាស្រ័យ ។ គ្រានោះទ្រង់បានជួបនឹងទីទួលមួយខ្ពស់ល្អ គួរជាទីរីករាយក្រៃពេក ទ្រង់ក៏ធ្វើព្រះពន្លា

បណ្តោះអាសន្ននៅទីនោះទៅ។ លុះស្តេចបានស្នាក់អាស្រ័យបានស្រួលបួលហើយ ទ្រង់ក៏សំណេះសំណាលជាមួយនឹងព្រះអគ្គមហេសី អំពីសេចក្តីកម្សត់ ទុក្ខវេទនារបស់ព្រះអង្គនិងព្រះនាងតាំងពីដើមទីមក។ ព្រះនាងទ្រង់រំលឹកព្រះរាជាពីរឿងដែលទ្រង់បន់ថា "នឹងដាក់ព្រះកេសា(កោរសក់) ថ្វាយអារក្សទឹកនោះ ពេលនោះព្រះអង្គត្រូវដាក់កេសាលាបំណន់"។ ព្រះរាជាក៏ចាត់ពិធីដាក់ព្រះកេសាលាបំណន់ក្នុងវេលានោះឯង ព្រោះស្តេចបាយ៉ង់ទ្រង់បន់កោរ ហើយទ្រង់កោរព្រះកេសថ្វាយអារក្សទឹកលាបំណន់ដូច្នេះ បានជាជាប់ព្រះនាមថា **ស្តេចបាយ៉ង់កោរ** ហើយនិងដីទួលខ្ពស់ដែលទ្រង់ធ្វើព្រះពន្លាជាប់ឈ្មោះថា **ភ្នំបាយ៉ង់កោរ** រហូតមកដល់សព្វថ្ងៃនេះ។

*(ដកស្រង់និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរ ភាគ៥)*

## សំណួរ

១. ហេតុអ្វីបានជាព្រះបាទបាយ៉ង់រត់ភៀសខ្លួនពីព្រះរាជដំណាក់នៅភ្នំដងរែក ? មុននឹងភៀសខ្លួន តើព្រះអង្គបានបន់ស្រន់ទេវតា អារក្សទឹកដូចម្តេចខ្លះ ?

២. នៅពេលភៀសខ្លួន តើព្រះនាងសក់ក្រអូបបានបន់ស្រន់ អារក្សទឹក អារក្សគោក និងអ្នកតាព្រៃភ្នំដូចម្តេចខ្លះ ? តើការបន់ស្រន់មានប្រសិទ្ធភាពដូចម្តេចដែរ ?

៣. ហេតុអ្វីបានជាព្រះរាជាប្តូរព្រះនាមទៅជាព្រះបាទបាយ៉ង់កោរ ?

៤. ចូរបង្ហាញពីកាលអាកាសរបស់រឿងនេះ។

៥. ចូររៀបរាប់ឈ្មោះភូមិ ស្រុក ឬទីកន្លែងដែលជាប់ឈ្មោះក្នុងរឿងនេះ។

៦. តាមរយៈឈ្មោះភូមិ ស្រុក ឬទីកន្លែងពិតប្រាកដក្នុងដំណើររឿងនេះ តើអ្នកមានយោបល់យ៉ាងណាចំពោះ ប្រវត្តិទឹកដីខ្មែរយើង ។

youtube.com/moeys facebook.com/moeys.gov.kh

# នាម

នៅពេលដែលគេហៅ ឬនិយាយពីឈ្មោះ មនុស្ស សត្វ វត្ថុ រុក្ខជាតិ ឬធម្មជាតិ គេប្រើនាម ។ តើនាមជាអ្វី ? ចូរពិនិត្យឧទាហរណ៍ ៖

- អង្គរវត្តជាតំបន់ទេសចរណ៍មួយយ៉ាងសំខាន់របស់កម្ពុជា ។
- មីងៗនាំកូនទៅលេងបុណ្យ ។
- ពូសំ លី នង្គ័លទៅស្រែ ។

**ពាក្យ :** អង្គរវត្ត តំបន់ទេសចរណ៍ កម្ពុជា មីងៗ កូន បុណ្យ ពូសំ នង្គ័ល ស្រែ គឺជានាម ។

តើនាមមានអ្វីខ្លះ ?

## ១ . សាធារណនាម ឬនាមសាធារណ៍

សាធារណនាម ឬនាមសាធារណ៍ គឺជានាមសម្តែងឈ្មោះទូទៅមិនចំពោះ ។

*ឧទាហរណ៍ :*

- កសិករបាចជីក្នុងស្រែ ។
- សាលារៀននេះ ទើបតែសង់ថ្មី ។
- សៀវភៅនេះ មានចំណុចដែលនិយាយពីពិធីបុណ្យប្រពៃណី ។

**ពាក្យ :** កសិករ ស្រែ សាលារៀន សៀវភៅ បុណ្យប្រពៃណី ជាសាធារណនាម ។

សាធារណនាមមានដូចជា កម្មករ ពលករ មាមីង បងប្អូន សាលារៀន ប្រាសាទ បុណ្យ ... ។

## ២ . អសាធារណនាម ឬនាមអសាធារណ៍

អសាធារណនាម គឺជានាមសម្តែងឈ្មោះមិនទូទៅ ចំពោះប្រាកដច្បាស់លាស់ ។

*ឧទាហរណ៍ :*

- កម្ពុជាសម្បូរប្រាសាទបុរាណណាស់ ។
- ប្រាសាទបន្ទាយស្រីស្ថិតក្នុងខេត្តសៀមរាប ។

**ពាក្យ :** កម្ពុជា ប្រាសាទបន្ទាយស្រី ខេត្តសៀមរាប ជានាមអសាធារណ៍ ឬអសាធារណនាម ។

អសាធារណនាម ឬនាមអសាធារណ៍មានដូចជា ភ្នំពេញ បុណ្យផ្កា ពូសំ ប្រាសាទភ្នំជីសូរ ... ។

## ៣ . ករណនាម ឬនាមករណ៍

ករណនាម ឬនាមករណ៍ គឺជានាមសម្រាប់សម្តែងសភាព ឬលក្ខណៈ អ្វីមួយ ។ ករណនាម ឬនាមករណ៍មានកំណើតមកពីកិរិយាសព្ទ ឬគុណនាម ។

*ឧទាហរណ៍ ៖*

- គាត់តែងបោសសំអាតទីធ្លាប្រាសាទនេះរាល់ថ្ងៃ ។ ទង្វើនេះ ចាត់ទុកជាគំរូល្អមួយ ។
- កម្ពុជាយើងសម្បូរប្រាសាទបុរាណណាស់ ។ ភាពសំបូរបែបនេះ ជាមោទនភាពរបស់កូនខ្មែរជំនាន់ក្រោយៗ ។ យើងត្រូវចេះថែរក្សាការពារកេរដំណែលទាំងនោះឱ្យបានគង់វង្ស ។

**ពាក្យ ៖** ទង្វើ ភាពសម្បូរ ជានាមករណ៍ ឬករណនាម ។ នាមករណ៍មានដូចជា ៖

| **កិរិយាសព្ទ>** | **នាមករណ៍ឬករណនាម** |
|---|---|
| ធ្វើ > | ទង្វើ |
| សង្កេត > | ការសង្កេត |
| កក > | កំណក |
| កើត > | កំណើត |
| ជោរ > | ជំនោរ ។ល។ |
| **គុណនាម >** | **នាមករណ៍ឬករណនាម** |
| សុខ > | សេចក្ដីសុខ |
| ខុស > | កំហុស |
| សម្បើម > | ភាពសម្បើម |
| ក្ដៅ > | កម្ដៅ |
| ថ្លៃថ្នូរ > | សេចក្ដីថ្លៃថ្នូរ ។ល។ |

## ៤ . ការកនាម ឬនាមការក៍

ការកនាម ឬនាមការក៍ គឺជានាមសម្ដែងអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ ។

*ឧទាហរណ៍ ៖* អ្នកភ្ជួរ អ្នករាស់ អ្នករែកកណ្ដាប់ អ្នកស្ទូងបំពេញការងាររៀងៗខ្លួនយ៉ាងសកម្ម ។ មិនយូរប៉ុន្មានវាលស្រែទាំងមូលប្រែក្លាយជាពណ៌ខៀវស្រងាត់ ។

**ពាក្យ ៖** អ្នកភ្ជួរ អ្នករាស់ អ្នករែកកណ្ដាប់ អ្នកស្ទូង ជានាមការក៍ ព្រោះពាក្យទាំងនោះប្រាប់ពីអ្នកធ្វើអំពើ ។ នាមការក៍ ឬការកនាម មានកំណើតមកពី កិរិយា គុណនាម និងនាម ។

| **កិរិយាសព្ទ >** | **នាមការក៍** |
|---|---|
| យាម > | អ្នកយាម |
| ចាំ > | ឆ្មាំ |
| ជួញ > | ឈ្មួញ |
| លេង > | អ្នកលេង ។ល។ |

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

| | | |
|---|---|---|
| **គុណនាម** | > | **នាមការក៍** |
| តូច | > | អ្នកតូច |
| ធំ | > | អ្នកធំ |
| មាន | > | អ្នកមាន ។ល ។ |
| **នាម** | > | **នាមការក៍** |
| ស្រែ | > | អ្នកស្រែ |
| ក្រុង | > | អ្នកក្រុង |
| ចំការ | > | អ្នកចំការ |
| ភូមិ | > | អ្នកភូមិ ។ល ។ |

តាមការបង្ហាញខាងលើបញ្ជាក់ថា ពាក្យសម្រាប់ហៅមនុស្ស សត្វ វត្ថុ ទីកន្លែង ... ទាំងអស់ គេប្រើនាម ហើយមានលក្ខណៈប្លែកៗគ្នា ។

***នាម** គឺជាថ្នាក់ពាក្យមួយប្រភេទសម្រាប់សម្ដែងឈ្មោះ មនុស្ស សត្វ វត្ថុ ទីកន្លែង រុក្ខជាតិ ធម្មជាតិ អ្វីមួយ ។ នាមចែកជា សាធារណនាមឬនាមសាធារណ៍ អសាធារណនាមឬនាមអសាធារណ៍ ករណនាមឬនាមករណ៍ និងការកនាមឬនាមការក៍ ។*

## លំហាត់

១. ក្នុងចំណោមពាក្យខាងក្រោម តើពាក្យណាខ្លះជាសាធារណនាម ឬនាមសាធារណ៍ ហើយពាក្យណាខ្លះជាអសាធារណនាម ឬនាមអសាធារណ៍ ។

| | | | | | |
|---|---|---|---|---|---|
| សាលារៀន | កម្មករ | បុណ្យភ្ជុំបិណ្ឌ | ប្រាសាទតាព្រំ | ពិធីបុណ្យ | ព្រះអង្គ |
| ភូមិសែនបន់ | សៀវភៅ | អ្នកនិពន្ធ | រមណីយដ្ឋានទន្លេបាទី | ព្រះបាទបាយ៉ង់កោរ | |

២. តើពាក្យណាខ្លះជាករណនាមឬនាមករណ៍ ? ហើយពាក្យណាខ្លះជាការកនាម ឬនាមការក៍ ?

| | | | | | |
|---|---|---|---|---|---|
| សម្ដី | ខ្មើយ | ការសង្កេត | អ្នកក្លាហាន | អ្នកស្រុក | ខ្មាន់កាំភ្លើង |
| ទំហំ | ជំនួញ | សេចក្ដីចម្រើន | ការអត់ធ្មត់ | ការសន្មត | |

៣. ចូរតែងល្បះដោយប្រើនាមមួយបែបៗឱ្យបានបួនល្បះ ។

## លក្ខណតថ:នៅក្នុងរឿង

ដូចម្ដេចហៅថាលក្ខណតថ: ? តើនៅក្នុងរឿងមានលក្ខណ:តថ:ដូចម្ដេច ?

ចូរពិនិត្យឧទាហរណ៍ :

១. [...] តាដុង យាយជ័យ មានប្អូនស្រីមួយឈ្មោះនាងទែន នៅភូមិស្រែរនោង ។ តានិងយាយបាននាំនាងត្រចើលដោះក្រាលទៅលេងឯផ្ទះនាងទែនជាញឹកញាប់ ។ ពេលដែលនាងទៅលេងឯផ្ទះម្ដាយមីងនាងតែងតែដើរកាត់ភូមិកាន់ក្អមមកដងទឹក អ្នកស្រុកបានឃើញដំណើរនាងដើរ ក៏នាំគ្នាសរសើរថា ដំណើរនាងដើរញ៉ែងញ៉ង ពាក្យសរសើរនោះ រាល់ពេលនាងដើរ បានជានៅកន្លែងនោះមានឈ្មោះថា ភូមិញ៉ែងញ៉ង ឃុំញ៉ែងញ៉ងដល់សព្វថ្ងៃ ។ លុះនាងដើរមកដល់ទឹកន្លែងអណ្ដូងទឹក មនុស្សដែលមកដងទឹកជាមួយនាង តែងតែពោលពាក្យសរសើរសាច់នាងថាសស្គុស ទើបមានជាប់ពាក្យសរសើរនោះដល់សព្វថ្ងៃថា ឃុំគុស ។ ឯឃុំញ៉ែងញ៉ងនិងឃុំគុសនេះ នៅជាប់គ្នាក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ។

ពេលនោះ នាងនៅលេងនឹងផ្ទះម្ដាយមីងបានពីរបីថ្ងៃ តាដុងយាយជ័យក៏មកយកនាង វិលទៅកាន់ទីលំនៅវិញ ។ តាដុងយាយជ័យនិងនាងត្រចើលដោះក្រាល ដែលមកកាន់ផ្ទះនាងទែននោះលោះខែតិចណាស់ ។ មានថ្ងៃមួយ តានិងយាយបាននាំនាងមកលេងផ្ទះនាងទែនទៀត លុះមកពាក់កណ្ដាលផ្លូវបានជួបនឹងព្រានរឹង កំពុងនាំចៅប្រមាញ់ រឹង ស៊ុង ដើរបរបាញ់សត្វក្នុងព្រៃ ។ ដោយព្រានរឹងនិងតាដុងយាយជ័យនោះ ធ្លាប់ស្គាល់គ្នាច្បាស់ពីមុនមកផង អ្នកទាំងនោះក៏មានការសួររាក់ទាក់រកគ្នាទៅវិញទៅមក ។ ឯចៅប្រមាញ់រឹងស៊ុងនិងនាងត្រចើលដោះក្រាល កាលបើឃើញគ្នាហើយក៏ចេះតែគយគន់គ្នាទៅវិញទៅមក ។ ដោយការគយគន់រកគ្នានោះ សេចក្ដីស្នេហាក៏ចាប់ផ្ដើមដុះដាលឡើងពេញពោរនៅក្នុងបេះដូងរៀងខ្លួន ហើយបញ្ចេញឫកពាទៅវិញទៅមក លុះត្រាតែដឹងចិត្តគ្នា ។ ដោយតាដុងយាយជ័យមានរវល់ច្រើន នាងត្រចើលដោះក្រាលក៏លបធ្វើដំណើរមកផ្ទះនាងទែនតែម្នាក់ឯងក្នុងបំណងមកជួបនឹងចៅប្រមាញ់រឹង ស៊ុងផង ។

ថ្លែងពីព្រះរាជាដែលគង់សំចតនៅព្រះបន្ទាយលង្វែក ព្រះអង្គឡើងគង់លើអស្សពាហ៍ មានសេនា ៤នាក់ ដង្ហែព្រះអង្គទៅផង ។ លុះចូលទៅដល់ក្នុងព្រៃជ្រៅ ស្រាប់តែប្រទះនាងត្រចើលដោះក្រាលដើរត្រាច់តែម្នាក់ឯង ។ ត្រង់ព្រៃដែលស្ដេចប្រទះនាងនោះ អ្នកស្រុកគេហៅថា ព្រៃប្រទះនាង ដែលសព្វថ្ងៃនេះគេហៅក្លាយមកថា ប្រទះឡាង ។ ព្រះអង្គបានទតឃើញនាងមានរូបឆោមលោមពណ៌ល្អដូចនាងទេពធីតា ក៏ទ្រង់លោតចុះពីលើខ្នងសេះយាងសំដៅទៅរករូបនាង ទ្រង់លួងលោមនាងដោយសេចក្ដីស្នេហា ។ នាងត្រចើលដោះក្រាល ក៏មានសេចក្ដីភិតភ័យ នាងមិនមានឆ្លើយតបទៅព្រះ

youtube.com/moeys moeys.gov.kh facebook.com/moeys.gov.kh

រាជាទេ នាងបែរជារត់ត្រឡប់មកក្រោយវិញ ។ ពេលនោះ ព្រះរាជានិងសេនាបួននាក់ក៏រត់ដេញតាមនាង ។ ដោយកម្លាំងនាងជាស្រីរត់មិនសូវលឿន ហើយដោយឃើញព្រះរាជាដេញប្រកិតជិតណាស់មកផង នាងបានឃើញដំបូកមួយនៅក្នុងព្រៃពីមុខ នាងក៏លើកដៃបួងសួងថា "បើខ្លួននាងពិតជាគូនឹងថៅប្រមាញ់ រឹង ស៊ុងមែន សូមឱ្យនាងចូលពួននៅដំបូកនេះបាត់កុំឱ្យគេរកឃើញឡើយ" ។ ព្រះរាជានិងសេនា៤នាក់មើលពីចម្ងាយមកឃើញនាងចូលទៅក្នុងព្រៃដំបូកនោះដែរ តែលុះមកដល់បែរជារកនាងមិនឃើញវិញ បានជាមានពាក្យហៅទីនោះថា "ដំបូកមានលក្ខណ៍" ។ កន្លែងនេះក្រោយមកអ្នកស្រុកបានសាងវត្តដំបូកមានលក្ខណ៍ នៅក្នុងឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្ដាល ។ ពេលនោះព្រះរាជាឆ្ងល់នឹងដំណើរ ដែលនាងរត់មកពួនបាត់ខ្លួននៅដំបូកនោះ ក៏ទ្រង់ពិគ្រោះជាមួយសេនាឯសេនាទាំង៤នាក់ក៏ទូលតបវិញថា ស្ត្រីដែលមានរូបល្អអម្បាញ់មិញនេះ បានជារត់មកពួនបាត់នៅដំបូកដែលជាកន្លែងមិនគួរនឹងលាក់ខ្លួនបាត់យ៉ាងដូច្នេះ ដោយព្រះអង្គដេញចាប់បង្ខំចិត្តនាង ប្រហែលជាមានទេវតាជួយយកអាសានាងជាមិនខាន ហើយសេនាទូលថែមទៀតថា បើព្រះអង្គសព្វព្រះរាជហឫទ័យនឹងរូបនាង សូមព្រះអង្គយាងចូលទៅស្ដីដណ្ដឹងដល់ឪពុកម្ដាយនាងតាមប្រពៃណីវិញ ។ [...]

*(ដកស្រង់ពីរឿង តាដុងយាយជ័យ ប្រជុំរឿងព្រេងខ្មែរភាគ៥)*

២. នៅឆ្នាំ ១៩២៤-២៥ អ្នករាជការឃុំទាំងឡាយនៃខេត្តកំពង់ឆ្នាំង បានធ្វើសេចក្ដីរាយការណ៍ទៅសាលាស្រុករៀងខ្លួន បញ្ជាក់អំពីស្ថានភាពដ៏លំបាករបស់មន្ត្រីឃុំក្នុងការដើរទារពន្ធលើបណ្ដារាស្ត្រទូទៅ ព្រោះប្រជាកសិករភាគច្រើនបានប្រកែករឹងរូសពុំព្រមបង់ពន្ធជូនរាជការ ដោយអាងលេសថាគ្មានប្រាក់ ។ ម្ល៉ោះហើយអស់លោកចៅហ្វាយស្រុកក៏រាយការណ៍ជូនលោកចៅហ្វាយខេត្តមួយជាន់ទៀត ។ ឯលោកចៅហ្វាយខេត្ត ក៏រាយការណ៍រឿងនេះជូនទៅរ៉េស៊ីដង់បន្តទៀតដែរ ។

ព្រោះហេតុនេះហើយ ទើបបានជានៅដើមឆ្នាំ ១៩២៤ លោករ៉េស៊ីដង់បារាំងឈ្មោះ បារដេសដែលនៅប្រចាំខេត្តកំពង់ឆ្នាំងនោះ បានបញ្ចេញសកម្មភាពយ៉ាងខ្លាំងក្លា ដើរទារពន្ធដោយខ្លួនឯងតែម្ដង ។ ចំពោះស្រុករលាប្អៀរ មុនដំបូងលោករ៉េស៊ីដង់បារាំងរូបនេះ បានចាប់ចេញដើរទារនៅឃុំព្រៃខ្មែរ ដើងគ្រាវហូរហែ រហូតទៅឃុំព្រៃមូលនិងឃុំក្រាំងលាវ ដែលជាកន្លែងទារពន្ធចុងក្រោយបង្អស់នៃជីវិតរបស់គាត់នៅក្នុងអតីតព្រះរាជាណាចក្រកម្ពុជា ។

គួរជ្រាបផងដែរថា ពន្ធដារសម័យនោះធ្ងន់ធ្ងរហួសហេតុ គឺធ្ងន់រហូតដល់អ្នកក្រ ដែលមានដីធ្លីបន្តិចបន្តួចសុខចិត្តលក់ដីនោះចោល យកប្រាក់មកបង់ពន្ធ ក៏នៅតែមិនគ្រប់ទៀត ។ គ្រាន់តែពន្ធអត្តសញ្ញាណប័ណ្ណ (កាត) ក្នុងមួយឆ្នាំៗ គេត្រូវបង់ម្នាក់ៗ ៥រៀល ។ នេះមិនគិតពីពន្ធដីធ្លីនិងអ្វីៗដទៃទៀតផង ។ កាតសម័យនោះ គេធ្វើជា៥ផ្នត់ ។ ហេតុនេះហើយទើបបានជាមានតំណាលថា

"កាត៥ផ្ទត់" តៗមក ។ ហើយព័ត៌មានស្ដីពីរឿងអ្នកស្រុករត់ពួនព្រៃដោយសារគ្មានលុយបង់កាតនោះ ក៏នៅតែមិនទាន់រលុបបាត់មកដល់សព្វថ្ងៃនេះផងដែរ ព្រោះរឿងនេះមានគ្រប់ខេត្ត ។

ថ្លែងពីលោកមេឃុំប៉ាល់ ។ លោកប៉ាល់ គឺជាមេឃុំក្រាំងលាវនេះឯង ។ គាត់មានអាយុប្រមាណ ៦០ឆ្នាំទៅហើយ ។ ចាស់ៗសម័យនោះ (១៩២៥) គេហៅគាត់ថា "មេស្រុកប៉ាល់" ។ ឯពួកកំលោះៗ និយមហៅថា "តាប៉ាល់ៗ" រត់មាត់ ។ ចំណែកសាលាឃុំក្រាំងលាវ គឺតាំងនៅខាងត្បូងរបងវត្តក្រាំងលាវ ។

នៅដើមឆ្នាំ ១៩២៥នេះ មេឃុំប៉ាល់ បានខិតខំចាត់មន្ត្រីឃុំឱ្យដើរទារពន្ធពីកូនឃុំក្នុងមួយផ្ទះៗបីបួនដងក៏មាន ប៉ុន្តែនៅតែពុំសូវបានលទ្ធផល ព្រោះចំនួនមនុស្សដែលគ្មានលុយបង់ពន្ធមានច្រើនលើសលប់ ។

មេឃុំប៉ាល់ទាល់តម្រិះអង្គុយច្បូតពុកមាត់ធ្វើភ្នែកភ្លឹះៗ ព្រោះរាជការជាន់លើចេះតែបង្គាប់ផ្ដួនៗមកឱ្យគាត់ប្រឹងខំទារឱ្យខាងតែបាន ។ ណាមួយខ្លួនឯងកាន់តែចាស់ជរាណាស់ទៅហើយមិនបានកាន់សីលប្រាំបីជាប់លាប់នឹងគេ ព្រោះរវល់តែពីរឿងកិច្ចការរាជការមមាញឹក ណាមួយនឹកមួម៉ៅក្ដៅក្រហាយទារពន្ធមិនបាន ណាមួយជួយអាណិតអាសូរកូនឃុំដែលភាគច្រើនកំពុងតែជួបប្រទះនឹងការខ្វះខាតគ្រឿងឧបភោគ បរិភោគសម្រាប់ចិញ្ចឹមជីវិតរាល់ថ្ងៃ ។ ចង់លាឈប់ធ្វើមេឃុំ រាជការថ្នាក់លើមិនព្រម ។ មេឃុំប៉ាល់តឹងទ្រូងស្ទើរបែកជាពីរភាគ ។

ថ្ងៃមួយ មេឃុំប៉ាល់បានកោះប្រជុំមន្ត្រីឃុំក្រោមឱវាទរបស់គាត់ ដើម្បីប្រឹក្សាគ្នារកច្រកចេញឱ្យរួច ដើម្បីកុំឱ្យមានការស្ដីបន្ទោសមកពីថ្នាក់លើ ។

ខណៈនោះ លោកជំទប់បានជម្រាបលោកមេឃុំប៉ាល់ថា ៖

- រឿងដើរទារពន្ធឆ្នាំនេះ ខ្ញុំសុំចាញ់ហើយ ! ព្រោះម្នាក់ៗ ឆ្លើយមកវិញថាតែគ្មានលុយៗ ហើយអ្នកខ្លះទៀតលើកដៃសំពះអង្វរករគួរឱ្យខ្លោចចិត្ត ឱ្យបង្អង់ចាំដល់ឆ្នាំក្រោយសឹមបង់ជូន ត្បិតឆ្នាំនេះអត្តខាត់ខ្លាំងណាស់ ។

មេឃុំប៉ាល់ខះបំពង់ក លើកពែងតែហុតគ្រូកដូចហុតសម្ល រួចយកដៃស្ដាំច្បូតពុកមាត់ ទើបមានប្រសាសន៍ថា ៖

- ខ្ញុំដឹងសុខទុក្ខកូនឃុំខ្ញុំដែរ តែឱ្យខ្ញុំធ្វើម៉េច បើគេចេះតែបង្ខំពីលើមកខ្លាំងពេក ។

ពេលនោះ ស្មៀនឃុំបានធ្វើតុល្យការប្រៀបធៀបពីរបររកស៊ីរបស់អ្នកស្រុកនឹងប្រាក់ពន្ធ ជូនមេឃុំស្ដាប់ ៖

- លោកមេឃុំជ្រាបស្រាប់ហើយ កូនឃុំយើងសព្វថ្ងៃ អ្នកខ្លះធ្វើស្រែបានស្រូវ ១ឆ្នាំ ៣០ថាំងក៏មាន ៤០ថាំងក៏មាន ទុកគ្រាន់តែទទួលទានប៉ុណ្ណោះ ។ ឯរបរឡើងត្នោតវិញ អ្នកខ្លះក្នុង ១ឆ្នាំៗ បានស្ករ ២៥៣ាង លក់បានប្រាក់តែត្រឹមពីររៀលមួយចំហៀងប៉ុណ្ណោះ ។

មេឃុំប៉ាល់ដកដង្ហើមព្ឋសូរឃូ ! ច្បូតពុកមាត់ស្រមាមរបស់គាត់ទៀត ទើបឱ្យយោបល់ថា

- រឿងនេះ មានតែមួយផ្លូវប៉ុណ្ណោះ គឺធ្វើសំបុត្រប្ដឹងទៅលើ ដើម្បីយករួចខ្លួនយើង ។

បន្ទាប់ពីមានការយល់ស្របពីអង្គប្រជុំ លោកមេឃុំប៉ាល់ក៏បង្គាប់ឱ្យស្មៀនធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ផ្ញើទៅចៅហ្វាយស្រុករលាប្អៀរ ។ ឯស្មៀននោះ ក៏ធ្វើប្រញាប់ប្រញាល់ ព្រោះដឹងថាលោករ៉េស៊ីដង់រៀបចេញមកទារពន្ធហើយ ។

*(ដកស្រង់ពីរឿង ភូមិតិរច្ឆាន វគ្គទី ៩)*

តាមឧទាហរណ៍ទី ១ បង្ហាញថា អ្នកនិពន្ធបានផ្សារភ្ជាប់ដំណើររឿងទៅនឹងឈ្មោះទីកន្លែងពិតប្រាកដនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាយើង ហើយឈ្មោះទាំងនោះនៅស្ថិតស្ថេររហូតមកដល់បច្ចុប្បន្ន ដូចជាផ្ទះនាងទែននៅភូមិស្រែរនោង ពាក្យអ្នកស្រុកសរសើរនាងត្រចើលដោះក្រាលនៅពេលនាងកាន់ក្អមដងទឹកដើរញ៉ែងញ៉ង ទីកន្លែងដែលដើរនោះ ជាប់ឈ្មោះជាភូមិញ៉ែងញ៉ងនិងឃុំញ៉ែងញ៉ង ។ កន្លែងអណ្ដូងទឹក ដែលអ្នកស្រុកសរសើរនាងថាសស្គុស ជាប់ឈ្មោះមកដល់សព្វថ្ងៃថាឃុំគុស ។ ភូមិឃុំទាំងអស់នេះ សព្វថ្ងៃស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ។

ឧទាហរណ៍ទី ២ អ្នកនិពន្ធបានផ្សារភ្ជាប់ដំណើររឿងទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាយើង ដែលស្ថិតក្រោមអាណានិគមបារាំង ។ វគ្គទី ៩ នេះបង្ហាញពីទុក្ខវេទនារបស់ប្រជាជនកម្ពុជាដែលត្រូវបារាំងជិះជាន់ឱ្យបង់ពន្ធគ្រប់ប្រភេទ តាំងពីដីស្រែ ចំការ មុខរបរ រហូតដល់អត្តសញ្ញាណប័ណ្ណថែមទៀត ។

*លក្ខណតថ:នៅក្នុងរឿង គឺជារឿងរ៉ាវ ហេតុការណ៍ ព្រឹត្តិការណ៍ ឈ្មោះ ទីកន្លែង សកម្មភាព ... ដែលមានពិតនៅក្នុងសង្គមជាក់ស្ដែង ហើយត្រូវបានអ្នកនិពន្ធបញ្ចូល ឬផ្សារភ្ជាប់ទៅនឹងដំណើររឿងដោយរួមផ្សំនឹងមនោគតិរបស់ខ្លួន ។*

## លំហាត់

ចូរបង្ហាញលក្ខណៈតថភាពនៅក្នុងអត្ថបទខាងក្រោម ៖

### ១. រឿងកុលាបប៉ៃលិន

[...] លុះថៅចិត្របានទទួលសំបុត្រគ្រូពេទ្យហើយ ក៏ចាត់ចែងសំពត់អាវដាក់វ៉ាលីសផ្ដៅនិងអីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រះដេកសម្រាកដោយសេចក្ដីត្រេកអរដ៏លើសលប់ក្នុងយប់នោះស្ទើរតែដេកមិនលក់ទល់ភ្លឺ។ ដល់ម៉ោង៥ជិតភ្លឺនាឡិកាឯផ្សារវិលវាយឮសូរម៉ឺងៗយ៉ាងច្បាស់រហូតដល់ផ្ទះថៅចិត្រៗ ក្រោកឡើងលុបលាងមុខមាត់រួច ក៏ស្ពាយពាក់យួរវ៉ាលីសចុះពីផ្ទះដើរសំដៅទៅផ្សារវិលបម្រុងទៅឡើងរថយន្ត ដែលដើរទៅផ្លូវបាត់ដំបង-បប៉ៃលិន។ ថៅចិត្រទិញសំបុត្រកន្លែងរួចស្រេចហើយ ក៏អង្គុយចាំដរាបដល់ពេលរថយន្តចេញពីទីផ្សារក្រុងបាត់ដំបងទៅ។ វេលាម៉ោង ៦និង១៥នាទី រថយន្តក៏បើកចេញសំដៅទៅទិសខាងត្បូង ដល់ទៅផ្សារភាស៊ីស្រា ក៏បត់ត្រង់ទៅឯលិចតាមផ្លូវបប៉ៃលិន។ ថៅចិត្រអង្គុយមើលភូមិប្រទេសសងខាងមាគ៌ានោះ មុខគួរឱ្យស្រងេះស្រងោច អណ្ដែតអណ្ដូងក្នុងចិត្តជាចម្លែកណាស់ នឹកដល់ឪពុកដែលទើបអនិច្ចកម្មទៅថ្មីៗកាលណាទឹកភ្នែកក៏ជោរជន់ចេញមក តែខំទប់ទល់មិនឱ្យទឹកភ្នែកស្រក់ចុះទាល់តែបាន ដើម្បីការពារកុំឱ្យអ្នកជិះរថយន្តជាមួយគ្នា មានសេចក្ដីសង្ស័យមន្ទិលមកលើខ្លួន ហើយបន្លំនិយាយលេងសើចកម្សាន្តជាមួយអ្នកជិះទាំងអស់គ្នារៀងៗទៅ។

រីឯផ្លូវដែលឡើងទៅស្រុកបប៉ៃលិន មិនសូវឆ្ងាយប៉ុន្មានពីក្រុងបាត់ដំបងក៏ពិតមែន តែជាផ្លូវលំបាកបន្តិច ត្បិតត្រូវបររថយន្តឡើងកាត់ភ្នំនិងសសៀរតាមជើងភ្នំខ្ពស់ឡើងៗហើយកោង បរបត់បែនដរាបដល់ស្រុកបប៉ៃលិន ទុកជាបង្ខំយ៉ាងណា ក៏គង់តែរថយន្តរត់មិនលឿនដូចផ្លូវរាបទេ។ ថៅចិត្រក្រឡេកមើលទេសភាពតាមសងខាងផ្លូវសឹងដេរដាសទៅដោយស្រែចំការច្បារដំណាំ និង ភូមិស្រុកដោយអន្លើៗ ឃ្លាតឆ្ងាយដាច់ៗពីគ្នា លុះជិតទៅដល់បប៉ៃលិន ក៏ឃើញតែព្រៃព្រឹក្សា លតាវល្លិ និងភ្នំតូចធំច្រើនអនេក ព្រមទាំងសត្វបក្សាបក្សី និងសត្វចតុបាទ ក៏មានកុះករច្រើននៅតាមដងព្រៃព្រឹក្សាអស់នោះ។ ថៅចិត្របានឃើញសព្វសត្វអស់នោះ ក៏កើតមានចិត្តសង្វេគនឹករលឹកដល់ឪពុកកាន់តែខ្លាំងឡើងៗ ស្ទើរតែទប់ទឹកភ្នែកពុំបាន។

លុះដល់រថយន្តបរបើកកាត់ព្រៃភ្នំក្រំថ្មជាច្រើនអន្លើ វេលាម៉ោង ១១ថ្ងៃត្រង់ រថយន្តក៏បានទៅដល់ទីផ្សារបប៉ៃលិនដោយស្រួល។ ថៅចិត្រចុះពីរថយន្ត ដើរទៅស៊ើបសួររកផ្ទះហ្លួងរតនសម្បត្តិ។ មានភូមាម្នាក់នៅទីផ្សារនោះ ចង្អុលប្រាប់ថា ផ្ទះហ្លួងរតនសម្បត្តិនៅឯណោះ ចម្ងាយពីទីផ្សារនេះទៅប្រហែល ៥០០ម៉ែត្រ ក្បែរមាត់ផ្លូវខាងជើង នៅខ្លោងទ្វារផ្ទះនោះមានសរសេរឃើហោ "គ្រឹះស្ថានរតនសម្បត្តិ" អញ្ជើញទៅចុះគង់នឹងឃើញមិនខាន។ [...]

*(ដកស្រង់ពីរឿង កុលាបប៉ៃលិន អ្នកនិពន្ធ ញ៉ុក ថែម គ.ស ១៩៦០)*

## ២. រឿងព្រេងទាក់ទងនឹងបុណ្យភ្ជុំបិណ្ឌ-បណ្ដែតដូនតា

មានសេចក្ដីតំណាលថា មានឈ្មួញសំពៅ ៥០០ ធ្វើដំណើរចេញទៅជួញតាមសមុទ្រ ។ លុះទៅដល់កោះមួយនោះ ជួនជាល្ងាច នឹងធ្វើដំណើរទៅមុខទៀតក៏ស្ទើរ ទើបនាំគ្នាចូលចតសំពៅនៅទីនោះ ។ កោះនោះជាកោះដាច់ស្រយាល ឥតមានមនុស្សនៅទេ ហើយពេលយប់តែងតែមានពួកប្រេតនាំគ្នាដើរមករកស៊ី ។ ពួកប្រេតទាំងនោះលុះដើរក្រវែលរកអាហារ ឃើញមនុស្សដេកក្នុងសំពៅក៏ចាប់មនុស្សកំពុងដេកលក់ យកទៅឱ្យថៅហ្វាយវាខ្លះ គិតនឹងហែកស៊ីខ្លះ ។ ដោយសារសំឡេងប្រេតនិយាយគ្នា ពួកមនុស្សដេកលក់ទាំងនោះក៏ភ្ញាក់ឡើង ភ័យស្លុត យំសោកទ្រហឹង ខំអង្វរករដូចម្ដេចក៏ពួកវាពុំព្រម ហើយគិតតែពីចាប់នាំទៅប្រគល់ឱ្យថៅហ្វាយនាយវា ។

សម្រែកយំសោកបណ្ដាលឱ្យផ្អើលមនុស្សអស់ទាំង ៥០០សំពៅ ។ ពេលនោះ នាយសំពៅម្នាក់ជាអ្នកឈ្លាសវៃ នឹកឃើញថា បើទោះជាត្រូវស្លាប់ ក៏ត្រូវតែហ៊ានប្រថុយនិយាយតវ៉ាឱ្យអស់ចិត្តសិន មិនត្រូវឱ្យគេផ្ដាច់ជីវិតទទេៗឡើយ គិតហើយ ក៏តាំងស្មារតីអង់អាច និយាយទៅកាន់ស្ដេចប្រេតសូមឱ្យលែងពួកខ្លួន តែស្ដេចប្រេតនោះឆ្លើយថា យើងនឹងលែងពួកឯងទៅវិញមិនបានទេ ព្រោះពួកយើងស្រេកឃ្លានណាស់ បើលែងពួកអ្នកឯងទៅ មិនដឹងថាកាលណានឹងបានទៀតទេ ពួកយើងខ្វះអាហារ ។

នាយឈ្មួញអង្វរ ៖

"សុំលោកលែងពួកយើងទាំងអស់វិញចុះ យើងសន្យាថា នឹងទទួលរកអាហារជូនលោករាល់ឆ្នាំលុះត្រាតែអស់ជីវិត បើលោកពិសាយើងនៅពេលនេះ លោកបានឆ្អែតតែមួយគ្រាប៉ុណ្ណោះ អំណឹះតទៅលោកនឹងត្រូវអត់ឃ្លានទៀត បើពួកយើងសន្យានឹងលោកយ៉ាងនេះ តើលោកជ្រើសយកផ្លូវណា ? លោកសុខចិត្តពិសារូបយើងឱ្យបានតែមួយចម្អែត ឬក៏សុខចិត្តទុកជីវិតពួកយើង ដើម្បីឱ្យទៅរកអាហារជូនលោកវិញ" ។

ពួកប្រេតឮសំណើរបស់នាយឈ្មួញដូច្នេះក៏គិតគ្នាមួយសន្ទុះ ទើបព្រមដោះលែងពួកឈ្មួញ ហើយផ្ដាំផ្ញើ ៖ "កាលបើពួកអ្នកបានទៅដល់ស្រុកទេសខ្លួនហើយ កាលណាមានខ្យល់ជំនោរធ្លាក់មកពីទិសឯជើង អ្នកទាំងអស់គ្នាត្រូវធ្វើក្បូនផ្ទុកធញ្ញជាតិនិងអាហារគ្រប់យ៉ាង មានលាជ សណ្ដែក ល្ង ដូង អំបុក ចេក ជាដើម បណ្ដែតតាមខ្សែទឹកមកឱ្យយើងចុះ មិនបាច់នាំមកផ្ទាល់ទេ ជំនោរខ្យល់នឹងបញ្ជូនមកដល់យើងហើយ" ។

ពួតែប៉ុណ្ណោះ ពួកអ្នកសំពៅអររកអ្វីប្រៀបពុំបាន ហើយក៏នាំគ្នាចុះសំពៅខ្សៀវខ្វារ បើកចេញផុតពីនោះយ៉ាងប្រញាប់ ។ លុះទៅដល់ភូមិស្រុក ជួបជុំគ្រួសារ ហើយត្រូវនឹងពេលជិតដល់រដូវភ្ជុំដែលទឹកឡើងដាល់ដាមផង អ្នកដែលបានសន្យានឹងប្រេតទាំងនោះ ក៏នាំគ្នាធ្វើនំនែក រកចេកអំពៅ លាជ ស្រូវ អង្ករ ផ្លែឈើ ដែលមាននៅក្នុងរដូវនោះ ធ្វើពោងពាយ ហើយដាក់បណ្ដែតបញ្ជូនទៅឱ្យប្រេតតាមខ្សែទឹករាល់ៗឆ្នាំ ។ មនុស្សជាន់ដើមកាន់ពាក្យសច្ចៈល្អណាស់ បើនិយាយសន្យាថាដូចម្ដេចហើយ មិនហ៊ានបំពានទេ ។

ចំណេរតមក អ្នកស្រុកក៏នាំគ្នាធ្វើតៗមកទៅជាទំនៀមទម្លាប់ ដោយយល់ថា ធ្វើបុណ្យបណ្ដែតស្រូវអង្ករទៅឱ្យដូនតា ដែលទៅកើតជាប្រេត ឋិតនៅឯស្រុកទន្លេស្ងួត កន្ទួតមួយដើមនោះវិញ ។

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរ ភាគ៩ )*



# រឿងប្រាសាទអង្គរវត្ត



## ក. សិក្សាពាក្យគន្លឹះ

- ទេពធីតា (ន) : កូនស្រីទេវតា ស្រីទេព្ត ។
- ព្រះឥន្ទ្រ (ន) : ព្រះនាមទេវរាជ ជាអធិបតីនៃពួកទេវតានៅឋានត្រៃត្រិង្សសួគ៌ ជាអ្នកមានអំណាចត្រួតត្រាលើគេនៅឋានលើ ។ ព្រះនាមព្រះឥន្ទ្រមានច្រើន ដូចជា ព្រះឥន្ទ្រា ព្រះឥន្ទ្រាធិរាជ អមរិន្ទ្រ អមរេន្ទ្រ ... ។
- ព្រះភក្ត្រ (ន) : មុខ ។
- ស្ញប់ស្ញែង (កិ) : កោតខ្លាច ខ្លាចក្រែង ក្រែងក្នុងចិត្ត ... ។
- សោយទិវង្គត (កិ) : ស្លាប់ ងាប់ ... ។
- អគ្គមហេសី (ន) : ប្រពន្ធស្តេច ។
- ពិស្ណុការ (ន) : ទេវតាខាងជាង ជាអ្នកសម្រេចកិច្ចការថ្វាយព្រះឥន្ទ្រ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីស្វែងយល់ខ្លឹមសារអត្ថបទឱ្យបានច្បាស់លាស់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងកាលអាកាស ប្រធានរឿង មូលបញ្ហារឿង និងខ្លឹមសារមួយចំនួនទាក់ទងនឹងប្រធានបទ ។

## គ. អត្ថបទ

[...] ថ្ងៃមួយ មាននាងទេពធីតា ៥អង្គឋិតនៅឯប្រាសាទព្រះឥន្ទ្រ បានហោះមករត់ប្រឡែងគ្នាលេងនៅឋានកណ្ដាល បានឃើញផ្កានៅសួនច្បារតាលឹម សេង រីកស្គុសស្គាយព្រោងព្រាត ក៏បបួលគ្នាចូលទៅក្នុងសួននោះ ។ ទេពធីតាម្នាក់ឈ្មោះនាងទិព្វសុតាចន្ទ ក៏បានបេះផ្ការបស់តាលឹម សេង ៦ទង ព្រោះផ្កានោះមានក្លិនក្រអូបសាយល្អ ។ ចំណែកទេពធីតាឯទៀត បានដើរលេងពាសពេញក្នុងសួនច្បារនោះដែរ តែឥតបានកាច់ផ្កាលេងទេ ។

លុះត្រឡប់ទៅដល់ឋានទេវតាវិញ ទេពធីតាស្លូតត្រង់ក៏បានទូលព្រះឥន្ទ្រពីរឿងនាងទិព្វសុតាចន្ទលួចបេះផ្កាគេ ព្រះឥន្ទ្រក៏ទ្រង់ផ្ដន្ទាទោសទិព្វសុតាចន្ទ ឱ្យចុះមកឋានកណ្ដាលនៅជាមួយមនុស្ស ចំនួន ៦ឆ្នាំ និងត្រូវទៅធ្វើជាប្រពន្ធតាលឹម សេង ទៀតផង ។

នាងទិព្វសុតាចន្ទ កាលបើបាននៅជាមួយតាលឹម សេង យូរមក នាងសង្កេតឃើញសេចក្ដីលំបាកវេទនារបស់តា និងចិត្តស្មោះត្រង់របស់គាត់ ក៏កើតមានចិត្តអាណិតតាខ្លាំង ទើបរកមធ្យោបាយដោះបំណុលឱ្យតាលឹម សេងជាប្ដី ។ នាងបានត្បាញសំពត់សូត្រលក់ ព្រមទាំងបង្ហាត់បង្រៀនវិជ្ជាត្បាញនេះដល់អ្នកស្រុកថែមទៀត ។

មិនយូរប៉ុន្មាន តា លឹម សេង ក៏បានឡើងជាអ្នកមានម្នាក់ មានអំណាចនិងគេរាប់រកជាច្រើន ។

ប្រមាណជាមួយឆ្នាំក្រោយមក នាងទិព្វសុតាចន្ទបានបុត្រប្រុសម្នាក់ ។ ទារកនេះរពឹសពន់ពេក នៅពេលដែលវាចេះវារ វាចេះជីកដីធ្វើជាកំពែងការពារ ពេលចេះអង្គុយវាគូរលេងនៅលើដីធ្វើជារូបសត្វ រូបមនុស្ស គឺថាវាចូលចិត្តគូរលេង ឥតចេះខ្ជិល ឥតឈប់ឈរ វាជាក្មេងពុំចេះនៅស្ងៀមមួយស្របក់ណាសោះឡើយ ។ អាស្រ័យហេតុដូច្នេះ ទើបម្ដាយដាក់ឈ្មោះថា ព្រះពិស្ណុការ ។

លុះកុមារមានវ័យ ៥ឆ្នាំ នាងទិព្វសុតាចន្ទក៏ត្រូវផុតកំណត់ការផ្ដន្ទាទោសរបស់ព្រះឥន្ទ ហើយក៏ដល់ពេលនាងត្រឡប់ទៅឋានលើវិញដែរ ។ ដើម្បីរំឭករឿងនោះដល់តាជាប្ដី នាងក៏បេះផ្កាចំនួន៦ទងយកទៅដាក់លើខ្នើយដេក រួចក៏ហោះទៅកាន់ឋានព្រះឥន្ទ្រវិញ ។

តាំងពីព្រះពិស្ណុការវិញ អ្នកខំរត់រកម្ដាយគ្រប់ច្រកល្ហកអស់ហើយ ប៉ុន្តែឥតបានដឹងថា ម្ដាយទៅណាសោះ ។ កុមារក៏កើតទុក្ខរកទីបំផុតគ្មាន ទើបថ្ងៃមួយសួរឪពុកថា ម្ដាយខ្ញុំជាអ្វី ។

ឪពុកឆ្លើយថា ម្ដាយកូនឯងជាទេពធីតា នាងត្រូវមកនៅក្នុងឋានមនុស្សយើងនេះតែត្រឹម ៦ ឆ្នាំទេ ឥឡូវនាងត្រឡប់ទៅឋានទេវតាវិញហើយ ឋាននោះនៅឆ្ងាយណាស់ ឪពុកមិនដឹងថាម្ដាយកូនឯងនៅត្រង់ណាទេ ។

កុមារនៅស្ងៀម ប៉ុន្តែចេះតែនឹកមករកម្ដាយឥតមានភ្លេច ក៏សម្រេចចិត្តថា ចេញទៅរកម្ដាយឱ្យទាល់តែឃើញ ទោះបីឪពុកខំនិយាយឃាត់យ៉ាងណា ក៏កុមារពុំយល់ស្របតាមជាដាច់ខាត ។ ព្រះពិស្ណុការកុមារបានធ្វើដំណើរចេញទៅ ដើរកាត់ព្រៃលេចវាល លេចវាលចូលព្រៃ ពេលឃ្លានបេះផ្លែរុក្ខជាតិនានាធ្វើជាអាហារ សម្លៀកបំពាក់រហែករយីរយ៉ៃអស់ ។ ប៉ុន្តែដោយហេតុកុមារនេះមានវាសនាល្អ ថ្ងៃមួយពួកទេពធីតាបានចុះមកលេងនៅលើភ្នំមួយ ហើយក្នុងបណ្ដាទេពធីតាទាំងនោះមាននាងទិព្វសុតាចន្ទមួយផង ។ នាងកំពុងនាំគ្នាដើរកាច់ផ្កាតាមដងព្រៃចងជាបាច់ ។

កាលព្រះពិស្ណុការបានឃើញស្ត្រីល្អៗ ដូច្នោះក៏នឹកថាអស់ពេលជាច្រើនឆ្នាំណាស់មកហើយដែលអញដើរចេញពីទីភូមិដែលមានមនុស្សលោកនៅ អញឥតដែលបានជួបមនុស្សម្នាក់សោះ សម្លៀកបំពាក់អញក៏រហែកដាច់ដាច ហើយអញពុំអាចរកអ្វីមកផ្លាស់បានទេ ក្រៅពីយកស្លឹកឈើមកចងបិទបាំងខ្លួន ។ ដូច្នេះមនុស្សស្រីទាំងឡាយដ៏ល្អៗក្រៃលែងនេះមកពីទីឋានណា ? ជាពួកទេពធីតាឬ ? គិតដូច្នេះហើយព្រះពិស្ណុការរត់ពួន ។ ស្ត្រីទាំងនោះបានដើរមកជិតដល់កុមារៗក៏លើកដៃបួងសួងឡើង ៖ “បើក្នុងស្ត្រីជាទេពធីតាទាំងអស់ឥតមានម្ដាយខ្ញុំនៅក្នុងនេះផងទេ សូមឱ្យហោះហើរទៅកាន់ឋានលំនៅគេវិញកុំមានសល់ឡើយ ប៉ុន្តែបើមានម្ដាយខ្ញុំមកនៅក្នុងទីនេះផងខ្ញុំសូមកុំឱ្យម្ដាយខ្ញុំហោះហើរទៅជាមួយនឹងគេរួច” ។

លុះបួងសួងដូច្នេះចប់ហើយ ព្រះពិស្ណុការក៏រត់ចេញសំដៅទៅកន្លែងដែលនាងទេពធីតាទាំងនោះកំពុងលេង ។ នាងទេពធីតាទាំងឡាយកាលបើឃើញកុមារមនុស្សលោកក៏ភ្ញាក់ផ្អើលស្ទុះហោះទៅឋានលើអស់នៅសល់តែនាងទិព្វសុតាចន្ទហោះទៅនឹងគេពុំរួច ។ ព្រះពិស្ណុការរត់ទៅចាប់ឱបនាងស្និទ្ធស្នាលជាទីបំផុត ។

នាងទិព្វសុតាចន្ទស្រែកយ៉ាងខ្លាំងៗថា “តើកម្មអ្វីតាមមកគ្របសង្កត់លើរូបខ្ញុំទៀតហើយ ខ្ញុំបានសោយទុក្ខទោស បានរួចពីឋានមនុស្សលោកហើយ ម្ដេចឡើយក៏មានមនុស្សលោកមកចាប់រឹតរួតខ្ញុំជាថ្មីទៀតដូច្នេះ” ។

ព្រះពិស្ណុការស្រែកឡើងថា ម៉ែ ! ម៉ែ ! ខ្ញុំនេះត្រូវជាកូនម៉ែ ។

នាងទិព្វសុតាចន្ទ ស្គាល់កុមារថាជាកូនរបស់ខ្លួនពិតដោយសារសម្ដីដែលកុមារនិយាយ ។ ដូច្នេះ នាងក៏យំទួញសោកអាណិតកូនជាខ្លាំង ហើយមានវាចាទៅកាន់កូន ៖

"ម៉ែឥតមានស្អប់ខ្ពើមឪពុកកូនឯងទេ ម៉ែតែងនឹកមកកូន នឹកឪពុកឯងពុំមានភ្លេច ព្រមទាំងអ្នកភូមិផងរបងជាមួយឯទៀតដែលម្ដាយធ្លាប់នៅជាមួយគេ ប៉ុន្តែជាតិជាទេពធីតាពុំអាចនៅជាមួយមនុស្សលោកបានយូរទេ ។ រាល់ថ្ងៃម្ដាយ ទៅបំពេញកិច្ចនៅចំពោះមុខព្រះភក្ត្រព្រះឥន្ទ្រាធិរាជ គឺសុំអង្វរឱ្យព្រះអង្គប្រទានពរដល់កូននិងឪពុកកូនឯងកុំបីខាន មិនតែប៉ុណ្ណោះម្ដាយបានទាំងទូលសុំព្រះឥន្ទ្រឱ្យព្រះអង្គមេត្តា ។ ពេលដែលថ្លែងពីសេចក្ដីនឹករឮករួចហើយនាងទិព្វសុតាចន្ទ ក៏នាំពិស្ណុកាទៅឋាន ទេវតា ។

នៅពេលដែលព្រះឥន្ទ្រាធិរាជយាងចេញមកតាមនោះ ទ្រង់ទតឃើញកុមារ ទ្រង់សួរទៅនាងទិព្វសុតាចន្ទថា តើមនុស្សនេះជាអ្វី បានជានាងនាំមកដល់ក្នុងប្រាសាទយើង ?

នាងទិព្វសុតាចន្ទទូលថា ជាបុត្រខ្ញុំម្ចាស់ កាលដែលខ្ញុំម្ចាស់ចុះទៅនៅឯឋានមនុស្សលោក រៀបការជាមួយលោកតាលឹម សេង ។

នាងទិព្វសុតាចន្ទបានទូលព្រះឥន្ទ្របន្ថែមថា បុត្រខ្ញុំម្ចាស់មានការប៉ិនប្រសប់ណាស់ គឺចេះគូរ ចេះឆ្លាក់ នាំឱ្យមនុស្សលោកមានសេចក្ដីកោតសរសើរស្ញប់ស្ញែងជាក្រៃលែង ប៉ុន្តែទាស់តែកូនខ្ញុំម្ចាស់ចេះចំណេះទាំងនេះដោយឥតបានរៀនពីគ្រូណាសោះ គឺវាចេះដោយសារគំនិតវាតែម្ដង ។ ព្រះឥន្ទ្រឆ្លើយថា មែនហើយ ! មនុស្សលោកណាចេះវិជ្ជាឥតគ្រូ លោកប្រដូចនឹងមនុស្សឆ្កួត បើដូច្នេះចូរឯងនាំកុមារនេះទៅជួបនឹងទេវបុត្ររោងជាងឈើ គេនឹងបង្រៀនកុមារឱ្យចេះមុខវិជ្ជាប្លែកៗសិន រួចសឹមឱ្យកុមារត្រឡប់ទៅឋានមនុស្សលោកវិញ ព្រោះកុមារមានសញ្ជាតិជាមនុស្សលោកពុំអាចមកនៅក្នុងទីឋាននេះរហូតទៅបានទេ ។

ព្រះពិស្ណុការក៏ទៅជាមួយទេវបុត្រ ដែលជាអ្នកបច្ចេកទេសខាងវិជ្ជាសិល្បៈនិងខាងសំណង់ ។ យុវជននោះខំរៀនគូរ រៀនឆ្លាក់ រៀនលេងភ្លេងអំពីសំណាក់ទេវបុត្រជាគ្រូទាំងនោះ បានចេះចាំស្ទាត់សព្វគ្រប់ទាំងអស់ គឺចេះសង់នាវាអាចបើកបរលើគោកបាន ចេះឆ្លាក់ប្រាក់ ឆ្លាក់មាស ចេះស្លដែកគ្រប់យ៉ាង ចេះវិជ្ជាលាយទឹកហើយទឹកនោះ បើកាលណាគេចាក់រាយលើដីឥដ្ឋ ដីនោះនឹងក្លាយទៅជាថ្ម ។ សរុបសេចក្ដីទៅគឺបានចេះចាំទាំងអស់នូវមុខវិជ្ជាទាំងឡាយណា ដែលទេវបុត្របានបង្រៀន ហើយទេវបុត្របាននិយាយលើកទឹកចិត្តកុមារដូច្នេះទៀតផងថា កិច្ចការដែលអ្នកបានចេះធ្វើទាំងប៉ុន្មាននេះអាចគង់ឋិតថេរនៅបានអស់ពេលជាច្រើនពាន់ឆ្នាំ ឯចំណែកការងាររបស់ខ្ញុំវិញអាចមានជីវិតត្រឹមមួយរជ្ជកាលស្ដេចមួយព្រះអង្គៗប៉ុណ្ណោះទេ ឧបមាថា បើព្រះមហាក្សត្រអង្គណាមួយបានសោយរាជ្យសម្បត្តិ ហើយទ្រង់សព្វព្រះរាជហឫទ័យឱ្យខ្ញុំសង់ប្រាសាទថ្វាយ ខ្ញុំអាចសង់ថ្វាយបាន

មួយរំពេច ប៉ុន្តែនៅថ្ងៃដែលព្រះមហាក្សត្រអង្គនោះ ទ្រង់សោយព្រះទិវង្គតទៅ ប្រាសាទនោះក៏ត្រូវរលាយបាត់ក្នុងពេលនោះដែរ ដូច្នេះឃើញថាឫទ្ធិអំណាចរបស់ឯងមានអានុភាពខ្លាំងលើសលប់លើឫទ្ធិអំណាចរបស់យើង ។ ទេវបុត្រក៏នាំសេចក្តីទៅក្រាបទូលព្រះឥន្ទ្រាធិរាជអំពីលទ្ធផលដ៏ប្រសើរក្រៃលែងដែលបានកើតមានអំពីការអប់រំព្រះពិស្ណុការ ព្រះឥន្ទ្រក៏ទ្រង់សព្វព្រះទ័យជាខ្លាំង ហើយទ្រង់ទទួលស្គាល់ថា ព្រះពិស្ណុការនឹងទៅជាអ្នកអប់រំ អ្នកបង្ហាត់បង្រៀនមនុស្សលោកទាំងអស់ដែលកាន់ព្រះពុទ្ធសាសនា ។ កាលព្រះឥន្ទ្រមានព្រះបន្ទូលមកដល់ត្រង់នេះ ព្រះអង្គនឹកឃើញដល់ព្រះកេតុមាលា ហើយព្រះអង្គក៏ទ្រង់ហោះចុះមកកាន់ប្រទេសកម្ពុជា ។

ពួកអ្នកយាមក៏រត់ទៅទូលព្រះបាទទេវងអស្ចារ្យថា មានសត្វពុំដែលស្គាល់ចុះមកពីឋានទេវតា មានភាពដូចមនុស្ស ប៉ុន្តែមានពណ៌ខៀវមានពន្លឺចាំងដូចភ្លើងបានចូលក្នុងប្រាសាទ ។

ព្រះបាទទេវងអស្ចារ្យយាងប្រញាប់តម្រង់ទៅប្រាសាទព្រះអង្គ ហើយទ្រង់បានស្គាល់ថាជាព្រះឥន្ទ្រ ព្រះរាជាក៏លុតជង្គង់ថ្វាយបង្គំ ពេលនោះព្រះឥន្ទ្រសួរព្រះរាជាថា តើព្រះអង្គមានស្គាល់ព្រះរាជបុត្រយើងឬទេ ?។ ព្រះបាទទេវងអស្ចារ្យទូលថា ទូលព្រះបង្គំពុំដែលស្គាល់ទេ ។

ព្រះឥន្ទ្រសួរ ៖ "កាលដែលព្រះអង្គកេតុមាលាទ្រង់ព្រះសម្ភព តើមានអាភេទដូចម្ដេច ?"

ព្រះបាទទេវងអស្ចារ្យទូលថា ឃើញពន្លឺខៀវលាតសន្ធឹងនៅលើមេឃ រួចស្រាប់តែមានកម្រងផ្កាធ្លាក់មកលើអគ្គមហេសីទូលព្រះបង្គំ ហើយតមកអគ្គមហេសីទូលព្រះបង្គំមានផ្ទៃពោះ ឥឡូវប្រសូតបុត្រមកសន្មតនាមថា កេតុមាលា ឥឡូវមានវ័យចម្រើនហើយ ។

ព្រះឥន្ទ្រមានបន្ទូល ៖ "ហ្នឹងហើយ ! គឺជាកូនយើង វាចុះមកចាប់បដិសន្ធិ" ។

ឮដូច្នោះ ព្រះបាទទេវងអស្ចារ្យ ទ្រង់ក៏ត្រាស់ហៅព្រះកេតុមាលាឱ្យចូលមក ។ ព្រះឥន្ទ្រក៏ចាប់លើកព្រះរាជកុមារឱ្យអង្គុយលើព្រះឧរូ (ភ្លៅ) រួចទ្រង់មានព្រះបន្ទូល ៖ " ពីដើមយើងឈ្មោះថាមាណព យើងបានស្ថាបនាផ្លូវថ្នល់ ស្ថាបនាទំនប់ទឹក សង់សាលា សង់ស្ពាន យើងបានធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រលំបាក ដោយផលនេះយើងបានទៅកើតជាព្រះឥន្ទ្រ ដូច្នេះយើងមានចិត្តនឹកមកដល់ប្រទេសកម្ពុជាណាស់ ព្រោះជាប្រទេសទើបនឹងកើតឡើងថ្មីៗ ហើយតាំងពីពេលនោះមកដល់ឥឡូវនេះគ្មានមនុស្សខ្លាំងពូកែណាម្នាក់មកនៅក្នុងប្រទេសនេះសោះ ។ ដូច្នេះយើងនឹងជួយធ្វើឱ្យឯងបានសប្បាយ ហើយឱ្យមានអាយុវែងផង ត្បិតអីមនុស្សលោកសម័យនេះអាយុខ្លីណាស់ កម្រមាននរណាអាយុបានមួយរយឡើយ ។ យើងនឹងនាំយកឯងទៅក្នុងប្រាសាទយើង ហើយឱ្យឯងចុះមុជទឹកក្នុងអាងមួយដើម្បីឱ្យបានអាយុវែង ។

ព្រះឥន្ទ្រក៏លើកព្រះកេតុមាលា ហោះទៅកាន់ឋានទេវតា ។ នៅក្នុងសួនច្បារនៃព្រះឥន្ទ្រមានអាងទឹកមួយ ព្រះឥន្ទ្រក៏យកព្រះកេតុមាលាទៅឱ្យមុជទឹកក្នុងអាងនោះមួយថ្ងៃ ៧ដង លុះត្រាតែគ្រប់

៧ថ្ងៃ ។ បន្ទាប់មកព្រះឥន្ទ្រនាំព្រះកេតុមាលាចូលទៅក្នុងប្រាសាទព្រះអង្គ រួចព្រះឥន្ទ្រអញ្ជើញទេវតាជាព្រាហ្មណ៍ ៧ នាក់ឱ្យមកសូត្រសែកមន្តគាថានិងប្រោះព្រំទឹកមន្តលើព្រះកេតុមាលា ដើម្បីឱ្យបានអាយុជាងមួយរយឆ្នាំ ។

កាលបើពិធីនេះបានចប់សព្វគ្រប់ហើយ ព្រះឥន្ទ្រក៏ទ្រង់បង្គាប់ឱ្យគេទឹមព្រះរាជរថបញ្ជិះព្រះកេតុមាលាបរហោះព័ទ្ធជុំវិញប្រាសាទព្រះអង្គ ដើម្បីឱ្យព្រះកេតុមាលាអាចមើលឃើញលំអប្រាសាទសព្វគ្រប់ទាំងអស់ ។

កាលបើព្រះកេតុមាលា បានសង្កេតមើលប្រាសាទព្រះឥន្ទ្រសព្វគ្រប់អស់ហើយ នាយសារថីនាំព្រះកេតុមាលាទៅមើលក្រោលគោសួគ៌ទៀត ។

ព្រះឥន្ទ្រក៏សួរទៅព្រះកេតុមាលាថា អ្នកពេញចិត្តនឹងអ្វីៗ ដែលអ្នកបានឃើញឬទេ ។

ព្រះកេតុមាលាទូលថា ទូលបង្គំមានសេចក្ដីស្ងប់ស្ងែងណាស់ ។

ព្រះឥន្ទ្រមានបន្ទូលថា ដូច្នេះយើងប្រគល់អាណាចក្រកម្ពុជានេះឱ្យឯង ហេតុនេះបើឯងពេញចិត្តនឹងប្រាសាទណាមួយដែលឯងបានឃើញ ហើយចង់សង់ប្រាសាទមួយនៅប្រទេសកម្ពុជាឱ្យល្អដូច្នេះចូរឯងគ្រាន់តែនឹកក្នុងចិត្តទៅ យើងនឹងបញ្ជូនស្ថាបនិកម្នាក់ឱ្យទៅសាងសង់នៅក្នុងប្រទេសឯងមួយរំពេច ។ ព្រះកេតុមាលាពេញចិត្តប្រាសាទមួយដែលមានលំអអស្ចារ្យ គឺក្រោលគោព្រះឥន្ទ្រ ។

ព្រះឥន្ទ្រក៏ទ្រង់ព្រះសម្រួលថា ក្រោលគោនេះជារបស់ល្អចំពោះភ្នែកចៅឯងហើយឬ ? ហើយទ្រង់មានព្រះបន្ទូលទៅកាន់ព្រះពិស្ណុការ ៖ "ចៅឯងជាតិមនុស្សលោក ពុំអាចឋិតនៅក្នុងឋានលើនេះបានរហូតទេ យើងនឹងបញ្ជូនចៅឯងទៅប្រទេសកម្ពុជា ហើយឯងត្រូវសង់ប្រាសាទឱ្យព្រះរាជបុត្រយើងមួយ ឱ្យមានសោភណភាពល្អជាងក្រោលគោយើង ។ កាលបើចៅឯងសង់រួចស្រេចហើយយើងនឹងចុះទៅធ្វើជាអធិបតីក្នុងពិធីរៀបចំអភិសេកព្រះរាជបុត្រយើងឱ្យឡើងសោយរាជ្យ" ។

កាលបើព្រះពិស្ណុការបានពិនិត្យមើលក្រោលគោព្រះឥន្ទ្រសព្វគ្រប់ហើយ ព្រះឥន្ទ្រទ្រង់ក៏ព្រះរាជបញ្ជាឱ្យគេរៀបចំទឹមព្រះរាជរថព្រះអង្គ បញ្ជិះព្រះកេតុមាលានិងព្រះពិស្ណុការចុះមកកាន់ផែនដីត្រង់ប្រទេសកម្ពុជា ។

ព្រះពិស្ណុការក៏ចាប់សង់ប្រាសាទភ្លាម នៅព.ស ៦២០ ។ លោកបានបង្គាប់ឱ្យជីកស្នាមភ្លោះយកអាចម៍ដីចាក់គរលើគ្នាយ៉ាងខ្ពស់ រួចទើបព្រះពិស្ណុការយករូបចម្លាក់ផ្សេងៗ ទៅផ្ដិតលើដីនោះគ្រប់ទិសទាំងអស់ ។ ការសង់ប្រាសាទ ព្រះពិស្ណុការឥតចាំបាច់ចងរន្ទា ដាំសសរមួយម្ដងៗដូចយើងទេ គឺលោកយកដីមកគរសង់ជាប្រាសាទប្រាំជាន់តែម្ដង ទើបយកទឹកថ្នាំលាយទៅលាបពីលើតួប្រាសាទដីទាំងមូល ។ ប្រាសាទក៏ក្លាយទៅជាថ្ម ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

អាស្រ័យហេតុនេះហើយ បានជាយើងឃើញត្រង់វង់កោងនៃដំបូលប្រាសាទឥតមានរនូត ឬសសរទ្រពីក្រោម ។

លុះការស្ថាបនាបានរួចស្រេចកាលណា ព្រះពិស្ណុការក៏លាបថ្នាំលើរូបចម្លាក់ទាំងនោះ តម្រូវឱ្យលាបពណ៌ផ្សេងៗ ធ្វើឱ្យប្រាសាទមានលំអយ៉ាងត្រចះត្រចង់ គឺល្អដូចជាក្រោលគោព្រះឥន្ទ្រ ។

ព្រះកេតុមាលាពេញចិត្តនឹងប្រាសាទនោះណាស់ បានពោលសរសើរព្រះពិស្ណុការជាច្រើន ហើយបានសុំឱ្យព្រះពិស្ណុការសង់ប្រាសាទឯទៀតជាច្រើន ដោយមានរូបចម្លាក់យ៉ាងឆើតឆាយ ។

ព្រះឥន្ទ្រាធិរាជដោយមានពួកទេវតាជាច្រើនតាមដង្ហែផងបានយាងចុះមកឋានក្រោមប្រសិទ្ធពរអភិសេកព្រះរាជបុត្រព្រះអង្គ ហើយព្រះអង្គក៏ថ្វាយព្រះនាមថា អរិដ្ឋពលពាហាទាន (ព្រះកេតុមាលា) រួចទ្រង់ហៅប្រទេសខ្មែរយើងថា កម្ពុជា ដូចសព្វថ្ងៃនេះ ។ [...]

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរ ភាគ៥)*

## សំណួរ

១. ហេតុអ្វីបានជានាងទិព្វសុតាចន្ទ ចុះមករស់នៅជាមួយតាលឹមសេង ឯឋានមនុស្សលោក ?

២. តើនាងទិព្វសុតាចន្ទទូលព្រះឥន្ទ្រដូចម្ដេចខ្លះអំពីព្រះពិស្ណុការ ? តើព្រះពិស្ណុការបានរៀនវិជ្ជាអ្វីខ្លះនៅទីនោះ ?

៣. តាមដំណើររឿង តើអតីតជាតិរបស់ព្រះឥន្ទ្រគឺនរណា ? ហេតុអ្វីបានជាព្រះអង្គបានកើតជាព្រះឥន្ទ្រ ?

៤. ចូរបង្ហាញពីបច្ចេកទេសត្រួសៗក្នុងការកសាងប្រាសាទរបស់ព្រះពិស្ណុការ ។

៥. ចូរបង្ហាញកាលអាកាសរបស់រឿង ។

៦. ចូររកប្រធានរឿង និងមូលបញ្ហារបស់រឿង ។

៧. តាមពិត តើព្រះពិស្ណុការតំណាងឱ្យនរណា ? ហេតុអ្វី ?

៨. ចូរស្រង់ពាក្យដែលជានាមនៅប្រភេទនីមួយៗឱ្យបានយ៉ាងតិចពីរពាក្យ ។

## ការសង្ខេប

ការសង្ខេប គឺជាការនិយាយ ឬសរសេរបំព្រួញឱ្យខ្លីតែមានន័យគ្រប់គ្រាន់ ដោយច្បិចយកតែចំណុច គំនិត ព្រឹត្តិការណ៍ ឬខ្លឹមសារសំខាន់ៗ ដោយរក្សាន័យខ្លឹមសារដើម ។ គេអាចសង្ខេបចេញពីបទអត្ថាធិប្បាយ អង្គពិភាក្សា អត្ថបទរឿង កំណាព្យ អត្ថបទអត្ថាធិប្បាយ ។ល ។

ចូរពិនិត្យឧទាហរណ៍ :

### រឿងព្រេងទាក់ទងនឹងទំនៀមទម្លាប់ដាក់ប្រាក់កាក់ក្នុងមាត់បុគ្គលស្លាប់

មានរឿងបុរាណតំណាលតៗគ្នាមកថា មានប្ដីប្រពន្ធពីរនាក់ខំប្រឹងរកស៊ី តាំងពីក្មេងរហូតដល់ចាស់បានមាសតែមួយបាទហើយគ្មានកូនម្នាក់សោះ ។ ប្ដីប្រពន្ធចំណាស់ទាំងពីរនាក់បានផ្ដាំគ្នាទៅវិញទៅមកថា បើនរណាស្លាប់មុនត្រូវយកមាសនោះដាក់ក្នុងមាត់អ្នកនោះ ។ ចំណោរតមក ប្ដីក៏ស្លាប់មុនទៅ ។ ប្រពន្ធក៏យកមាសនោះដាក់ក្នុងមាត់សពប្ដី ។ នៅពេលបូជាសពប្ដី ភ្លើងឆេះមាសនោះរលាយអស់នៅសល់តែ ៣ស្លឹង ។

សម័យមួយ ព្រះមហាក្សត្រចេញព្រះរាជបញ្ជាឱ្យរៃយកមាសក្នុងមួយផ្ទះចំនួនមួយបាទជាកំហិត ។ យាយជាប្រពន្ធរបស់ខ្មោចតានោះ ក៏យកមាស ៣ស្លឹង ដែលគាត់រើសទុកនោះទៅថ្វាយព្រះមហាក្សត្រដោយទូល ៖ “ក្រាបទូលព្រះករុណា ! មាសនេះពីដើមពេញ ១បាទ តែខ្ញុំម្ចាស់យកទៅបង់មាត់ឱ្យប្ដីខ្ញុំម្ចាស់ ក៏ត្រូវភ្លើងឆេះអស់នៅសល់តែប៉ុណ្ណេះ ! សូមព្រះករុណា មេត្តាដល់សត្វទាល់ក្រផងចុះ ! ខ្ញុំម្ចាស់ទាល់មធ្យោបាយហើយ ! មិនអាចទៅរកមាសឯណាឱ្យបានគ្រប់ចំនួនថ្វាយព្រះអង្គបានឡើយ !” ។ ព្រះមហាក្សត្រទ្រង់សណ្ដាប់ចប់ហើយ ទ្រង់ក៏កើតក្ដីសង្វេគ ស្លុតព្រះទ័យ អាសូរដល់ប្រជារាស្ត្រយ៉ាងខ្លាំង ទើបទ្រង់ប្រកាសឱ្យលើកលែងការរៃយកមាសពីបណ្ដារាស្ត្រទាំងអស់ក្នុងនគរ ។

អាស្រ័យហេតុនេះហើយ ទើបបណ្ដារាស្ត្រទាំងអស់យល់ថា ប្រាក់ឬមាសដែលបង់ក្នុងមាត់បុគ្គលដែលស្លាប់ទៅនោះ មានអានុភាពខ្លាំងក្លាណាស់ សូម្បីព្រះមហាក្សត្រក៏ចាញ់អានុភាពនេះដែរ ។ ហេតុដូចនេះហើយបានជាប្រជាជនខ្មែរយើងចាត់ទុកថា ប្រាក់ឬមាសដែលបង់ក្នុងមាត់សព ជាវត្ថុស័ក្ដិសិទ្ធិ ហើយនាំគ្នាអនុវត្តទម្លាប់នេះរហូតមកដល់សព្វថ្ងៃ ។

*(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរ ភាគ៩ )*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# អត្ថបទសង្ខេប

មានតំណាលតៗគ្នាមកថា មានតានិងយាយប្ដីប្រពន្ធពីរនាក់ពុំមានកូនចៅឡើយ ។ ពួកគាត់ខំប្រឹងរកស៊ីមានតែមាស ១បាទប៉ុណ្ណោះ ។ នៅពេលតាស្លាប់ទៅ យាយក៏យកមាស ១ បាទនោះទៅដាក់ក្នុងមាត់សពតា ។ ក្រោយពីបូជាសពតារួច មាសត្រូវភ្លើងឆេះអស់សល់តែ ៣ស្លឹង ។ គាប់ជួនសម័យមួយព្រះមហាក្សត្រតម្រូវឱ្យរៃយកមាសពីប្រជារាស្ត្រក្នុងមួយគ្រួសារ ១បាទ ។ យាយគ្មានមាសគ្រប់មួយបាទ គឺមានតែមាស ៣ស្លឹងប៉ុណ្ណោះ សល់ពីបង់មាត់ខ្មោចតា យកមកថ្វាយព្រះមហាក្សត្រដោយរៀបរាប់ពីសេចក្ដីទុក្ខលំបាកនិងភាពទាល់ច្រករបស់គាត់ ថ្វាយទ្រង់សណ្ដាប់ ។ ព្រះមហាក្សត្រកើតក្ដីសង្វេគអាណិតប្រជារាស្ត្រ ព្រោះអ្នកស្លាប់ទៅគ្រាន់តែប្រាក់មួយបាទយកទៅមិនបានផង ទ្រង់ក៏ប្រកាសលើកលែងការរៃមាសនេះពីប្រជារាស្ត្រទូទាំងនគរ ។

ហេតុដូចនេះបានជាប្រជាជនយល់ថា ប្រាក់ឬមាសបង់មាត់បុគ្គលដែលស្លាប់នេះមានអានុភាពខ្លាំងក្លាណាស់ ហើយនាំគ្នាអនុវត្តទម្លាប់ដាក់ប្រាក់ ឬមាសក្នុងមាត់បុគ្គលដែលស្លាប់តៗគ្នារហូតដល់បច្ចុប្បន្ននេះ ។

## សំណួរ

១. តើរឿងខាងលើនិយាយពីបញ្ហាអ្វី ?

២. តើរឿងទាំងមូលខាងលើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ ?

៣. តើរឿងទាំងមូលនិងអត្ថបទសង្ខេបមានលក្ខណៈដូចគ្នានិងខុសគ្នាត្រង់ណាខ្លះ ?

## លំហាត់

ចូរអ្នកសង្ខេបអត្ថបទរឿងក្នុងអំណានទី ១ និងទី ២ ឡើងវិញ ។ ពេលសង្ខេបរឿងឡើងវិញចូរអនុវត្តតាមការណែនាំមួយចំនួនដូចខាងក្រោម

- លើកយកតែព្រឹត្តិការណ៍សំខាន់ៗរបស់រឿងមកបង្ហាញ ។
- ចងក្រងព្រឹត្តិការណ៍ ឬគំនិតសំខាន់ៗទាំងនោះឱ្យមានលក្ខណៈរៀបរយល្អតាមលំដាប់លំដោយនៃដំណើររឿង ។
- ប្រើប្រាស់ពាក្យប្រាប់លំដាប់ឱ្យបានត្រឹមត្រូវ ។
- ប្រើពាក្យសម្ដីផ្ទាល់ខ្លួនឱ្យបានសមរម្យនិងត្រឹមត្រូវ ។

# បំពេញទម្រង់កិច្ចសន្យាផ្សេងៗ

មានសន្តិភាព គឺមានការអភិវឌ្ឍ ។ ក្រោយពីសង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សរ៍ត្រូវបានបញ្ចប់ ប្រទេសកម្ពុជាយើងមានការអភិវឌ្ឍលើគ្រប់វិស័យដូចជា សេដ្ឋកិច្ច គមនាគមន៍ កសិកម្ម ទេសចរណ៍ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ។ ដោយឡែកផ្នែកសេវាកម្ម ក៏កំពុងរីកលូតលាស់គួរជាទីមោទនៈ ។ សេវាកម្មទាំងនោះមានដូចជា សេវាកម្មផ្នែកទេសចរណ៍ គមនាគមន៍ ដឹកជញ្ជូន ជំនួញការលក់ដូរអចលនវត្ថុ ... ។ ដើម្បីញ៉ាំងដំណើរការសេវាកម្មទាំងនោះឱ្យប្រព្រឹត្តទៅត្រឹមត្រូវតាមច្បាប់និងមានភាពរលូន ហើយទទួលបានលទ្ធផលល្អនិងត្រឹមត្រូវតាមច្បាប់នោះ គឺត្រូវមានលិខិតស្នាមតាមទម្រង់បែបបទផ្សេងៗនិងទៅតាមការកំណត់ ។ លិខិតស្នាមទាំងនោះមានដូចជា លិខិតធ្វើដំណើរ វិក្កយបត្រ លិខិតរាយការណ៍របស់អ្នកដំណើរ ទិដ្ឋាការធ្វើដំណើរ កិច្ចសន្យា ... ។

ឥឡូវនេះចូរអ្នកសិក្សាទម្រង់កិច្ចសន្យាមួយចំនួនដូចខាងក្រោម រួចចម្លងគំរូកិច្ចសន្យានេះដាក់ក្នុងសៀវភៅរបស់អ្នក ។ បន្ទាប់មកចូរអ្នកបំពេញព័ត៌មានផ្សេងៗតម្រូវទៅតាមគំរូនៃកិច្ចសន្យានីមួយៗឱ្យបានត្រឹមត្រូវ ។

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាលក់ដី

ខ្ញុំឈ្មោះ .................. ភេទ ..... អាយុ ...... ឆ្នាំ ជនជាតិ ...... សញ្ជាតិ ........ និងប្រពន្ធឈ្មោះ ............ អាយុ...... ឆ្នាំ ជនជាតិ ...... សញ្ជាតិ ........ មានទីលំនៅផ្ទះលេខ .......ភូមិ / ក្រុម ......ឃុំ / សង្កាត់ ................ ស្រុក / ខណ្ឌ ..................... ខេត្ត / ក្រុង .................. ។

បានលក់ដីមួយកន្លែងឱ្យទៅឈ្មោះ .................................... អាយុ ........... ឆ្នាំ និងប្រពន្ធឈ្មោះ ............ អាយុ...... ឆ្នាំ មានទីលំនៅផ្ទះលេខ .......ភូមិ / ក្រុម ...... ឃុំ / សង្កាត់ ................ ស្រុក / ខណ្ឌ ............... ខេត្ត / ក្រុង .................. ដែលមានទទឹង .................... បណ្តោយ ................. ទំហំ .................. ។

- ព្រំប្រទល់ខាងជើងជាប់នឹង .............................
- ព្រំប្រទល់ខាងត្បូងជាប់នឹង .............................
- ព្រំប្រទល់ខាងលិចជាប់នឹង .............................
- ព្រំប្រទល់ខាងកើតជាប់នឹង .............................

តម្លៃ .................................... ( ...................................................... )

យើងខ្ញុំសូមសន្យាថា បើថ្ងៃក្រោយមានជនណាមកចោទប្រកាន់ ឬតវ៉ាដោយប្រការណាមួយ ខ្ញុំបាទ នាងខ្ញុំជាម្ចាស់កម្មសិទ្ធិចាស់សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។ ក្រែងពុំប្រាកដសូមផ្តិតមេដៃខាងស្តាំទុកជាភស្តុតាង ។

ស្នាមមេដៃអ្នកដឹងឮ ថ្ងៃទី ...... ខែ ........ ឆ្នាំ ..........

សាក្សីទី ១ សាក្សីទី ២ ស្នាមមេដៃស្តាំ

អ្នកទទួល អ្នកប្រគល់

បានឃើញនិងបញ្ជាក់ថា

ឈ្មោះ .................... ពិតជាបានលក់ដី

ឱ្យឈ្មោះ ........................ ពិតមែន ។

ថ្ងៃទី ........ ខែ ........... ឆ្នាំ ............

ហត្ថលេខានិងត្រាមេឃុំ ឬចៅសង្កាត់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាជួលផ្ទះ

## ភាគី "ក" ម្ចាស់ផ្ទះ

ឈ្មោះ : ...............................................................................................

អាសយដ្ឋានផ្ទះលេខ ................. ផ្លូវលេខ .................... ក្រុមទី .......................

## ភាគី "ខ" អ្នកជួលផ្ទះ

ឈ្មោះ : ...............................................................................................

អាសយដ្ឋានផ្ទះលេខ ............ ផ្លូវលេខ ............. ក្រុមទី ........... ភូមិ ..............

សង្កាត់ /ឃុំ ..................... ខណ្ឌ / ស្រុក ................... ខេត្ត / ក្រុង ..............

ភាគីបានព្រមព្រៀងនិងឯកភាពគ្នាលើលក្ខខណ្ឌដូចខាងក្រោម ៖

**ប្រការ ១ :** ភាគី "ក" បានយល់ព្រមជួលផ្ទះរបស់ខ្លួនលេខ .......... ផ្លូវលេខ ........... ក្រុមទី ...........សង្កាត់ ................. ខណ្ឌ ............ រាជធានីភ្នំពេញ ឱ្យភាគី "ខ" ដើម្បីស្នាក់នៅរយៈពេល .....ឆ្នាំ ដោយគិតតម្លៃ ...ក្នុង១ខែ ។

**ប្រការ ២ :** ភាគី "ខ" បានយល់ព្រមនិងឯកភាពជួលផ្ទះតាមតម្លៃនិងរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ ៣ :** ភាគី "ខ" ត្រូវបង់ថ្លៃឈ្នួលផ្ទះចំនួន ........ខែ មុនឱ្យទៅភាគី "ក" ផុតរយៈពេល ...............ខែ ភាគី "ខ" ត្រូវបង់ថ្លៃឈ្នួលផ្ទះក្នុងអាទិត្យទី ........... នៃខែនីមួយៗជារៀងរាល់ខែ ។

**ប្រការ ៤ :** មុនពេលជួលភាគី "ក" ត្រូវពិនិត្យជួសជុលប្រសិនបើផ្ទះនោះមានកន្លែងខ្លះធ្លុះធ្លាយ បាក់ពុក លិចនៅពេលភ្លៀងធ្លាក់ រាំងស្ទះចរន្តទឹក និងរៀបចំប្រព័ន្ធទឹក ចរន្តអគ្គិសនី ធ្វើយ៉ាងណាឱ្យផ្ទះមានភាពសមរម្យងាយស្រួលក្នុងការស្នាក់អាស្រ័យ ។ ចំណែកភាគី "ខ" ក៏ត្រូវពិនិត្យពិច័យផ្ទះឱ្យបានមុនជាស្រេច ដើម្បីសម្រេចចិត្តយល់ព្រមជួល ។ ភាគី "ក" មិនធានាជួសជុលជាបន្តបន្ទាប់នូវការខូចខាតទាំងឡាយដោយមូលហេតុមិនសមស្របឡើយ ។

**ប្រការ ៥ :** ភាគី "ខ" ត្រូវរក្សាសភាពផ្ទះឱ្យនៅដូចដើមបើមានការចាំបាច់ត្រូវជួសជុលកែផ្ទះ ចាំបាច់ត្រូវពិគ្រោះជាមួយម្ចាស់ផ្ទះជាមុនសិន ។ នៅពេលខូចខាតសភាពផ្ទះ ដោយមានមូលហេតុ ភាគី "ខ" ជាអ្នកធ្វើឱ្យខូចខាតនោះ ភាគី "ខ" ត្រូវជួសជុលសងម្ចាស់ផ្ទះវិញ ។

**ប្រការ ៦ :** រយៈពេល ១អាទិត្យមុនផុតកំណត់នៃកិច្ចសន្យា បើភាគី "ខ" មានបំណងចង់ជួលផ្ទះនេះបន្តទៀត ភាគី "ខ" ត្រូវជូនដំណឹងទៅ ភាគី "ក" ដើម្បីពិនិត្យពិចារណា ហើយបើ ភាគី "ក" មានការយល់ព្រម នោះត្រូវធ្វើកិច្ចសន្យាសាជាថ្មី ។

**ប្រការ ៧ :** បើមានរឿងហេតុអ្វីកើតឡើង ពាក់ព័ន្ធដល់បញ្ហាផ្ទះនេះ ភាគីទាំងពីរត្រូវពិភាក្សាគ្នាដោះស្រាយ ដោយផ្អែកលើឆន្ទៈយោគយល់គ្នាទៅវិញទៅមក ។

**ប្រការ ៨ :** កិច្ចសន្យានេះ អាចបន្តច្រើនឆ្នាំបាន ប្រសិនបើ ភាគី "ខ" អាចមានលទ្ធភាពជួលក្នុងតម្លៃជួលឯកភាពគ្នារវាងអ្នកជួលនិងម្ចាស់ផ្ទះ ។

កិច្ចសន្យានេះ បានរៀបចំចងក្រងឡើងជា ភាសាខ្មែរ ចំនួន ០៣ច្បាប់

- ភាគី "ក" រក្សាទុក ០១ច្បាប់
- ភាគី "ខ" រក្សាទុក ០១ច្បាប់
- សាក្សីរក្សាទុក ០១ច្បាប់

ភាគីទាំងពីរបានឯកភាពគ្នា អនុវត្តកិច្ចសន្យានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅ ........... ថ្ងៃទី ...... ខែ ......... ឆ្នាំ ..........

| ហត្ថលេខា | | | ហត្ថលេខា |
|---|---|---|---|
| អ្នកជួលផ្ទះភាគី "ខ" | សាក្សីទី ១ | សាក្សីទី ២ | ម្ចាស់ផ្ទះភាគី "ក" |

ប្រធានក្រុមទី ...
ហត្ថលេខា

បានឃើញនិងបញ្ជាក់ថា
ឈ្មោះ .................... ពិតជាបានជួលផ្ទះ
ឱ្យឈ្មោះ ......................... ពិតមែន ។
ថ្ងៃទី ........ ខែ ........... ឆ្នាំ ............
ហត្ថលេខានិងត្រាមេឃុំ ឬចៅសង្កាត់

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាជួលដី

ខ្ញុំឈ្មោះ .................. ភេទ ..... អាយុ ...... ឆ្នាំ ជនជាតិ ...... សញ្ជាតិ ........
និងប្រពន្ធឈ្មោះ ............ អាយុ...... ឆ្នាំ មានទីលំនៅផ្ទះលេខ .......ភូមិ / ក្រុម ......
ឃុំ / សង្កាត់ ................ ស្រុក / ខណ្ឌ ............. ខេត្ត / ក្រុង ..................។
បានជួលដីមួយកន្លែងឱ្យទៅឈ្មោះ .................................... អាយុ ........... ឆ្នាំ
និងប្រពន្ធឈ្មោះ ............ អាយុ...... ឆ្នាំ មានទីលំនៅផ្ទះលេខ .......ភូមិ / ក្រុម ......
ឃុំ / សង្កាត់ ................. ស្រុក / ខណ្ឌ ................ ខេត្ត / ក្រុង ..................
ដែលមានទទឹង .................... បណ្ដោយ ................. ទំហំ ................... ។

- ព្រំប្រទល់ខាងជើងជាប់នឹង ..............................
- ព្រំប្រទល់ខាងត្បូងជាប់នឹង ..............................
- ព្រំប្រទល់ខាងលិចជាប់នឹង ..............................
- ព្រំប្រទល់ខាងកើតជាប់នឹង ..............................

តម្លៃ .................................... ( ...................................................... )

យើងខ្ញុំសូមសន្យាថា បើថ្ងៃក្រោយមានជនណាមកចោទប្រកាន់ ឬតវ៉ាដោយប្រការណាមួយ ខ្ញុំបាទ នាងខ្ញុំជាម្ចាស់កម្មសិទ្ធិចាស់សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។ ក្រែងពុំប្រាកដសូមផ្ដិតមេដៃខាងស្ដាំទុកជាភស្ដុតាង ។

ថ្ងៃទី .......... ខែ ........ ឆ្នាំ ...........

ស្នាមមេដៃអ្នកដឹងឮ

សាក្សីទី១ សាក្សីទី២

ស្នាមមេដៃខាងស្ដាំ

អ្នកទទួល អ្នកប្រគល់

បានឃើញនិងបញ្ជាក់

ឈ្មោះ ................. ពិតជាបានជួលដីឱ្យ

ឈ្មោះ ............................ពិតមែន ។

ថ្ងៃទី ........ ខែ .......... ឆ្នាំ .........

ហត្ថលេខានិងត្រាមេឃុំ ឬចៅសង្កាត់

**មេរៀនទី ២**

# អត្តសញ្ញាណជាតិ



អត្តសញ្ញាណជាតិ គឺជាគ្រឿងសម្គាល់ ជាទីអាងនូវលក្ខណៈពិសេសនិងដោយឡែករបស់ជាតិសាសន៍នីមួយៗ ។ អត្តសញ្ញាណជាតិខ្មែររួមមាន ទង់ជាតិ ភ្លេងជាតិ ភាសា អក្សរ សិល្បៈ វប្បធម៌ អក្សរសាស្ត្រ ជំនឿ សាសនា ប្រពៃណី និងទំនៀមទម្លាប់ជាតិផ្សេងៗទៀតដែលឆ្លុះបញ្ចាំងនូវផ្នត់គំនិត ទស្សនៈ ចរិតលក្ខណៈជាតិ ។

ក្នុងមេរៀននេះ អ្នកនឹងស្វែងយល់ដឹងពីអត្តសញ្ញាណជាតិខ្មែរមួយចំនួនដែលទាក់ទងនឹងជំនឿ ប្រពៃណី ទំនៀមទម្លាប់ សាសនា ភាសា អក្សរ ព្រមទាំងផ្នត់គំនិតរបស់ជាតិសាសន៍ខ្មែរមួយចំនួន ។

ទន្ទឹមនេះ អ្នកនឹងសិក្សាអំពីអ្នកនិពន្ធ កាលកំណត់តែងនិងសង្គមបរិយាកាសនៃរឿង ចំណោទបញ្ហា កាលអាកាស ប្រធានរឿង មូលបញ្ហានៃរឿង ការនិយាយបញ្ចេញមតិផ្ទាល់ខ្លួន ការសរសេរសំណេរវិភាគអត្ថបទ និងអំពីសព្វនាមនិងប្រភេទរបស់សព្វនាម ។

## អំពីអ្នកនិពន្ធ កាលកំណត់តែង និងសង្គមបរិយាកាសនៃរឿង

ការសិក្សាអត្ថបទអក្សរសិល្ប៍ ចាំបាច់យើងត្រូវសិក្សាជាដំបូងពីប្រវត្តិនៃរឿង ដើម្បីដឹងអំពីប្រភពនិងប្រភេទរឿង ។ ជាពិសេស ត្រូវស្គាល់អ្នកនិពន្ធ ស្នាដៃ កាលកំណត់តែង និង សង្គមបរិយាកាសនៃរឿង ។ មានស្នាដៃរឿងខ្លះបានប្រាប់ពីឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទ ឬកាលកំណត់តែងច្បាស់លាស់ ។ ប៉ុន្តែក៏មានរឿងខ្លះទៀតមិនបានប្រាប់ឈ្មោះអ្នកនិពន្ធ ឬកាលកំណត់តែងឡើយ ដូចជារឿងព្រេងជាដើម ។

ចូរអ្នកអានអត្ថបទរឿងខាងក្រោម :

### អត្ថបទដកស្រង់ពីរឿង ផ្កាស្រពោន : វគ្គទី ៩

នៅក្នុងព្រៃដែលដុះព័ទ្ធបុរាណប្រាសាទនានា មានរបស់ពីរយ៉ាងដែលនាំបង្កើតដួងចិត្តទេសចរឱ្យរីងរឹតតែស្រងេះស្រងោចខ្លោចផ្សា ដោយសេចក្តីស្តាយអាល័យដល់កេរស្នាដៃនៃបុព្វបុរសខ្មែរ ។ វត្ថុនោះហាក់ដូចជាខ្យល់ព្រលឹងនិងសំឡេងនៃប្រវត្តិមាតុភូមិយើង ។

ពេលរសៀល ! វេលាដែលព្រះសុរិយាកំពុងដុតចំហុយអស់ទាំងធម្មជាតិ រៃកណ្តឹងយំទំលាក់សំឡេងពីចុងស្រឡៅ ឬចុងឈើទាលដែលខ្ពស់ត្រដែតក្នុងអាកាស ។ សព្ទតូរ្យតន្ត្រីចម្លែកនេះ ជ្រាបចូលសព្វសារពាង្គកាយ ហើយមករុំស្រោបបេះដូង នាំឱ្យអ្នកដំណើរទាំងពួងយន់ចិត្តអាសូរដល់ស្រុកកំណើតដែលធ្លាប់ចុំថ្មើង ។

នៅខែចេត្រនិងពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរក្លិនផ្ការំដួលបញ្ចេញក្លិនរំភើយពិដោរក្រអូបឈ្ងុយ ។ បើជួនជាមានវាយោបក់បន្តិចៗផង អ្នកដែលដើរយកអាកាសពេលល្ងាចតាមថ្នល់នេះនឹងមានចិត្តរសាប់រសល់អណ្តែតអណ្តូងប្រហែលជានឹងលាន់មាត់ថា ទោះជាឋានតុសិត ក៏មិនសប្បាយជាជាងនេះទេមើលទៅ ។

ឱក្លិនរំដួល ! ឱសំឡេងរៃ ! កម្លាំងអ្នកដូចជាទិព្វឱសថដែលអាចចូលមករំសាយសេចក្តីសោកសង្រេងមួយពេលបាន ។

នៅពេលរសៀល រទេះសេះមួយបរចូលតាមខ្លោងទ្វារខាងកើតមកក្នុងកំពែងនគរធំ ។ ត្រចៀកប្រុងស្តាប់ ភ្នែកប្រុងមើលនាងវិធាវីអង្គុយអែបនឹងមាតា ដែលនិយាយចេកចាចនឹងនាងសុចិត្រាគ្មានឈប់មាត់ឡើយ ។ នាងស្រីក្រមុំគិតក្នុងចិត្ត ៖ "ឱពីបុរាណកាល ម្ល៉េះសមមានមនុស្សអ៊ូអរកុះករម្តេចឡើយឥឡូវក៏វិលទៅជាព្រៃស្ងាត់អស់រលីង មុខគួរស្រណោះពេក" ។ នៅក្នុងពេលដែលចិត្តនាងកំពុងតែលន្លោចទៅក្នុងអតីតសម័យនៃមាតុភូមិដូច្នោះ ស្រាប់តែរទេះសេះឈប់ង៉ក់ ហើយពួនាង

សុចិត្រានិយាយមកកាន់នាង ៖ "មកក្មួយ យើងចុះមើលប្រាសាទបាយ័នសិន"។ នាងវិធាវីរៀបខ្លួននឹងចុះ ទទួលងាកមុខទៅម្ខាងថ្មល់ ឃើញអង្គពុទ្ធបដិមាមួយយ៉ាងធំបិទមាសច្រាលផ្អោគង់នៅក្នុងរោងប្រក់ក្បឿងមួយ។ ឃើញដូច្នោះហើយ នាងថ្លែងថា ទេមីងខ្ញុំចង់ថ្វាយបង្គំព្រះអង្គនេះសិន សឹមយើងទៅមើលប្រាសាទជាក្រោយ។

សេចក្តីប្រាថ្នានេះ អ្នកសហចរបានយល់ព្រមផងហើយ នារីនាងក៏ទាញយកទៀនមួយ ធូបបីសរសៃពីសំណុំ ហើយក៏លីលាទៅកាន់សំណាក់ព្រះពុទ្ធរូបអង្គនោះ។ លំដាប់ក្រោយដែលបានអុជគ្រឿងសក្ការបូជារួច នាងក៏តាំងសូត្រនមស្ការយ៉ាងផ្ចិតផ្ចង់។ លុះចប់ហើយ នាងក៏តាំងនឹកប្រាថ្នាសុំតែក្នុងចិត្តថា ឱព្រះអង្គដែលធ្លាប់ស្រោចស្រង់សត្វលង់ទឹកបាន សូមព្រះអង្គទ្រង់សន្តោសខ្ញុំព្រះករុណាឱ្យបានផុតរណ្តៅពីគ្រោះធំ។ ខ្ញុំព្រះករុណាតាំងពីឃើញរស្មីព្រះអាទិត្យមកដល់សព្វថ្ងៃនេះ ខ្ញុំព្រះករុណាឥតបានធ្វើបាបជនណា សត្វមួយណាឡើយ។ ខ្ញុំព្រះករុណាបានកាន់សីលប្រាំខ្ជាប់មិនរសាយ បានធ្វើបុណ្យបំពេញទានតាមកម្លាំងទ្រព្យនៃយុវជន ហើយបានស្គាល់ព្រះធម៌ទាំងពួងផង។ ហេតុនេះសូមព្រះអង្គសន្តោសជួយខ្ញុំព្រះករុណាឱ្យបានរួចពីក្រញាំចៅណៃស៊ិតកំណាចចេញ ហើយឱ្យខ្ញុំព្រះករុណាជួបតែបង ប៊ុន ធឿន ដែលជាគូព្រេងកម្សត់វៀងទៅ...។ នាងវិធាវីកំពុងតែផ្ចិតផ្ចង់បន់យ៉ាងនេះ ស្រាប់តែរថយន្តមួយបើកមកឈប់ប្រែបរទេះសេះ។ នាងដាក់ភ្នែកមើលទៅឃើញនាងថូនិងចៅណៃស៊ិតដើរមកចំរោង នាងក៏លើកនេត្រាសម្លឹងទៅចំព្រះភក្ត្រព្រះពុទ្ធរូបដែលនៅតែញញឹមស្ងួតដូចពីមុន។ ទឹកភ្នែកក៏ហូរមកស្រពមុខនាង។ នាងនឹកក្នុងចិត្ត ៖ "ឱព្រះអង្គអើយ ! មារជ្រែកមកដល់ទៀតហើយ"។

ឯយាយនួនដែលអង្គុយរង់ចាំពីក្រោយខ្នងកូនគាត់នោះ កាលបើបានឃើញដន្លងគាត់មកដល់ ក៏ស្ទុះទៅសាកសួរសុខទុក្ខដោយរាក់ទាក់។ ក្រោយដែលបានលើកដៃសំពះសួរគ្នាទៅវិញទៅមកជាមួយនាងសុចិត្រារួចហើយ នាងថូក៏និយាយទៅកាន់យាយនួន ៖

- ចែអើយចែ កាលដែលខ្ញុំប្រទះចែនៅផ្សារស្វាយប៉ោ រួចខ្ញុំត្រឡប់ទៅផ្ទះវិញនោះ ខ្ញុំបានប្រាប់ណៃស៊ិតថា ចែអញ្ជើញទៅលេងអង្គរ នុ៎ះណៃស៊ិត ក៏ចេះតែកន្ទក់កន្ទេញឱ្យខ្ញុំនាំវាមក ដើម្បីយកឡានមកជូនចែដើរលេង។

យាយនួនគាត់ឮសម្តីនេះហើយ គាត់ក៏ងាកទៅមើលមុខចៅណៃស៊ិត ហើយទឹកមុខគាត់ក៏រីកថ្លាដោយសេចក្តីប្រតិព័ទ្ធយ៉ាងជ្រាលជ្រៅ។ ឯចៅណៃស៊ិតដែលឈរដាច់ពីខាងក្រោយស្ត្រីទាំងពីរនោះរវល់តែនឹងបែរបៀងនាយអាយ ញញឹមរំពៃទៅរកនាងវិធាវី ធ្វើឱ្យយុវតីនេះក្តៅរំខានពន់ប្រមាណ។ នាងខំទប់មិនឈ្នះក៏បបួលម្តាយនាងឱ្យឡើងជិះរទេះសេះត្រឡប់ទៅសៀមរាបវិញ។ នាងថូឮដូច្នោះ

ហើយ ក៏ខំនិយាយអង្វរលួងលោមនាងវិធាវីឱ្យជិះឡានជាមួយខ្លួន។ បុត្រីយាយនួនដែលភ្លើងទោសៈកំពុងដុតរោលដើមទ្រូងនោះ ក៏ខំសង្កត់ចិត្តឆ្លើយដោយស្រួលវិញ :

- ខ្ញុំសូមអរគុណមីងចុះ តែឥឡូវជិះឡានមិនបានទេ ព្រោះបើជិះកាលណាហើយ ខ្ញុំចេះតែវិលមុខ។

ថាហើយនាងក៏ទាញដៃនាងសុចិត្រាឡើងរទេះសេះ។ ឯយាយនួនដែលស្មារតីនៅនឹងឡាននាងថូ ក៏ធ្វើមុខជូរហើយដើរតាមកូនគាត់ទៅដោយទាល់គំនិត ...។

កាលដែលយាននៃស្ត្រីទាំងបីនាក់ចរបានបន្តិចទៅ មេឃខែចេត្រដែលថ្លាត្រចះជាច្រើនថ្ងៃមកហើយ ក៏ប្រែជាងងឹតមានពពកខ្មៅតាន់តាប់មកបាំងពន្លឺព្រះអាទិត្យភ្លាម ព្រមទាំងមានព្យុះបក់ធូលីនិងស្លឹកឈើហុយដង្កោលផង។ ហើយមិនយូរប៉ុន្មានក៏មានភ្លៀងបង្អុរធ្លាក់មកដោយគ្រាប់ធំៗ ជះសាចទទឹកស្ត្រីដំណើរទាំងបីញ័រខ្លួនចំប្រប់។ ទទួលពេលនោះ រទេះបរដល់ភូមិនាគដែលនៅត្រង់មុខប្រាសាទអង្គរវត្ត នាងសុចិត្រានិងយាយនួន ក៏បបួលនាងវិធាវីឱ្យជ្រកភ្លៀងនៅទីនោះសិន។ ប៉ុន្តែយុវតីនេះដែលនឹកក្នាញ់មមៃក្នុងចិត្តចង់ឱ្យបានដល់ទីលំនៅឆាប់ៗ ព្រោះនឹកក្រែងថៅណៃស៊ិតមកទាន់ទៀត ក៏និយាយអង្វរឱ្យរទេះខំស្រូតតម្រង់ទៅសៀមរាបតែម្តង។

នៅពេលល្ងាចនោះ នាងវិធាវីកើតក្តៅរោលក្នុងខ្លួន ហើយបណ្តាលឱ្យនាងទៅជាគ្រុននិទ្រាដណ្តប់ភួយ ឥតបានទទួលម្ហូបអាហារអ្វីឡើយ។

*(ដកស្រង់ពីរឿង ផ្កាស្រពោនរបស់លោកនូហាច ១៩៤៧ បោះពុម្ពឡើងវិញឆ្នាំ ២០០៣ ទំព័រទី ៦៣-៦៥)*

តាមអត្ថបទដកស្រង់នៃរឿងខាងលើនេះ យើងឃើញថាអត្ថបទនេះ ដកស្រង់ចេញពីរឿងផ្កាស្រពោន របស់អ្នកនិពន្ធឈ្មោះ នូ ហាច ដែលតែងឡើងចប់សព្វគ្រប់និងបោះពុម្ពផ្សាយនៅឆ្នាំ ១៩៤៧។ សង្គមបរិយាកាសនៃរឿងនេះ ស្ថិតនៅក្នុងសម័យប្រទេសកម្ពុជាត្រូវបែងចែកអាណាខេត្តខាងជើងទៅនៅក្រោមអាណានិគមនិយមបារាំងនិងប្រទេសជិតខាង។ ផ្នត់គំនិតសង្គមនាសម័យនោះគឺការប្រកាន់ខ្ជាប់នូវជំនឿ ទំនៀមទម្លាប់ ប្រពៃណីជាធំ។ ព្រឹត្តិការណ៍សំខាន់ៗនៃរឿង គឺការប្រកាន់ឋានៈនៅក្នុងសង្គមរវាងអ្នកមាននិងអ្នកក្រ និងភាពកតញ្ញូចំពោះអ្នកមានគុណ បានធ្វើឱ្យសេចក្តីស្រឡាញ់ដ៏ស្មោះស្ម័គ្រនៃគូអង្គទាំងពីរត្រូវបាត់បង់យ៉ាងខ្លោចផ្សា។ ។

*អ្នកនិពន្ធ គឺជាអ្នកសរសេរ ឬតាក់តែងរឿង ។*

*កាលកំណត់តែង* គឺជាពេលវេលា ថ្ងៃខែឆ្នាំ ដែលអ្នកនិពន្ធបានសរសេរចប់សព្វគ្រប់ ហើយបានបញ្ជាក់នៅក្នុងស្នាដៃរបស់ខ្លួនយ៉ាងពិតប្រាកដ ។

*សង្គមបរិយាកាស* គឺដំណើររឿងដែលអ្នកនិពន្ធលើកមកបង្ហាញស្ថិតក្នុងសម័យកាលណាមួយ ហើយមានព្រឹត្តិការណ៍សង្គមអ្វីខ្លះនៅក្នុងរឿងដែលគួរកត់សម្គាល់ក្នុងស្នាដៃរបស់ខ្លួន ។

## លំហាត់

ចូរអ្នកប្រាប់ពីឈ្មោះអ្នកនិពន្ធ កាលកំណត់តែង និងសង្គមបរិយាកាសនៃរឿងណាមួយដែលប្អូនធ្លាប់បានសិក្សានៅថ្នាក់មុនៗនិងរឿងដែលអ្នកធ្លាប់បានអាន ៖

១. រឿងកុលាបប៉ៃលិន

២. រឿងមាលាដួងចិត្ត

៣. រឿងផ្កាស្រពោន

៤. រឿងទុំទាវ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# វិធីតែងនិពន្ធ

ការសិក្សាអំពីវិធីតែងនិពន្ធ គឺជាការសិក្សាពីរបៀបតាក់តែងរឿងដែលមានច្រើនប្រភេទដូចជា ការតែងរឿងបុរាណ រឿងទំនើប ហើយប្រភេទរឿងនីមួយៗមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាំងពីចំណុចផ្ដើមរឿង តួរឿង និងការបញ្ចប់រឿង ។

## ក. ការផ្ដើមរឿង

អ្នកនិពន្ធសរសេរផ្ដើមរឿងតាមវិធីផ្ដើមមួយដោយមានការបង្ហាញ ៖

- ធម្មជាតិនៅត្រង់កន្លែងណាមួយ
- ឈ្មោះតួអង្គ ឬទំនាស់
- សកម្មភាព -ល- ។ រួចភ្ជាប់ទៅនឹងដំណើររឿងតែម្ដង ។

***ឧទាហរណ៍ :*** ការផ្ដើមរឿងរបស់អ្នកនិពន្ធ នូហាច នៅក្នុងរឿង ផ្កាស្រពោន ៖

រទេះភ្លើងបោលលឿនដូចព្យុះ កាត់ព្រៃខ្លុង និងព្រិច រត់ឆ្លងអូរ ហើយជ្រែកពុះជើងភ្នំ ដោយបញ្ចេញសន្ធឹកខ្ទរទំពងធ្វើឱ្យរញ្ជួយផែនពសុធា ។ [...]

ប៊ុនធឿន គឺជានាមនៃកុមារដែលមានមុខក្រៀមក្រំ ... ។

## ខ. តួរឿង ឬដំណើររឿង

នៅក្នុងតួរឿង ឬដំណើររឿង អ្នកនិពន្ធបានប្រើវិធីច្រើនយ៉ាង ដើម្បីធ្វើឱ្យដំណើររឿងស្របគ្នាទៅនឹងបញ្ហាចោទ ស្រាយក្នុងរឿង ដោយធ្វើយ៉ាងណាឱ្យសាច់រឿងមានសកម្មភាពប្រទាក់ក្រឡាគ្នា ហើយមានភាពរស់រវើក ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ អ្នកទស្សនាជក់ចិត្ត ជិតអារម្មណ៍ ... ។ និយាយរួម គឺជាវិធីរបស់អ្នកនិពន្ធ ដែលធ្វើឱ្យស្នាដៃខ្លួនមានសោភ័ណទាំងអត្ថរូប អត្ថន័យ និងអត្ថរស ។

**ពណ៌នាវិធី :** គឺអ្នកនិពន្ធប្រើវិធីរៀបរាប់ធម្មជាតិ តួអង្គ សកម្មភាពប្រកបដោយសិល្បៈរូបារម្មណ៍ខ្ពស់ ធ្វើឱ្យអ្នកមើល អ្នកអាន អ្នកស្ដាប់ ហាក់ដូចជាឃើញរូបពិតក្នុងអារម្មណ៍របស់ខ្លួន ។

**សំវាទវិធី :** គឺអ្នកនិពន្ធប្រើវិធីរៀបរាប់ បង្កើតនូវស្ថានភាពផ្សេងៗនៅក្នុងសាច់រឿងដើម្បីឱ្យតួអង្គមានការសន្ទនា ឬនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក ... ។

**ឯកវាទវិធី :** ជាវិធីដែលអ្នកនិពន្ធធ្វើឱ្យតួអង្គនិយាយ ឬគិតតែម្នាក់ឯងទៅលើបញ្ហាអ្វីមួយក្នុងជីវិតក្នុងសាច់រឿងរបស់ខ្លួន ទោះជាការគិតនោះមានស្ថានភាពបែបណាក៏ដោយ ។

**ឧបមានវិធី :** ជាវិធីដែលអ្នកនិពន្ធ លើកយកនូវការប្រៀបប្រដូចអ្វីមួយទៅនឹងអ្វីមួយទៀត ដោយសិល្បៈវិធីនិងសិល្បៈរូបារម្មណ៍ ។

**បដិវិធី** : អ្នកនិពន្ធប្រើវិធីបង្ហាញនូវភាពខុសគ្នាផ្ទុយគ្នាពីស្ថានភាព សកម្មភាព តួអង្គ ឬព្រឹត្តិការណ៍ណាមួយ ដើម្បីរំលេចផ្ទៃរឿងតាមមនោគតិរបស់ខ្លួន ។

**សន្ទេហវិធី** : ជាវិធីដែលអ្នកនិពន្ធបង្កើតឡើងនៅក្នុងដំណើររឿងរបស់ខ្លួន ដើម្បីឱ្យអ្នកអាន អ្នកស្តាប់ឆ្ងល់ចង់ដឹងតទៅទៀត ។

**វឌ្ឍមានវិធី** : វិធីបង្ហាញរបស់អ្នកនិពន្ធ ដើម្បីធ្វើឱ្យសកម្មភាពក្នុងរឿងមានភាពប្រសើរឡើង កើនឡើង ។

**វចនវិធី** : អ្នកនិពន្ធចេះប្រើប្រាស់ពាក្យពេចន៍សាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ឬប្រើពាក្យពេចន៍ពិបាកយល់ ពិបាកអានដូចជា ពាក្យខ្មែរបុរាណ បាលីសំស្ក្រឹត ... ។

**រចនាវិធី** : ជាវិធីដែលអ្នកនិពន្ធប្រើដើម្បីសរសេរតាក់តែងអត្ថបទរឿងរបស់ខ្លួន ទោះជាពាក្យរាយ ពាក្យកាព្យឱ្យមានពាក្យពេចន៍ ឃ្លា ល្បះធម្មតាៗដែលប្រជាជនទូទៅនិយមប្រើ ធ្លាប់ស្តាប់ ធ្លាប់ប្រើ មិនពិបាកអាន ពិបាកស្តាប់ ឬពិបាកយល់ឡើយ ។

## គ. ការបញ្ចប់រឿង

ជាវិធីដែលអ្នកនិពន្ធសរសេរបញ្ចប់រឿងរបស់ខ្លួនដោយវិធីច្រើនយ៉ាង ។ ជួនកាលអ្នកនិពន្ធសរសេរបញ្ចប់រឿងដោយ :

- ឱ្យតួអង្គឯករបស់រឿងនៅរស់
- ជួនកាលឱ្យតួអង្គឯកស្លាប់
- ជួនកាលបញ្ចប់រឿងទាំងមូលដោយក្តីសង្ឃឹមគ្រប់គ្នា
- ជួនកាលបញ្ចប់រឿងទាំងមូលដោយបន្សល់ក្តីអស់សង្ឃឹម ឬបរាជ័យ ទៅតាមឧត្តមគតិរបស់អ្នកនិពន្ធ
- ជួនកាលបញ្ចប់រឿងដោយបង្ហាញជោគជ័យរបស់តួអង្គល្អនិងផ្តល់សេចក្តីសប្បាយរីករាយដល់អ្នកអាន អ្នកស្តាប់ ។ល ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## លំហាត់

ចូរប្អូនអានអត្ថបទដកស្រង់ខាងក្រោមក្នុងរឿងផ្កាស្រពោន រួចបង្ហាញពីវិធីតែងនិពន្ធតាមវគ្គនីមួយៗខាងក្រោមនេះឱ្យបានត្រឹមត្រូវ ។

### អត្ថបទដកស្រង់រឿង ផ្កាស្រពោន វគ្គទី ៩

[...] សៀមរាបជាកូនក្រុងមួយស្អាតញញឹម លំអដោយថ្នល់ដែលមានរុក្ខជាតិចោលម្លប់ទៅលើត្រឈឹងត្រឈៃនិងដោយកូនស្ទឹងតូចមួយ ដែលមានទឹកថ្លាឆ្វង់ហូរមកបង្វិលរហាត់ធ្វើឱ្យឮសំឡេងថ្ងូរយ៉ាងស្រងេះស្រងោច ។ អ្នកដំណើរណាក៏តែងប្រតិព័ទ្ធស្រឡាញ់ទីប្រជុំជននេះ ។

នៅសាយណ្ហកាល រថយន្តបើកចូលក្នុងក្រុងសៀមរាប ហើយទៅឈប់ចតនៅត្រង់ផ្សារវិល ។ អ្នកដំណើរទាំងពួងក៏ប្រញាប់ប្រញាល់ចុះពីឡាន ម្ចីម្ចារកអីវ៉ាន់រៀងខ្លួន ។ យាយនួនគាត់ឈរនៅចិញ្ចើមថ្នល់ ហើយរំពៃមើលឆ្វេងស្តាំ ។ ខណៈនោះមានបុរសម្នាក់ ជាកណ្តាលមនុស្សពាក់អាវទេសឯកស ស្លៀកខោឡាញ់ខ្មៅ ដើរចូលមកជិតគាត់ ហើយលើកដៃសំពះ :

- ខ្ញុំជម្រាបសួរថៃ ។

  យាយនួនគាត់ដាក់ភ្នែកមកចំ :

- ឱ ! បេងជុនទេនេះ ឯងខំសម្លឹងរកមើល ...
- ថៃ ! ឯណាអីវ៉ាន់ថៃខ្លះ ? ខ្ញុំនឹងអាលឱ្យគេជញ្ជូនដាក់រ៉ឺម៉កទៅ
- បេងជុនអើយ ខ្ញុំគ្មានអីទេព្រោះបន្ទាន់ណាស់ រកស្អីៗ គ្រាន់ជាបញ្ញើក៏មិនបានផង
- ចាំធ្វើធ្វើអីថៃនុ៎ះ តែអញ្ជើញមកលេងខ្ញុំ ក៏អរណាស់ទៅហើយ ។
- យីអាវី ឯងសំពះ សួរមា ។ កញ្ញានេះឮហើយក៏លើកដៃសំពះ ជម្រាបសួរទៅលោកបេងជុន ។

លុះអ្នកធាក់រ៉ឺម៉កបានជញ្ជូនវ៉ាលីសទាំងពីរដាក់ស្រេចបាច់ហើយ យាយនួន នាងវិធាវីព្រមទាំងម៉ែផៃនាំគ្នាឡើងជិះក្នុងយាន ។ ឯឈ្មោះបេងជុន ក៏ឡើងជិះបីស៊ីក្លេតអមរ៉ឺម៉ក ហើយនិយាយសួរសុខទុក្ខតាមធម្មតាទៅ ។

ឈ្មោះបេងជុននេះជាអ្នកមានធនធានមួយគ្រាន់បើ នៅក្នុងខេត្តសៀមរាប ។ គាត់ធ្លាប់នៅធ្វើជំនួញស្រូវឯបាត់ដំបង ហើយតែងមានពឹងពាក់គ្នាទៅមកនឹងខ្មោចឪពុកនាងវិធាវី ។ ឯមេត្រីភាព ក៏កើតឡើងរវាងគ្រួសារទាំងពីរនាំឱ្យរាប់អានគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ។

ហេតុដែលបណ្តាលឱ្យយាយនួនគាត់ដាច់ស្រេចនាំកូនគាត់មកកម្សាន្តអង្គរនេះ ពីព្រោះតែគិតឃើញដល់បេងជុនប៉ុណ្ណោះឯង ។ មុនពេលដែលគាត់ចេញដំណើរមួយថ្ងៃនោះ គាត់បានពឹងអ្នកជិតខាងម្នាក់ឱ្យវាយខ្សែលួសមកប្រាប់ឈ្មោះបេងជុន ដើម្បីកំណត់ថ្ងៃនិងពេលដែលគាត់ចេញពីបាត់ដំបងមកសៀមរាប ។

ផ្ទះបេងជុនសង់នៅត្រើយខាងឆ្វេង ដែលមានដើមចំប៉ាធំៗដុះបាំងពីមុខ ។ ក្នុងរបងដែលធ្វើអំពីឥដ្ឋនៅប្រែបថ្នល់នោះ មានចោះជាខ្លោងទ្វារធំមួយ វិចិត្រទៅដោយផ្កាកុលាបដែលរីកស្រស់បំព្រង ។ នៅប្រែបផ្ទះធំ រថយន្តជិះលេងមួយជ្រកក្នុងរោងដែលមានជញ្ជាំងថ្ម ដំបូលប្រក់ក្បឿង ។ នៅមាត់កំពង់ចំមុខលានផ្ទះ កង់រហាត់មួយវិលគ្មានស្រាកស្រាន្ត ហើយចាក់ទឹកពីបំពង់ទៅក្នុងទីមួយដែលសម្រាប់បង្ហូរទៅស្រោចរុក្ខជាតិក្នុងភូមិឋាន ។

នាងវិធាវី កាលបើដល់គេហដ្ឋាននេះហើយ ក៏ហាក់ដូចជាមានអាកាសត្រជាក់មករុំស្រោបកាយនាង ព្រោះផ្ទះនេះស្រឡះល្វឹងល្វើយ ហើយមានតុ ទូ ធ្វើសុទ្ធពីបេងចាស់មានរបៀបសមឥតមានទាស់ភ្នែក នៅលើក្តារកម្រាលធ្វើពីកកោះរលីងថ្លាដូចកញ្ចក់ ។

នាងសុចិត្រា ភរិយានៃបេងជុន ជាស្ត្រីមួយអាយុជាងសាមសិបឆ្នាំហើយ តែដោយនាងមិនដែលមានបុត្រនោះ រូបនាងក៏នៅស្រស់ចំប្រប់ដូចព្រហ្មចារីសុទ្ធវិស័យ ។ កាលបើឃើញអ្នកដំណើរទៅដល់ហើយ នាងក៏ស្ទុះមកទទួលដោយសាទរ ហើយនាំនាងវិធាវីនិងយាយនួនទៅបង្ហាញបន្ទប់ដែលបម្រុងទុកជូន ដើម្បីឱ្យយាយផែគាត់យកអីវ៉ាន់ទៅទុកដាក់ ។ រួចហើយ នាងសុចិត្រាក៏អញ្ជើញអ្នកដំណើរទាំងពីរទៅងូតទឹកក្នុងបន្ទប់ជម្រះកាយ ។

ទឹកត្រជាក់ដែលហូរស្រពរាងកាយនាងវិធាវី បានធ្វើឱ្យនាងមានកម្លាំងព្រមទាំងយកសេចក្តីរំហើយក្នុងចិត្តមករំលុបមន្ទិលសៅហ្មងបានជាច្រើនភាគផង ។ ដូច្នេះហើយ នាងក៏ទទួលដោយញញឹមញញែមសេចក្តីអញ្ជើញនៃស្ត្រីម្ចាស់ផ្ទះ ឱ្យទៅដើរលេងក្នុងសួនច្បារ ។ នាងសុចិត្រា កាលបើបានគយគន់រូបរាងនិងកិរិយាស្រគត់ស្រគំនៃនាងវិធាវីហើយ ក៏មានចិត្តចាប់ស្រឡាញ់ ហាក់ដូចជាប្អូនរួមផ្ទៃតែមួយ ។ នារីទាំងពីរនេះត្រាច់កម្សាន្តតាមប្រឡោះគុម្ពផ្កា ហើយសម្តីដែលនិយាយរកគ្នារទូៗ អណ្តែតរសាត់ទៅច្រឡូកច្រឡំនឹងសត្វភូមរីដែលហើរត្រឹបសុគន្ធមាលា ។ នាងចរចា ... ចរចាដើរតាមផ្លូវខ្សាច់ដែលមានស្មៅបៃតងនិងផ្កាគ្រប់ពណ៌អមសងខាង ។ នារីនាងលីលា ... លីលាទឹកមុខញញឹមប៉ប្រែកណ្តាលទេសភាពមួយល្អឥតខ្ចោះ ។ ជួនប្រទះនឹងដើមម៉ាវែងដែលជ្រកក្រោមម្លប់ចំប៉ាមួយធំ ស្ត្រីទាំងពីរក៏នាំគ្នាអង្គុយព្រលឹងអណ្តែតអណ្តូងទៅឆ្ងាយ ឯនេត្រាគយគន់មើលរហាត់ទឹកដែលវិលញើបៗ ហើយថ្ងូរពំនោលមិនចេះខ្ជិលឡើយ ។ វិញ្ញាណនាងវិធាវីក៏ភ្លឹកស្លុងទៅក្នុងសកលមួយថ្មី ឯសេចក្តីអួលក្តៅទាំងប៉ុន្មាន ក៏ផាត់ច្រានបានឆ្ងាយមួយគ្រាដែរ ។

ប៉ុន្តែ ដោយហេតុតែសេចក្តីសុខសម្រាន្តនៃមនុស្សលោកមិនដែលឋិតថេរនៅយូរបាន សំឡេងបេងជុនដែលនិយាយថា ចែ ខ្ញុំស្តាយណាស់ កុំតែឡានខ្ញុំវាខូច កុំអីបើកជូនចែមើលប្រាសាទលេងសប្បាយ ដូច្នេះក៏មកកាត់ចិញ្ច្រាំការភ្លាំងភ្លេចស្មារតីនៃនារីនោះអស់ទៅ ។ នាងវិធាវីដោះពីយល់សប្តិទាំងភ្នែកបើកនេះហើយ ក៏សម្លឹងមើលទៅឃើញយាយនួននិងបុរសម្ចាស់ផ្ទះដើរត្រង់មក ។

យាយនួនគាត់តបទៅបេងជុនវិញ ៖

មិនអីទេ ជួលតែរទេះសេះមួយបានហើយ

- មិនស្រួលសោះ ចៃ! ល្ងើយស្អែកនេះ ចែអញ្ជើញរទេះសេះមើលវង់តូចសិនចុះ ។ ចំណែកខ្ញុំ ខ្ញុំនឹងនៅខំធ្វើឡានឱ្យរួចទាន់ខានស្អែកនេះ ដើម្បីជូនចែមើលខាងវង់ធំ មើលបន្ទាយស្រី ហើយប្រសិនជាមានពេលយើងទៅដល់ភ្នំគូលែនម្តង ។ [...]

*(ដកស្រង់ពីរឿង ផ្កាស្រពោនរបស់លោកនូ ហាច ១៩៤៧ )*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh



# ជំនឿ



## ក សិក្សាពាក្យគន្លឹះ

- ភាជន៍ : ចាន
- សមាធិ : ការតាំងចិត្តឱ្យស្ងប់ស្ងៀម
- ជតា : កំណើត វេលាកើត
- ព្រះឱស្ឋ : មាត់
- ពិភាល់ : ឆ្វល់
- ប្រណាក : ប្រដាប់ធ្វើដោយដែកសម្រាប់ឆាក ឬចិតស្លា ...
- ទិសឦសាន : ទិសព្រះឥសូរ គឺទិសតូច ឬទិសជ្រុងត្រង់ចន្លោះទិសឧត្តរនិងទិសបូព៌ា ។
- តោក : វត្ថុម្យ៉ាងមានសណ្ឋានស្រដៀងនឹងកញ្ជើ ល្អី តែមានជើងទម្រ
- រោគព្យាធិ : ការមានជំងឺដោយសាររោគ ។

facebook.com/moeys.gov.kh krou.moeys

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ហើយកត់ចំណាំសេចក្ដីលម្អិតសំខាន់ៗមួយចំនួន ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងទៅនឹងឈ្មោះអ្នកនិពន្ធ កាលកំណត់តែងរបស់រឿង សង្គមបរិយាកាស វិធីតែងនិពន្ធ និងតម្លៃអប់រំនៅក្នុងរឿង ។

## គ. អត្ថបទ

[...]លុះគេបាននិមន្តលោកឱ្យឡើងរួចហើយ លោកក៏គង់កន្លែងមួយដែលគេរៀបបម្រុងជាមុន ។ ក្រោយដែលគេលើកទឹកតែ បារី ម្លូស្លាមកប្រគេនលោក លោកក៏មានថេរដីកា សួរដោយសម្ដីស្អកៗមួយៗ :

- ញោមនិមន្តអាត្មាមកនេះ តើមានការដូចម្ដេចខ្លះ ?

យាយនួនក៏ខិតចូលជិត ហើយនិយាយពិតលោកតាមដំណើរ ។ ភ្ញៀវម្នាក់ដែលជិតខាង ក៏លើកថាំងមួយដាក់ទឹកពេញមកប្រគេនលោក ។ ក្នុងធុងនេះមានផ្កាម្លិះក្រពុំអណ្ដែតសក្បុស ។ លោកយកធូបបីសរសៃមកផ្គុំគ្នានឹងដុំក្រមួនប៉ុនកូនដៃ ហើយយកទៅបិទភ្ជាប់នឹងមាត់ធុងទឹក ។ លោកអុជទៀនមួយឱ្យឆេះ ហើយយកទៅបង្កាត់ធូបបីសរសៃនោះឱ្យឆេះទៀត ទើបបិទទាននោះនៅក្បែរធូប ។ លោកលើកហត្ថប្រណម្យហើយសូត្រផ្លុំៗទឹកក្នុងថាំង ។ មួយស្របក់ក្រោយមក លោកបែរយកទៀនអុជមកសូត្រកូរទឹកទៀត បង្កើតឱ្យមានជាខ្សែទឹកនាំពពួកផ្កាម្លិះ ហែលរសាត់តាមគ្នាមានវិស័យដូចជាកូនក្អុកសម្បុរស ។

យូរៗម្ដង លោកបង្អោនប្រឆេះទៀនទៅក្នុងទឹកបណ្ដាលឱ្យផ្ទុះប្រែះៗ ! ហើយមានក្រមួនរលាយធ្លាក់ចុះទៅអណ្ដែតត្រា ។

នៅកំលុងកន្លះម៉ោងដែលព្រះសង្ឃនេះសូត្រមន្តកូរទឹក ពពួកភ្ញៀវនិងអ្នកម្ចាស់ផ្ទះអង្គុយបត់ជើងធ្វើមុខស្ងួត ភ្នែកចាំផ្ទៀងមើល ។ នៅពេលបង្ហើយលោកក៏ជ្រមុជទៀនទៅក្នុងទឹកពន្លត់តែម្ដង ។ អ្នកដែលនៅចាំជួយមើលការ លុះឃើញដូច្នោះហើយក៏នាំគ្នាគ្រាហ៍នាងវិធាវីអង្គុយនៅមាត់ជណ្ដើរ ។ ព្រះសង្ឃក៏លើកទឹកនោះទៅស្រោចលើខ្លួននាងដែលកំពុងគ្រុនយ៉ាងក្ដៅនិងនៅចំពេលព្រលប់ធំដែលធ្លាក់ខ្យល់ត្រជាក់ ។ នាងវិធាវីដែលគេបានដោះអាវចេញទុកឱ្យនៅខ្លួនទទេ ដើម្បីទទួលទឹកមន្ត កាលបើត្រូវខ្យល់បក់មកតិចៗហើយ ក៏កើតរងាញ័រញាក់ទទ្រើក តែនាងខំខាំធ្មេញសង្កត់ចិត្ត ។ ដល់លោកលើកទឹកចាក់ទៅលើថែមទៀត ខ្លួននាងក៏ញ័រចំប្រប់ដូចកូនសត្វ មានធ្មេញរណ្ដំគ្នាគួរឱ្យអាណិតពន់ពេក ។

យាយនួនឃើញដូច្នោះ ក៏នឹកស្រណោះស្ទើររលួយថ្លើមប្រមាត់ ។ គាត់ក៏ខំហាមាត់ទាំងអួលអាក់និយាយ :

- ខំអត់ទៅកូន ! លោកតាស្រោចឱ្យឯងជាហ្នឹង ។

មុនពេលដែលលោកនឹងនិមន្តទៅទីសមាធិវិញ លោកមានសង្ឃដីកាផ្តាំថាស្អែកលោកនឹងនិមន្តមកម្តងទៀត លុះគ្រប់បីដងទើបឈប់ ។

នៅយប់នោះ នាងវិធាវីក៏ចាប់គ្រុនយ៉ាងខ្លាំង ។ ក្នុងទ្រូងនាងក្តៅដូចរងើកភ្លើង ។ អ្នកផងតែងតែដឹងថាជំងឺទ្រូងនេះ តាមនិយមវេជ្ជសាស្ត្រនៃបច្ចុប្បន្នកាល គេតែងតែហ៊ុមដណ្តប់ឱ្យជិតមិនឱ្យត្រូវអាកាសត្រជាក់ ឬទឹកត្រជាក់សោះឡើយ ។ ឥឡូវនេះ លោកដែលជាបព្វជិតមានសីលមានធម៌ បានមកស្រោចទឹកបណ្តាលឱ្យរោគនោះរឹតតែធ្ងន់ជាងមុនទៅទៀត !

នាងវិធាវីតាំងតែពីនាងចាប់ឈឺមក នាងឥតមាននិយាយស្តីទេ ។ នាងនឹកឃើញថា ខ្លួននាងឈឺម្តងនេះ ប្រហែលជាមិនជាទេមើលទៅ ។ ល្ហើយរស់ជាមនុស្សធ្វើអ្វីផងបើមុខជាមិនបានជួបគូសង្សារមុខជាមិនសប្បាយ មុខតែរងទឹកភ្នែកដដែល ។ ឱ ! បងប៊ុន ធឿនអើយ ! បងកុំប្រកាន់ទោសដល់អូនឡើយ ដោយអូនមិនបានមករួមជីវិតដូចពាក្យសន្យា ។ ឱ ! គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃដ៏ប្រសើរថ្លៃថ្លា ខ្ញុំសូមប្រាថ្នាថាកើតជាតិកាលណា កុំឱ្យមានព្រួយនិងព្រាត់គូកម្សត់ដូច្នេះឡើយ ។

នៅយប់នោះ មានអ្នកជិតខាងជាច្រើននាក់ដែលធ្លាប់ស្រឡាញ់រាប់អាននាងវិធាវី បានមកនៅជួយកំដរកុះករ ។ តែឥតមានជនណាមួយធ្មេចភ្នែកបានឡើយ ព្រោះតែនាងវិធាវីចេះតែក្អាក់ខាកស្ពោះមកធ្លាក់ឈាមមិនស្រាកស្រាន្ត ។

លុះដល់ព្រហាម ទើបអ្នកជំងឺបានស្រយាលសម្ងំទទួលដំណេកបាន ។ យាយនួនគាត់ឆ្លៀតយកឱកាសនេះរត់ទៅនិមន្តលោកអានមើលជតាកូនគាត់ ។ ព្រះសង្ឃរូបនេះ កាលបើបានពិនិត្យក្រាំងគម្ពីរនិងវាយលេខគន់គូរសព្វគ្រប់ហើយ ក៏មានសង្ឃដីកា :

- ញោម កូនញោមមានគ្រោះធ្ងន់ ។ លេខចង្កុលត្រង់ព្រះរាមត្រូវសរឥន្ទជិត ។ បើដូច្នេះចាំអាត្មាទៅសូត្ររំដោះគ្រោះឱ្យ ។ ញោមកុំព្រួយ រោគនេះធ្ងន់មែនពិតតែគង់រកគ្រូមើលជា ។

នៅពេលថ្ងៃរសៀល គេព្ធសូរព្រះឱស្ឋលោកគ្រូអានសូត្រធម៌រអ៊ូ ហើយបាចទឹកមន្តដូចជាគ្រាប់ភ្លៀងធ្លាក់មកលើរាងកាយនាងវិធាវី ដែលរងាញ័រចំប្រប់នៅក្រោមជួយ ។

លុះសូត្រចប់ លោកគ្រូអានក៏បង្គាប់ឱ្យគេលើកអ្នកឈឺអង្គុយសណ្តូកជើងហើយលោកទំពាស្លាក្រៀមគ្រួបៗ មានសូត្រគាថាបណ្តើរផង ប៉ុន្មាននាទីក្រោយមក លោកក៏ព្រួសកញ្ចាក់ស្លាម្លូព្រមទាំងទឹកមាត់ក្រហមទៅលើនាងវិធាវីព្ធសូរផែតៗ ។

បន្ទាប់ពីពេលដែលលោកគ្រូអាននិមន្តផុតទៅ នាងធូក៏ឡើងមកដល់ភ្លាមនាំទាំងស្រីម្នាក់មកផង ។ ភ្ញៀវថ្មីនេះមានភ្នែកឡើងបាយម្ខាងស្រលៀងម្ខាង អុតស៊ីសុសមុខ សក់ក្រញាញ់កន្ទ្រីង ស្លៀកចងក្បិន និងពាក់នាក្រមាមួយជាប់ក្អែលឡើងពត្លក់ដែលអ្នកផងមិនអាចថាពណ៌អ្វីបានឡើយ ។

លុះបានសួរដំណឹងសព្វគ្រប់ពីអ្នកឈឺរួចហើយ នាងថូក៏និយាយទៀត ៖

- ថ្ងៃនេះខ្ញុំមិនបានឱ្យឡានទៅនិមន្តលោកភ្នំសំពៅទៀតទេ ព្រោះខ្ញុំនឹកពិភាល់ថាមានទាស់ខុសនឹងខ្មោចបិសាចណាក៏មិនដឹង បានជាស្រោចទឹកម្តងហើយនៅមិនឃើញគ្រាន់សោះ ។ ហេតុនេះ បានជាខ្ញុំនាំម៉ែអេងល្បីខាងចេះបូលឆុត ឱ្យគាត់មកបូលលមើល ក្រែងលោជាធ្វើទៅបានសមប្រកប ។

យាយនួនតប ៖

- គាប់ចិត្តថូពេក ជួយឈឺឆ្អាលយ៉ាងនេះ ខ្ញុំអរគុណណាស់ ។ បើយ៉ាងនេះហើយអញ្ជើញគាត់មើលទៅ ។

ម៉ែអេងឮដូច្នោះហើយក៏បង្គាប់ឱ្យយកប្រណាក១ អង្ករមួយគ្រាប់ និងអំបោះមួយសរសៃ ។ គាត់យកអំបោះចងទងប្រណាកមួយខាង លៃឱ្យល្មមតែវត្ថុនោះនៅស្មើត្រង់ បើប្រសិនណាគេចាប់អំបោះយួរឡើង ។ លុះលៃបានស្រួលហើយ ទើបម៉ែអេងយកគ្រាប់អង្ករមកដាក់បន្ទំលើក្បាលប្រណាកដែលកាន់បន្តោងលើខ្លួនអ្នកឈឺ ។ ក្នុងគ្រានោះមានអុជទៀនធូបបិទនឹងមាត់ពានមួយ ។ ម៉ែអេងក៏អង្គុយនឹងថ្កល់ ភ្នែកស្រលៀងខំស្រងៀវមើលប្រណាក ។ ទើបគាត់សួរ ៖ " អ្នកតាដំដែកហ៎ ? អ្នកតាក្បាលក្រហម ?" ប្រណាកនៅស្ងៀមឥតកម្រើក ម៉ែអេងក៏ចេះតែរាប់ឈ្មោះអ្នកតា អ្នកដូនសួរយ៉ាងនេះតទៅទៀតទាល់តែដល់ឈ្មោះនាងកន្ទោងខៀវ ប្រណាកនោះក៏តាំងកន្ត្រាំងមុជងើបៗទម្លាក់អង្ករទៅលើទ្រូងនាងវិធាវី ។ តាមយោបល់អ្នកដែលមិនជឿខ្មោចបិសាចនោះគេថា គឺម៉ែអេងនេះបន្លិកន្ត្រាក់សរសៃអំបោះ បានជាប្រណាកចេះកម្រើកយ៉ាងនេះ ។ តែតាមយោបល់អ្នកដែលជឿវិញ គេហ៊ានប្រាកដថា គឺជាអ្នកដូនកន្ទោងខៀវនេះឯង ដែលមកបៀតបៀនបុត្រីយាយនួន ។

បានស្តាប់ឈ្មោះបិសាចដែលធ្វើកលដូច្នោះហើយ ម៉ែអេងក៏បង្គាប់ឱ្យធ្វើពៃច្រមុះជ្រូកសែនហើយយកទៅចោលនៅទិសឦសាន ។ នៅពេលល្ងាចនោះ គេឃើញមនុស្សប្រមឹកប្អូនប្រាំនាក់ កាន់ស្គរជាសដោយស្បែកពស់ថ្លាន់និងក្រពើចូលមកលេងភ្លេងញ៉ែៗ ហើយច្រៀងបន្ទរផង ឮរំពងដូចហ៊ឹងយំ នៅពេលភ្លៀងដំបូង ។ ឯម៉ែអេងវិញគាត់ពាក់អាវបំពង់ព្រៃក្រហម អង្គុយសម្លឹងតោក ដងខ្លួនគាត់ញាក់ពព្រើត ។ មួយសន្ទុះក្រោយមក គាត់ចាក់ស្រាសផឹកមួយពែង ហើយធ្វើសំឡេងស្អកៗថា ចង់ស៊ីកន្ទន់បាក់ក ។ អ្នកដែលនៅជិតខាងទីនោះ ក៏ស្ទុះយកចេកមួយស្និតមកឱ្យ ។ តួមេមត់ពមចេកអស់ពីរបីហើយ ក៏ចាប់យកតោកគ្រវីគ្រវាត់ ហើយក្រោករាំចាក់ក្បាច់ ធ្វើដៃជើងជង្គ្រឹងជង្គ្រាងមួយសន្ទុះក៏អង្គុយស្ងៀម ឯភ្លេងនិងចម្រៀងក៏ឈប់នៅស្ងៀមដែរ ។

ចំណែកម៉ែផៃវិញ កាលបើគាត់ឃើញនាងតូចរបស់គាត់ឈឺចាប់ខ្លាំងយ៉ាងនេះហើយ គាត់ក៏ភ័យស្លុតចិត្តស្ទើររកព្រលឹងគ្មាន ។ នៅល្ងាចដែលគេលេងមេមត់ដើម្បីសុំឱ្យបិសាចអភ័យទោសនោះ

គាត់បានរ៉ាប់រងធានាខ្លួននឹងមកសុំឱ្យបិសាចស្រណោះដល់នាងតូច ។ លុះដល់ឃើញតួមេមត់គេឈប់ស្ងៀមដូច្នោះហើយ គាត់ក៏លើកដៃសំពះហើយថា :

- ឱលោកម្ចាស់អើយ ខ្ញុំសូមទោសចុះ គ្នានៅក្មេងណាស់ ! កុំចាប់ទោសពៃរ៍ធ្វើអ្វី ឱ្យគ្នាបានជាស្រាកស្រាន្តទៅ ។

មេមត់ឆ្លើយតប :

ក្មេងនេះព្រហើនណាស់ ធ្វើឱ្យយើងខឹងណាស់ ! យើងខឹងណាស់ ! តែឥឡូវនេះ គេបានឱ្យយើងសប្បាយរួចហើយ មិនអីទេ យើងព្រមឱ្យជាបាន ... ។

ឯនាងវិធាវីដែលទុក្ខអួលក្ដៅនោះ កាលបើឮភ្លេងអារក្សយ៉ាងនេះនាងរឹតតែក្តាញ់ក្នុងចិត្ត តែមិនចេញស្តី ព្រោះនាងដឹងខ្លួនថា រោគព្យាធិនេះកើតឡើងដោយទុក្ខព្រួយរបស់នាងប៉ុណ្ណោះ ។ ឱបើប្រសិនណាជាយាយនួនគាត់ភ្ញាក់ដឹងខ្លួន ហើយផ្ដាច់នាងពីឈ្មោះ ណៃ ស៊ិតសម្ពប់ចេញ ហើយលើកនាងដាក់ទុកឱ្យទៅ ប៊ុន ធឿន គូព្រេងវិញ ឱម្ល៉េះហើយសមនាងមានកម្លាំងទទួលឱសថ ទទួលម្ហូបអាហារដោយរីករាយ ហើយនឹងបានស្បើយជំងឺដោយរហ័សពុំខាន ។ តែនាងនៅតែមិនហ៊ានចេញស្តីសោះដោយខ្លាចទាស់ចិត្តម្ដាយ ។ ម្ល៉េះហើយ ខ្លួននាងចេះតែស្រពោនរញមទៅៗរាល់ថ្ងៃ ។

អ្នកដែលថែរក្សាជំងឺ រឹតតែខំបំពោកថ្នាំ មិនថាថ្នាំអ្វីជាថ្នាំអ្វីទេ ចិនក៏មាន យួនក៏មាន ខ្មែរក៏មានបារាំងក៏មាន ... អស់ពីភ្លុកដំរី ប្រមាត់ខ្លាឃ្មុំ អស់ពីឫសឈើ ដល់ថ្នាំធាប ថ្នាំគុលិកា ថ្នាំចាក់ ថ្នាំដោតសព្វគ្រប់អស់ហើយ ។

ពាក្យសន្យាលោកគ្រូអាននិងមេមត់ ព្រមទាំងឫទ្ធានុភាពនៃមន្តអាគមលោកភ្នំសំពៅ ក៏មិនឃើញជាបានផលប្រយោជន៍ឯណា ។ នាងវិធាវីក៏នៅតែស្ទូកស្ទឹង តែនាងនៅវិញ្ញាណចាំជានិច្ច ។ ល្ហើយធ្វើម្ដេចកម្មក្រាស់របស់ខ្លួន ... ។

*(ដកស្រង់ពីរឿង ផ្កាស្រពោនរបស់លោកនូហាច បោះពុម្ពឆ្នាំ ១៩៦០ ទំព័រទី ៧០-៧៤)*

## សំណួរ

១. ចូរប្រាប់ឈ្មោះអ្នកនិពន្ធនិងកាលកំណត់តែងរបស់រឿង ផ្កាស្រពោននេះ ។

២. ចូរបង្ហាញពីស្ថានភាពសង្គមខ្មែរ តាមរយៈអត្ថបទដកស្រង់នេះថា តើមានលក្ខណៈដូចម្ដេចខ្លះ?

៣. ចូររកកាលអាកាសនៃអត្ថបទដកស្រង់នេះ ។

៤. តើវគ្គដកស្រង់នេះ មានចំណុចណាខ្លះដែលបញ្ជាក់ពីបញ្ហាជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ខ្មែរដែលជាអត្តសញ្ញាណជាតិខ្មែរ ?

៥. តើវគ្គដកស្រង់នេះមានតម្លៃអប់រំយ៉ាងដូចម្ដេច ?

៦. ចូរអ្នកអានរឿង ផ្កាស្រពោន រួចប្រាប់ពីវិធីផ្ដើមនិងបញ្ចប់រឿងឱ្យបានត្រឹមត្រូវ ។

# អំពីសព្វនាម

នៅមេរៀនមុនអ្នកបានសិក្សារួចមកហើយអំពីនាមនិងប្រភេទរបស់នាម ។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាប្រភេទរបស់សព្វនាម ។

## ក. ចូរអ្នកសង្កេតល្បះខាងក្រោម

- ពូខ្ញុំភ្ជួរស្រែ ។ គាត់ភ្ជួររប៉ះក្រឡចាស់មួយ ។
- នៅទីនេះ ខ្ញុំសប្បាយចិត្តណាស់ ឯគេទាំងអស់គ្នាក៏សប្បាយចិត្តដូចខ្ញុំដែរ ។
- តើអ្នកណា ទើបនឹងមកអំបាញ់មិញ?

តាមល្បះខាងលើនេះ យើងឃើញថាពាក្យ “ គាត់ ខ្ញុំ គេ អ្នកណា ” គឺជាសព្វនាមដែលប្រើជំនួសកន្សោម “ ពូខ្ញុំ អ្នកណា (ម្នាក់ដែលជាភ្ញៀវរបស់គេ) ”។

## ខ. ចូរពិនិត្យល្បះខាងក្រោម

- សំខំរៀនណាស់ ។ **វា**ជាក្មេងពូកែភាសាខ្មែរជាងគេនៅក្នុងថ្នាក់ ។ “វា” ជំនួស “សំ ” ជាសព្វនាមបុរិសៈ ។
- តើ**ឯង**ចូលចិត្តរៀនមុខវិជ្ជាអ្វី ? “ឯង” ជំនួសមនុស្សកំពុងនិយាយគ្នា ជាសព្វនាមបុរិសៈ ។
- **នេះ**ជាសៀវភៅរបស់ខ្ញុំ ។ ឯ**នោះ**ជាសៀវភៅរបស់ឯង ។ “នេះ នោះ” ជាសព្វនាមចង្អុល ។
- តើប្រាសាទបុរាណនេះឈ្មោះអ្វី ? “អ្វី” ជាសព្វនាមសំណួរ ។
- សុខជាកល្យាណមិត្ត**ដែលខ្ញុំស្រឡាញ់**ជាងគេ ។ គាត់ស្លូតណាស់ ។ “ដែល” ជំនួស “គាត់” ជាសព្វនាមឈ្នាប់ ។

តាមឧទាហរណ៍ក្នុងល្បះខាងលើ យើងសង្កេតឃើញពាក្យ “វា ឯង នេះ នោះ អ្វី ដែល ...” ក៏ជាសព្វនាម ។ វាមាននាទីប្រើជំនួសកន្សោមនាមជាប្រធាន កម្មបទ កម្មទេសកាល ...នៅក្នុងល្បះ ។

ដូចនេះ សព្វនាមមានច្រើនប្រភេទ ហើយមានមុខងារខុសៗគ្នាដូចជា :

- សព្វនាមបុរិសៈ : ខ្ញុំ ឯង វា គាត់ គេ
- សព្វនាមចង្អុល : នេះ នោះ អ្នកនេះ អ្នកនោះ ...
- សព្វនាមសំណួរ : អ្នកណា នរណា អ្វី ណា ណាខ្លះ ...
- សព្វនាមឈ្នាប់ : ដែល
- សព្វនាមមិនច្បាស់ : នរណាមួយ ណាមួយ អ្នកណាមួយ អ្វីមួយ ... ។

youtube.com/moeys
facebook.com/moeys.gov.kh

*សព្វនាម គឺជានាមប្រើជំនួសកន្សោមនាម ដែលគេនិយាយរួចហើយ ដែលគេពុំទាន់និយាយ ឬសម្រាប់ចង្អុលបុគ្គលណាម្នាក់ដែលគេប្រាស្រ័យទាក់ទងគ្នា ឬរបស់ណាមួយ ... ដែលគេចង់បង្ហាញ ... នៅក្នុងល្បះ ។*

សព្វនាម មានច្រើនប្រភេទ គឺសព្វនាមបុរិសៈ សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមឈ្នាប់ និងសព្វនាមមិនច្បាស់ ។

## លំហាត់

១. ចូររកពាក្យបង្ហាញសព្វនាមក្នុងល្បះខាងក្រោម ៖

ក. តាសុខាលេងភ្លេងពិណពាទ្យ ។ គាត់លេងបានល្អហើយពីរោះថែមទៀត ។

ខ. បុប្ផាជាអ្នករបាំវ័យក្មេង ។ វាពូកែរាំជាងគេ ។

គ. អ្នកណាមិនបានទៅលេងអង្គរវត្ត អ្នកនោះនឹងស្ដាយក្រោយ ។

ឃ. មីងចាន់កំពុងត្បាញក្រមា ។ គាត់ត្បាញបានលឿន ហើយល្អទៀតផង ។

២. ចូរកំណត់ពីប្រភេទនៃសព្វនាមនីមួយៗក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. សំជាសិស្សដែលគេស្រឡាញ់ចូលចិត្តជាងគេ ។

ខ. តើមួយណាដែលអ្នកត្រូវការ ?

គ. តើមួយណាដែលលោកត្រូវការ ? មួយនោះហើយដែលខ្ញុំត្រូវការ ។

ឃ. ពូមឿនជាជាងចម្លាក់ដ៏ល្បីម្នាក់ ។ គាត់មានទេពកោសល្យតាំងពីកំណើត ។

៣. ចូរអ្នកតែងល្បះទាក់ទងប្រភេទសព្វនាមទាំង ៥ប្រភេទឱ្យបានមួយប្រភេទចំនួនមួយល្បះ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh



# អក្សរខ្មែរ



## ក. សិក្សាពាក្យគន្លឹះ

- គ្រហស្ថ : អ្នកមានផ្ទះ អ្នកគ្រប់គ្រងផ្ទះ អ្នកមិនបួស អ្នកមានគ្រួសារ
- វិបត្តិ : ទំនាស់ ជម្លោះ
- បន្ទារ : ប៉ែកទទឹងក្តារ ឬបន្ទះឫស្សី
- ប្រារព្ធ : ចាប់ផ្តើម
- រូបសព្ទ : ស័ព្ទដែលមានរូប (រូបនិងសូរ)។
- សំនួន : ពាក្យដែលជាវោហាសម្តី
- សម្ផស្ស : សម្រស់។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទកំណាព្យខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ទាំងផ្នែកខ្លឹមសារនិងអត្ថន័យ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងក្នុងអត្ថបទកំណាព្យឱ្យបានត្រឹមត្រូវ ដូចជាសេចក្តីលម្អិត គំនិតសំខាន់បង្ហាញត្រង់ អ្នកនិពន្ធនិងគំនិតអប់រំដែលមានក្នុងអត្ថបទ។

## គ. អត្ថបទ : បទពាក្យ៧

[...] ចំណេះកើតមានព្រោះការរៀន កម្ចិលអៀនប្រៀនកុំសំដែង
ធ្វើឱ្យគេស្ងើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេ ។
ត្រូវរិះគន់ខ្លួនឯងជាមុន កុំឱ្យស័យស៊ុនខុសទទេ
បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតថោកអ្វីទេថ្លៃទេតើ ។
បុរាណថាថោកអីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើរើ
រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះប្រសើរណាស់ ។
ចាស់ថាបើល្ងង់កុំធ្វើចេះ បើមានចំណេះឱ្យជាក់ច្បាស់
បើស្ទើងហើយចង់ឱ្យបានក្រាស់ ត្រូវថែមកម្រាស់ផ្សំសាច់គ្នា ។
អបស្មបប៉ះប៉ុនយកកម្រាស់ កុំថាំងកុំប្រាស់ហួសមាត្រា
ប៉ះផ្សំផ្គុំផ្ចិតទើបកើតជា ទោល ឬបន្ទារម្ទួនជាងមុន ។
បើចេះអក្សរនិងភាសា នៃជាតិណាៗកុំជ្រុលស៊ុន
ងាប់ស័ព្ទប្រែស្រាយក្លាយជាប់កុន សុនត្រុនប្រែស្រាយឃ្លាតក្តីពិត ។
កាលដែលប្រារព្ធនឹងប្រែស្រាយ ត្រូវគិតនាយអាយដោយពិនិត្យ
ឱ្យឃើញសេចក្តីជាខ្មែរពិត សឹមផ្ចិតប្រែយកតាមពាក្យគេ ។
ត្រូវប្រែឱ្យមកជាសេចក្តី ដែលខ្មែរប្រុសស្រីអាចរិះរេ
ស្តាប់យល់មិនឆ្ងល់ទើបហៅប្រែ ត្រឹមត្រូវតាមតែសេចក្តីពិត ។
អ្នករៀនភាសាជនបរទេស ទ្វេធ្វេសដោយការឥតបើគិត
កាលខ្លួនកំពុងរៀនប្រឹងប្រិត ប្រែផ្ចិតឱ្យចំតាមរូបសព្ទ ។
ភ្លេចនឹកគិតមកភាសាខ្លួន ឱ្យយល់សំនួនដែលងាយស្តាប់
សម្លឹងសង្កេតតែរូបសព្ទ ក៏ស្រាប់តែប្រែខុសទាំងស្រុង ។
អ្នករៀនសំស្ក្រឹតឬបាលី ប្រែខុសសេចក្តីព្រោះភ័ន្តផុង
យល់ខុសទទេទាំងដើមចុង ចូលក្នុងរឹងស៊ិងខ្មាសអ្នកផង ។
តិដ្ឋបាលីប្រែថាឈរ អ្នករៀនឈ្លក់វរភ័ន្តម្តងៗ
ត្រង់មានសេចក្តីថាស្ងួនគ្រង ប្រែឆ្គងថាឈរហៅងាប់សព្ទ ។
បារាំងពរ៍កគេសួរល៉ាតែត ខ្មែរឆ្កែតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនចេះឱ្យគ្នាស្តាប់ បង្គាប់ថាឱ្យកាន់លើក្បាល ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

មិនប្រាប់ឱ្យគ្នាដឹងថាទូល　　　នេះហៅប្រមូលពុំត្រកាល
ពាក្យខ្មែរថាទូលក៏លើក្បាល　　　ត្រអាលប្រែខុសពីពាក្យខ្លួន ។
តែងកាព្យឱ្យត្រូវនឹងសម្ពស្ស　　　តាមពាក្យចាស់ៗដែលមានចួន
ក៏ចេះតែតែងតាមចិត្តខ្លួន　　　ឱ្យកាព្យមានចួនខុសមាត្រា ។

ពាក្យអើយនិងអ៊ើយសូរផ្សេងគ្នា　　　ដូចជាប្អូនអើយ[២] ម្ដេចឡើយថា
ស្ដាប់បងមិនព្ធឬស្ងួនភ្ងា　　　ធ្វើជាមិនព្ធព្រោះរឹងខ្លួន ?
ព្រះបាទសម្ដេចព្រះហរិរ័ក្ស　　　ទ្រង់បានបញ្ជាក់ដោយផ្ទួនៗ
ក្នុងកាព្យព្រះអង្គដែលមានចួន　　　សំនួនសម្ពស្សឥតមានឆ្គង ។
កវីគួរតែយកតម្រាប់　　　ពុំគួរប្រញាប់កាត់រំលង
រំលុបបែបនោះមិនត្រាប់ត្រង　　　ខុសពីបំណងអ្នកប្រាជ្ញចាស់ ។
មានអ្នកតែងកាព្យខ្លះហ៊ានថា　　　ម្ដេចមិនវាចាឱ្យជាក់ច្បាស់
ប្រើជាកិរិយាសព្ទខុសណាស់　　　គួរផ្លាស់សម្ដីនេះចោលចេញ ។ល ។

*(ដកស្រង់ពីសៀវភៅ ស្នាព្រះហស្ដក្រោយបង្អស់នៃសម្ដេច ជួន ណាត បោះពុម្ពឆ្នាំ ១៩៧០ ទំព័រទី ៨៣-៨៥)*

## សំណួរ

១. តើអត្ថបទកាព្យខាងលើនេះ និពន្ធដោយនរណា ?
២. តើអត្ថបទកាព្យនេះ និយាយពីអ្វី ? គាត់តែងជាបទអ្វី ?
៣. ចូរបង្ហាញចំណាប់ចួនក្នុងវគ្គទី ១ និងទី ២ ដោយគំនូសតាងបញ្ជាក់ ។
៤. ចូររកគំនិតសំខាន់នៃអត្ថបទកាព្យខាងលើនិងគំនិតអប់រំរបស់អ្នកនិពន្ធ ។

---

*(១) អានថា អ្ហើយ កុំថាអើយ ឬអឺយឡើយ ។*
*(២) អានថា ប្អូនអើយ ឬប្អូនណើយ កុំថា ប្អូនអើយ*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh



# រឿងទំនៀមចោះត្រចៀកកូនស្រី



ប្អូនធ្លាប់បានសិក្សារួចមកហើយអំពីសេចក្ដីលម្អិត ចំណោទបញ្ហា និងកាលអាកាសជាដើម ។ ឥឡូវនេះ ចូរប្អូនស្ដាប់រឿងទាក់ទងទំនៀមចោះត្រចៀកកូនស្រី ។ សូមប្អូនត្រៀមស្ដាប់ដោយយកចិត្តទុកដាក់ ហើយឆ្លើយនឹងសំណួរទាក់ទងនឹងបំណិនខាងលើឱ្យបានត្រឹមត្រូវ ។

## សំណួរ

១. តើរឿងនេះដកស្រង់ចេញពីណា ? និយាយពីអ្វី ?

២. ចូរបង្ហាញពីចំណោទបញ្ហានិងកាលអាកាសរបស់រឿងនេះ ?

៣. តើរឿងនេះកើតឡើងក្នុងសម័យកាលណា ?

៤. ហេតុអ្វីបានជាស្រីៗនាំគ្នាចោះត្រចៀក តាមនាងប្រពន្ធចុង ? តើអ្នកយល់ដូចម្ដេច ?

៥. តើចំណុចត្រង់ណាខ្លះបញ្ជាក់អត្តសញ្ញាណជាតិខ្មែរ ?

# ការនិយាយបញ្ចេញមតិផ្ទាល់ខ្លួន

ដូចម្តេចហៅថា ការបញ្ចេញមតិ ?

ការបញ្ចេញមតិ គឺជាការនិយាយ សំដែង ឬបង្ហាញឱ្យឃើញនូវគំនិត យោបល់ ឬទស្សនៈរបស់មនុស្សម្នាក់ៗចំពោះទង្វើ សកម្មភាព រឿងរ៉ាវ មតិ យោបល់ ... របស់អ្នកដទៃ តាមរយៈពាក្យសម្តី ឬសំណេរ ។ ការបញ្ចេញមតិអាចជាការគាំទ្រ ជំទាស់ ប្រឆាំង សំយោគ ឬការបង្ហាញនូវរបកគំហើញនៃគំនិតថ្មីៗ ដោយមានការវិភាគ ពិចារណា មានអំណះអំណាង ហេតុផលច្បាស់លាស់និងសមស្រប ។

ខាងក្រោមនេះ ជាការបញ្ចេញមតិរបស់ដារិន ចំពោះការចោះត្រចៀកកូនស្រី ដែលជាប្រពៃណី ទំនៀមទម្លាប់ខ្មែរបន្ទាប់ពីគេបានស្តាប់រឿងទាក់ទងនឹងទំនៀមនេះ ។

**ដារិន :** តាមដំណើររឿង យើងឃើញថា ការចោះត្រចៀកកូនស្រីនេះ ជាទំនៀមទម្លាប់របស់ខ្មែរយើងដែលមានតាំងពីសម័យកំណកំណើតរឿងព្រេងនេះមកម្ល៉េះ ។

តាមប្រពៃណីនេះ ជាតំណរៀងមក កាលណាប្រជាជនខ្មែរយើងកើតបានកូនស្រី ក៏តាំងនាំគ្នាចោះត្រចៀកតាំងពីតូចៗមក ដើម្បីពាក់ក្រវិលលម្អតៗគ្នារហូតក្លាយជាប្រពៃណីមួយក្នុងការរស់នៅរហូតដល់សព្វថ្ងៃ ។ គេធ្វើបែបនេះ ព្រោះគេយល់ថា ជាទម្លាប់ល្អក្នុងការតុបតែងរូបរាងកូនស្រីឱ្យកាន់តែមានសម្រស់និងបញ្ជាក់នូវវប្បធម៌រស់នៅដ៏សម្បូររុងរឿងថែមទៀតផង ព្រោះឪពុកម្តាយដែលមានមាស ពេជ្រ ... ច្រើនធ្វើក្រវិលឬទុំហូល្អៗតាមការរចនាផ្សេងៗដើម្បីឱ្យកូនពាក់ ... ។

## លំហាត់

ចូរអ្នកបញ្ចេញមតិផ្ទាល់ខ្លួនចំពោះ ៖

១. ការចោះត្រចៀកពាក់ក្រវិលរបស់បុរសខ្មែរនាសម័យបច្ចុប្បន្ន ។

២. ការខិតខំរកគ្រូនិងថ្នាំព្យាបាលជំងឺនាងវិធាវីពីសំណាក់ក្រុមគ្រួសាររបស់នាង ។

facebook.com/moeys.gov.kh youtube.com/moeys

# សំណេរវិភាគអត្ថបទ

បន្ទាប់ពីអានអត្ថបទដកស្រង់ក្នុងអំណានទី១រួច ចូរអ្នកអានអត្ថបទអក្សរសិល្ប៍រឿងផ្កាស្រពោនទាំងមូលថែមទៀត ដើម្បីបង្ហាញពីការផ្ដើមរឿង តួរឿង និងការបញ្ចប់រឿង ។

ពេលនេះ ចូរអ្នកសរសេរវិភាគរឿងផ្កាស្រពោននេះតាមលំនាំខាងក្រោម :

## ក. ការបង្ហាញអត្ថបទ

- អ្នកនិពន្ធ
- កាលកំណត់តែង
- សង្គមបរិយាកាសនៃរឿង
- ការសង្ខេបរឿង
- តួអង្គ
- កាលអាកាស

## ខ. អត្ថន័យ

- ប្រធានរឿង
- មូលបញ្ហារឿង
- តម្លៃអប់រំរបស់រឿង ឬគំនិតដឹកនាំរឿង

## គ. អត្ថរូប

- ការផ្ដើមរឿង : អ្នកនិពន្ធផ្ដើមដោយបង្ហាញពីអ្វី ?
- តួរឿង : តើអ្នកនិពន្ធបានប្រើវិធីអ្វីខ្លះ ដើម្បីបកស្រាយខ្លឹមសាររឿងទាំងមូល ? (ពណ៌នាវិធី សំវាទវិធី ឯកវាទវិធី ឧបមានវិធី បដិវិធី សន្ទេហវិធី វឌ្ឍមានវិធី វចនវិធី រចនាវិធី ។ល ។)
- បញ្ចប់រឿង : តើអ្នកនិពន្ធបញ្ចប់រឿងនេះយ៉ាងដូចម្ដេច ? (បញ្ចប់ដោយសេចក្ដីសង្ឃឹម ទុក្ខព្រួយ សេចក្ដីសោកសង្រេង ជោគជ័យ បរាជ័យ វិជ្ជមាន ឬអវិជ្ជមាន មានការជួបជុំ ឬការព្រាត់ប្រាស ។ល ។)
- សរុបមតិ : សរុបខ្លឹមសារទាំងអស់ដែលបានបង្ហាញរួច ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

### ឃ. អត្ថរស

តម្លៃដែលលេចចេញពីខ្លឹមសាររបស់រឿងដូចជា តថរស កុសលរស សង្គមរស វីររស អច្ឆរិយរស ហាសរស ។ ល ។

ពេលសរសេរ អ្នកត្រូវធ្វើសេចក្តីព្រាងតាមចំណុចណែនាំខាងលើជាមុន។ ពេលធ្វើសេចក្តីព្រាងរួច ចូរអ្នកពិនិត្យសំណេររបស់ខ្លួន :

- តើសំណេររបស់អ្នកមានប្រើសំនួន ពាក្យពេចន៍ ឃ្លា ល្បះ បានត្រឹមត្រូវហើយឬនៅ ?
- តើសំណេររបស់អ្នក មានកំហុសអក្ខរាវិរុទ្ធដែរឬទេ ?
- តើនៅតួសេចក្តីមានសេចក្តីលម្អិតទាក់ទងនឹងការបង្ហាញពីការផ្តើមរឿង តួរឿង និងការបញ្ចប់រឿងស្របតាមដំណើរដែលបានអានចប់ត្រឹមត្រូវដែរឬទេ ?
- តើសេចក្តីបញ្ចប់នៃសំណេរមានការបញ្ចេញមតិផ្ទាល់ខ្លួននិងបង្ហាញពីតម្លៃអប់រំបាន សមរម្យ និងសមហេតុផលដែរឬទេ ?

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី ៣

# ការគោរពបូជា



សេចក្ដីសុខជាបំណងប្រាថ្នារបស់មនុស្សទូទៅ ។ អ្នកដែលមានសេចក្ដីសុខពិតប្រាកដលុះត្រាតែអ្នកនោះទទួលបានសេចក្ដីសុខទាំងផ្លូវកាយនិងផ្លូវចិត្ត ។ ការគោរពបូជាក៏ជាមធ្យោបាយមួយញ៉ាំងឱ្យវិញ្ញាណស្មារតីរបស់មនុស្សមានភាពស្ងប់ស្ងាត់និងជំរុញឱ្យមានសេចក្ដីសុខផ្លូវចិត្ត ។ ការគោរព គឺជាការប្រតិបត្តិ ការប្រព្រឹត្តតាមឱវាទរបស់បុគ្គលដែលគួរគោរព ដោយមានការលះបង់ថ្វាយឬជូនវត្ថុផ្សេងៗចំពោះបូជនីយបុគ្គល ។

ក្នុងមេរៀននេះ អ្នកនឹងបានឃើញពីទស្សនៈមួយចំនួនស្ដីពីការស្វែងរកសេចក្ដីសុខទាំងបច្ចុប្បន្នជាតិនិងអនាគតជាតិ ។ ទន្ទឹមនេះ អ្នកនឹងបានសិក្សាអំពីលក្ខណៈសម្គាល់របស់រឿងបែបព្រាហ្មណ៍និយម ខ្លឹមសារអត្ថបទ គុណនាម ការបញ្ចេញមតិគាំទ្រ និងសំណេរតែងសេចក្ដីពន្យល់ ។

facebook.com/moeys.gov.kh

## លក្ខណៈសម្គាល់របស់រឿងបែបព្រាហ្មណ៍និយម

អក្សរសិល្ប៍ព្រាហ្មណ៍និយមសម្គាល់អត្ថបទអក្សរសិល្ប៍ណា ដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍។ អក្សរសិល្ប៍នេះតែងលើកយកអច្ឆរិយៈ បុគ្គល ទេវតា អាទិទេព ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ យក្ស ដោយរួមផ្សំនឹងមន្តអាគមគាថាអួមអាម បែងភាគ កាឡាខ្លួន ចេះជប ចេះហោះហើរ ដើរលើអាកាសជាដើម ។

លក្ខណៈសម្គាល់អក្សរសិល្ប៍បែបព្រាហ្មណ៍និយមមាន ៖

### ក. ផ្តើមរឿង

ការផ្តើមរឿងនៃស្នាដៃអក្សរសិល្ប៍ប្រភេទនេះ គឺចាប់ផ្តើមឡើងដោយការបង្ហាញពីឈ្មោះរបស់អាទិទេពធំៗ ទាំងបីដូចជាព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ ពិធីបូជាយញ្ញ ឬពិធីផ្សេងៗទៀត ។

ឧទាហរណ៍ ៖ ផ្តើមរឿងរាមកេរ្តិ៍ ៖ ដងនោះមានអសុរា មាន្យមួយនាមា ហៅកាកនាសូរស្តែង ។ ពួស័ព្ទសង្ខធុជថ្កើងថ្លែងព្រតព្រះគម្តែង ឥសូរដ៏រាមឫទ្ធា ។ អសុរនោះនិរ-មិត្ររូបាជាកាកមួយសា ហោះហើរនូវតេជបីពន្លឹក ។ មកចឹកហោមសាស្ត្រាធម្មិក ពួស័ព្ទគគឹក ស្លឹកស្មឹភ្នឹញ័ររុះរោយ ។ ស្រែកស័ព្ទកាកនោះពួន្សាយធុជធោងព្រាត់ព្រាយក៏ភិតពួនពឹងនៅនិត្យ ... ។

### ខ. តួរឿង

- តួអង្គ ៖ ជាអាទិទេព ឬអវតារនៃព្រះវិស្ណុមកយោនយកកំណើតជាមនុស្សជាបុរសអស្ចារ្យ និងជានារីអស្ចារ្យ ឯតួអង្គផ្សេងទៀតមានឥសី ទេវតា យក្ស គ្រុឌ ... ។ល ។
- ដំណើររឿង ៖ ច្បាំងមិនចេះចប់ប្រកបដោយសិល្ប៍សាស្ត្រអស្ចារ្យ ។ ដំណើររឿងមានភាពអច្ឆរិយៈដូចជា ជប ប្រស់ ហោះហើរ ផ្លែងសរ ... ។
- ទីកន្លែង ៖ ព្រៃហេមពាន្ត ក្រុងពួយុធ្យា ស្ថានសួគ៌ ក្រុងបាតាល ស្ថានសិម្ពលី ពោល គឺឋានទាំងបី ។
- បញ្ហាដោះស្រាយ ៖ ដោយសិល្ប៍មន្ត ឫទ្ធិអំណាច សងសឹកធ្វើចម្បាំងនឹងគ្នាដោះស្រាយដោយយុទ្ធវិធី ។
- ស្នេហា ៖ អ្នកឈ្នះ ឬអ្នកខ្លាំង គឺបានទទួលស្នេហា ។
- ទំនាស់ ៖ កើតឡើងដោយវិបត្តិទំនាស់រវាងសភាវៈល្អនិងសភាវៈអាក្រក់ច្បាំងទាស់ទែងគ្នាមានទារុណកម្មខាងផ្លូវចិត្តឬផ្លូវកាយ ។

- ឧត្តមគតិរឿង ៖

អប់រំមនុស្សឱ្យជឿលើអាទិទេព ហើយមានជំនឿថា ទុក្ខសោក ល្អអាក្រក់របស់ខ្លួនបានមកពីអាទិទេព ជាអ្នកកំណត់ ។

## គ. បញ្ចប់រឿង

ការបញ្ចប់រឿងបែបព្រាហ្មណ៍និយម គឺតួអង្គតំណាងអាទិទេព (សភាវៈល្អ) មានជ័យជម្នះលើសភាវៈអាក្រក់ (យក្ស គ្រុឌ អសុរៈ) ។ល ។

*អក្សរសិល្ប៍ព្រាហ្មណ៍និយម គឺអត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍ ដោយការផ្ដើមរឿងច្រើនលើកសរសើរពីឫទ្ធិអំណាចរបស់ព្រះឥសី ព្រះឥសូរទេវៈ អាទិទេពជាដើម ។ ឯតួរឿង ឬដំណើររឿងមានភាពអច្ឆរិយៈហួសហេតុ ហើយតួអង្គប្រុសជាអវតារនៃព្រះនារាយណ៍ ស្ត្រីជាកំពូលនារីល្អឯក និងបញ្ចប់រឿង អ្នកនិពន្ធបញ្ចប់ដោយឱ្យសភាវៈល្អឈ្នះសភាវៈអាក្រក់ ។*

## លំហាត់

តើអត្ថបទដកស្រង់ខាងក្រោមនេះ ចំណុចណាខ្លះ ដែលបញ្ជាក់ថារឿង នេះជាអក្សរសិល្ប៍បែបព្រាហ្មណ៍និយម ?

[...] ហនុមានក៏ស្ទុះហោះឡើងទៅលើមេឃ ហើយចុះចំកំពូលភ្នំខ្ពស់ ដោយខ្លួនមិនអាចស្គាល់ច្បាស់ថាណាមួយជាស្មៅថ្នាំស័ក្ដិសិទ្ធិនោះ អង្គកបិក៏ច្បាមយកទាំងកំពូលភ្នំ មកប្រគល់ឱ្យសូសេនៈ ។ សូសេនៈ បេះស្មៅមកកិន ហើយចាក់បញ្ចូលទៅក្នុងច្រមុះព្រះលក្ស្មណៈ ព្រះអង្គក៏បើកព្រះនេត្រឡើង ហើយបន្ទោសព្រះរាមៈពីភាពស្លុតស្លន់ព្រះអង្គ ! សង្គ្រាមត្រូវតែបន្តទៅទៀតយ៉ាងបន្ទាន់បំផុត ។

ខណៈនោះ ដើម្បីឱ្យការប្រយុទ្ធមានលក្ខណៈស្មើគ្នារវាងក្រុមរាវណៈដែលរាវណៈមានរាជរថនិងព្រះរាមៈយាងដោយបាទា ព្រះឥន្ទ្រក៏បានបញ្ជូនរាជរថនិងនាយសារថីនាមមាតលីព្រមទាំងអាវុធផ្ទាល់របស់ព្រះអង្គមកថ្វាយព្រះរាមៈ ។ សរដែលក្រុងរាវណៈដកយកមកប្រើប្រាស់ស្រាប់តែក្លាយទៅជានាគវិញ ប៉ុន្តែសរគ្រុឌ អ្នកស៊ីពស់ ដែលព្រះរាមៈបាញ់ចេញមក ក៏ប្រែជាសត្វរំពាដ៏ច្រើនឥតគណនា ដេញត្របាក់សត្វនាគវិនាសហិនហោចអស់ ។ ពេលនោះ មាតលីត្រូវរបួស ឯសេះក៏ត្រូវដរខ្យល់ដែរ ។ ប្រផ្នូលអាក្រក់លេចឡើងពាសពេញអាកាសវេហាស៍ ។ ព្រះទេវៈទាំងឡាយនាំគ្នាតាមដាន

នៅក្នុងភាពកោលាហលដ៏ស្អុតរន្ធត់នេះ ព្រះរាមៈឥតថមថយឫទ្ធីសោះឡើយ ។ ហឫទ័យព្រះអង្គរំភើបដោយក្ដីរីករាយ ស្ដេចឈរបង់ជំទែងក្រេវក្រោធយ៉ាងខ្លាំងនៅកណ្ដាលគ្រោះមហន្ដរាយ ហើយបាញ់សរស្រោចទៅលើមហាសត្រូវ ដែលកំពុងតែខឹងឆេវឆាវស្រាប់ ។ ប៉ុន្តែ ក្រុងរាវណៈឥតតក់ស្លុត ព្រះអង្គគ្រវីលំពែងរំលាយសរទាំងនោះវិនាសអស់ ។ ខណៈនោះព្រះរាមៈកញ្ឆក់លំពែងនិងអាវុធរបស់ព្រះឥន្ទ្រា ហើយសំពងកម្ទេចលំពែងក្រុងរាវណៈ បន្ទាប់មកព្រះអង្គវាយសម្លាប់សេះ ហើយពួយមួយលំពែងលិចកប់ទៅចំកណ្ដាលដើមទ្រូងស្ដេចរាក្សសៈ ក្រុងរាវណៈទ្រេតទ្រោតធេងធោង ។ នាយសារថីទាញបង្វៀរសេះវិលត្រឡប់វឹងខ្មី ចំណែកព្រះរាម ឃើញសត្រូវមានរបួសរត់គេចខ្លួនដូចនេះ ក៏ស្រែកប្រមាថដៀលត្មះឥតសំចៃ ក្សត្ររាក្សសៈឈឺផ្សាហឫទ័យដោយអៀនខ្មាសក៏បញ្ជាសារថីឱ្យវិលវិញ ហើយលោតយ៉ាងសាហាវសង្កុញទៅរកគូបដិបក្ខប្រសើរខ្ពស់ឧត្តម ។

ពេលនោះ ព្រះមហាឫសីសម្បុរសអគស្ស: ដែលបានអង្គុយមើលចម្បាំងតតួនេះជាមួយព្រះទេវៈឯទៀតដែរនោះ បានចុះចាកស្ថានសួគ៌ា ហើយសូត្រប្រសិទ្ធីដល់ព្រះរាមៈ ថ្វាយពរជ័យជម្នះដល់ព្រះអង្គ ។ ព្រះរាមៈសែនរំភើបដោយបីតិសោមនស្ស ! ប្រផ្នូលអាក្រក់ជាច្រើនកើតមានឡើង ទោះអ្នកក្លាហានក៏ព្រឺព្រួចបះរោមច្រូងគ្រប់គ្នា ។ ឈាមហូរស្រោចស្រពជោកខ្លួនអង្គរាវណៈ ហ្វូងត្មាតហើរក្រឡឹងពីលើកេសា សត្វចចកដ៏មានមាត់ព្រួសចេញមកស៊ុទ្ធតែអណ្ដាតភ្លើង រត់តាមដានពីក្រោយប្រកិត ។ ផ្គរលាន់គគ្រាំគគ្រឹក ដុំភ្លើងធ្លាក់ដូចគ្រាប់ភ្លៀងពីមេឃា ផែនដីញ័ររញ្ជួយ ។ នៅឯនាយបូរីលង្កាហាក់ដូចកំពុងលិចលង់នៅក្នុងចំហាយស្ពាន់ ! ប៉ុន្តែព្រះរាជានៃរាក្សសៈ ក្រុងរាវណៈ ក្សត្រឆ្អើមទេវៈបញ្ជា មិនព្រមចុះញ៉មចំពោះហេតុភេទព្រមាននេះឡើយ អង្គអសុរាវាយលុក ហើយគូប្រយុទ្ធជើងឯកទាំងទ្វេអង្គប្រយុទ្ធក្នុងលក្ខណៈអង់អាចក្លាហានដូចគ្នា ហាក់បីដូចជាថាទាំងពីរត្រូវតែឈ្នះដាច់ខាតយ៉ាងនោះ ។

ស្ដេចអសុរាវាយតម្រង់ ទង់សេះ នាយសារថីរបស់ព្រះរាម ប៉ុន្តែលំពែងចេះតែវេរវៀចឃ្លាតឆ្ងាយពីគោលដៅ ចំណែកព្រះរាមៈវាយទម្លាក់ជាបន្តបន្ទាប់នូវអាវុធគ្រប់បែបនិងគ្រឿងតុបតែងអង្គរបស់គូបដិបក្ខ ។ ប៉ុន្តែរាជរាក្សសៈនៅតែឥតតក់ស្លុត ប្រើដៃម្ភៃនិងក្បាលដ៏គួរស្ញើបទាំងដប់របស់ខ្លួន ហើយអាវុធថ្មីៗទៀតរមែងកើតឡើងបំពេញដៃទាំងនោះជានិច្ច ។ កងចក្រដែលព្រះរាមចោលទៅបានផ្ដាច់កេសាអសុរាម្ដងមួយៗ ប៉ុន្តែគ្រាន់តែក្បាលមួយរមៀលធ្លាក់ដល់ដីភ្លាម ក្បាលមួយទៀតក៏ដុះឡើងជំនួសភ្លាមដែរ បន្ទុបនៅពីលើកអាវជោកទៅដោយឈាម ហើយរឹតតែអាក្រក់អាក្រីលើសពីដើមទៅទៀត ស្ដេចរាក្សសៈចំអកចំពោះភាពទន់ខ្សោយរបស់ព្រះរាមៈ ។ ខណៈនោះ មាតលីនាយសារថីនៃស្ដេចព្រះទេវៈ ដែលគ្មានសេះណារឹងរូសនឹងបញ្ជូសោះនោះ បានទូលទូន្មានព្រះរាមឱ្យប្រើ

អាវុធកសាងឡើងដោយព្រះព្រហ្ម បុព្វជននៃពិភពលោក គឺសរព្រហ្មាស ដែលពីដើមជាអាវុធរបស់ព្រះឥន្ទ្រ ព្រះរាមៈលើកអាវុធអស្ចារ្យនេះមកគ្រវី នៅពេលរបូតចេញផុតពីដៃ សរបានខ្សៀកបន្លឺសូរឃ្មៀកយ៉ាងរីករាយ ហើយទៅចាក់ទម្លុះបេះដូងក្រុងរាវណៈ បន្ទាប់មកវិលត្រឡប់មកកាន់បំពង់វិញប្រៀបដូចបក្សីស្មោះត្រង់វិលមកកាន់សំបុកវិញដូចនោះ។ ក្រុងរាវណៈឈរធេងធោង ហើយបន្ទាប់មកដួលដេកស្លាប់ច្រងាង !

ការអបអរសាទររបស់ពពួកទេពតាទាំងឡាយលាន់ឮឡើងខ្ទរខ្ទារពេញស្ថានសួគ៌ ៖ សំណូរគគ្រឹកគគ្រេងនៃស្គរនិងភ្លៀងបុប្ផា !

*(ដកស្រង់ពីសង្ខេបរឿងរាមាយណៈ អក្សរសិល្ប៍បរទេសក្រសួងអប់រំ ១៩៨៧)*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ព្រះរាមលើកធ្នូ



## ក. សិក្សាពាក្យគន្លឹះ

- សុភតិត្ថិ : ពេលាដែលជាសុភឫក្ស ថ្ងៃដែលល្អ ។
- ពសុធា : ដី ផែនដី ។
- ឧសភរាជ : ស្ដេចគោ (គោព្រះរាជទ្រព្យ) ។
- រូ : ដូច ។
- រូបហាន : ដូច ប៉ីដូច ប៉ុន ។
- សីហនាទ : បន្លឺសូរសៀងដូចសីហៈ ។
- នទី : ស្ទឹង ទន្លេ ។
- សុពណ្ណ : ពណ៌ល្អ ពណ៌មាស ។
- ភុល : សូរឮដោយបក្សីស្អុះហើរព្រមគ្នា ឬសូរទឹកខ្ពុរចេញជាដើម ។
- សុបវរ : ល្អប្រសើរ ។
- ឧទរ : ពោះ ផ្ទៃ ។

facebook.com/moeys.gov.kh

- អភិសេក : ការប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរថ្វាយជ័យចំពោះព្រះពុទ្ធ ឬ ក្សត្រិយ៍ឱ្យពេញលក្ខណៈ ។
- ទេពទសសហស្សា : ទេវតាទាំងដប់ពាន់ ទេវតាទាំងម៉ឺន ។
- ពិសុទ្ធសន្ធរ : ស្អាតវិសេស ហ្មត់ហ្មង ឥតមន្ទិល ។
- សច្ចាអធិដ្ឋាន : សំបូងសង្រូងប្រកាសពាក្យសច្ចៈ ។
- ទសទិសា : ទិសទាំង១០ ។
- ឧណ្ហា : កម្ដៅ ។
- ទេពនិករ : ពពួកទេវតា ។
- អមរនាគេន្ទ្រ : ដំរីរបស់ទេវតា ។
- មោះហិមា : ធំ សម្បើម អស្ចារ្យ ។
- អស្សពាហ៍ : សេះ ពាជី ។
- លេណ : គុហាដែលកើតឯងក្នុងភ្នំ រូង រូងភ្នំ ។
- ជលធី : សមុទ្រ ទន្លេសាប ។
- ពិពិធពិពណ៌ : ច្រើនបែប ច្រើនពណ៌ ។
- មយូរ : ក្ងោក ។
- ព្រតសីលា : ការប្រតិបត្តិសីល ។
- តបៈ : ការប្រព្រឹត្តកាន់វត្តយ៉ាងតឹងដើម្បីធ្វើកាយចិត្តឱ្យស្ងប់ ។
- ព្រះពិរុណ : ឈ្មោះទេវតា ដែលបណ្ដាលឱ្យមានភ្លៀង ។
- មហាធិបតិន្ទ : ទេវតាជាអធិបតីធំលើសគេ ។
- ត្រៃភព : ភពទាំងបី ។
- ទត : មើល ។
- តេជ : អំណាច អានុភាព ។
- ព្រះហរិ : ព្រះនារាយណ៍ ។
- ភូធរ : អ្នកទ្រទ្រង់ដែនដី ស្ដេច ។
- កោទ័ណ្ឌសហស្សថាម : ធ្នូដែលមានទម្ងន់បុរស ១០០០នាក់ទើបលើករួច ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអ្នកត្រូវយកចិត្តទុកដាក់ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងអ្នកនិពន្ធ កាលអាកាស សង្គមបរិយាកាស ទំនាស់ វិធីតែងនិពន្ធ តម្លៃអប់រំ ។

ស្តេចនគរមិថិលា ព្រះនាមព្រះបាទជនក រើសយកកុមារីម្នាក់មកធ្វើជាបុត្រីចិញ្ចឹម នៅពេលដែលព្រះអង្គកំពុងប្រារព្ធពិធីច្រត់ព្រះនង្គ័លសុំសេចក្តីសុខចម្រើនដល់ប្រជារាស្ត្រនាឆ្នេរទន្លេយមុនា ។ ព្រះអង្គប្រទានឈ្មោះបុត្រីចិញ្ចឹមដ៏ស្អាតនេះថា នាងសីតា ។ លុះនាងសីតាពេញរូបរាងព្រះអង្គក៏ប្រកាសបើកការប្រឡងប្រជែងរកស្វាមីឱ្យនាង ។

## គ. អត្ថបទ

ដងនោះព្រះបាទមិថិលា ស្តេចធ្វើចរិយា បីដោយនូវក្រិត្យដ៏ពិធី ។
លុះពិសាខសុភតិត្ថិ ភ្ជុំមុខមន្ត្រី ប្រយោជន៍នូវប្រែព្រសុធា ។
ដើម្បីនូវធ្វើឱ្យក្សេមដ៏ប្រជា រាស្ត្ររដ្ឋដោយនា ក្រិតាអធិការដ៏បុរាណ ។
ស្តេចទ្រង់នង្គ័លមាសមាន ព្រះឧសភរាជបីរូហាន ដំណើរសីហនាទលេលា ។
ស្តេចភ្ជួរលុះដ៏ឆ្នេរយមុនា នទីទេពកញ្ញា- សុពណ្ណពោងពាយភុល ។
លើឈូករ័តន៍រាជកោមល បរិបូណ៌និមល ប្រសើរពិសេសលើសក្រៃ ។
ស្តេចមានព្រះរាជហឫទ័យ ត្រេកត្រិះអរក្រៃ នឹងរាជបុត្រីកញ្ញា ។
ដងនោះឥស្សរមិថិលា រៀបរាជយោធា នូវថ្វាត់រឹងថ្កានព្រះនគរ ។
នាំរាជកញ្ញាសុបវរ ស្មើបុត្រដ៏ឧទរ ក៏លុះលើរាជពិភព ។
ស្តេចរក្សារាស្ត្រផងស្កល់ស្កប់ ស្តេចទើបឱ្យអ- ភិសេកប្រកបនាមា ។
ដោយហេតុហៅរាជសីតា បរិសុទ្ធសោភា ដូចបូណ៌ព្រះចន្ទ្រច្រាលច្រាស ។
វរភក្ត្រវរលក្សណ៍យល់ច្បាស់ អស់ទេពទសហ័ស្ស ពុំស្មើនូវរាជបុត្រី ។
ដងនោះព្រះបាទនរបតី យល់រាជបុត្រី ពិសេសពិសុទ្ធសុន្ទរ ។
នោះព្រះមុនីរាជដ៏បវរ ជបធនូសិល្ប៍សរ នូវស័ព្ទសច្ចាអធិដ្ឋាន ។
ថាទោះទេពតាឫទ្ធិមាន ជ័យអាចលើកបាន ធនូសិល្ប៍នូវតេជោជ័យ ។
យើងនូវយករ័តន៍សីតាថ្លៃ អភិសេកឱ្យព នាទេពដ៏មានចេស្តា ។
អស្ចារ្យទូទសទិសា កក្រើកត្រៃត្រិង្សា ឧណ្ហាអស់ទេពដ៏និករ ។
អស់ទេពតាផងសឹងដ៏អរ បរគ្នាវីវរ រត់ចុះពីត្រ័យត្រិង្ស ។
ព្រះឥន្ទ្រស្តេចលើព្វរា អមរនាគេន្ទ្រា រស្មីរុងរឿងគិតដ៏ថ្កើង ។

ព្រះអគ្គីស្តេចលើរមាសភ្លើង តេជោជ័យថ្កើង ឫទ្ធិរមាសមោះហិមា ។
ព្រះពាយផ្សាយផ្សព្វដ៏វេហាស៍ អស្សុពាហ៍លេលា គឺពាយក៏បក់បីប្រហារ ។
ព្រះពិរុណព្រះអង្គបីឧទារ ស្តេចលើនាគនាថ ពិពិធពិពណ៌ជលធី ។
ព្រះចន្ទ្រកុមារស្តេចលី- លាលើបក្សី សុពណ៌មយូររចនា ។
ព្រះព្រហ្មទ្រង់ព្រតសីលា ស្តេចលើហង្សា ធិរាជរឹងឫទ្ធីដ៏តបៈ ។
ព្រះនេហ្ធតិរាជតេជះ គង់លើយក្សតបៈ កម្លាំងក៏ស្តេចយាត្រា ។
ព្រះពៃស្រពណ៌រាជដ៏មហា- ធិបតិន្ទលេលា លើក្រាលពិមានដ៏មង្គល ។
ព្រះឥសូរសិទ្ធិសក្តិ៍ស្ងួស្តីសល់ ត្រៃភពដ៏មណ្ឌល សំណាក់នៃទេពឥន្ទ្រា ។
ស្តេចលើឧសភរាជដ៏មហា អតិរេកមោះហិមា- នុភាពអំណាចព្រះធនូ ។
អស់ទេពកិន្នររាជព្រះភូ- ធរទតឫទ្ធិធនូ ប្រយោជន៍នូវចង់លើកលង ។
ព្រះឥសូរឫទ្ធីដ៏កន្លង ទូតទេពក្សត្រផង ក៏លងនូវតេជះប្រាណ ។
ពុំអាចបីនូវលើកធនូបាន នឹងនៅនាស្ថាន សំបិតនៅព្រះមុនី ។
នោះព្រះមុនីនាថនរបតី ស្តេចយល់ព្រះហរី សម្តេចព្រះនារាយណ៍រាមា ។
ទោះនូវលើកធនូសិល្ប៍នូវឫទ្ធា បានបរិបូរអា- នុភាពនូវតេជោពល ។
ព្រះឥសូរនរនាថស្តេចយល់ អស់ទេព្តាដល់ ក៏ស្តេចនូវរឹងស្ថានស្ថិត ។
ដងនោះព្រះពិស្វាមិត្រ នាំរាជដ៏បពិត្រ នូវលក្ស្មណ៍សម្តេចយាត្រា ។
លុះដល់បុរីមិថិលា ចូលទូលរាជា- ធិរាជនូវសូមលើកលង ។
ក្រុងមិថិលារឹងស្នង អញ្ជើញស្តេចហោង សម្តែងនូវតេជព្រះធនូ ។
ព្រះរាមស្តេចមើលអស់ភូ- ធរលើកឫទ្ធីធនូ ក៏ព្រើសព្រះភក្ត្រប្រិមប្រិយ៍ ។
ស្តេចចូលលងឫទ្ធិដ៏ពិធី អស់ទេពដ៏ឥសី ក្សត្រទតអានុភាពចេស្តា ។
ព្រះរាមរឹងឫទ្ធិមោះហិមា ស្តែងស្តេចចេស្តា ធិការនុភាពលើសក្រៃ ។
ស្តេចលើកកៅទណ្ឌសរជ័យ អស់ទេពមនុស្សព្ទ ដ៏មានកំឡុងលោកធាតុ ។
សឹងថ្វាយសព្ទសាធុការសាទរ ព្រះបរមនាថ ឫទ្ធីអំណាចយល់ថ្កើង ។
ស្តេចវាត់កៅទណ្ឌបីជុំឡើង កោះសរសក្តិថ្កើង សម្តែងនូវតេជប្រត្យក្ស ។
ស្តេចក្រាយកៅទណ្ឌសរសក្តិ រូមណ្ឌលចក្រ រំភាយព្រះករសោភា ។
ដងនោះព្រះបាទមិថិលា ស្តេចយល់ដ៏ឫទ្ធា- នុភាពព្រះរាមលើសក្រៃ ។
ស្តេចត្រេកអរឱ្យពរជ័យ ជយោជ័យក្រៃ សម្រិទ្ធីរាមមោះហិមា ។
ស្តេចយករ័តន៍រាជសីតា ប្រកបនូវលក្ខណា ក៏ថ្វាយព្រះរាមដ៏កន្លង ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

ស្ដេចមុខមន្ត្រីផង ប្រើទូតទៅចង មេត្រីព្រះបាទទសរថ ។
ស្ដេចផ្ដាំទូតទៅបីកំណត់ ថ្កានព្រះទសរថ បីលុះបុរីអយុធ្យា ។
ស្រេចចូលទូលព្រះករុណា បុត្ររ័តន៍រាជា- ធិរាជបរមបពិត្រ ។
ថាឥឡូវព្រះពិស្វាមិត្រ មហាឫសីសក្ដិសិទ្ធិ ប្រសិទ្ធិនូវព្រតសីលា ។
នាំព្រះរាមរាជក្សត្រា នូវព្រះអនុជា ធិរាជព្រះរាជបុត្រដល់ ។
បុរីមិថិលាមណ្ឌល ស្ដេចភ្ជុំរេហ៍ពល នូវលើកធ្នូសរសិល្ប៍ហោង ។
ស្ដេចធ្វើសច្ចាអធិស្ឋានផ្សង ទោះទេពក្សត្រផង នាមានតេជឈ្នះប្រាណ ។
ទោះបីអាចលើកធនូសិល្ប៍បាន ដូចក្សត្រអធិស្ឋាន ព្រះបាទជនករាជា ។
ស្ដេចនូវលើករាជកញ្ញា នាមនាងសីតា បូជានៃក្សត្រនោះហោង ។
កាលនោះអស់ទេពក្សត្រផង សឹងចូលលើកលង កម្លាំងទីទៃសព្វប្រាណ ។
ពុំអាចនូវក៏លើកបាន និត្យនឹងនៅស្ថាន ក្រលាព្រះរោងដ៏ពិធី ។
លុះព្រះរាជបុត្រនរបតី ចូលលងនូវឫទ្ធី តេជះសម្ដេចនៃព្រះរាម ។
ស្ដេចលើកកៅទ័ណ្ឌសហស្សថាម បាញ់បាននៃស្ថាន កណ្ដាលជំនុំដ៏ឥសី ។
ឮខ្ទរខ្ទារទាំងប្រថពី ឮស័ព្ទអសនី គឺសែនរន្ទះគណនា ។
ព្រះបាទចក្រពត្តិរាជា ជនករាជដ៏មហា ក្សត្រត្រេកព្រះរាជហឫទ័យ ។
ស្ដេចនូវយកសីតារ័តន៍ថ្លៃ ស្ដួតីឱ្យជ័យ ប្រដាប់នូវមង្គលការ ។
ផ្សំនូវព្រះរាមឫទ្ធីមោះហិមា ប្រើខ្ញុំព្រះករុណា មកទូលសម្ដេចភូបាល ។
ឱ្យអញ្ជើញព្រះភូវនាថ ស្ដេចទៅនៅត្រអាល រណ្ដាប់អាពាហ៍ពិពាហ៍ ។

*(ដកស្រង់ពីរឿង រាមកេរ្តិ៍ខ្សែ១ បោះពុម្ពផ្សាយពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥៣៩ គ.ស ១៩៩៥)*

## សំណួរ

១. តើអត្ថបទកាព្យនេះមានចំណងជើងដូចម្ដេច ? ដកស្រង់ចេញពីរឿងណា ? ក្នុងខ្សែទីប៉ុន្មាន ? បោះពុម្ពផ្សាយក្នុងឆ្នាំណា ?
២. ចូរបង្ហាញកាលកំណត់តែងនិងសង្គមបរិយាកាសក្នុងរឿង ។
៣. តើក្នុងអត្ថបទដកស្រង់នេះ អ្នកនិពន្ធប្រើវិធីតែងនិពន្ធអ្វីខ្លះ ?
៤. តើអត្ថបទដកស្រង់រឿងរាមកេរ្តិ៍ស្ថិតនៅក្នុងអក្សរសិល្ប៍ប្រភេទណា ? ចូរបង្ហាញលក្ខណៈសម្គាល់របស់រឿងនេះ ។
៥. ចូរបង្ហាញពីគំនិតសំខាន់ៗនៅក្នុងអត្ថបទ ។

# ខ្លឹមសារអត្ថបទ

ក្នុងអត្ថបទទាំងឡាយ ទោះជាពាក្យរាយក្ដី ពាក្យកាព្យក្ដី អ្នកនិពន្ធតែងចងក្រងពាក្យពេចន៍ខ្លឹមសារសំខាន់ៗជាគតិចំពោះអ្នកអាន ។

## ក. អត្ថបទកាព្យ

ឃើញឫកគេល្អ ទោះបីមានក្រ យកគេជាញាតិ
គួររាប់អ្នកក្រៅ ផៅអ្នកឯទៀត រាប់រើសមារយាទ
សុចរិតត្រឹមត្រូវ ។
រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ
កុំភ្លើនភ្លេចម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំស្ងូវមើលងាយ ។

*(ដកស្រង់ពីសៀវភៅច្បាប់ក្រម ង៉ុយ គ.ស១៩៦៦ ទំព័រទី ៣៨)*

អត្ថបទកាព្យនេះមានខ្លឹមសារដូចតទៅ ៖

- វគ្គទី ១ : ការគប់មិត្រ គឺត្រូវជ្រើសរើសយកអ្នកមានឫកពាល្អ មារយាទត្រឹមត្រូវហើយមិនប្រកាន់វណ្ណៈ ។
- វគ្គទី ២ : មានសីលធម៌ គឺចេះប្រើពាក្យគួរសម អាកប្បកិរិយារាបសាគោរពឪពុកម្ដាយចាស់ទុំ ហើយមិនដើរតាមផ្លូវខុស ។

## ខ. អត្ថបទពាក្យរាយ

[...] លោកអធិបតីចូលមក : "សូផាត ! បន្ទប់នេះ គឺបន្ទប់ឯងការរចនាឱ្យបានរុងរឿងស្រេចនៅលើចិត្តបាស្រាប់ អញរៀបប្រដាប់ឱ្យឯងឱ្យស្រួលបួលនេះ គឺអញសង្ឃឹមថាឯងគង់តែនឹងបានរៀនសូត្រកើនទៅមុខទៀតពុំខាន" លោកមានប្រសាសន៍តែប៉ុណ្ណឹងរួចក៏អញ្ជើញទៅវិញភ្លាម ។ វេលាណារិនជួយរៀបបន្ទប់ឱ្យមិត្តស្រេច ណារិនក៏លាសូផាតទៅទីអាត្មាវិញទៅ ។ សូផាតនៅតែម្នាក់ឯងសញ្ជឹងគិតថា ខ្លួនអញអើយចំជាមានភ័ព្វមានសំណាងមែនដោយបានមកជួបនឹងអ្នកមានចិត្តសប្បុរសដល់ម្ល៉េះ ឱ ! គេទំនុកបម្រុងអញយ៉ាងនេះ គឺគេធ្វើឱ្យអញសប្បាយចិត្តនិងបានថ្លាប្រាជ្ញាក្នុងការរៀនសូត្រ បើដូចនេះគួរអញមិនត្រូវធ្វេសប្រហែសមួយវេលាឡើយនឹងបំពេញកិច្ចគេ ។ សូមឱ្យគុណបុណ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជួយលោកថៅហ្វាយខ្ញុំឱ្យបានសេចក្ដីសុខចម្រើនគ្រប់ប្រការ ។ [...]

*(ដកស្រង់ចេញពីរឿងសូផាត របស់លោករីម គីន គ.ស ១៩៦៥)*

អត្ថបទនេះមានខ្លឹមសារដូចតទៅ ៖ លោកសួនមានគំនិតចង់ជួយផ្គត់ផ្គង់សូជាតឱ្យរៀនសូត្របានខ្ពង់ខ្ពស់មានចំណេះជ្រៅជ្រះ មានកិត្តិយសថ្លៃថ្នូរនោះទើបមានសុភមង្គល ។

សរុបមកទោះជាអត្ថបទពាក្យរាយក្ដី ពាក្យកាព្យក្ដី អ្នកនិពន្ធតែងតែបង្កប់នូវខ្លឹមសារសំខាន់ៗសម្រាប់ជាគតិចំពោះអ្នកអាន ។

***ខ្លឹមសារអត្ថបទ គឺជាគំនិតសំខាន់ៗទាំងអស់ដែលរៀបរាប់ក្នុងអត្ថបទ ។***

## លំហាត់

ចូរបង្ហាញខ្លឹមសារនៃអត្ថបទខាងក្រោមនេះ

**ក.** គួរស្ដាយកេរ្ដិ៍ម៉ែឪ　　　　កិរិយាត្រូវគួរខំត្រាប់
កិរិយាណាខុសច្បាប់　　　　គួរក្រឡាប់ក្រឡាស់ចោល ។
អាពុកម្ដាយនិងកូន　　　　បីដូចខ្លួននិងស្រមោល
ឃើញខុសកុំអាលដោល　　　　កុំថ្កោលទោសអ្នកមានគុណ ។
ល្ងង់ខ្លៅត្រូវតែសួរ　　　　ពាក្យឱ្យគួរកុំឱ្យស៊ុន
យកពាក្យផ្អែមជាមុន　　　　ទន់លំទោនឱ្យប្រណិប័តន៍ ។
ទោះម៉ែឪស្លូតកាច　　　　គួរតែខ្លាចដូចមហាក្សត្រ
ម្ដាយជេរពីរបីម៉ាត់　　　　គួរតែស្ងាត់ស្ងៀមឱ្យឈឹង ។
ប្រដៅត្រូវតែស្ដាប់　　　　យកតម្រាប់កុំទទឹង
ម្នោម្នះចចេសរឹង　　　　ហ្នឹងហើយហៅកូនសេសកម្ម ។

*(ដកស្រង់ពីសៀវភៅអ្នកនិពន្ធខ្មែរ ភិរម្យ ង៉ុយ គ.ស ១៩៦៦ ទំព័រទី ៣៤)*

**ខ.**[...] ប្រជាជនយើងមួយចំនួនមានជំនឿថា អ្នកមានមាសប្រាក់ច្រើនហូរហៀរបុណ្យសក្ដិធំដុំដោយសារគេបានធ្វើបុណ្យពីជាតិមុន ចំណែកឯអ្នកក្រដោយសារតែមិនបានធ្វើបុណ្យពីជាតិមុន ។ ហេតុនេះហើយបានជាពួកគេខំសន្សំប្រាក់ដែលរកបានបន្តិចបន្តួចទៅធ្វើបុណ្យ ហើយប្រាថ្នាជាតិក្រោយឱ្យសម្បូរសប្បាយដូចគេ ខ្លះទៀតប្រាថ្នាសុំឱ្យរូបស្អាត ខ្លះទៀតប្រាថ្នាឱ្យរៀនពូកែ ខ្លះទៀតប្រាថ្នាសុំឱ្យមានបុណ្យសក្ដិធំ ។ ខ្ញុំសុំលើកឡើងដើម្បីវិភាគថា ជំនឿនេះផ្ទុយស្រឡះពីគំនិតរបស់ស្រីហិតោបទេស ដែលបានលើកឡើងថា "ម្រឹគមិនដែលបោលចូលមាត់សីហៈ ដេកលក់ឡើយ" មានន័យថា បើសត្វសិង្ហមិនដើរស្វែងរកចំណីទេ ច្បាស់ជាក្រពះមិនឆ្អែតឡើយ ។ ព្រះពុទ្ធបានសម្ដែងថា "ខ្លួនទីពឹងខ្លួន" ។ ទ្រឹស្ដីរបស់គ្រិស្តសាសនាបាននិយាយថា "ជួយខ្លួនឯងសិន ទើបព្រះជួយជាក្រោយ" ។ ទ្រឹស្ដីទាំងបីនេះមានខ្លឹមសារស្របគ្នា បំណងប្រាថ្នាមនុស្សម្នាក់ៗមិនអាចសម្រេចបានដោយគ្មានពលកម្មផ្លូវកាយនិងពលកម្មផ្លូវប្រាជ្ញាឡើយ ។ [...]

*(ដកស្រង់ចេញពីសៀវភៅ ធ្វើដូចម្ដេចទើបប្រទេសជាតិរីកចម្រើនដោយ អ៊ឹង ហុងជួរ ទំព័រទី ៣៩)*

# ចលនាអក្សរសិល្ប៍

ពុទ្ធសាសនា ជាសាសនាមួយដែលជនជាតិខ្មែរធ្លាប់បានគោរពបូជាតាំងពីបុរាណកាលមកម្លេះ ។ សាសនានេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងក្រអៅបេះដូងរបស់មនុស្សខ្មែរដូចជាព្រហ្មញ្ញសាសនាដែរ ។ ក្នុងពេលខ្លះ ពុទ្ធសាសនាបានរួមចំណែកយ៉ាងខ្លាំងដល់ការកសាងប្រទេសឱ្យរីកចម្រើននិងការពារទឹកដីឱ្យមានអត្ថិភាពថែមទៀត ។ សព្វថ្ងៃនេះ ទោះបីពុទ្ធសាសនាបានជ្រៀតចូលក្នុងចិត្តគំនិតទំនៀមទម្លាប់ប្រពៃណីនៃសង្គមខ្មែរក៏ដោយ ក៏ឥទ្ធិពលនៃសាសនាព្រាហ្មណ៍ដែលរលុបរលាយស្ទើរតែអស់គ្មានសល់រូបរាងពីសង្គមខ្មែរនោះនៅតែជ្រៀតចូលលាយឡំនៅក្នុងសន្តានចិត្តខ្មែរដដែល ។

ទន្ទឹមនឹងនោះឥទ្ធិពលបរទេសផ្សេងទៀតកំពុងជះឥទ្ធិពលប្រជែងនឹងលក្ខណៈជាតិខ្មែរដែរ ។ ឥទ្ធិពលទាំងអស់នេះហើយបានជះឥទ្ធិពលមកលើអក្សរសិល្ប៍ខ្មែរយើង ។

## ១ . ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម

អក្សរសិល្ប៍គោលព្រាហ្មណ៍និយម ឬអក្សរសិល្ប៍បែបព្រាហ្មណ៍និយម គឺជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងបែបបទលទ្ធិសាសនាព្រាហ្មណ៍ ។ អក្សរសិល្ប៍បែបនេះគេតែងតែជឿលើអាទិទេពមានព្រះព្រហ្ម ព្រះឥសូរឬសិវៈ ព្រះវិស្ណុ ឬព្រះនារាយណ៍ ។ ម្យ៉ាងទៀតគេជឿថាពុទ្ធិទាំងឡាយស្ថិតនៅក្នុងគម្ពីរវេទ ។ តួអង្គសំខាន់ៗ ជាតួអង្គអាទិទេព ឬអវតារជាដើម ។

*ឧទាហរណ៍ :* រឿង រាមាយណៈ មហាភារតយុទ្ធ ... ។

## ២ . ចលនាអក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍គោលពុទ្ធនិយម ឬអក្សរសិល្ប៍បែបពុទ្ធនិយម ជាអត្ថបទរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងការលើកយកទ្រឹស្តីពុទ្ធសាសនាធ្វើជាគោល ហើយទ្រឹស្តីទាំងនោះស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិដកដែលអ្នកនិពន្ធលើកយកបញ្ហាបុណ្យ បាប ផលល្អ អាក្រក់របស់តួអង្គមកចោទនិងដោះស្រាយ ។ អក្សរសិល្ប៍បែបពុទ្ធនិយមនេះមានអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ ពុទ្ធនិយមក្លាយ និងពុទ្ធនិយមក្លាយហួសហេតុ ។

*ឧទាហរណ៍ :* រឿង សុវណ្ណសាម ... ។

## ៣ . ចលនាអក្សរសិល្ប៍ខេមរនិយម

គោលនិយមនេះ ប្លែកពីចលនាដទៃទៀតដោយពុំបានយកគោលពីលទ្ធិណា ឬសាសនាណាឡើយ គឺជាការប្រឌិតតាមការណ៍ដែលគេធ្លាប់ឃើញពិតជាក់ស្តែងក្នុងសង្គមជាតិខ្មែរតែម្តង ។ បើស្រុកទេសយើងជួបប្រទះនឹងបញ្ហាផ្សេងៗ បញ្ហានោះក៏បានជាការផ្តួចផ្តើមគំនិតកកើតជាបញ្ហាក្នុងវប្បធម៌

និងសង្គមធម៌ជាតិឡើង ។ ដូច្នេះបញ្ហាដែលកើតឡើងក្នុងគោលនិយមនេះពុំមានភាពអច្ឆរិយៈឡើយ គឺសុទ្ធសឹងតែជាភាពពិតមែនទែនដែលស្របទៅនឹងលោកិយសច្ចៈទាំងស្រុង ។

*ឧទាហរណ៍ :* រឿង ផ្កាស្រពោន រឿង កុលាបប៉ៃលិន រឿង សូផាត ... ។

## ៤ . ចលនាអក្សរសិល្ប៍បរទេសនិយម

គោលនិយមនេះសំដៅដល់គោលគំនិតផ្សេងៗ ដែលពុំស្របតាមលទ្ធិព្រាហ្មណ៍សាសនាព្រះពុទ្ធ ឬជាទំនៀមសុទ្ធសាធរបស់ខ្មែរ ដែលធ្លាប់មានមកនោះទេ ។ ប្រទេសយើងទើបតែមានគោលនិយមនេះកើតឡើងក្នុងរវាងដែលប្រទេសខ្មែរត្រូវធ្លាក់ខ្លួនគ្រាំគ្រា ហើយបរទេសនាំយកគោលគំនិតពីស្រុកគេមកផ្សាយបញ្ចូល ។ ប៉ុន្តែគោលនិយមនេះមានឥទ្ធិពលខ្លាំងក្លាណាស់ក្នុងពេលបច្ចុប្បន្ន ព្រោះមនុស្សទូទៅក្នុងសកលលោកច្រើនចូលចិត្តគោលនិយមបែបនេះ ។ សព្វថ្ងៃ គេឃើញនៅសល់គោលនិយមនេះពាសពេញ ដូចខាងសុជីវធម៌ សម្លៀកបំពាក់ សិល្បៈ រាំរែក ... ។ល ។

*ចលនាអក្សរសិល្ប៍ គឺជាដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមលើទ្រឹស្តីទស្សនៈគោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ។ គេអាចចែកចលនាអក្សរសិល្ប៍ខ្មែរជាបួនប្រភេទ គឺចលនាអក្សរសិល្ប៍ព្រាហ្មនិយម ពុទ្ធនិយម ខេមរនិយម និងបរទេសនិយម ។*

## លំហាត់

១. តើគេអាចចែកអក្សរសិល្ប៍ខ្មែរជាប៉ុន្មានចលនា ? គឺអ្វីខ្លះ ?

២. ដូចម្តេចហៅថាចលនាអក្សរសិល្ប៍ព្រាហ្មនិយម ? ពុទ្ធនិយម ? ខេមរនិយម ? បរទេសនិយម ?

៣. ក្នុងបណ្តារឿងខាងក្រោមនេះ រឿងណាដែលស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ព្រាហ្មនិយម ពុទ្ធនិយម និងខេមរនិយមដូចជា រឿងមរណមាតា រឿងកុលាបប៉ៃលិន រឿងអ្នកតាទឹក អ្នកតាភ្នំ រឿងមាយាស្ត្រី រឿងមាយើង រឿងពុទ្ធិសែន រឿងក្រុងសុភមិត្រ រឿងស៊ឹមបរឡាន រឿងរាមកេរ្តិ៍ រឿងរាមាយណៈ រឿងវេស្សន្តរ រឿងទុំទាវ ។



# លក្ខណៈនៃភាសាខ្មែរ

**ព្យញ្ជនៈវែបបទី១** (សម័យមុនអង្គរ)



**ព្យញ្ជនៈវែបបទី២** (សម័យអង្គរ)



**ព្យញ្ជនៈវែបបទី៣** (សម័យក្រោយអង្គរ)



ភាសាជាពាក្យសម្ដីដែលយើងនិយាយប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីសម្ដែងនូវឆន្ទៈ សញ្ចេតនាចិត្តគំនិតអ្វីមួយ ។ នៅក្នុងលោកយើងនេះ គ្រប់ជាតិសាសន៍សុទ្ធតែមានភាសាផ្ទាល់ខ្លួន សម្រាប់ប្រើទាក់ទងគ្នានៅក្នុងសង្គមជាតិរៀងៗខ្លួន ។ ភាសានៃជាតិសាសន៍នីមួយៗ មានកំណើតឡើង ដំណាលគ្នានឹងកំណាកំណើតនៃជាតិសាសន៍នោះដែរ ហើយវិវឌ្ឍប្រែប្រួល ចម្រើនលូតលាស់ឬ អន់ថយទៅតាមសង្គមមនុស្សនោះថែមទៀត ។ ភាសាវិទូបានសិក្សាស្រាវជ្រាវអំពីភាសាទាំងអស់ក្នុង លោកឃើញថា ភាសាមានចំនួនច្រើនណាស់បើរាប់ទាំងភាសាតូច ធំ ស្លាប់ រស់ មានចំនួនប្រមាណពីរ ពាន់ប្រាំរយ ទៅបីពាន់ប្រាំរយភាសា ។ ក្នុងចំណោមភាសាទាំងនោះ ភាសាវិទូបានធ្វើប្រភេទវិភាគ ចែកភាសាជាក្រុមឬអំបូរ ។ ភាសាដែលអាចស្ថិតនៅក្នុងអំបូរជាមួយគ្នាបាន លុះត្រាតែមានលក្ខណៈ ពិសេសប្រហាក់ប្រហែលគ្នា ។ អំបូរភាសាធំៗមានចំនួ ២០ ដូចជា ៖

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

- អំបូរឥណ្ឌូ-អឺរ៉ុប គឺជាអំបូរភាសាមួយទូលំទូលាយក្នុងបណ្ដាអំបូរភាសាក្នុងលោកគ្របដណ្ដប់លើទ្វីបអឺរ៉ុបស្ទើរតែទាំងអស់និងលើមួយភាគធំនៃប្រទេសឥណ្ឌា ។
- អំបូរខ្មែរ-មន គឺជាអំបូរធំសំខាន់មួយនៅទ្វីបអាស៊ីអាគ្នេយ៍ ។
- អំបូរម៉ាឡាយូ-ប៉ូលីនេស៊ី គឺជាអំបូរធំគួរសមស្ថិតនៅតាមកោះ និងនៅទៀបកោះក្នុងភាគខ្លះនៃមហាសមុទ្រប៉ាស៊ីហ្វិកនិងមហាសមុទ្រឥណ្ឌា ។

ចំពោះភាសាខ្មែរយើង តើមានប្រភពវិវឌ្ឍន៍និងលក្ខណៈពិសេសយ៉ាងណាទៅ ?

យើងបានដឹងហើយថា ភាសាមានកំណើតដំណាលគ្នានឹងកំណើតមនុស្ស យ៉ាងណាមិញប្រវត្តិសាស្ត្រខ្មែរបានបញ្ជាក់ថា ជាតិសាសន៍ខ្មែរមានយូរយារណាស់មកហើយ (ប្រមាណ៥០០០ឆ្នាំមុន គ.ស) ជាជាតិសាសន៍ដែលធ្លាប់មានអរិយធម៌រុងរឿងក្នុងចំណោមជាតិសាសន៍ដទៃក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ។ ដូច្នេះ ភាសាខ្មែរដែលមានប្រភពជាប់គ្នានឹងជាតិកំណើតមនុស្សខ្មែរ ក៏កើតមានតាំងពីយូរណាស់មកហើយដែរ ។ ក្រោយពេលដែលបានសិក្សាស្រាវជ្រាវអំពីភាសាខ្មែរអស់ពេលជាយូរមកហើយ ភាសាវិទូបរទេសបានបញ្ចូលភាសានេះ ទៅក្នុងអំបូរភាសាធំមួយក្នុងចំណោមអំបូរភាសានៅទ្វីបអាស៊ីអាគ្នេយ៍ គឺអំបូរខ្មែរ-មននេះឯង ។ តាមលោកពីណូវ អំបូរខ្មែរ-មនជាក្រុមភាសាមួយដែលគួរចាប់អារម្មណ៍ជាងគេក្នុងបណ្ដាភាសាអាស៊ីភាគខាងត្បូង( អំបូរភាសាអូស្ត្រូ-អាស៊ី : អំបូរភាសាម៉ាឡាយូ ប៉ូលីនេស៊ី អំបូរភាសាថៃ វៀតណាម អំបូរភាសាខ្មែរ-មន) ព្រោះជាភាសាដែលមានប្រវត្តិអក្សរប្លែកពីភាសាដទៃទៀត ដែលទើបតែមានភាសាសរសេរ ហើយខ្លះទៀតនៅតែគ្មានអក្សរសរសេរដដែល ។

ចំពោះពាក្យខ្មែរ-មននេះធ្វើឱ្យយើងមានចម្ងល់តទៅទៀតថា តើមនជាអ្វី ? ហើយនៅឯណា? តើមានតែជាតិសាសន៍ខ្មែរនិងមនពីរនេះទេឬដែលនៅក្នុងអំបូរនេះ ។

តាមការស្រាវជ្រាវគេបានដឹងថា នៅក្នុងអំបូរខ្មែរ-មន ពុំមែនមានតែជាតិខ្មែរនិងជាតិមនប៉ុណ្ណោះទេ គឺមានជាតិជាច្រើនទៀត ដែលរស់នៅក្នុងប្រទេសនានានៃអាស៊ីអាគ្នេយ៍ ហើយដែលមានភាសាស្រដៀងគ្នាក្នុងផ្នែកសូរសាស្ត្រ រូបសាស្ត្រ និងនិយណ្ឌសាស្ត្រ។ ឯជនជាតិទាំងនោះមានជាអាទិ៍ ៖

- សេណូយសេម៉ាង ... នៅសហព័ន្ធម៉ាឡេស៊ីយ៉ា ។
- ប៉ាឡោងវ៉ា ... នៅប្រទេសភូមា ។
- ខ្មុ អាឡាក់ល្មិត ... នៅប្រទេសឡាវ ។
- ស្ទៀង កួយ ព័រ ស្អូច ជង ពង្ង ... នៅប្រទេសខ្មែរ ។
- ម្នង បាហ្នារ សេដង់ព្រុ ... នៅប្រទេសវៀតណាម ។

ក្នុងចំណោមជនជាតិទាំងនោះមានតែជនជាតិខ្មែរនិងមនទេ ដែលមានអរិយធម៌ខ្ពង់ខ្ពស់ជាងគេ ពីព្រោះជនជាតិទាំងពីរនេះរស់នៅត្រង់តំបន់វាលទំនាបនៃទន្លេដែលមានដីជាតិអាចប្រកបរបរកសិកម្មបានយ៉ាងប្រសើរ ហើយមានទំនាក់ទំនងជាមួយនឹងបរទេសជាច្រើនថែមទៀត។ ជនជាតិខ្មែររស់នៅត្រង់តំបន់វាលទំនាបនៃទន្លេមេគង្គ ឯជនជាតិមនរស់នៅត្រង់តំបន់មេណាម (ប្រទេសសៀម)និងតំបន់វាលទំនាបនៃទន្លេឥរាវតី (ប្រទេសភូមាសព្វថ្ងៃ)។ ឯជនជាតិក្រៅពីនេះច្រើនរស់នៅតាមព្រៃភ្នំ។ អាស្រ័យដោយអរិយធម៌នៃជនជាតិខ្មែរនិងមនលូតលាស់រុងរឿងនេះហើយ ទើបគេនិយមប្រើពាក្យ មន-ខ្មែរ (តាមទស្សនៈអ្នកប្រាជ្ញបរទេស) ឬខ្មែរ-មន (តាមទស្សនៈខ្មែរ) ដូចពាក្យអំបូរខ្មែរ-មន អរិយធម៌ខ្មែរ-មនជាដើម។ ប៉ុន្តែចាប់ពីសតវត្សទី ១៦មក ជនជាតិមនក៏បានបាត់បង់ទឹកដី និងអធិបតេយ្យរបស់ខ្លួនរហូតមក ដូចជនជាតិចាមសព្វថ្ងៃនេះដែរ។

ចំពោះកំណកំណើតភាសាខ្មែរ ដែលមានជីវិតរហូតមកដល់បច្ចុប្បន្ននេះអ្នកប្រាជ្ញខាងភាសាបានសង្កេតឃើញថា មានវិវឌ្ឍន៍បីលើកធំៗគឺ

- ភាសាខ្មែរបុរាណ (តាំងពីកំណកំណើតដល់សតវត្សទី ១៥)
- ភាសាខ្មែរកណ្តាល (សតវត្សទី ១៦ ដល់ សតវត្សទី ១៩)
- ភាសាខ្មែរបច្ចុប្បន្ន (សតវត្សទី ២០ ...)

នៅសម័យអាណាព្យាបាលបារាំង ការវិវឌ្ឍនៃភាសាខ្មែរត្រូវបានបន្ថយល្បឿន ហើយរត់ទៅសម្ងំក្នុងវត្តអារាមដែលមានព្រះសង្ឃជួយថែរក្សា។ គេបង្ខំឱ្យរៀនភាសាបារាំងជាយានជាផ្លូវការ ដែលជាបុព្វហេតុនាំឱ្យខូចប្រយោជន៍ដល់ភាសាជាតិឯង។

នៅសម័យឯករាជ្យ ភាសាខ្មែរត្រូវបានប្រកាសឱ្យប្រើជាផ្លូវការ។ កំណើតគណៈកម្មការវប្បធម៌ មហាវិទ្យាល័យគរុកោសល្យ (អតីតវិជ្ជាស្ថានជាតិគរុកោសល្យ) មហាវិទ្យាល័យអក្សរសាស្ត្រវិជ្ជាស្ថានជាតិខេមរយានកម្មជំរុញឱ្យមានការបង្កើតពាក្យពេចន៍ថ្មីៗជាច្រើនទៀត ដើម្បីប្រើការឱ្យទាន់សម័យនិយម។ ក្រៅពីកំណើតពាក្យបង្កើតថ្មី គេប្រទះឃើញពាក្យបរទេសជាច្រើននៅលាយឡំក្នុងភាសាខ្មែរ។

ឯល្បាយភាសានេះ កើតឡើងនៅពេលដែលខ្មែរមានទំនាក់ទំនងជាមួយនឹងបរទេសដូចជាទាក់ទងក្នុងកិច្ចការទូត ទេសចរណ៍ ពាណិជ្ជកម្ម សិក្សាអប់រំ ជំនឿសាសនា។ល។ គេបានកត់សម្គាល់ឃើញថាឥទ្ធិពលបរទេសមានអាយុវែងកាលណាល្បាយភាសាក៏កាន់តែមានច្រើនឡើងៗ សឹងរកពាក្យសុទ្ធរបស់ខ្លួនពុំឃើញ។ ឯភាសាបរទេសដែលនៅលាយឡំច្រើនជាងគេក្នុងភាសាខ្មែរយើងសព្វថ្ងៃ គឺភាសាបាលីនិងសំស្ក្រឹត។ ភាសាបាលីហូរចូលមកក្នុងភាសាខ្មែរតាមរយៈពុទ្ធសាសនាហីនយាន

ឯភាសាសំស្ក្រឹតហូរចូលតាមរយៈពុទ្ធសាសនាមហាយាននិងព្រាហ្មណ៍សាសនា ។ ជនជាតិខ្មែរយើងនិយមគោរពសាសនាឥណ្ឌា ទាំងនេះហើយបានជាភាសាបាលីសំស្ក្រឹតព្រមទាំងក្បួនខ្នាតវេយ្យាករណ៍មានឥទ្ធិពលខ្លាំងក្លាមកលើភាសាខ្មែរ ហើយចាក់ឫសគល់មកដល់សព្វថ្ងៃ ។ ការណ៍នេះជាហេតុនាំឱ្យអ្នកខ្លះដែលមើលលក្ខណៈដើមនៃភាសាខ្មែរពុំឃើញ ហើយក៏តាំងចោទថាភាសាខ្មែរមានប្រភពពីបាលីសំស្ក្រឹត ។ ការពិតភាសាទាំងពីរនេះចូលមកក្រោយពេលដែលខ្មែរមានភាសាផ្ទាល់ខ្លួនរួចស្រេចទៅហើយ ។ ដូច្នេះភាសាខ្មែរពុំមែនកើតចេញមកពីភាសាបាលី សំស្ក្រឹត ឬភាសាបាលី សំស្ក្រឹតជាម្ដាយនៃភាសាខ្មែរដូចទស្សនៈរបស់លោក **j.Taupin** នោះទេ ។ ខ្មែរប្រើពាក្យបាលីសំស្ក្រឹតជាពាក្យកម្ចីដើម្បីបង្គ្រប់នូវកង្វះខាតតែប៉ុណ្ណោះ ។ រីឯពាក្យបាលីសំស្ក្រឹតនេះសោត ក៏ត្រូវកែប្រែទាំងសូរស័ព្ទ ទាំងរូបស័ព្ទដើម្បីឱ្យស្របស្រួលមកនឹងសម្ដីខ្មែរ ចំណង់ចំណូលចិត្តខ្មែរ ។ ខេមរនីយកម្មបែបនេះ ពុំមែនធ្វើចំពោះតែពាក្យបាលី សំស្ក្រឹតប៉ុណ្ណោះទេ ភាសាបរទេសដទៃទៀត ដែលជ្រាបចូលមកក្នុងភាសាខ្មែរត្រូវទទួលការផ្លាស់ប្ដូរឱ្យមានលក្ខណៈជាខ្មែរដែរ ។ ដូច្នេះភាសាបាលី សំស្ក្រឹតស្ថិតនៅដាច់អំពីអំបូរខ្មែរ-មន ព្រោះមានវិភត្តិដូចភាសានៃជនជាតិអឺរ៉ុបដែរ ។ វាស្ថិតនៅក្នុងអំបូរឥណ្ឌូ-អឺរ៉ុបឯណោះទេ ។ ចំពោះភាសាខ្មែរ បើយើងសិក្សាឱ្យស៊ីជម្រៅលើក្បួនខ្នាតវេយ្យាករណ៍ យើងឃើញថា វាមានលក្ខណៈខុសគ្នាពីបរទេស ពិសេសភាសាបាលី សំស្ក្រឹត ។ ភាពខុសគ្នានោះគឺអាស្រ័យភាសាខ្មែរមានលក្ខណៈពិសេសធំៗមួយចំនួនដូចជា ការបន្លឺសំឡេង ចំនួន ស្រៈ ព្យាង្គ ព្យញ្ជនៈ វិធីកម្លាយពាក្យលិង្គ វចនៈ និងក្បួនសម្ព័ន្ធ ។ លក្ខណៈពិសេសនេះបង្ហាញឱ្យឃើញថា ភាសាខ្មែរជាភាសាងាយសិក្សាងាយយល់ជាងពពួកភាសាឥណ្ឌូ-អឺរ៉ុប ។ ការលើកយកលក្ខណៈសំខាន់ៗនៃភាសាខ្មែរមកប្រៀបធៀបនឹងភាសាបរទេសមានភាសាបាលី-សំស្ក្រឹតជាដើម ឃើញថាប្លែកគ្នាទាំងផ្នែកសូរ ផ្នែករូបសព្ទ ផ្នែកសម្ព័ន្ធ ។ ភស្តុតាងទាំងនេះបានបញ្ជាក់ថា ភាសាខ្មែរមានលក្ខណៈពិសេសរបស់ខ្លួន ពោលគឺពុំមែនកើតចេញអំពីភាសាណាមួយឡើយ ។ ទំនាក់ទំនងរវាងខ្មែរនិងបរទេសធ្វើឱ្យមានល្បាយភាសាបរទេសក្នុងភាសាខ្មែរក៏ពិតមែនហើយ ក៏ប៉ុន្តែការទទួលឥទ្ធិពលភាសាបរទេសនេះ តែងប្រព្រឹត្តទៅដោយការកែសម្រួលឱ្យស្របស្រួលទៅនឹងភាសាជាតិជាដរាប តួយ៉ាងដូចជាខេមរនីយកម្មចំពោះភាសាបាលីសំស្ក្រឹតដែលបានពោលនៅខាងលើរួចមកហើយ ។

ប្រសិនបើយើងបានដឹងបានយល់អំពីដើមកំណើតនិងក្បួនខ្នាតដ៏ប្រពៃនៃភាសាជាតិរបស់យើងហើយ តើយើងដែលជាខ្មែរត្រូវមានករណីយកិច្ចបែបណាដែរ ? ទោះបីយើងមានការលំបាកខ្លះក្នុងការសរសេរ ឬនិយាយដោយសារឥទ្ធិពលបរទេសមកលើភាសាយើងយ៉ាងណាក៏ដោយ ក៏យើងត្រូវមានស្មារតីជាតិជានិច្ច លើកតម្កើងភាសាជាតិ ដោយនាំគ្នានិយមប្រើភាសាជាតិក្នុងករណីណាដែល

អាចចៀសវាងភាសាបរទេសបាន ហើយខំការពារភាសាខ្មែរ កុំបង្អាប់កុំខំទាញបញ្ចូលទៅក្នុងក្បួនភាសាបរទេស។ លើសពីនេះទៅទៀតត្រូវខំពង្រឹងនិងពង្រីកឱ្យកាន់តែដុះដាលឡើង។ បើខ្មែរម្នាក់ៗមានស្មារតីជាតិបែបនេះមែន យើងសង្ឃឹមថា ភាសាជាតិយើងមុខជាមានការរីកចម្រើនលូតលាស់ហើយនិងបានជាគ្រឹះយ៉ាងមាំនៃជាតិខ្មែរជាពុំខាន។

*(ដកស្រង់និងកែសម្រួលពីសៀវភៅអរិយធម៌ខ្មែររបស់ លោកស្រី ត្រឹង ងា បោះពុម្ព គ.ស ១៩៧៥)*

## សំណួរ

១. តាមអត្ថបទខាងលើ តើភាសាជាអ្វី ? មានអម្បូរធំៗប៉ុន្មាន ?
២. តើក្នុងអំបូរខ្មែរ-មនមានជនជាតិអ្វីខ្លះ ? នៅឯណាខ្លះ ?
៣. តើភាសាខ្មែរមានអភិវឌ្ឍន៍ធំៗប៉ុន្មានលើកហើយ ?
៤. តើល្បាយភាសាបរទេសនៅក្នុងភាសាខ្មែរកើតឡើងតាមរយៈអ្វីខ្លះ ?
៥. តើភាសាខ្មែរយើងមានលក្ខណៈពិសេសធំៗអ្វីខ្លះដែលខុសប្លែកពីភាសាបរទេស ?
៦. ចូររកតម្លៃអប់រំនៅក្នុងអត្ថបទនេះ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# គុណនាម

អ្នកបានសិក្សារួចហើយអំពី នាម សព្វនាម និងប្រភេទរបស់វា ។ ឥឡូវនេះអ្នកនឹងសិក្សាពីគុណនាមនិងប្រភេទរបស់គុណនាមបន្ថែមទៀត ។ ដូចម្ដេចហៅថាគុណនាម ? តើគុណនាមមានអ្វីខ្លះ ? ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

- វត្តនេះមានទីធ្លាធំទូលាយ ។
- តើវត្តនេះមានព្រះសង្ឃប៉ុន្មានអង្គ ?
- ខ្ញុំធ្វើកិច្ចការផ្ទះយ៉ាងហោចណាស់ពីរម៉ោងមុននឹងខ្ញុំចូលសម្រាន្ត ។
- តុខ្ញុំនៅខាងក្រោយគេបង្អស់ ។
- ខ្ញុំមិនដឹងថាគាត់ត្រូវការសៀវភៅណាមួយទេ ។
- សៀវភៅនេះទើបតែបោះពុម្ពសាឡើងវិញទេ ។

ពាក្យ "ធំ ប៉ុន្មាន ពីរម៉ោង តុខ្ញុំ ណាមួយ នេះ" ជាគុណនាម ។ គុណនាមទាំងនោះមាននាទីផ្សេងៗគ្នានៅក្នុងល្បះនីមួយៗខាងលើ ។ តើគុណនាមមានអ្វីខ្លះ ?

## ១ . គុណនាមប្រក្រតីឬបកតិគុណនាម

គុណនាមនេះសម្រាប់ប្រាប់លក្ខណៈធម្មតា ឬសម្ដែងគុណភាព លក្ខណៈរបស់មនុស្ស សត្វ វត្ថុ ទីកន្លែង ... ។

*ឧទាហរណ៍ :*

- បារីគ្មានផលល្អដល់សុខភាពឡើយ ។
- បារីមួយដើមមានជាតិពុលច្រើន ។
- ដារិនជាក្មេងស្លូតបូត ។
- ព្រះវិហារនេះធំជាងព្រះវិហារវត្តនៅភូមិខ្ញុំ ។

ពាក្យ "ល្អ ច្រើន ស្លូតបូត ធំ" ជាគុណនាមប្រក្រតី ។ គុណនាមប្រក្រតីមានច្រើនដូចជា ខ្ពស់ ទាប ខ្លាំង ខ្សោយ តិច ច្រើន តូច ធំ ស្លូត កាច ខ្មៅ ស ក្រហម ... ។

## ២ . គុណនាមកំណត់

គុណនាមកំណត់សម្រាប់ប្រាប់ការបង្ហាញ សភាព ចម្ងាយ (ច្បាស់ មិនច្បាស់ ជិត ឆ្ងាយ ...) ជាដើម ។ គុណនាមកំណត់មាន ៖

youtube.com/moeys khmou.moeys.gov.kh facebook.com/moeys.gov.kh

## ក. គុណនាមកម្មសិទ្ធិ

គុណនាមកម្មសិទ្ធិបង្ហាញពីម្ចាស់នៃកម្មសិទ្ធិ ។ គុណនាមនេះទាក់ទងនឹងសព្វនាមបុរិសៈ ខ្ញុំ ឯង គេ វា គាត់ យើង អ្នក ... ។ វានៅជាប់ខាងស្តាំនាម ។

*ឧទាហរណ៍ :*

- គោខ្ញុំ សម្បុរខ្មៅរលោង ។
- តុគាត់ វែងជាងតុខ្ញុំ ។

ពាក្យ "ខ្ញុំ គាត់ ខ្ញុំ" ជាគុណនាមកម្មសិទ្ធិ ។ ពាក្យ "ខ្ញុំ គាត់ ខ្ញុំ" កំណត់ម្ចាស់កម្មសិទ្ធិ ។

## ខ. គុណនាមសំណួរ

គុណនាមសំណួរសម្រាប់សួររកសភាពលក្ខណៈចំនួន...ពិតប្រាកដនៃមនុស្ស សត្វ វត្ថុជាដើម ។

*ឧទាហរណ៍ :*

- តើម៉ែអញ្ជើញទៅវត្តណា ?
- តើលោកអញ្ជើញមកដល់ម៉ោងប៉ុន្មាន ?

ពាក្យ "ណា ប៉ុន្មាន" ជាគុណនាមសំណួរ ។ គុណនាមសំណួរមាន អ្វី អ្វីខ្លះ ស្អី អី ណា ណាខ្លះ ប៉ុន្មាន ... ។

## គ. គុណនាមចំនួន

គុណនាមចំនួនបង្ហាញពីចំនួនបរិមាណនិងលំដាប់ ។ គុណនាមចំនួនមានពីរ **គឺចំនួនរៀបនិងចំនួនរាប់** ។

**ចំនួនរៀប** : សំរាប់រាប់ឱ្យដឹង ទី ជាន់ ថ្នាក់ ប៉ុណ្ណោះ ប៉ុណ្ណោះ ។

*ឧទាហរណ៍ :*

- ខ្ញុំរៀនថ្នាក់ទី ១០ ។ ប្អូនខ្ញុំរៀនថ្នាក់ទី ៩ ។
- ចូរប្អូនៗមកសាលារៀនឱ្យបានមុនម៉ោងប្រាំមួយសាមសិបនាទី ។
- តុខ្ញុំនៅជួរទីពីរខាងស្តាំដៃ ។

ពាក្យ "ទី ១០ ទី ៩ ទីពីរ" ជាគុណនាមចំនួនរៀប ។

**ចំនួនរាប់** : សំរាប់រាប់ឱ្យដឹង ប៉ុណ្ណោះ ប៉ុណ្ណោះ ។

*ឧទាហរណ៍ :*

- វត្តនេះមានស្រះទឹកធំៗពីរ ។



youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

- បុប្ផាទិញផ្លែក្រូចប្រាំឡូ ។
- ពុកខ្ញុំយកចេកទុំប្រាំស្ទងទៅប្រគេនលោកនៅវត្ត ។

ពាក្យ "ពីរ ប្រាំឡូ ប្រាំស្ទង" ជាគុណនាមចំនួនរាប់ ។ ចំពោះពាក្យ "ឡូ ស្ទង" យើងហៅថា រនាប់ ។ រនាប់មានដូចជា ដើម ស្លឹក ឡូ ស្ទង ផ្លូន ឆ្នាំ ខែ ... ។ រនាប់នៅជាប់ខាងស្ដាំចំនួនរាប់ ។ រនាប់មានទម្រង់ ៖

- នាម + ចំនួនរាប់ + រនាប់ ។ ***ឧទាហរណ៍ :*** ស្រូវមួយដឹក ខ្មៅដៃមួយដើម ។
- ចំនួនរាប់ + រនាប់ ។ ***ឧទាហរណ៍ :*** បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ... ។

## ឃ. គុណនាមចង្អុល

គុណនាមចង្អុលសម្រាប់ប្រាប់បង្ហាញកំណត់ចង្អុលនៅទីជិតឬទីឆ្ងាយក្នុងស្ថានភាពបែបណាមួយ ។

***ឧទាហរណ៍ :*** ចំការនេះជាចំការពោត ឯចំការនោះជាចំការឪឡឹក ។

ពាក្យ "នេះ នោះ" ជាគុណនាមចង្អុល ។

**ជិត** : នេះ ណេះ ទីនេះ ឯណេះ ... ។

**ឆ្ងាយ** : នោះ ទីនោះ ណោះ ឯណោះ ... ។

## ង. គុណនាមមិនច្បាស់

គុណនាមមិនច្បាស់ប្រាប់សេចក្ដីមិនជាក់លាក់ មិនប្រាកដ ។

***ឧទាហរណ៍ :***

- ខ្ញុំមិនដឹងថាគាត់ជក់បារីតាំងពីពេលណាមកទេ ទើបធ្វើឱ្យគាត់មានជំងឺសួតធ្ងន់ធ្ងរដូចនេះ ។
- ខ្ញុំរកវិធីផ្សេងទៀតដើម្បីផ្ដាច់ការជក់បារី ។
- ពួកគេទាំងអស់ ជាសិស្សពូកែ ។

ពាក្យ "ពេលណា ផ្សេងទៀត ទាំងអស់" ជាគុណនាមមិនច្បាស់ ។ គុណនាមមិនច្បាស់មាន ដូចជា អ្វី អ្វីមួយ ណា ណាមួយ ណាខ្លះ ខ្លះ ដទៃ ទាំងអស់ ... ។

យើងឃើញថាគុណនាមមានលក្ខណៈផ្សេងគ្នាទៅតាមប្រភេទនីមួយៗ ។

*គុណនាម គឺជាសម្ដីសម្រាប់សម្ដែងសភាពលក្ខណៈរបស់នាម ។ គុណនាមមានគុណនាមប្រក្រតី គុណនាមកម្មសិទ្ធិ គុណនាមសំណួរ គុណនាមចំនួន គុណនាមចង្អុល និងគុណនាមមិនច្បាស់ ។*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## លំហាត់

១. ចូរស្រង់គុណនាមក្នុងល្បះខាងក្រោមដោយប្រាប់ប្រភេទរបស់វា ៖

- ការជក់បារីនាំឱ្យរាងកាយចុះស្គមនិងខ្សោយកម្លាំង ។
- នៅក្នុងក្រោលនេះមានគោឈ្មោលប្រាំនឹម ។ គោញីបីក្បាលនិងកូនគោម្ភៃក្បាល ។
- ប្អូនសុខឈរទីមួយ ។ ប្អូនសៅឈរទីពីរ ។ បូផាឯងឈរគម្រប់បី ។ ឯកុមារនោះឈរគំរប់បួន ។
- តើប្អូនទៅរៀនសាលាណា ?
- សៀវភៅនេះជារបស់ឯង ឯសៀវភៅនោះជារបស់ខ្ញុំ ។
- ក្មេងៗពុំចូលចិត្តអានសៀវភៅណាដែលនាំទៅរកផ្លូវខុសទេ តែគេចូលចិត្តសៀវភៅណាដែលនាំឱ្យចម្រើន ។

២. អត្ថបទ

ចូរអ្នកស្រង់យកគុណនាមក្នុងអត្ថបទដោយប្រាប់ប្រភេទរបស់វាផង ៖

នៅប្រទេសកម្ពុជាក្នុងរយៈពេលដ៏ខ្លីកន្លងមកនេះ ការហូរចូលនៃបារីគ្រប់ប្រភេទគួរឱ្យរន្ធត់ពន់ពេក ។ បារីទាំងអស់នេះបានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុនិងទូរទស្សន៍យ៉ាងគគ្រឹកគគ្រេង ។ អ្នកទស្សនាកម្មវិធីខ្សែភាពយន្ត កីឡា សិល្បៈផ្សេងៗ ជួនកាលមានការធុញទ្រាន់នឹងការផ្សព្វផ្សាយពាណិជ្ជកម្មបារីនេះច្រើនដង ។ អ្នកជក់បារីនៅប្រទេសកម្ពុជាមានស្ទើរតែគ្រប់គ្រួសារ ឯកុមារអាយុ ១៥ឆ្នាំក៏មានអ្នកជក់បារីច្រើន ។ គេសង្កេតឃើញថា បារីសម្បូរបែបឯអ្នកជក់ក៏មានច្រើនមិនតិចដែរ ។

ផ្ទុយទៅវិញនៅប្រទេសយើងក៏មានករណីហាមជក់បារីដែរ ។ នៅពេលជាមួយគ្នានេះដែរ ក្រុមហ៊ុនបារីត្រូវបានបញ្ជាឱ្យបោះពុម្ពបម្រាមលើកញ្ចប់បារីរបស់ខ្លួនថា **ការជក់បារីនាំឱ្យខូចសុខភាព** ដើម្បីឱ្យសាធារណជនដឹង ។ អ្នកជក់បារីមានគ្រោះថ្នាក់ច្រើនប្រការ ។ ជំងឺដែលមានប្រភពមកពីការជក់បារីគឺមហារីកសួត ជំងឺបេះដូង ជាពិសេសស្ត្រីមានផ្ទៃពោះហើយជក់បារីនាំឱ្យមានគ្រោះថ្នាក់ដល់ទារកក្នុងផ្ទៃយ៉ាងខ្លាំងក្លា ។

# រឿង សិរិធរ

ចូរអ្នកស្តាប់អត្ថបទរឿង សិរិធរ (ក្នុងបញ្ញាសជាតក) ហើយឆ្លើយនឹងសំណួរខាងក្រោម ៖



## សំណួរ

១. តើសេដ្ឋីសិរិធរជាមនុស្សដូចម្តេច ?

២. តើគាត់បានប្រគេនអ្វីដល់ព្រះបច្ចេកពុទ្ធ ? តើគាត់បានទទួលផលល្អអ្វីខ្លះ ?

៣. ចូរបង្ហាញកាលអាកាសនៅក្នុងអត្ថបទ ។

៤. តើរឿងសិរិធរស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ណា ?

៥. តើអត្ថបទនេះបង្ហាញខ្លឹមសារអ្វីខ្លះ ?

facebook.com/moeys.gov.kh krou.moeys.gov.kh



# ការបញ្ចេញមតិគាំទ្រ

ការបញ្ចេញមតិមានការបញ្ចេញមតិគាំទ្រ ឬយល់ស្រប បញ្ចេញមតិជំទាស់ ឬប្រឆាំងនឹងសំយោគ ។ ដូចម្តេចហៅថា ការបញ្ចេញមតិគាំទ្រ ?

ការបញ្ចេញមតិគាំទ្រ គឺជាការបង្ហាញគំនិតយោបល់ ការយល់ឃើញ ទស្សនៈរបស់នរណាម្នាក់ចំពោះមតិ គំនិត យោបល់ ទស្សនៈ សកម្មភាព ... របស់អ្នកដទៃ ។

ខាងក្រោមនេះជាការបញ្ចេញមតិគាំទ្រមួយ ៖

សន្តិភាពគឺជាបំណងប្រាថ្នារបស់មនុស្សជាតិដែលឆ្ពោះទៅរកភាពអហិង្សា គ្មានទំនាស់ និងអភិវឌ្ឍ ។ ឯព្រះពុទ្ធសាសនាក៏មាននាទីសំខាន់ដោយបានអប់រំពន្យល់ពុទ្ធបរិស័ទឱ្យពត់ចិត្តគំនិតដើម្បីឈានទៅរកសេចក្តីសុខសន្តិភាពដែរ ។

សន្តិភាពបានដល់ភាពស្រួលកាយនិងចិត្តដែលគ្មានទំនាស់វិបត្តិជាឧបសគ្គណាមួយមករារាំងចិត្តនោះទេ ។ ឯអប់រំ គឺជាការទូន្មានប្រៀនប្រដៅ ហើយពុទ្ធបរិស័ទជាអ្នកកាន់ ឬគោរពបូជាសាសនាព្រះពុទ្ធ ។ មានន័យថា ការទូន្មានប្រៀនប្រដៅនៃព្រះពុទ្ធដែលមានលក្ខណៈជាពុទ្ធសាសនា គឺចង់ជំរុញឱ្យអ្នកស្តាប់ដំបូន្មានព្រះពុទ្ធបានទទួលការអប់រំខាងផ្លូវកាយនិងចិត្តដោយខ្លួនឯងដើម្បីស្វែងរកសេចក្តីសុខសន្តិភាព ។

ទស្សនៈអប់រំនៅក្នុងពុទ្ធសាសនាមានលក្ខណៈអហិង្សា គឺការមិនចងកំហឹងមិនត្រូវយកកំហឹងទៅដោះស្រាយបញ្ហាទេ ។ មានន័យថាគេមិនត្រូវបៀតបៀនគ្នា ដោយការចងគំនុំគុំគួនគ្នាទៅវិញទៅមកឡើយ ។ យ៉ាងណាមិញគេត្រូវចេះកសាងសេចក្តីល្អ សង្គ្រោះគ្នាដោយការឱ្យជាទាន ជាអំណោយគ្រប់បែបយ៉ាងនិងការហាត់ពត់ចិត្តឱ្យបានស្អាតស្អំល្អប្រសើរឡើង ។ គោលដៅនៃការប្រៀនប្រដៅនេះបើគេធ្វើការសង្ខេបមកមានបីចំណុចសំខាន់ៗ គឺទីមួយទ្រង់ហាមធ្វើអ្វីដែលបានបាបជាអំពើអាក្រក់ដល់គ្នានឹងគ្នាជាហេតុនាំឱ្យមនុស្សជួបគ្នាមានទុក្ខ ទារុណកម្ម វេទនា ខ្លោចផ្សាគ្រប់បែបយ៉ាង ។ ទីពីរគឺទ្រង់ឱ្យបំពេញអំពើណាដែលជាកុសល ជាសេចក្តីល្អដល់គ្នានឹងគ្នា ដោយសាងអំណោយទាន ។ ឯចំណុចទីបីទ្រង់ឱ្យធ្វើចិត្តឱ្យស្អាតស្អំ ប្រាសចាកអំពើសៅហ្មង កុំឱ្យមានគំនិតគុំគួន ឬព្យាបាទចងកំហឹងគ្នាឡើយ ។ ដំបូន្មានចុងក្រោយនេះជាទស្សនៈអប់រំមួយដែលមានគោលដៅចង់ឱ្យពុទ្ធបរិស័ទធ្វើចិត្តឱ្យល្អ មានគំនិតខ្ពស់លើសផុតពីអំពើសៅហ្មងនេះតែម្តង ។

សរុបមក សន្តិភាពដែលគេសាងឡើងតាមរយៈព្រះពុទ្ធសាសនាអាចជួយសង្គមមនុស្សឱ្យកាត់បន្ថយទំនាស់ ស្ងប់ស្ងាត់គ្មានហិង្សា ជាពិសេសធ្វើឱ្យមនុស្សមានទឹកចិត្តស្រឡាញ់និងរាប់អានគ្នាផង ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## សំណួរ

១. តើប្រធានបទនៃអត្ថបទនេះនិយាយពីអ្វី ?

២. តើទស្សនៈអប់រំនៅក្នុងពុទ្ធសាសនាមានលក្ខណៈដូចម្ដេចខ្លះ ?

៣. គោលដៅនៃការប្រៀនប្រដៅតាមព្រះពុទ្ធសាសនា បើគេធ្វើការសង្ខេប តើមានប៉ុន្មានចំណុច ? គឺអ្វីខ្លះ ?

៤. ក្នុងចំណោមជំបូន្មានទាំងបី តើជំបូន្មានមួយណាដែលមានទស្សនៈអប់រំល្អជាងគេ ?

## លំហាត់

ចូរអ្នកជ្រើសរើសប្រធានមួយក្នុងចំណោមប្រធានបទខាងក្រោម ដើម្បីនិយាយបញ្ចេញមតិដោយរកអំណះអំណាងមកបញ្ជាក់ឱ្យសមស្រប ៖

១. អំពើអហិង្សា ជាប្រភពនៃការអភិវឌ្ឍសង្គម ។

២. ការគោរពសិទ្ធិមនុស្ស ជាសុវត្ថិភាពរបស់ពលរដ្ឋ ។

៣. សប្បុរសធម៌រួមចំណែកកាត់បន្ថយទុរគតភាពក្នុងសង្គម ។

ក្នុងការនិយាយបញ្ចេញមតិយោបល់អ្នកត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម ៖

១. ស្វែងយល់ន័យនៃប្រធានបទដែលអ្នកបានជ្រើសរើស ។

២. បញ្ចេញមតិយោបល់ទៅលើប្រធានបទដោយផ្ដល់អំណះអំណាងឱ្យសមហេតុផលដើម្បីគាំទ្រគំនិតសំខាន់នីមួយៗ ។

៣. គោរពតាមក្បួនតែងសេចក្ដី គឺមានសេចក្ដីផ្ដើម តួសេចក្ដី និងបញ្ចប់សេចក្ដី ។

៤. ចៀសវាងការប្រើពាក្យមិនពីរោះចំពោះអ្នកដែលមានមតិខុសពីយើង ។

៥. បញ្ចេញមតិដោយប្រើពាក្យពេចន៍ ឃ្លា ល្បះ ឱ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ។

៦. រាល់ការបញ្ចេញមតិត្រូវចេះប្រើសំនួនឱ្យបានត្រឹមត្រូវ ។

youtube.com/moeys
facebook.com/moeys.gov.kh

# តែងសេចក្តីពន្យល់

តែងសេចក្តីពន្យល់ គឺជាការអធិប្បាយស្រាយបំភ្លឺបកស្រាយមតិគំនិតរបស់នរណាម្នាក់ ទស្សនៈរបស់អ្នកប្រាជ្ញណាម្នាក់ សុភាសិត ពាក្យស្លោក ... ឬបង្ហាញការយល់ឃើញរបស់ខ្លួនផ្ទាល់ស្របតាមគំនិតរបស់ប្រធាន ។ ក្នុងការពន្យល់អ្នកត្រូវវិភាគរកហេតុផលមកធ្វើជាអំណះអំណាង ហើយប្រើសិល្បវិធីឱ្យគេយល់ច្បាស់ពីខ្លឹមសារ អត្ថន័យនៃមតិគំនិតទស្សនៈ ឬបញ្ហានោះ ។

ចូរអ្នកអានសំណេរខាងក្រោមនេះ ៖

ប្រធាន : គេពោលថា "ការបំបរបង់ព្រះរាមចេញពីនគររយៈពេលដប់បួនឆ្នាំ គឺដោយសារពាក្យសត្យ" ។

ចូរអ្នកបកស្រាយពំនោលខាងលើនេះ ។

## សេចក្តីអធិប្បាយ

នាពេលបច្ចុប្បន្ននេះ ស្នាដៃអក្សរសិល្ប៍មួយចំនួនធំត្រូវបានក្រសួងអប់រំដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ។ ក្នុងនោះស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមច្រើនលើកយកបញ្ហាបុណ្យ បាប កម្មពៀរវេរាមកចោទនិងធ្វើការដោះស្រាយតាមពុទ្ធបញ្ញត្តិ ។ ចំណែករឿងខ្មែរបែបព្រាហ្មណ៍និយមវិញ ច្រើនតែលើកយកឫទ្ធិសម្តែងបាដិហារ្យ ឬប្រពៃណី និងបញ្ហាសច្ចធម៌ជាដើម ។

ហេតុដូចនេះហើយ បានជាតាមរយៈរឿងរាមកេរ្តិ៍ខ្មែរមានពំនោលមួយពោលថា "ការបំបរបង់ព្រះរាមចេញពីនគរចំនួនដប់បួនឆ្នាំ គឺដោយសារពាក្យសត្យ" ។

តើរឿងរាមកេរ្តិ៍ឆ្លុះបញ្ចាំងបញ្ហានេះដូចម្តេចខ្លះ ?

ដើម្បីជាជំនួយដល់ការបំភ្លឺចំពោះបញ្ហារបស់ប្រធានខាងលើ ជាបឋមគប្បីស្វែងយល់ពីពាក្យសត្យជាមុនសិន ។

ពាក្យសត្យមានន័យថា ដំណើរទៀងទាត់ សេចក្តីពិត ឬសច្ចៈ ។ បើពិនិត្យតាមដំណើររឿងរាមកេរ្តិ៍ខ្មែរឃើញថា ក្រោយពេលដែលព្រះរាមបានទទួលជោគជ័យក្នុងការលើកធ្នូសិល្ប៍នៅនគរមិថិលា ហើយបានព្រះនាងសីតាធ្វើជាមហេសីមក ព្រះបាទទសរថបានជំនុំអស់អាមាត្យ មន្ត្រី កវី បណ្ឌិត ហោរាបម្រុងនឹងលើករាជសម្បត្តិឱ្យទៅព្រះរាមឡើងសោយរាជ្យស្នងបន្តពីព្រះអង្គតរៀងទៅ ។ ប៉ុន្តែនៅពេលនោះព្រះនាងកៃកេសីជាមហេសីចុងបានក្រោកទូលជំទាស់ដាច់អហង្ការ ព្រមទាំងសំណូមពរឱ្យព្រះរាមចេញទៅក្រៅនគរថែមទៀតផង ។ សភាពការណ៍បែបនេះបង្កើតបានជាទំនាស់ដ៏ធំមួយឡើង រវាងព្រះបាទទសរថ ព្រះរាមជាមួយនឹងនាងកៃកេសី ពោលគឺបញ្ហារាជសម្បត្តិបានចោទឡើង ។

ក្នុងរឿងនេះ គេមានចម្ងល់ថា ហេតុអ្វីបានជាព្រះបាទទសរថត្រូវលើករាជសម្បត្តិឱ្យព្រះរាមសោយរាជ្យស្នង ? ហើយបណ្ដាលមកពីបុព្វហេតុអ្វីដែរបានជានាងកៃកេសីទូលជំទាស់បែបនេះ ? តាមធម្មតាក្នុងវង្សត្រកូលក្សត្រ គេគោរពប្រពៃណីមួយធំសំខាន់ណាស់គឺ ប្រពៃណីតម្រូវឱ្យព្រះរាជបុត្រច្បងឡើងសោយរាជ្យស្នងព្រះបិតាមុនគេ ។ ដូចនេះព្រះរាមជាបុត្រច្បងត្រូវមានបុព្វសិទ្ធិទទួលរាជសម្បត្តិបន្តពីវររាជបិតាមុនព្រះអនុជឯទៀតៗ ។ ប្រការនេះ គឺពុំអាចមាននរណាហ៊ានជំទាស់ ឬពោលរិះគន់បានឡើយ ។ ប្រសិនបើ ព្រះបាទទសរថធ្វើខុសប្រពៃណីបែបនេះប្រជារាស្ត្រមន្ត្រីគ្រប់ជាន់ថ្នាក់ទូទាំងនគរប្រាកដជារិះគន់ព្រះអង្គជាក់ពុំខាន ។ ប៉ុន្តែហេតុការណ៍នេះបែរជាមហេសីកៃកេសីជំទាស់យ៉ាងខ្លាំងក្លាទៅវិញ ។ តើនាងប្រឆាំងនឹងច្បាប់ប្រពៃណីឬ ?

បើមើលមួយភ្លែតប្រាកដជាយល់ឃើញថា កៃកេសីនាងជំទាស់នឹងស្វាមីព្រោះតែនាងមានការលោភលន់ចង់បានរាជសម្បត្តិនេះឱ្យទៅព្រះភិរុតជាបុត្ររបស់នាងជាពុំខាន ។ ការយល់បែបនេះក៏ត្រឹមត្រូវខ្លះៗដែរ ។ ប៉ុន្តែការដែលសំខាន់នោះ គឺពាក្យសត្យ ឬពាក្យសច្ចៈ ។ កាលកន្លងទៅហើយ នៅពេលដែលព្រះបាទទសរថច្បាំងឈ្នះស្ដេចអាទិត្យសូរ្យា (សុរិយា) ដោយសារតែអន្តរាគមន៍ដ៏ប្រពៃរបស់នាងកៃកេសី ហើយក្នុងបំណងតបស្នងសងគុណមហេសីចុងនោះក៏បានសន្យាថាព្រះអង្គនឹងប្រគល់រាជសម្បត្តិនេះដល់ព្រះភិរុតដែលត្រូវជាអនុជរួមបិតានឹងព្រះរាម ។

ដូចនេះ បើតាមពាក្យសន្យា រាជសម្បត្តិ គឺពិតត្រូវបានទៅព្រះភិរុតមិនត្រូវបានទៅព្រះរាមនោះទេ ទោះជាព្រះរាមជាបុត្រច្បងក៏ដោយ ។ ហេតុនេះ ទើបនាងកៃកេសីទូលជំទាស់ គឺជំទាស់ក្នុងនាមនៃសច្ចធម៌ ។ ឥឡូវបញ្ហាបាននិងកំពុងតែចោទឡើងធំទៅៗ ហើយបើគោរពតាមប្រពៃណីគេត្រូវបោះបង់ពាក្យសច្ចៈ ហើយបើគោរពពាក្យសច្ចៈត្រូវតែបោះបង់ប្រពៃណីពោល គឺពុំអាចគោរពទាំងពីរនេះបានឡើយ ។ តើគេសម្រេចបែបណាទើបដោះស្រាយបញ្ហានេះបាន ?

គ្រាដំបូងគេឃើញព្រះរាមដែលធ្លាប់តែមានឫទ្ធិអំណាចមិនដែលចុះចាញ់នរណាម្ដងនោះ ពេលនោះបែរជាសុខចិត្តចាកចេញពីនគរទៅនៅក្នុងព្រៃតាមសំណើនាងកៃកេសី ដើម្បីទុកឱ្យវរបិតាមានលទ្ធភាពគោរពពាក្យសច្ចៈរបស់ព្រះអង្គដោយលើករាជសម្បត្តិឱ្យទៅព្រះភិរុត ។ ត្រង់នេះ គឺដោះស្រាយបានផ្នែកសច្ចធម៌ តែបញ្ហាប្រពៃណីពុំទាន់បានដោះស្រាយនៅឡើយ ។

នៅពេលដែលព្រះភិរុតមកដល់នគរដឹងហេតុការណ៍សព្វគ្រប់ក៏បដិសេធពុំព្រមទទួលរាជ្យតាមមាតាបិតាទេ ព្រោះព្រះអង្គត្រូវគោរពប្រពៃណីរបស់ដូនតា ។ ដូចនេះ ព្រះអង្គត្រូវមានកាតព្វកិច្ចទៅសុំយាងព្រះរាមពីព្រៃឱ្យមកសោយរាជ្យវិញ ។ ប៉ុន្តែព្រះរាមពុំព្រមយាងមកទេ ព្រោះព្រះអង្គបានប្ដេជ្ញារួចហើយថាមិនមកសោយរាជ្យមុនពេលគ្រប់កំណត់ដប់បួនឆ្នាំនោះឡើយ ។ នេះក៏ចាត់ទុកថាជាពាក្យសច្ចៈរបស់ព្រះរាមផងដែរ ។

ដោយមានបំណងដោះស្រាយបញ្ហារាជសម្បត្តិនិងដោយមានការអង្វរខ្លាំងពេករបស់ព្រះអនុជ ព្រះរាមក៏ព្រមប្រគល់សុពណ៌បាទដល់ព្រះភិរុតជានិមិត្តរូបនៃការប្រគល់ឆន្ទៈរបស់ព្រះអង្គឱ្យអនុជវិល ទៅនគរសោយរាជ្យជំនួសព្រះអង្គ ។ ពេលនេះឃើញថា បញ្ហារាជសម្បត្តិបានដោះស្រាយទៅតាមការ គោរពទាំងប្រពៃណី ទាំងសច្ចធម៌ ពោលគឺប្រពៃណីក៏ត្រូវបានគេគោរព រីឯសច្ចធម៌ក៏ត្រូវបានគេ គោរពដែរ ។

រួមសេចក្ដីមក សច្ចធម៌និងប្រពៃណីក្នុងទ្រឹស្ដីព្រាហ្មណ៍និយម ក៏ដូចជាក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ បែបព្រាហ្មណ៍និយមបានត្រូវគេឱ្យតម្លៃខ្ពស់ ដូចឧទាហរណ៍ខាងលើ ។ ដូចនេះ ការបំបរបង់ព្រះរាម ចេញពីនគររយៈពេលដប់បួនឆ្នាំ គឺជាការគោរពពាក្យសត្យ ។

ជាយោបល់បញ្ចប់ បញ្ហាដែលគេឱ្យតម្លៃក្នុងទស្សនៈព្រាហ្មណ៍និយមមិនមែនត្រឹមតែពាក្យសត្យ ឬសច្ចធម៌ និងប្រពៃណីប៉ុណ្ណោះទេ ការពិតឫទ្ធិអំណាច បាដិហារ្យ ភាពអស្ចារ្យជាច្រើនទៀតក៏ត្រូវ បានផ្ដល់ការឱ្យតម្លៃដ៏ខ្ពស់ដែរ ។

ហេតុនេះ កាលណាយើងសិក្សារឿងរាមកេរ្ដិ៍ យើងតែងបានយល់ដឹងពីបញ្ហាទ្រឹស្ដីសំខាន់ៗក្នុង សាសនាព្រាហ្មណ៍និយម ដែលបានទុកជាកេរមរតកយ៉ាងច្រើន រហូតប្រជាជនខ្មែរបានយកពិធីខ្លះៗ មកអនុវត្តទៅជាទំនៀមទម្លាប់សម្រាប់សង្គមជាតិដរាបដល់សព្វថ្ងៃ ដូចជាការរៀបអាពាហ៍ពិពាហ៍បង ត្រូវការមុនប្អូនជាដើម ។

## សំណួរ

១. តើសំណេរខាងលើនេះនិយាយពីអ្វី ? ហើយមានផ្នែកសំខាន់ៗអ្វីខ្លះ ?

២. តើកថាខណ្ឌទី១ របស់សំណេរបង្ហាញពីអ្វី ?

៣. តើក្នុងតួសេចក្ដីមានប៉ុន្មានកថាខណ្ឌ ? កថាខណ្ឌនីមួយៗនិយាយពីអ្វី ?

៤. តើសេចក្ដីបញ្ចប់នៃសំណេរនេះនិយាយពីអ្វី ?

## លំហាត់

១. ចូរបកស្រាយបំភ្លឺទស្សនៈដែលយល់ថា "អំពើហិង្សានាំឱ្យគ្រួសារបាត់បង់សុភមង្គល" ។

២. ចូរពន្យល់ទស្សនៈដែលថា "សេរីភាព គឺជាបំណងប្រាថ្នារបស់មនុស្ស" ។

៣. ទស្សនៈមួយយល់ថា "ការគោរពច្បាប់នាំឱ្យសង្គមជាតិមានការអភិវឌ្ឍ" ។ ចូរពន្យល់ ។

នៅពេលធ្វើតែងសេចក្តីពន្យល់ អ្នកត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម ៖

## ១ . ផ្តើមសេចក្តី

- លំនាំបញ្ហា : ដោយនិយាយឱ្យទាក់ទងនឹងប្រធានបទ ។
- ចំណូលបញ្ហា : ដោយលើកយកប្រធានបទមកបង្ហាញ ។
- ចំណោទបញ្ហា : ចោទសួរតាមបែបប្រធានពន្យល់ ។

## ២ . តួសេចក្តី

- ល្បះ ឬឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យ
- ពន្យល់ន័យប្រធាន
- បំណកស្រាយប្រធាន

គំនិតសំខាន់ទី ១ (មានសេចក្តីលម្អិតគាំទ្រ និងអំណះអំណាង)

គំនិតសំខាន់ទី ២ (មានសេចក្តីលម្អិតគាំទ្រ និងអំណះអំណាង)

.................................................................................

- សរុប គឺជាការសរុបគំនិតសំខាន់ៗឡើងវិញក្នុងចំណុចនៃបំណកស្រាយគំនិតប្រធានបទ ។

## ៣ . បញ្ចប់សេចក្តី

- ការសន្និដ្ឋាន : តើគំនិតប្រធានមានឥទ្ធិពលយ៉ាងណាចំពោះសង្គមមនុស្ស?
- មតិផ្ទាល់ខ្លួន : បទពិសោធផ្ទាល់ខ្លួនទាក់ទងនឹងប្រធានបទក្នុងការផ្តល់ដំបូន្មាន ឬការអប់រំមនុស្ស ។

youtube.com/moeys khmer.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី ៤

# សប្បុរសធម៌



ដើម្បីធ្វើឱ្យជីវិតកាន់តែមានតម្លៃថែមទៀតនោះ មនុស្សម្នាក់ៗគប្បីលះបង់អំពើអាក្រក់ហើយខិតខំកសាងអំពើល្អនិងសុចរិតទៀងត្រង់ ។ អំពើល្អទាំងនោះ បានស្តែងចេញតាមរយៈសន្តានចិត្តទូលាយរបស់បុគ្គលដូចជា ការជួយសង្គ្រោះគ្នា មិនប្រមាថ ឬរំលោភសិទ្ធិអ្នកដទៃ និងការប្រកាន់យកសច្ចធម៌ជាដើម ។

មេរៀននេះនឹងធ្វើឱ្យអ្នកកាន់តែមានចិត្តស្រឡាញ់ អាណិតអាសូរ និងប្រព្រឹត្តនូវអំពើជាកុសល និងមានសេចក្តីថ្លៃថ្នូរ ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពី លក្ខណៈសម្គាល់របស់រឿងបែបពុទ្ធ និយម កិរិយាសព្ទ ការបញ្ចេញមតិចំពោះសកម្មភាពតួអង្គ និងសំណេរបំពេញលិខិតផ្សេងៗ ។

# ប្រធានរឿង ឬមូលន័យ និងមូលបញ្ហារឿង

ប្រសិនបើយើងសិក្សាអត្ថបទរឿងណាមួយ យើងត្រូវវិភាគឱ្យឃើញផ្នែកធំៗនៃរឿងដូចជា អត្ថរូប អត្ថន័យ និងអត្ថរស ។ ក្នុងផ្នែកនីមួយៗមានចំណុចសំខាន់ៗច្រើនដូចជា ផ្នែកអត្ថន័យមាន ប្រធានរឿង មូលបញ្ហារឿង គំនិតដឹកនាំរឿង (តម្លៃអប់រំ) ទំនាស់ជាដើម ។

តើដូចម្តេចហៅថាប្រធានរឿង មូលបញ្ហារឿង ? ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

## រឿងចន្ទរាជ

មានរឿងតំណាលថា កាលណោះមានដង្វៅធំម្នាក់ឈ្មោះធនកៈនៅក្រុងពារាណសី ដែលមានដង្វៅតូចបន្ទាប់ៗចំនួន ៥០០នាក់ រកស៊ីជាមួយ ។ នាយដង្វៅមានភរិយាឈ្មោះ នាងនន្ទាមានគភ៌ចាស់ខែបានយល់សុបិននៅពេលជិតភ្លឺ បានឃើញតាបសមួយរូបហោះឆ្ពោះទៅរកព្រះចន្ទ ហើយចាប់យកព្រះចន្ទនោះមកដាក់លើដៃនាង ។ តមកមិនយូរប៉ុន្មាននាងប្រសូតបុត្រមួយ មានរូបឆោមលោមពណ៌ល្អល្អះ ហើយតាំងនាមបុត្រថា ចន្ទកុមារ ព្រោះមាតាយល់សប្តិថាបានព្រះចន្ទ ។

លុះកុមារធំចម្រើនឡើងក្នុងអាយុ ១៦ឆ្នាំ ក៏បានរៀនសិល្បសាស្ត្រចេះចប់សព្វយ៉ាង ។ ថ្ងៃមួយដង្វៅ ៥០០នាក់ ចុះសំពៅទៅធ្វើជំនួញឯស្រុកសុវណ្ណភូមិ ។ ចន្ទកុមារក៏បានជម្រាបលាមាតាបិតាទៅជួញជាមួយនឹងគេដែរ ។ លុះសំពៅបើកចេញទៅក្នុងសមុទ្រ ហើយបានដល់កំពង់មួយ ចន្ទកុមារក៏បានឡើងទៅមើលផ្សារលក់ទំនិញនឹងគេដែរ ។ គេបានឃើញសត្វរស់ផ្សេងៗមាន ស្វាក្រេះ ទន្សាយ ពស់ជាដើម ក៏បានតថ្លៃទិញសត្វរស់អស់នោះយកមកទុកក្នុងសំពៅ ។ ចន្ទកុមារត្រូវឈ្មួញឯទៀតស្តីបន្ទោស តែគេឆ្លើយថាមិនមែនយកសត្វទាំងនោះធ្វើជំនួញទេ គឺទិញវាយកទៅលែងនៅព្រៃឆ្ងាយពីទីលំនៅរបស់មនុស្ស ។ សំពៅបើកចេញពីទីនោះទៀត បានដល់ឆ្នេរសមុទ្រមួយអន្លើដែលមានភ្នំខ្ពស់ៗ ទើបចន្ទកុមារឡើងទៅលើភ្នំនោះ ឃើញទីរហោឋានហើយបានជួបនឹងមហាថេរមួយអង្គ ។ គេបានដងទឹកផ្កាឈូក យកមកប្រគេនលោកស្រង់ រួចប្រគេនភេសជ្ជៈនិងបាយទឹក អុជប្រទីបធូបបូជាព្រះថេរៈ រួចយកសត្វទាំងអម្បាលម៉ានមកដោះលែងនៅទីនោះតែម្តង ។ ចន្ទកុមារបានតាំងសេចក្តីប្រាថ្នាសូមឱ្យបានត្រាស់ជាព្រះពុទ្ធមួយអង្គ ដើម្បីជួយស្រោចស្រង់សត្វលោកទៅអនាគតកាល ហើយនមស្ការព្រះមហាថេរ លាចុះសំពៅចេញដំណើរទៅជាមួយនឹងពួកឈ្មួញទាំងនោះ ។ សំពៅបើកចេញទៅមិនយូរប៉ុន្មាន ត្រូវខ្យល់ព្យុះយ៉ាងខ្លាំងបក់បោកបាក់បែកធ្លុះធ្លាយ លិចលង់ក្នុងមហាសាគរនោះទៅ ។

ដួនជាថ្ងៃដែលចន្ទកុមារលិចសំពៅនោះ ជាថ្ងៃដែលព្រះមហាក្សត្រក្នុងប្រទេសសុវណ្ណភូមិមានប្រឈួនជាទម្ងន់ ហើយស្ដេចសោយទិវង្គតទៅ ។ ព្រះមហាក្សត្រអង្គនេះមានព្រះរាជធីតាមួយអង្គព្រះនាមសិម្ពលី ប៉ុន្តែពុំមានព្រះរាជបុត្រាមួយអង្គសោះ ។ លុះថ្វាយព្រះភ្លើងព្រះបរមសពហើយ ទើបព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតកវីអាមាត្យ មុខមន្ត្រីនាំគ្នាធ្វើពិធីផ្សងបុស្សរថ ។

ឯចន្ទកុមារខំហែលឆ្លងសមុទ្រអស់កំលុង ៧ថ្ងៃ ទើបនាងមណីមេខលាទេពធីតា បានមកស្រង់ចន្ទកុមារនាំទៅដាក់ក្នុងព្រះរាជឧទ្យាននៃស្ដេចសុវណ្ណភូមិ ។ ដោយអស់កម្លាំងនិងអត់អាហារមកយូរថ្ងៃ គេក៏ដេកលក់លើផែនសិលាក្នុងឧទ្យាននោះទៅ ។ ចំណែកបុស្សរថចេញដំណើរប្រទក្សិណព្រះនគរបីជុំ ក៏ឆ្ពោះសំដៅទៅរកឧទ្យានតែម្ដង ។ លុះទៅដល់ទៀបជិតចុងជើងចន្ទកុមារ ក៏ឈប់នៅនឹងថ្កល់ ទើបបុរោហិតម្នាក់ទៅពិនិត្យលក្ខណៈចន្ទកុមារ ក៏បានដឹងជាក់ច្បាស់ថា យុវជននេះបុណ្យចេស្ដាបារមីក្រៃលែង ទើបបង្គាប់ពួកភ្លេងឱ្យប្រគំតូរ្យតន្ត្រីឡើង អ្នកក៏រលឹកឡើងនៅពេលនោះ ។ ឯពួកអាមាត្យមុខមន្ត្រីក្រាបទូលអញ្ជើញឱ្យទៅគ្រងរាជ្យសម្បត្តិ ។

គេបានអភិសេក ព្រះនាងសិម្ពលីជាអគ្គមហេសី គេថ្វាយព្រះនាមព្រះអង្គថា **ព្រះបាទចន្ទរាជ** ។ ក្រោយដែលទ្រង់ឡើងគ្រងរាជ្យហើយ ទ្រង់បានយកព្រះទ័យទុកដាក់ក្នុងការបរិច្ចាគទានជានិច្ច ហើយទ្រង់ឱ្យអាមាត្យទៅអញ្ជើញព្រះវររាជបិតា ព្រះវររាជមាតាពីក្រុងពារាណសី ហើយទំនុកបម្រុងឱ្យបានក្ដីសុខក្សេមក្សាន្ត ។

ចន្ទកុមារបានសម្ដែងថា ដោយផលានិសង្ស ដែលព្រះអង្គបានដងទឹក ៨ ក្អមប្រគេនព្រះថេរៈស្រង់លើកំពូលភ្នំនោះ បានជាពួកទេពតាទៅដងទឹកយ៉ាងថ្លាមានក្លិនក្រអូបចំនួន ៨ម៉ឺន ៤ពាន់ក្អមអំពីស្រះអនោតត្តៈ មកថ្វាយព្រះអង្គស្រង់រាល់ៗថ្ងៃ ។ ដោយផលបូជាប្រទីប ៨ដួង មានពួកទេពតាអុជប្រទីប៨ម៉ឺន ៤ពាន់ដួងបូជារាល់ៗថ្ងៃ ។ល ។

លុះចំណេរតមក ព្រះនាងសិម្ពលី ប្រសូតព្រះរាជបុត្រមួយអង្គ ក្រុមព្រះញាតិថ្វាយព្រះនាមថាមហិសកុមារ ។

ព្រះមហាក្សត្រ គ្រងរាជសម្បត្តិជាសុខ អស់កាលយូរលង់ លុះទ្រង់ព្រះជរា មានព្រះចំណង់ចង់បរិច្ចាគសត្តសតកមហាទាន គឺទានយ៉ាងធំមាន ៧មុខ ក្នុងមួយមុខៗចំនួន ៧០០ គឺខ្ញុំប្រុស ៧០០ ខ្ញុំស្រី ៧០០ គោឈ្មោល ៧០០ គោញី ៧០០ ដំរី ៧០០ សេះញី ៧០០ រថ ៧០០ ។ អាមាត្យមុខមន្ត្រីក៏បានចាត់ចែងធ្វើមហាទាននេះបានសម្រេចដូចព្រះបំណង ។

ព្រះឥន្ទ្រាធិរាជ ជាស្ដេចនៃទេពតា ស្ដេចចុះពីឋានត្រ័យត្រិង្សមកកាន់ឋានមនុស្សលោក ស្ដេចចូលទៅគាល់ព្រះបាទចន្ទរាជ ថ្វាយព្រះពរស័ព្ទសាធុការនិងសេចក្ដីសរសើរជាអនេកប្បការ រួចទ្រង់លាត្រឡប់ទៅទេវលោកវិញ ។ ឯព្រះបាទចន្ទរាជ ជាក្សត្រទ្រង់ធម៌ទ្រង់បានបំពេញកុសលនិងសីល

ទានជានិច្ចដរាបដល់អស់ព្រះជន្មាយុ ស្តេចទៅកើតក្នុងឋានតុសិតទេវលោក សោយសម្បត្តិទិព្វជាសុខក្សេមក្សាន្ត ។

*(ដកស្រង់ពីបញ្ញាសជាតកសង្ខេប ភាគទី ១ អ្នកនិពន្ធ ញ៉ុក ថែម)*

តាមរយៈរឿងនេះ យើងឃើញថា ព្រះបាទចន្ទរាជមានចិត្តសប្បុរសធម៌និងបំពេញកុសលកម្មតាំងពីកុមារភាព ដូចជាប្រមូលទិញសត្វគ្រប់យ៉ាងពីឈ្មួញយកទៅលែង ដងទឹក ប្រគេនភេសជ្ជៈ បាយទឹក អុជប្រទីបថ្វាយមហាថេរនៅលើភ្នំ។ រហូតដល់ព្រះអង្គបានគ្រងរាជសម្បត្តិ ហើយបានធ្វើទានបរិច្ចាគដល់ជនក្រីក្រទាំងឡាយទៀតផង ។ ដូចនេះ ៖

- ប្រធានរឿងនៃរឿងចន្ទរាជ គឺចិត្តសប្បុរសធម៌និងការបំពេញកុសលកម្មរបស់ព្រះបាទចន្ទរាជ ។
- មូលបញ្ហារឿងនៃរឿងចន្ទរាជគឺ ៖
  - ប្រផ្នូលនៃកំណើតចន្ទរាជកុមារ
  - ការសង្គ្រោះជីវិតសត្វទាំងឡាយពីឈ្មួញ
  - ការបំពេញកុសលចំពោះមហាថេរ
  - ការធ្វើសត្តសតកមហាទានរបស់ព្រះបាទចន្ទរាជ ។

*ប្រធានរឿង ឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង ឬជាបញ្ហារួមរបស់រឿងដែលអ្នកនិពន្ធចង់បង្ហាញដល់អ្នកអាន ។*

*មូលបញ្ហារឿង ជាគំនិតសំខាន់ៗ បញ្ហាចម្បងៗ ដែលទាក់ទងនឹងប្រធានបទរបស់រឿង ឬអត្ថបទ ។ មូលបញ្ហារឿងមានតិច ឬច្រើនអាស្រ័យលើដំណើររឿង ។*

## លំហាត់

ចូរអ្នករកប្រធានរឿងនិងមូលបញ្ហារបស់រឿងខាងក្រោម ៖

១. រឿងដើមកំណើតទីក្រុងភ្នំពេញ (ប្រជុំរឿងព្រេងខ្មែរ ភាគ៥)

២. រឿងភ្នំបាយ៉ង់កោរ នៅខេត្តតាកែវ (មេរៀនទី ១)

៣. រឿងប្រាសាទអង្គរវត្ត (មេរៀនទី ១)

៤. អត្ថបទដកស្រង់ រឿងផ្កាស្រពោន (អំណានទី ១ មេរៀនទី ២)

# លក្ខណៈសម្គាល់របស់រឿងបែបពុទ្ធនិយម

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមសម្គាល់អក្សរសិល្ប៍ណា ដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា គឺលើកយកសកម្មភាពពោធិសត្វក្នុងការកសាងបារមី ឬបានលើកយកទស្សនៈសំខាន់ៗក្នុងពុទ្ធសាសនាមានបញ្ហាកម្មផល បុណ្យ បាប ពៀរវេរា ជាដើមមកបង្ហាញ ៖

## ក. ផ្ដើមរឿង

រឿងផ្ដើមឡើងដោយធ្វើបទនមស្ការមានតំណាលថា ព្រះពុទ្ធគង់នៅក្នុងអារាមណាមួយទ្រង់សម្ដែងឡើងនូវរឿងអតីតជាតិរបស់ព្រះអង្គទៅកាន់ពុទ្ធបរិស័ទ ។ល ។

## ខ. តួរឿង ឬដំណើររឿង

- តួអង្គ : តួអង្គប្រុសជាព្រះពោធិសត្វ ឯតួអង្គស្រីជាកន្សែស្បរពេជ្ជ ។ តួអង្គរងមានមនុស្ស ទេវៈ អសុរៈ ... ។
- ទីកន្លែង : ដំណើររឿងប្រព្រឹត្តទៅនៅនគរពារាណសី តក្កសិលា ព្រៃហេមពាន្ត ឋានទាំងបី... ។
- បញ្ហាចោទ : ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស ទំនៀមទម្លាប់ កម្មពៀរ អំពើបាប ... ។
- បញ្ហាដោះស្រាយ : ព្យាយាមតស៊ូប្រឹងប្រែងដោយយកសីលធម៌ទៅអប់រំតាមសន្តិវិធី ធម៌ខន្តី សន្ដោសប្រណី មិនប្រើហិង្សា ដើម្បីដោះស្រាយបញ្ហាជានិច្ច ។
- ស្នេហា : គឺស្នេហារវាងព្រះពោធិសត្វនិងកន្សែស្បរពេជ្ជ ជាស្នេហាបរិសុទ្ធ ។
- ឧត្ដមគតិរឿង : អប់រំមនុស្សឱ្យស្គាល់បុណ្យបាប ឱ្យធ្វើអំពើល្អខំប្រឹងតស៊ូព្យាយាមដោយជឿជាក់លើខ្លួនឯង ។

## គ. បញ្ចប់រឿង

ការបញ្ចប់រឿងដោយមានការសជាតិរបស់តួអង្គព្រះពោធិសត្វនិងកន្សែស្បរពេជ្ជ ។

*អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមសម្គាល់អត្ថបទអក្សរសិល្ប៍ដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា ដោយការផ្ដើមរឿង គឺធ្វើបទនមស្ការរំលឹកគុណព្រះរតនត្រ័យមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ឯក្នុងដំណើររឿងតួអង្គឯកបុរសជាពោធិសត្វ នារីជាកន្សែស្បរពេជ្ជ និងការបញ្ចប់រឿង ដោយមានការសជាតិរបស់តួអង្គ ពោធិសត្វទៅជាព្រះពុទ្ធ ឯកន្សែស្បរពេជ្ជទៅជានាងពិម្ពា ។ ចំពោះតួអង្គអាក្រក់វិញ បើតួអង្គនោះប្រឆាំងនឹងទៅជាទេវទត្ត ឯតួអង្គស្រីទៅជានាងចិញ្ចា ។*

## លំហាត់

ចូរប្អូនអានអត្ថបទដកស្រង់រឿងខាងក្រោម រួចបង្ហាញពីការផ្ដើមរឿងនៅក្នុងអត្ថបទនេះ ៖

ក. ពេលបានត្រាស់ដឹងហើយព្រះសមណគោតមទ្រង់គង់នៅក្នុងវត្តវេឡុវ័ន នាក្រុងរាជគ្រឹះ ដែនមគធរដ្ឋ ដើម្បីប្រកាសផ្សាយព្រះពុទ្ធសាសនា ។ ក្រោយពីបានអារាធនាអំពីរាជាមាត្យលើកទី១០ របស់ព្រះបាទសុទ្ធោទនៈពុទ្ធបិតាព្រះពុទ្ធអង្គ ។ បន្ទាប់មកទៀត ព្រះអង្គក៏និមន្តមកថ្កានក្រុងកបិលភស្តុ ដែលមានភិក្ខុសង្ឃ អង្គអរហន្តាខីណាស្រពប្រមាណពីរម៉ឺនជាបរិវារ ។

កាលទ្រង់យាងមកដល់ចំពោះព្រះភក្ត្រក្រុមព្រះញាតិវង្ស ស្ដេចសាក្យរាជចំនួនប្រាំបីម៉ឺនបួនពាន់រូប ក៏ស្រាប់តែមានភ្លៀងបោក្ខរព័ស៌ធ្លាក់មកពីនភាល័យ ។ ភ្លៀងនោះជាបុព្វហេតុនៃការសដែងរឿងមហាវេស្សន្តរនេះ ។

ក្នុងពេលភ្លៀងនោះ ព្រះពុទ្ធទ្រង់បានទេសនាអំពីប្រវត្តិបុព្វកម្មរបស់ព្រះនាងសុបារសុប្បតី ។ កាលមុនពេល បានមកជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យ ព្រះនាងសុបារសុប្បតីជាស្រីសួគ៌ ។ លុះពេលដែលត្រូវច្យុតិចាកទេវលោកព្រះនាងបានទូលសុំព្រះពរ១០ ប្រការអំពីព្រះឥន្ទ្រាធិរាជ ។ ពរទាំង ១០ប្រការនោះគឺ :

១. សូមឱ្យបានជាអគ្គមហេសីព្រះបាទស្រីសញ្ជ័យ នាក្រុងចេតុត្តរនគរ ។

២. សូមឱ្យមានភ្នែកល្អ មូលខ្មៅយង់ ចិញ្ចើមកោងទ្រទេសទ្រទ្រួយបីដូចចង្កួយកៅទណ្ឌ ។

៣. សូមឱ្យមានឈ្មោះថា សុបារសុប្បតីដដែល ។

៤. សូមឱ្យមានកូនប្រុសមួយមានកិត្តិនាមល្បីល្បាញ ។

៥. ពេលមានគភ៌សូមកុំឱ្យមានផ្ទៃពោះ នៅធំប៉ោងប៉ើសច្រលើសនឹងចុងដង្ហើមនោះឡើយ ឱ្យរាបសុភាពល្អបីដូចអ្នកយកកាំផ្ទួច្រកក្នុងបំពង់ ។

៦. សូមកុំឱ្យមានដោះសណ្ដាយ សូមឱ្យមានដោះមូលក្បួសមនឹងឱរា ។

៧. សូមកុំឱ្យមានសក់ស្កូវ អាស្រូវអាក្រក់ សូមឱ្យមានសក់រលើបរលោងដូចស្លាបភមរា ។

៨. សូមឱ្យមានសាច់ល្អ ស្បែកម៉ដ្ឋខៃល្អដូចពពិលមាស ។

៩. សូមឱ្យមានអំណាច អាចដោះទុក្ខទោសរបស់មនុស្ស សត្វទាំងឡាយ ។

១០. សូមឱ្យមានសព្វសត្វគឺហង្ស ក្រៀល ក្ងាន ក្ងោក បន្លឺសូរស័ព្ទពីរោះព្ធដ៏ព្រះរាជមន្ទីរ ។

ព្រះឥន្ទ្រាធិរាជទ្រង់ព្រម ហើយបានប្រសិទ្ធីឱ្យព្រះនាងបានសម្រេចដូចសេចក្ដីប្រាថ្នា ។

*(ដកស្រង់ពីរឿងមហាវេស្សន្តរជាតក របស់លោក ញ៉ុក ថែម)*

youtube.com/moeys khmer.moeys.gov.kh facebook.com/moeys.gov.kh

**១.** កាលព្រះពុទ្ធជាព្រះបរមសាស្ត្រាចារ្យ គង់នៅវត្តជេតពនទ្រង់ប្រារព្ធនូវមហាភិនិក្ខមនបារមី ទ្រង់សដែងធម៌ទេសនាថា : មាបណ្ឌិច្ចយំវិភាវយ ដូច្នេះជាដើម ។

សេចក្ដីថា : ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងសាលាធម្មសភា សរសើរនូវមហាភិនិក្ខមនបារមីរបស់ព្រះមានបុណ្យ ។ ព្រះអង្គទ្រង់បុច្ឆាថា អ្នកទាំងឡាយប្រជុំនិយាយនូវរឿងអ្វី ? ភិក្ខុទាំងនោះក្រាបទូលបង្គំទូលតាមដំណើរ ។ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា ឥឡូវនេះ តថាគតមានបារមីពេញគ្រប់គ្រាន់ហើយ លះបង់រាជសម្បត្តិទៅសាងមហាភិនិស្រ្កមណ៍ មិនអស្ចារ្យទេ បើពីដើមទើបអស្ចារ្យ កាលភិក្ខុទាំងឡាយ អារាធនាក៏ព្រះអង្គទ្រង់សដែងនូវអតីតនិទានដូចតទៅនេះ ៖

អតីតេ ភិក្ខវេ ពារាណសិយំ កាសិការាជា នាមធម្មេន សមេន រជ្ជំ ការេសិ ... ។ ម្នាលភិក្ខុទាំងឡាយក្នុងកាលកន្លងទៅហើយ ព្រះមហាក្សត្រព្រះនាម កាសិករាជសោយរាជ្យតាមច្បាប់មានសមភាពក្នុងនគរពារាណសី ។ ទ្រង់ ... សម័យនោះ ព្រះបាទកាសិករាជនិងព្រះនាងចន្ទាទេវីព្រមទាំងស្នំមួយម៉ឺនប្រាំមួយពាន់នាក់ ហើយនិងពួកបរិពារមានអាមាត្យជាដើម ក៏សព្វព្រះរាជហឫទ័យនឹងទ្រង់ព្រះផ្នួសដែរ ។ ទើបទ្រង់ឱ្យចំហទ្វារឃ្លាំងទាំងអស់ហើយប្រកាសថា "ជនណាប្រាថ្នាអ្វី ចូរយកចុះ" ហើយទៅទ្រង់ផ្នួសតាមព្រះរាជបុត្រ ។ សូម្បីអ្នកផ្សារក៏ចំហទ្វារផ្សារ ទៅបួសតាមព្រះអង្គដែរនៅពេញៗអាស្រម ដែលព្រះឥន្ទនិម្មិតថ្វាយចម្ងាយបីយោជន៍បានសម្រេចនូវសមាបត្តិប្រាំបីនិងអភិញ្ញាប្រាំទាំងអស់គ្នា ។

គ្រានោះ ស្ដេចសាមន្តរាជទាំងឡាយ បានឮថាព្រះបាទកាសិករាជទៅទ្រង់ផ្នួសក៏មកបន្តៗគ្នាចំនួនបីប្រទេស ដើម្បីប្រជែងយករាជសម្បត្តិ ក្នុងនគរពារាណសី តែប្រែព្រះទ័យទៅទ្រង់ផ្នួសតាមទាំងអស់ទៀតក៏បានសម្រេចសមាបត្តិដូចគ្នាដែរ ។ ពួកដំរី ពួកសេះក្លាយជាដំរីព្រៃ សេះព្រៃអស់ដោយមានសេចក្ដីសោមនស្សនឹងម្ចាស់ខ្លួនទ្រង់ព្រះផ្នួស លុះស្លាប់ទៅបានទៅកើតជាទេវតានៅឆកាមាវចរសួគ៌ ។

ឯតាបសនិងតាបសិនី មានព្រះពោធិសត្វជាប្រធាន ឋិតនៅដល់ជីវិតបរិយោសាន បានទៅកើតក្នុងព្រហ្មលោកគ្រប់ៗព្រះអង្គហោង ។

សម្ដេចព្រះបរមសាស្ដាទ្រង់នាំព្រះធម៌ទេសនានេះមកសម្ដែង ហើយទ្រង់ប្រជុំជាតកថា ទេវតារក្សាស្វេតច្ឆត្រក្នុងគ្រានោះ គឺជានាងឧប្បលវណ្ណាថេរី នាយសារថី គឺជាសារីបុត្តត្ថេរ ព្រះឥន្ទ្រ គឺអនុរុទ្ធត្ថេរ ព្រះមាតាព្រះបិតាទាំងឡាយ គឺជាពុទ្ធមាតាពុទ្ធបិតាព្រះមហារាជត្រកូល បរិស័ទទាំងឡាយ គឺជាពុទ្ធបរិស័ទក្នុងគ្រាឥឡូវនេះ ឯបណ្ឌិតដែលពុតធ្វើជាគ គឺអង្គអញតថាគតជាសម្មាសម្ពុទ្ធនេះឯងហោង ។

*(ដកស្រង់ពីសៀវភៅសង្ខេបទសជាតករបស់លោក ឈឹម ស៊ុម)*

# បំណងប្រាថ្នារបស់ព្រះបាទវេស្សន្តរ



## ក. សិក្សាពាក្យគន្លឹះ

- វេស្សន្តរ <វេស្ស : ឈ្មួញ+ អន្តរ = ចន្លោះ រវាងពាក់កណ្ដាល ។ ហេតុបានជាទ្រង់មាននាមដូច្នេះ ពីព្រោះព្រះអង្គបានប្រសូតនៅចន្លោះផ្លូវឈ្មួញ ។
- ពោធិសត្វ : អ្នកដែលកំពុងខំប្រឹងបំពេញបារមី ។
- អរុណោទ័យ : ព្រះអាទិត្យទើបភ្លឺច្រាលពីទិសបូព៌ា ពេលព្រឹកព្រាង ។
- សត្តសតកមហាទាន : ទានដ៏ធំអស្ចារ្យមានក្នុងមួយមុខៗ ៧០០ ។
- បរិច្ចាគ : ការលះបង់អ្វីមួយសម្រាប់ជាទាន ។
- ទានបារមី : ឈ្មោះបារមីទី១ ក្នុងបារមីទាំង ១០ ។
- បព្វជ្ជា : ការបួស ផ្នួស ។
- ព្រះសវនីយ៍ : ព្រះបន្ទូលព្រះវររាជនី ឬសម្ដេចព្រះអគ្គមហេសី ។

facebook.com/moeys.gov.kh

- ព្រះហស្ត : ដៃ ។
- ព្រះរាជសុណិសា : កូនប្រសាស្រី ។
- កាសិកព័ស្ត្រ : សំពត់ជ្រលក់ទឹកអម្ចត់ពណ៌លឿងសម្រាប់សមណៈក្នុងព្រះពុទ្ធសាសនាប្រើប្រាស់ ។
- ព្រះកន្សែង : យំ ។
- ព្រះសសុរ : ព្រះបិតាក្មេក ឪពុកក្មេក ។
- ប្រទក្សិណ : ដើរព័ទ្ធជុំវិញ ។
- ចតុរង្គ : ដែលមានអង្គ៤ កងទ័ពមានអង្គ៤ គឺកងទ័ពដំរី កងទ័ពសេះ កងទ័ពរទេះ កងទ័ពថ្មើរជើង ។
- ភ្នំគីរីវង្កត : ឈ្មោះភ្នំមួយក្នុងពួកភ្នំហេមពាន្ត ។
- មគ្គុទ្ទេសក៍ : អ្នកដឹកនាំ ។
- អយ្យកា : ជីដូន ។
- អយ្យកោ : ជីតា ។
- កណ្ហាជិនា : ឈ្មោះព្រះរាជធីតានៃព្រះវេស្សន្តរមានក្នុងមហាវេស្សន្តរជាតក ។
- បោក្ខរព័ស៌ : ភ្លៀងមានអាការៈ ដូចជាទឹកធ្លាក់លើស្លឹកឈូក ។
- អញ្ជលី : ការផ្គុំប្រាមដៃទាំង១០គោរព ។
- សិរសា : ក្បាល ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអ្នកត្រូវយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹង ៖

អ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាស ទំនាស់ វិធីតែងនិពន្ធ (ការផ្ដើមរឿង ដំណើររឿង បញ្ចប់រឿង) និងតម្លៃអប់រំ ។

## គ. អត្ថបទ

[...] ព្រះបាទស្រីសញ្ជ័យ "យើងបណ្ដេញបាវេស្សន្តរដែលជាទង់ជ័យនៃពួកអ្នកស្រីពិរាស្ត្រ ឈ្មោះថាធ្វើនូវសេចក្ដីគោរព ចំពោះបវេណីធម៌ ទុកជាបាវេស្សន្តរជាទីស្រឡាញ់ជាងជីវិតរបស់យើង ក៏យើងស៊ូតែបណ្ដេញចេញខានពុំបាន" ។

ព្រះវេស្សន្តរបវរពោធិសត្វទ្រង់ឱ្យចាត់រៀបចំព្រះរាជទ្រព្យព្រះរាជទាន ។ ពួកអ្នកកាន់មុខតំណែងទាំងប៉ុន្មាន ក៏បានចាត់ចែងតាមព្រះរាជបញ្ជា ។

លុះរាត្រីកាលកន្លងទៅ ក្នុងពេលព្រឹកព្រាងស្វាងអរុណោទ័យ សម្តេចព្រះចក្រីទ្រង់ស្តេចទៅកាន់សាលាឆទាន ទ្រង់ព្រះរាជទាននូវសត្តសតកមហាទាន ដែលគេរៀបចំស្រេចស្រាប់ចំនួនប្រាំពីររយ ។

ដំរីប្រាំពីររយ សឹងប្រដាប់នីទៅនូវខ្នង កញ្ចោងមាត់ខ្យង ចងដង្គន់ខ្សែក្រពាត់ ខ្សែងឹង ខ្សែហាង សំអាងមុខ ស្រោមភ្លុក ជាវិការៈនៃមាសមានក្បាច់ចម្លាក់ព្រមទាំងទ្រមាក់ពាក់នីទៅនូវម្លូកផ្កាយមាស ខោស្នាប់ភ្លៅ អាវក្រោះក្រាយរាយ ផ្កាយមាសដៃកាន់នីទៅនូវកង្វេរនិងលំពែងស្នែងក្របី ។

សេះប្រាំពីររយ សុទ្ធតែជាសេះអាជានេយ្យ ដែលសារថីបង្ហាត់បានបត់ស្រេចស្រាប់ ព្រមទាំងគ្រឿងប្រដាប់ គឺខ្នងចងកែបដោយខ្សែអុកផ្តក់ដោយខ្សែហាង សងខាងមានឈ្នាន់ ព័ន្ធច្រមុះដោយខ្សែឃ្លុំ បង្ខាំដោយបង្ហៀរ ព្រមទាំងគង្វាលវាសុទ្ធតែពាក់នីទៅនូវម្លូកមាស ខោស្នាប់ភ្លៅ អាវក្រោះក្រាលរាយផ្កាយមាស មានដៃកាន់នីទៅនូវស៊ែនិងធ្នូសរ ។ រថប្រាំពីររយ ព្រមទាំងគ្រឿងប្រដាប់និងមនុស្សស្រីប្រាំពីររយដែលស្អិតស្អាងយ៉ាងល្អជិះលើរថ ព្រមទាំងភាជន៍មាសប្រាំពីររយសម្រាប់ត្រងទឹកដោះ គោបាប្រាំពីររយ គោផ្អាត់ប្រាំពីររយ ខ្ញុំស្រីប្រាំពីររយ ខ្ញុំប្រុសប្រាំពីររយ និងវត្ថុផ្សេងៗដែលអ្នកផងតែងត្រូវការសុទ្ធតែប្រាំពីររយមួយមុខៗ ។ សូម្បីតែសុរាដែលជាទានឥតផលល្អសោះ ក៏ព្រះអង្គទ្រង់ព្រះរាជទានដែរ ។ កាលដែលព្រះវេស្សន្តរទ្រង់បរិច្ចាគនូវសត្តសតកមហាទាន ការស្ញប់ស្ញែង ការព្រឺរោមព្រឺស្បែក ការអស្ចារ្យចម្លែកក៏កើតឡើងព្រោះផែនដីកក្រើក ។

គ្រានោះសំឡេងគ្រលួចយ៉ាងពន្លឹកក៏លាន់ឮឡើង ៖ "ពួកអ្នកស្រីពិរាស្ត្របណ្តេញព្រះវេស្សន្តរព្រោះតែការឱ្យទាន ឥឡូវព្រះវេស្សន្តរនៅតែឱ្យទានទៀត ។ ពួកអ្នកស្រែកនូវសម្រែកទាំងនេះយំយែកបោកខ្លួនដួលស្រូសៗទៅដូចបុគ្គលស្រវឹងស្រា ដឹងខ្លួនកាលណាក៏ងើបឡើងស្រែកទៀត" ។

ព្រះវេស្សន្តរថ្លែងបញ្ជាក់៖ "បពិត្រព្រះបិតា សត្វទាំងឡាយសុទ្ធតែពុំឆ្អែតដោយកាមទាំងអស់ ។ ហេតុដូចនេះ សត្វទាំងនោះរមែងទៅកាន់ទីយមរាជ ។ ឯទូលព្រះបង្គំជាខ្ញុំចង់ចៀសវាងទីយមរាជបានជាឱ្យទាន ។ ការឱ្យទានជាអំពើល្អសោះទេ តែត្រឡប់ជាបានឈ្មោះថាជាការបៀតបៀនអ្នកដែនទៅវិញ ។ ទូលព្រះបង្គំជាខ្ញុំទោះបីចេញទៅរងទុក្ខក្នុងព្រៃ ដែលច្របូកច្របល់ដោយម្រឹគសាហាវក៏ឈ្មោះថាបានធ្វើបុណ្យជាគ្រឿងនាំមកនូវសេចក្តីសុខក្នុងអនាគតដែរ ឯពួកអ្នកស្រីពិរាស្ត្រឥតឃើញអនាគតវែងឆ្ងាយដូចខ្ញុំព្រះអង្គទេ ទាំងព្រះអង្គដែលរួមគំនិតបណ្តេញទូលព្រះបង្គំ ក៏សុំទ្រង់គង់នៅជាសុខក្នុងកាម ដូចជាគេលិចវីវក់ក្នុងភក់ដូច្នោះចុះ ។ បពិត្រព្រះវររាជមាតា សូមទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំពេញចិត្តនឹងបព្វជ្ជា" ។

ព្រះនាងផុស្សតីមានព្រះសវនីយ៍ ៖ "ម្នាលកូន យើងអនុញ្ញាតឱ្យអ្នកហើយ តែនាងមទ្រីនេះចូរនៅជាមួយកូនទាំងពីរនេះចុះ" ។ ទ្រង់ព្រះកន្សែងបណ្ដើរ ចាប់ព្រះហស្តព្រះរាជសុណិសាបណ្ដើរ ។

ព្រះវេស្សន្តរ ៖ " សូមទ្រង់ព្រះមេត្តាប្រោស បើនាងមទ្រីចង់ទៅក៏ទៅ ចង់នៅក៏នៅចុះ" ។

ព្រះបាទស្រីសញ្ជ័យ ៖ "មទ្រីកូនអើយ នាងធ្លាប់តែស្លៀកដណ្ដប់សំពត់កាសិកព័ស្ត្រ ហើយត្រឡប់ជាស្លៀកសំពត់ ដែលគេក្រងដោយស្បូវភ្លាំងវិញដូចម្ដេចកើត ! កុំទៅអីកូន !" ។

ព្រះនាងមទ្រីទ្រង់ព្រះកន្សែងថ្លែងថា ៖ "ខ្ញុំម្ចាស់បើប្រាសចាកព្រះវេស្សន្តរហើយ នឹងនៅជាសុខពុំបានឡើយ ។ ខ្ញុំម្ចាស់អាចអត់ទ្រាំភ័យទាំងនេះបាន ។ ឯត្រង់សេចក្ដីទុក្ខ ព្រោះការព្រាត់ប្រាសចាកព្រះវេស្សន្តរ ខ្ញុំម្ចាស់អត់ទ្រាំពុំបានទេ ។ ខ្ញុំម្ចាស់នឹងទៅពុំខាន ។ សូមទ្រង់ព្រះរាជាអនុញ្ញាត ។ បពិត្រព្រះសុស្សរា ធម្មតាស្រីមេម៉ាយ រមែងក្ដៅក្រហាយឥតស្រាក បរមបុរាណបានចែងទុកមកថា ៖

| | | |
|---|---|---|
| **ទន្លេគ្មានទឹក** | **ហៅថា** | **ទន្លេអាក្រាត** |
| **ដែនគ្មានស្ដេច** | **ហៅថា** | **ដែនអាក្រាត** |
| **ស្រីមេម៉ាយ** | **ហៅថា** | **ស្រីអាក្រាត** |

ធម្មជាតិអាក្រាតទាំងបីមុខនេះ ជាទីមើលងាយនៃជនជុំវិញ ។ ខ្ញុំម្ចាស់នឹងទ្រាំនៅទាំងទុក្ខម្ដេញដូច្នេះពុំបានទេ ខ្ញុំម្ចាស់ស៊ូតែទៅពុំខាន ។

ព្រះបាទស្រីសញ្ជ័យ ៖ "បើនាងទៅចូរនាងទុកកូនតូចទាំងពីរ យើងនឹងចិញ្ចឹមកូនតូចទាំងនោះកុំឱ្យមានក្ដីព្រួយលំបាក" ។

ព្រះនាងមទ្រី ៖ "កូនតូចទាំងពីរនឹងញុំាងហឫទ័យនៃយើងខ្ញុំដែលក្រំដោយសំណោកឱ្យត្រេកអរក្នុងព្រៃបាន" ។

លំដាប់នោះព្រះបាទស្រីវេស្សន្តរបវរពោធិវង្សទ្រង់ថ្វាយបង្គំព្រះបរមរាជបិតានិងព្រះវររាជមាតាធ្វើប្រទក្សិណ ហើយទ្រង់ឡើងកាន់ព្រះរាជរថដែលទឹមដោយសេះបួន នាំព្រះរាជបុត្រី បុត្រាអគ្គជាយាស្ដេចទៅកាន់ភ្នំគីរីវង្កត ។ លុះទ្រង់បរព្រះរាជរថដល់ជិតផុតចក្ខុវិស័យ ក្សត្រថ្លៃទ្រង់ងាកក្រោយឱ្យព្រះនាងមទ្រីទតព្រះរាជវាំង " នុ៎ះន៏ ! ព្រះរាជវាំងរបស់យើង " ។ ទ្រង់មានព្រះរាជឱង្ការតែប៉ុណ្ណោះ ក៏កំពូលព្រះរាជវាំងថយផុតវិស័យនៃព្រះនេត្រា ដោយសារសន្ទុះលឿននៃសេះទាំងបួននាំព្រះអង្គទៅ ដោយព្រះរាជរថ ។ គ្រាដែលផុតចក្ខុវិស័យនៃក្សត្រទាំងពីរ ព្រះធរណីក៏កម្រើក ។

គ្រានោះមានពួកព្រាហ្មណ៍បួននាក់ស្ទាក់សុំសេះទាំងបួនអំពីព្រះអង្គ ។ ព្រះពោធិវង្សទ្រង់ព្រះរាជទាន តាមក្ដីប្រាថ្នារបស់ព្រាហ្មណ៍ ។ ខណៈនោះទេវបុត្របួនព្រះអង្គបាននិម្មិតភេទជារមាំងអូសព្រះរាជរថទៅ ។ ព្រះអង្គទ្រង់គង់លើព្រះរាជរថ ដែលពួករមាំងទេវបុត្រអូសទៅនោះមិនយូរប៉ុន្មាន

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

បានជួបនឹងព្រាហ្មណ៍ប្រាំនាក់ទៀត មកស្ទាក់សុំព្រះរាជរថក្នុងព្រៃ ។ ព្រះចក្រីទ្រង់ព្រះរាជទានព្រះរាជរថនោះ ហើយទ្រង់ឱ្យព្រះនាងមទ្រីពថៅក្រីស្នា ព្រះអង្គពបាជាលី យាងទៅតាមផ្លូវក្នុងពានីជាទីទូរគមន៍មុខគួរឱ្យអណោចអធមក្រៃពេកហោង ។ [...]

ទើបព្រះបាទស្រីសញ្ជ័យទ្រង់ត្រាស់បង្គាប់អាមាត្រមុខមន្ត្រីនិងពួកពលសកលយោធាថា ព្រះអង្គនឹងចេញទៅភ្នំគីរីវង្កត ដើម្បីអញ្ជើញព្រះវេស្សន្តរនិងព្រះនាងមទ្រីឱ្យវិលថ្កានព្រះនគរ ។ លុះបានឫក្សពារពេលាល្អ ព្រះអង្គនិងនាងផុស្សតីនិងព្រះរាជវង្សានុវង្សលើកចតុរង្គសេនាចេញទៅភ្នំគីរីវង្កតមានថៅជាលីជាមគ្គុទ្ទេសក៍ ។

ព្រះបាទស្រីសញ្ជ័យព្រះនាងផុស្សតី និងព្រះរាជវង្សានុវង្សមានចតុរង្គសេនាព្រមទាំងអាមាត្យមុខមន្ត្រីជាបរិវារមានព្រះជាលីកុមារជាមគ្គុទ្ទេសក៍ចេញទៅភ្នំគីរីវង្កត ទៅដល់ជិតស្រះមុច្ចលិន្ទព្រះជាលីកុមារទ្រង់បញ្ជាឱ្យរង់ចាំក្បួនដង្ហែនៃសម្ដេចព្រះអយ្យកោ ។

ឯព្រះបរមពោធិសត្វទ្រង់បានឮសូរស័ព្ទគឹកកងរំពងនៃពួកពលសេនាទ្រង់ស្មានជាកងទ័ពសត្រូវលើកមកចោមចាប់ព្រះអង្គ ទើបទ្រង់ចាប់ព្រះហស្ដព្រះនាងមទ្រីឡើងទៅលើកំពូលភ្នំគីរីវង្កត ។ ព្រះនាងមទ្រីទូលរំលឹកព្រះអង្គកុំឱ្យខ្លាច ត្បិតព្រះឥន្ទ្រាធិរាជទ្រង់បានប្រសិទ្ធពរប្រទានព្រះអង្គរួចស្រេចហើយ ។ ព្រះបរមពោធិសត្វទ្រង់បានស្ដាប់ពាក្យរំលឹកព្រះស្មារតីរបស់ព្រះនាងមទ្រី ក៏ទ្រង់មានព្រះហឫទ័យក្សេមក្សាន្តស្ដេចយាងចុះមកប្រថាប់នៅសាលារបស់ព្រះអង្គវិញ ។

លុះក្បួនដង្ហែសម្ដេចព្រះអយ្យកោ ព្រះអយ្យកាទៅដល់ចំណតនៃថៅជាលី ទើបព្រះបាទស្រីសញ្ជ័យទ្រង់មានព្រះរាជឱង្ការនឹងព្រះអគ្គមហេសីថា ព្រះអង្គនឹងស្ដេចយាងទៅជួបបាវេស្សន្តរមុនបន្តិចទៀតសឹមព្រះនាងយាងទៅតាមក្រោយ ។ បន្ទាប់មកសឹមបើកឱ្យថៅជាលីនិងនាងកណ្ហាជិនាទៅតាមក្រោយជាលំដាប់បន្តបន្ទាប់គ្នា ។ ព្រះបាទស្រីវេស្សន្តរនិងព្រះនាងមទ្រីបានក្រលេកឃើញព្រះវរបិតាមកអំពីចម្ងាយ ក៏ស្ទុះទៅទទួលសម្ដេចវរបិតា ក្រាបថ្វាយបង្គំព្រះបាទាទ្រង់ព្រះកន្សែងសោក ទ្រង់ត្រាស់សួរសុខទុក្ខចំពោះព្រះអង្គ ហើយទូលសួររកព្រះមាតា សួរដំណឹងថៅជាលីនិងកណ្ហាជិនាទៀត ។ [...]

កាលណោះ មានហេតុអស្ចារ្យកើតឡើង គឺមហាមេឃបានបង្អុរភ្លៀងបោក្ខរព័ស៌ធ្លាក់ចុះមកស្រោចស្រពលើក្សត្រទាំង ៦ អង្គព្រមទាំងពួកពលសេនា អាមាត្យមុខមន្ត្រី ត្រាតែបានភ្ញាក់រលឹកមានស្មារតីឡើងវិញទាំងអស់គ្នា ។ ទើបអស់មុខមន្ត្រីសូមឱ្យស្ដេចត្រឡប់ថ្កានព្រះនគរ សោយរាជសម្បត្តិឋិតនៅជាឥស្សរនៃប្រជារាស្ត្រហោង ។

*(ដកស្រង់ចេញពីសៀវភៅសង្ខេបទសជាតករបស់លោក ឈឹម ស៊ុម ទំព័រទី ៣១៩ និង ទំព័រទី ៣៥៣)*



facebook.com/moeys.gov.kh youtube.com/moeys krou.moeys.gov.kh

## សំណួរ

១. តើអត្ថបទសម្រង់នេះដកស្រង់ពីរឿងណា ? អ្នកនិពន្ធឈ្មោះអ្វី ?

២. តើព្រះបាទវេស្សន្តរជាតួអង្គដូចម្ដេច ? ចំណែកឯនាងមទ្រីជាតួអង្គដូចម្ដេចដែរ ?

៣. ចូរបង្ហាញកាលអាកាសនៅក្នុងអត្ថបទនេះ ។

៤. ចូរបង្ហាញពីបញ្ហាទំនាស់នៅក្នុងអត្ថបទនេះ ។

៥. ចូររកតម្លៃអប់រំក្នុងអត្ថបទនេះតាមរយៈសកម្មភាពតួអង្គព្រះវេស្សន្តរ ។

៦. ចូរអ្នកអានរឿងព្រះវេស្សន្តរ រួចប្រាប់ពីវិធីតែងនិពន្ធរបស់រឿង គឺការផ្ដើមរឿង ដំណើររឿង និងការបញ្ចប់រឿង ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# កិរិយាសព្ទ

អ្នកបានសិក្សារួចហើយអំពីគុណនាមនិងប្រភេទរបស់គុណនាម ។ ឥឡូវនេះអ្នកនឹងសិក្សាពីកិរិយានិងប្រភេទរបស់កិរិយាសព្ទបន្ថែមទៀត ។ ដូចម្ដេចដែលហៅថាកិរិយាសព្ទ?

ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

- កសិករភ្ជួរស្រែ ។
- ចាបហើរ ។
- ឆ្កែចេះតែព្រុស មនុស្សចេះតែដើរ ។
- យើងខំកាប់ឆ្ការស្មៅបានធំល្វឹងល្វើយ ។
- ការជក់បារីធ្វើឱ្យខូចសុខភាព ។

ពាក្យ "ភ្ជួរ ហើរ ព្រុស ដើរ កាប់ឆ្ការ ជក់" ជាកិរិយាសព្ទ ។

កិរិយាទាំងនោះមាននាទីផ្សេងៗគ្នានៅក្នុងល្បះនីមួយៗខាងលើ ។ តើកិរិយាសព្ទមានអ្វីខ្លះ ?

## ១ . កិរិយាសុទ្ធ

កិរិយាសុទ្ធ គឺជាកិរិយាសម្ដែងនូវអំពើរបស់ប្រធានដែលធ្វើដោយខ្លួនឯងផ្ទាល់ ។

*ឧទាហរណ៍ :*

- កសិករស្ទូងស្រូវនៅក្នុងស្រែ ។
- យើងត្រូវប្រឆាំងដាច់ខាតចំពោះអំពើហិង្សាក្នុងគ្រួសារ ។
- យើងខិតខំរៀនសូត្រទើបបានលទ្ធផលល្អ ។

ពាក្យ "ស្ទូង ប្រឆាំង ខិតខំ រៀន" ជាកិរិយាសុទ្ធ ។

កិរិយាសុទ្ធមានច្រើនដូចជា "ហូប ផឹក ស៊ី ប្រយុទ្ធ ប្រឆាំង ភ្ជួរ រាស់ ដុត ជំរះ" ។

## ២ . កិរិយាហេតុ

កិរិយាហេតុ គឺជាកិរិយាសម្ដែងនូវអំពើរបស់ប្រធានដែលធ្វើឡើងគ្រាន់តែជាហេតុដើមចមប៉ុណ្ណោះ ។

*ឧទាហរណ៍ :*

- លោកគ្រូខំប្រឹងបង្រៀនសិស្សឱ្យចេះដឹង ។
- ម្ដាយផ្ដេកកូននៅក្នុងអង្រឹងដោយថ្នមៗ ។
- ចូរអ្នកធ្វើឱ្យលោកសប្បាយចិត្ត ។

កិរិយាហេតុដទៃទៀតមានដូចជា ៖ ពន្យល់ បង្កើប ពន្សើត បន្សាប ពន្លូត ពន្យារ បន្ថយ បន្ថែម បន្ទុះបង្អាប់ ពន្លើស ពន្លាត ... ។

## ៣ . កិរិយាសកម្ម

កិរិយាសកម្ម គឺជាកិរិយាត្រូវការកម្មបទ ។

*ឧទាហរណ៍ ៖*

ពូៗកសិករធ្វើការងារបានប្រសើរណាស់ ។ ឯមីងៗកម្មការិនីវិញខំប្រឹងបំពេញភារកិច្ចក្នុងរោងចក្របានល្អណាស់ដែរ ។

ពាក្យ “ធ្វើ បំពេញ” ជាកិរិយាសកម្ម ។

- ធ្វើ ជាកិរិយាសុទ្ធសកម្ម
- បំពេញ ជាកិរិយាហេតុសកម្ម ។

## ៤ . កិរិយាអកម្ម

កិរិយាអកម្ម គឺជាកិរិយាមិនត្រូវការកម្មបទ ។

*ឧទាហរណ៍ ៖*

- កុមារឈរលើភ្លឺស្រែ ។
- សិស្សទាំងអស់អង្គុយយ៉ាងសុភាព ។
- ក្មេងយំ ។

ពាក្យ “ឈរ អង្គុយ យំ” ជាកិរិយាអកម្ម ។

កិរិយាទាំងនេះ ពុំមានកម្មបទទេ ។

កិរិយាអកម្មមានច្រើនទៀតដូចជា សើច សន្លប់ រវើរវាយ ព្រុស ផ្កា ផ្លែ រះ ញញឹម ដុះ ប្រកាច់ រាំ របើក រមៀល ត្អូញ ថ្ងូរ ដួល គ្រហឹម ស្លាប់ លូ ងាប់ បោល រត់ លូន ។

យើងឃើញថា កិរិយាសព្ទមានលក្ខណៈផ្សេងគ្នាទៅតាមប្រភេទនីមួយៗ ។

*កិរិយាសព្ទ គឺជាពាក្យឬសម្ដីសម្រាប់សម្ដែងនូវអំពើរបស់ប្រធាន ។ កិរិយាសព្ទ មានកិរិយាសុទ្ធ កិរិយាហេតុ កិរិយាសកម្ម និងកិរិយាអកម្ម ។*

## លំហាត់

១. ចូរអ្នកតែងល្បះដោយបញ្ជាក់ពីកិរិយាសព្ទនិងប្រាប់ប្រភេទរបស់វាឱ្យបានបួនល្បះ ។

២. ចូរអ្នកស្រង់យកកិរិយាសព្ទនៅក្នុងអត្ថបទខាងក្រោមដោយបញ្ជាក់ពីប្រភេទរបស់វា ៖

នៅលើសកលលោក ប្រទេសណាក៏មានលក់បារីដែរ ។ ប្រជាជនស្គាល់បារីតាំងពីមនុស្សចាស់រហូតដល់កូនក្មេង ។

អ្នកជក់បារីហាក់ដូចជាមិនសូវគិតគូរពីសុខភាពខ្លួនទេ ។ អ្នកជក់បារីខ្លះធ្វើដូចជាមិនដឹងមិនឮពីអ្វីឡើយ ក្រៅពីការបម្រើអារម្មណ៍របស់គេ ។ តាមការស្រាវជ្រាវ គេដឹងថា អត្រាមរណៈប្រមាណនៃអ្នកជក់បារីបានកើនឡើងយ៉ាងខ្ពស់ជាងអត្រាមរណៈប្រមាណនៃអ្នកមិនជក់បារី ។ ក្នុងចំណោមអ្នកជក់បារីទាំងឡាយ អ្នកស្លាប់ដោយសារការជក់បារីមានចំនួនពាក់កណ្ដាល ។ នៅក្នុងទិវាប្រឆាំងនឹងការជក់បារី ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៦ នៅចុងសតវត្សទី ២០នេះ មានចំនួនប្រមាណ៦២លាននាក់ ក្នុងប្រទេសកំពុងអភិវឌ្ឍ ។ បណ្ដាអ្នកស្លាប់ទាំងនោះបុរសមាន ៥២លាននាក់ ស្រី ១០លាននាក់ ។

*(ដកស្រង់និងកែសម្រួលពីកំរងឯកសារថ្នាំជក់ ឬសុខភាព)*

# វប្បធម៌ អរិយធម៌ខ្មែរ



## ក. សិក្សាពាក្យគន្លឹះ

- វប្បធម៌ : ការផ្សាំបណ្ដុះចំណេះវិជ្ជាឱ្យបានលូតលាស់ចម្រើន ។
- សន្តិភាព : ភាពសុខសាន្ត ភាពស្ងប់ស្ងាត់ ភាពសាន្តត្រាណ ។
- វឌ្ឍនភាព : សេចក្ដីរីកចម្រើនលូតលាស់ ។
- សមិទ្ធផល : ផលប្រយោជន៍ដែលបានសម្រេចហើយ ។
- ភាពអន្ធការ : ភាពងងឹតសូន្យសុង ។
- ទស្សនវិស័យ : ដំណើរគំនិតដែលយល់ឃើញ ។
- សច្ចៈ : សេចក្ដីពិត ដំណើរទៀង ទៀងទាត់ ។
- យុត្តិធម៌ : សេចក្ដីទៀងទាត់ មិនលម្អៀង ។
- អរិយធម៌ : ធម៌ដែលនាំឱ្យកើតសេចក្ដីសុខចម្រើន ។
- ស្ថាបត្យកម្ម : ការសាងសង់ ឬស្ថាបនា ។

facebook.com/moeys.gov.kh

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអ្នកត្រូវយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងតម្លៃអប់រំអត្ថបទ សេចក្តីលម្អិតសំខាន់ៗ គំនិតសំខាន់បង្កប់ ។

## គ. អត្ថបទ

បណ្ឌិតចាស់ទុំ វប្បធម៌វិទូខ្មែរស្ទើរតែគ្រប់សម័យកាលបានទូន្មានថា បញ្ហាវប្បធម៌ គឺជាបញ្ហារបស់ខ្មែរគ្រប់រូប ដែលមិនគ្រាន់តែខិតខំស្វែងយល់ រៀនសូត្រអំពីសារៈសំខាន់និងកំណើតរបស់វាប៉ុណ្ណោះទេ គឺត្រូវខិតខំរក្សាការពារមរតកវប្បធម៌ជាតិឱ្យបានគង់វង្ស ដើម្បីបុព្វហេតុសន្តិភាព វឌ្ឍនភាពនិងព្រលឹងរបស់ប្រជាជាតិខ្លួន ។

តាមនិយមន័យទូទៅ វប្បធម៌គឺជាសមិទ្ធផលនៃជ័យជម្នះដោយបញ្ញា ពលកម្ម ហត្ថពលកម្មរបស់មនុស្សលើធម្មជាតិ លើអវិជ្ជា លើភាពអន្ធការ ។ គោលដៅជាមូលដ្ឋានរបស់វប្បធម៌ គឺមនុស្ស ។ កាលណាស្នាដៃវប្បធម៌កាន់តែខ្ពង់ខ្ពស់ គោលដៅរបស់មនុស្សកាន់តែជ្រាលជ្រៅនិងសុក្រឹត ។

វប្បធម៌មានតួនាទីចង្អុលទិស បណ្តុះបណ្តាលអប់រំចំណេះដឹង និងបញ្ញាស្មារតី ដើម្បីសេចក្តីចម្រើនខាងផ្លូវចិត្តគំនិត និងឧត្តមគតិប្រសើរខ្ពង់ខ្ពស់របស់មនុស្ស ។ វប្បធម៌ជួយកែច្នៃមនុស្សឱ្យមានកិរិយាមារយាទល្អប្រសើរ មានរបៀបរស់នៅថ្លៃថ្នូរ មានច្បាប់ទម្លាប់ត្រឹមត្រូវ មានសច្ចៈ យុត្តិធម៌ និងមានសេចក្តីសុខសន្តិភាព ។

ប្រជាជាតិខ្មែរធ្លាប់ជាជាតិមួយមានអរិយធម៌ថ្កុំថ្កើងរុងរឿង ព្រមទាំងមានកិត្តិនាមល្បីល្បាញទូទាំងសកលលោកទាំងមូល ដោយសារតែតម្លៃសិល្បៈវប្បធម៌ជាតិខ្លួន ។ ជាការពិតណាស់ កាលណាគេទស្សនាសិល្បៈខ្មែរដូចជា របាំ ក្បាច់បុរាណ ស្ថាបត្យកម្ម គំនូរ ល្ខោន តន្ត្រី គេត្រូវពិចារណាទើបយល់ខ្លឹមសារពិតរបស់វា ។

អាស្រ័យហេតុនេះ ខ្មែរគ្រប់រូបគប្បីព្យាយាមសិក្សាអរិយធម៌ជាតិរបស់ខ្លួន ដើម្បីស្គាល់ប្រភពលក្ខណៈផ្ទាល់ និងតម្លៃនៃអរិយធម៌ ។ ការដឹងនិងស្គាល់តម្លៃនៃអរិយធម៌ជាតិខ្លួននេះហើយ ជំរុញឱ្យយើងមានមោទនភាព សេចក្តីស្រឡាញ់អរិយធម៌របស់យើងក៏កើតមានឡើង ។ ដរាបណាយើងមានចិត្តស្រឡាញ់ ដរាបនោះយើងមុខជាព្យាយាមលើកតម្កើង ហើយខិតខំថែរក្សាការពារអរិយធម៌ជាកេរមរតកដែលដូនតាបានកសាងទុកមកអស់ពេលច្រើនសតវត្សឱ្យបានគង់វង្សយូរអង្វែងតទៅទៀត ។

អំពើបែបនេះ ជាកត្តាដាស់ស្មារតីយើងជាពលរដ្ឋខ្មែរឱ្យមានមនសិការជាតិនិងផ្ដល់ឱ្យយើងគ្រប់គ្នានូវកម្លាំងជាតិនិយម ។ ការណ៍នេះជំរុញឱ្យមានការតស៊ូពុះពារគ្រប់ឧបសគ្គ ដើម្បីការពារទឹកដីនិងថែរក្សាជាតិសាសន៍ខ្មែរឱ្យនៅគង់វង្សក្នុងឋានៈជាពលរដ្ឋប្រកបដោយ ឯករាជ្យ និងបូរណភាពទឹកដី ។

*(ដកស្រង់និងកែសម្រួលពីទស្សនាវដ្ដីសម្រាប់គ្រូស្ដីពីសិទ្ធិមនុស្សប្រជាធិបតេយ្យនិងអហិង្សា លេខ០៧-០៨ ទំព័រទី ៩៦)*

## សំណួរ

១. តើអត្ថបទនេះដកស្រង់ពីណា ?

២. តាមអត្ថបទនេះ តើវប្បធម៌មានន័យដូចម្ដេច ?

៣. តាមអត្ថបទនេះ តើវប្បធម៌មានតួនាទីដូចម្ដេចខ្លះ ?

៤. តើអរិយធម៌មានមែកធាងអ្វីខ្លះ ?

៥. ចូររកតម្លៃអប់រំនៅក្នុងអត្ថបទនេះ ។

៦. ចូររកគំនិតសំខាន់បង្កប់នៅក្នុងអត្ថបទនេះ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ព្រះតេមិយ



ចូរអ្នកស្តាប់រឿង ព្រះតេមិយ ហើយឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើហេតុអ្វីបានជាព្រះតេមិយធ្វើជាគថ្លង់ ខ្វិនខ្វង់ ? ចូរបញ្ជាក់ ។

២. ចូរបង្ហាញប្រធានរឿងនៅក្នុងអត្ថបទនេះ ។

៣. ចូរប្រាប់មូលបញ្ហានៃរឿងព្រះតេមិយ ។

៤. ចូរបង្ហាញខ្លឹមសាររបស់អត្ថបទនេះ ។

facebook.com/moeys.gov.kh



# ការនិយាយ បញ្ចេញមតិចំពោះសកម្មភាពតួអង្គ

អ្នកបានស្ដាប់រឿង តេមិយរួចមកហើយ ។ ឥឡូវនេះ ចូរអ្នកនិយាយបញ្ចេញមតិចំពោះសកម្មភាពតួអង្គព្រះតេមិយ ក្នុងរឿងព្រះតេមិយដែលអ្នកបានស្ដាប់រួចហើយ ។

នៅពេលអ្នកនិយាយបញ្ចេញមតិ អ្នកគប្បីអនុវត្តតាមការណែនាំខាងក្រោម ៖

- សុំអនុញ្ញាតបញ្ចេញមតិ
- ស្ដាប់យោបល់អ្នកដទៃ
- កុំនិយាយកាត់គេ
- ប្រើសម្ដីសមរម្យ
- និយាយម្នាក់ម្ដងតាមវេនរបស់អ្នក
- សុំការអនុញ្ញាតពីប្រធានក្រុមសិន មុននឹងបញ្ចេញមតិជំទាស់ ។

**រំលឹកបញ្ញត្តិ**

ការបញ្ចេញមតិ គឺជាការនិយាយ សម្ដែង ឬបង្ហាញឱ្យឃើញនូវគំនិត មតិយោបល់ ឬទស្សនៈរបស់មនុស្សម្នាក់ៗចំពោះមតិ យោបល់ ទស្សនៈ គំនិត ទង្វើ ឬសកម្មភាព ... របស់អ្នកដទៃតាមរយៈពាក្យសម្ដី ឬសំណេរ ។ ការបញ្ចេញមតិអាចជាការគាំទ្រ ជំទាស់ ប្រឆាំង សំយោគ ឬបង្ហាញគំនិតថ្មី ដោយមានអំណះអំណាងនិងហេតុផលច្បាស់លាស់ ។

**សំនួនបញ្ចេញមតិ**

**ក. ការគាំទ្រ**

- គំនិតនេះពិតជាត្រឹមត្រូវ ...
- មតិ យោបល់ ... សមហេតុផលមែន ...
- ខ្ញុំក៏យល់ដូចនេះដែរ ...
- គំនិត យោបល់ ... នេះពិតជាប្រសើរនិងមានប្រយោជន៍ ព្រោះ ...
- តាមហេតុផលនេះ គឺពិតជាត្រឹមត្រូវ ...
- ............................................. ។

**ខ. ការជំទាស់**

- មតិ យោបល់នេះល្អហើយ ប៉ុន្តែ ...
- ខ្ញុំយល់ផ្សេងពីនេះ គឺ ...
- អ្នកខ្លះយល់ថា ...

youtube.com/moeys
moeys.gov.kh
facebook.com/moeys.gov.kh

- គំនិតនេះត្រឹមត្រូវម្យ៉ាងដែរ ប៉ុន្តែ ...
- ហេតុផលនេះមិនសមសោះ ព្រោះថា ...
- មិនគប្បីសោះ ព្រោះថា ...
- យើងមិនគួរ ...
- .............................................. ។

គ. ការសំយោគ

- គំនិត មតិ យោបល់ទាំងនេះសុទ្ធតែប្រសើរដូចគ្នា ព្រោះថា ...
- អំណះអំណាងអ្នកទាំង ... សុទ្ធតែសមហេតុផល ...
- ទង្វើអ្នកទាំង ... សុទ្ធតែជាទង្វើ ...
- មតិ គំនិត ... ក៏មិនខុសពីគំនិត ... ដែរ ព្រោះ ...
- .............................................. ។

ឃ. គំនិតថ្មី

- គំនិត មតិ យោបល់ទាំងនេះត្រឹមត្រូវហើយ ប៉ុន្តែមិនទាន់ ...
- តាមពិតមិនដូចនេះទេ ព្រោះថា ...
- ទង្វើរបស់អ្នកទាំងនោះមិនទាន់ត្រឹមត្រូវទេ ព្រោះ ...
- មតិទាំងនោះ នៅមានចំណុចខ្វះចន្លោះ គួរ ...
- .............................................. ។

## លំហាត់

ចូរអ្នកអានរឿងទុំទាវ រួចបញ្ចេញមតិចំពោះគំនិតនិងសកម្មភាពតួអង្គមួយចំនួនក្នុងរឿងទុំទាវ៖

១. សេចក្តីស្នេហារបស់ទុំនិងទាវមិនត្រឹមត្រូវទេ ព្រោះទុំជាសង្ឃ ។

២. មរណភាពដ៏សោកសៅរបស់ទុំទាវ គឺបណ្តាលមកពីម្តាយទាវតែម្នាក់គត់ ។

# បំពេញពាក្យបណ្ដឹង

នៅមេរៀនទីមួយអ្នកធ្លាប់បានសិក្សារួចមកហើយអំពីការបំពេញលិខិតផ្លូវការមួយចំនួនដូចជា កិច្ចសន្យា ជួល លក់ ...។ ឥឡូវនេះអ្នកនឹងសិក្សាពីការបំពេញលិខិតឯកជនមួយចំនួនដូចជាពាក្យបណ្ដឹង លិខិតជូនពរ ....។

ចូរអ្នកអានគំរូពាក្យបណ្ដឹងខាងក្រោម ៖

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

...... ❧❋❧ .....

## ពាក្យបណ្ដឹង

ខ្ញុំបាទ-នាងខ្ញុំ **ស.ប** ជាតិខ្មែរ សញ្ជាតិ កម្ពុជា អាយុ ៤៨ឆ្នាំ របររកស៊ី លក់ដូរ
ទីលំនៅពិតប្រាកដ នៅ ភូមិ ដ.ព ឃុំ វ.ស ស្រុក ស.រ.ទ ខេត្ត ក.ស
មានប្រពន្ធ-ប្ដីឈ្មោះ **ស.ក** មានកូន ៤នាក់។

**សូមគោរពជូន**

**លោកប្រធានតុលាការ ខេត្ត ក.ស**

**ឬលោកព្រះរាជអាជ្ញាអមតុលាការ ខេត្ត ក.ស**

សូមទានជ្រាប ។

កម្មវត្ថុ : សំណើសុំធ្វើបណ្ដឹងពីឈ្មោះ **រ.ទ**

យោង : (គ្មាន)

លិខិតភ្ជាប់ : (គ្មាន)

ត្បិតខ្ញុំបាទ-នាងខ្ញុំកើតទុក្ខមិនសុខចិត្តពីឈ្មោះ **រ.ទ** ភេទប្រុស ទីលំនៅ នៅភូមិ ត.ជ ឃុំ ស.ព ស្រុក ច.ម ខេត្ត ក.ស ពីបទបានប្រព្រឹត្តខុសច្បាប់ ដោយចូលផ្ទះរបស់ខ្ញុំបាទ-នាងខ្ញុំ រួចក៏បានលួចម៉ូតូ សេ ១២៥ ស៊េរី ឆ្នាំ ២០០៨ ចំនួន១គ្រឿង។

ដោយអាងហេតុថា កាលពីយប់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ឈ្មោះ **រ.ទ** បានលបលួចយកបានម៉ូតូមួយគ្រឿងដែលខ្ញុំចតទុកនៅមុខផ្ទះរួចជិះចេញបាត់ទៅ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការឬលោកព្រះរាជអាជ្ញាខេត្តសម្រេចដូចតទៅ ៖

១. សុំឱ្យឈ្មោះ **រ.ទ** នេះប្រគល់ម៉ូតូមកឱ្យខ្ញុំបាទ-នាងខ្ញុំវិញ ។

២. សុំឱ្យលោកប្រធានតុលាការឬលោកព្រះរាជអាជ្ញាដាក់ទោសដល់ជនអាក្រក់នេះតាមច្បាប់ដែលត្រូវកំណត់ ។

សូមលោកប្រធានតុលាការឬលោកព្រះរាជអាជ្ញា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ ។

ក.ស ,ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៨

ស្នាមមេដៃស្តាំ

ឈ្មោះ **ស.ប**

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## សំណួរ

១. តើផ្នែកខាងលើនៃពាក្យបណ្ដឹងបង្ហាញព័ត៌មានអ្វីខ្លះ ?

២. តើក្នុងចំណុចនៃកម្មវត្ថុបង្ហាញពីអ្វី ?

៣. តើផ្នែកខាងក្រោមបង្ហាញពីអ្វីខ្លះ ?

## លំហាត់

ចូរអ្នកបំពេញលិខិតពាក្យបណ្ដឹងខាងក្រោមឱ្យបានត្រឹមត្រូវ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

..... ❀✱❀ .....

**ពាក្យបណ្ដឹង**

ខ្ញុំបាទ-នាងខ្ញុំ ........................ ជាតិ ......... សញ្ជាតិ ........... អាយុ ........ ឆ្នាំ របររកស៊ី .................. ទីលំនៅពិតប្រាកដ ................................................

មានប្រពន្ធ-ប្ដីឈ្មោះ ..................................................................

**សូមគោរពជូន**

**លោកប្រធានតុលាការ .......................**

**ឬលោកព្រះរាជអាជ្ញាអមតុលាការ .......................**

សូមទានជ្រាប ។

កម្មវត្ថុ : .........................................................................

យោង : ......................................................................... (បើសិនមាន)

លិខិតភ្ជាប់ : ......................................................................... (បើសិនមាន)

ត្បិតខ្ញុំបាទ-នាងខ្ញុំកើតទុក្ខមិនសុខចិត្តពីឈ្មោះ ........................... ភេទ ..............

ទីលំនៅ ...........................................................................................

ពីបទបានប្រព្រឹត្ត ......................................................................................

ដោយអាងហេតុថា...................................................................................

.........................................................................................................

.....................................................................................................

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការឬលោកព្រះរាជអាជ្ញាខេត្តសម្រេចដូចតទៅ ៖

១. ..........................................................................................................

២. .......................................................................................................... ។ល ។

សូមលោកប្រធានតុលាការឬលោកព្រះរាជអាជ្ញា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ ។

.......,ថ្ងៃទី ..... ខែ ........ ឆ្នាំ ........

ស្នាមមេដៃស្តាំ

ឈ្មោះ ...........

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

មេរៀនទី
៥

# សោភ័ណភាសា





គ្រប់ជាតិសាសន៍លើសាកលោកសុទ្ធតែមានភាសានិងអក្សរ សម្រាប់ប្រាស្រ័យទាក់ទងគ្នាក្នុងសង្គម ។ ភាសាជាអត្តសញ្ញាណជាតិពិសេសមួយ ក្នុងចំណោមអត្តសញ្ញាណជាតិជាច្រើនទៀត ។ សោភ័ណភាសាមានន័យថាជាភាសាមួយដែលកើតមានភាពត្រឹមត្រូវ មានក្បួនខ្នាត មានកំណាកំណើត និងការវិវត្តច្បាស់លាស់ ។ ការចេះប្រើប្រាស់សិល្បៈភាសា ឬសិល្បៈក្នុងការនិយាយ ការសរសេរ និងចេះឱ្យតម្លៃ ហៅថាសោភ័ណភាសា ឬសិល្បៈភាសាពិតៗ ។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីស្នាដៃមួយចំនួនរបស់បុព្វបុរសខ្មែរដែលមានថ្វីដៃនិងទេពកោសល្យវិសេសវិសាលក្នុងការប្រើប្រាស់សិល្បៈភាសានិងលក្ខណៈពិសេសរបស់ភាសាខ្មែរ ។ ទន្ទឹមនេះ អ្នកនឹងសិក្សាផងដែរអំពី ខ្លឹមសារអត្ថបទ កាព្យរូបារម្មណ៍ គំនិតសំខាន់បង្កប់ ការវិវត្ត លក្ខណៈពិសេសរបស់ភាសា គុណកិរិយានិងប្រភេទនៃគុណកិរិយា ការប្រៀបធៀប និងសំណេរសំយោគ ។

# អំពីគុណកិរិយា

ប្អូនបានសិក្សារួចមកហើយអំពីនាម គុណនាម កិរិយា និងសព្វនាមព្រមទាំងប្រភេទនៃកិរិយា ។ ក្នុងមេរៀននេះ ប្អូនៗនឹងរៀនអំពីគុណកិរិយានិងប្រភេទនៃគុណកិរិយាបន្តទៀត ។

## ក. គុណកិរិយា

ចូរប្អូនពិនិត្យល្បះខាងក្រោម ៖

- រទេះគោនេះ បរលឿនណាស់ ។
- បងស្រីខ្ញុំច្រៀងពីរោះគួរឱ្យចង់ស្តាប់ ។
- សូមឯងមកនេះជាមួយខ្ញុំ ។
- ស្អែកសុភាពនឹងមកលេងផ្ទះយើង ។
- ពូផាធ្វើច្រើន តែគាត់ហូបតិច ។

តាមល្បះខាងលើនេះ យើងឃើញថាពាក្យ "ណាស់ ពីរោះ នេះ(ឬនោះ) ស្អែក ច្រើន តិច ដូចម្តេច" គឺជាគុណកិរិយាដែលជាពាក្យសម្រាប់សម្តែងនូវលក្ខណៈរបស់ "បរ ច្រៀង ធ្វើ គិត និង នេះស្អែក ..." ។

## ខ. ប្រភេទគុណកិរិយា

ចូរប្អូនពិនិត្យល្បះខាងក្រោម ៖

- ខ្ញុំឃើញក្របីមួយធំណាស់ ។
- រថយន្តនេះបើកយឺតៗ ។
- ហេតុអ្វីបានជាឯងមិនទៅធ្វើការ ?
- ស្អែកពូសំនឹងចេញដំណើរទៅស្រែ ។

តាមល្បះខាងលើ យើងឃើញថាពាក្យ "ណាស់ យឺតៗ ហេតុអ្វី ស្អែក" គឺជាគុណកិរិយាដែលសម្តែងនូវលក្ខណៈរបស់កិរិយា គុណនាម ឬគុណកិរិយាខុសៗគ្នាដូចជា ៖

ល្បះទី១ : ពាក្យ "ណាស់" សម្តែងនូវលក្ខណៈរបស់គុណនាម "ធំ" ដែលមានលក្ខណៈជាគុណកិរិយាបរិមាណ បង្ហាញពីចំនួន ។

ល្បះទី២ : ពាក្យ "យឺតៗ" សម្តែងនូវលក្ខណៈរបស់កិរិយា "បើក" ដែលមានលក្ខណៈជាគុណកិរិយាបំណែប បង្ហាញពីបែបបទផ្សេងៗ ។

ល្បះទី៣ : ពាក្យ "ហេតុអ្វី ?" ជាគុណកិរិយាសំណួរ បញ្ជាក់ពី "ហេតុ"

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

ល្បះទី៤ ៖ ពាក្យ "ស្អែក" ជាពាក្យបញ្ជាក់ គុណកិរិយាកាល ។

ដូចនេះ យើងឃើញថា គុណកិរិយាមានច្រើនថ្នាក់ ឬច្រើនប្រភេទ ។

*គុណកិរិយា គឺជាពាក្យសម្រាប់សម្ដែងលក្ខណៈរបស់កិរិយាសព្ទ គុណនាម ឬគុណកិរិយា ។*
*គុណកិរិយាមានច្រើនប្រភេទ គឺគុណកិរិយាកាល និងគុណកិរិយាកន្លែង បរិមាណ គុណកិរិយាសំណួរ និងគុណកិរិយាបំណែប ។*

## លំហាត់

១. ចូរបង្ហាញពាក្យដែលជាគុណកិរិយា និងបញ្ជាក់ពីប្រភេទ នៃគុណកិរិយាក្នុងល្បះនីមួយៗដូចខាងក្រោម ៖

- សុភីនិយាយភាសាអង់គ្លេសបានល្អ ។
- ប្រាសាទនេះធំណាស់ ។
- គាត់មកយឺតពេក ។
- ហេតុដូចម្ដេច បានជាគាត់តែងរឿងបានល្អម្ល៉េះ ?
- គាត់ចេញពីផ្ទះអំបាញ់មិញ ។

២. ចូរតែងល្បះដោយប្រើគុណកិរិយាបំណែប គុណកិរិយាសំណួរ គុណកិរិយាបរិមាណ គុណកិរិយាកាល និងកន្លែងឱ្យបានមួយប្រភេទមួយល្បះៗ ។

# កាព្យរូបារម្មណ៍

ក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីកាព្យរូបារម្មណ៍ដែលកវីប្រើនៅក្នុងអត្ថបទកំណាព្យមួយចំនួន ដូចជា បំរៀបន័យរូបារម្មណ៍ ឧបមានរូបារម្មណ៍ និងរូបារូប្បារម្មណ៍ ។

តើកាព្យរូបារម្មណ៍ជាអ្វី ?

កាព្យរូបារម្មណ៍ គឺជារូបារម្មណ៍ដែលមាននៅក្នុងអត្ថបទកាព្យ ។ កាព្យរូបារម្មណ៍នឹងមានរូបារម្មណ៍ (អារម្មណ៍ដែលលេចចេញជារូប) ទៅបានក៏ដោយសារកវីចេះជ្រើសរើសសំនួនសេចក្ដីសម្ដី ពាក្យពេចន៍ មកផ្សំជាឃ្លា ល្បះ និងប្រើសំនួនគំនិត សម្រាប់តុបតែងពាក្យជួននោះឱ្យមានសភាពលក្ខណៈប្លែកពិសេសនិងមានសម្ផស្ស មានសភាពរស់រវើក ពីរោះឡើង ដើម្បីភ្ញោចសរីរាង្គឥន្ទ្រិយ៍អ្នកអាន អ្នកស្ដាប់ ឱ្យរំភើបញាប់ញ័រសប្បាយជក់ចិត្ត ហើយចង់អាន ចង់ស្ដាប់តទៅទៀត ។

**ចូរប្អូនសូត្រឧទាហរណ៍កាព្យខាងក្រោម៖**

១. ផ្គរភរអ្នកស្រែ មេឃមីរខ្មៅអែ
ហាក់រលំប្រេះ សង្ឃឹមថាភ្លៀង
មិនទៀងថាផេះ ក្លាយជាភ្លើងឆេះ
ខ្លោចអស់ព្រឹក្សា ។

*(មើលដែនដីខ្មែររបស់លោក ជួន ម៉ែន)*

២. គ្មានដៃទន់ល្វន់ដូចសំឡី មកចេះថ្នមបីដូចដៃមិត្ត
ចេះជួយឈឺចាប់យល់គំនិត ចេះប្ដូរជីវិតជាមួយគ្នា ។

*(ចិត្តក្រមុំ កេង វ៉ាន់សាក់ )*

៣. សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្ដាប់ទាំងកំលោះចាស់មេម៉ាយ
ក្រមុំតូលូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្ដាប់សព្ទភាសា ។

*(ភិក្ខុសោម រឿង ទុំទាវ)*

៤. កបកាយក្រអូប ទោះទាំងរាងរូប ប្រហើរពុំបាច់
រកផ្កាគ្រឿងអប់ ឈ្ងុយឈ្ងប់សព្វសាច់ ពិដោរបណ្ដាច់
បណ្ដូលអស់ស្រី ។

*(កាកីរបស់ព្រះបាទអង្គឌួង)*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

៥. ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា ខ្លួនអ្នកឧបមាដូចកន្លង់
ហើររកឃើញផ្កាចូលត្រឹបត្រង់ រួចមិនបង្អង់ត្រាច់លីលា ។
ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា
រាជសីហ៍បើបានលំនៅជា មិនឱ្យឃ្លាតឃ្លាគុហាឡើយ ។

*(ទុំទាវ ភិក្ខុសោម)*

តាមឧទាហរណ៍ខាងលើនេះ យើងឃើញថា កាព្យរូបារម្មណ៍មានសភាពប្លែកៗគ្នា ដោយហេតុថាមានរូបារម្មណ៍ខ្លះ ស្ថិតនៅក្នុងពាក្យសម្ដីដែលកវីលើកយកមកប្រើ មួយម៉ាត់ ពីរម៉ាត់ ខ្លះទៀតស្ថិតនៅក្នុងឃ្លាពីរ ឬបី ឬនៅក្នុងវគ្គទាំងមូល ឬវគ្គតៗមកទៀត ហើយក៏មានរូបារម្មណ៍ខ្លះទៀតស្ថិតនៅក្នុងកំណាព្យទាំងមូលតែម្ដង ។

ឧទាហរណ៍ ១ : កវីប្រើពាក្យ ហាក់

ឧទាហរណ៍ ២ : កវីប្រើពាក្យ ដូច

ឧទាហរណ៍ ៣ : កវីប្រើពាក្យ សំឡេងផ្អែមល្ហែម ស្រួយពីរោះ

ឧទាហរណ៍ ៤ : កវីប្រើពាក្យ ប្រហើរ ក្រអូប ពិដោរ ឈ្ងុយឈ្ងប់

ឧទាហរណ៍ ៥ : កវីប្រើពាក្យ ប្រៀបដូច ឧបមា ដូច ។

ដូចនេះ ការធ្វើឱ្យកាព្យរបស់ខ្លួនមានសម្ផស្សរស់រវើក មិនសោះកក្រោះ និងមានតម្លៃគឺជាការចាំបាច់ដែលកវីត្រូវតែមានសិល្បវិធីដែលខ្ពស់ ដើម្បីធ្វើយ៉ាងណាឱ្យអ្នកអាន អ្នកស្ដាប់រំភើបចិត្តជិតអារម្មណ៍ កោតសរសើរចំពោះស្នាដៃខ្លួន ។ វិធីមួយដែលកវីយកមកប្រើក្នុងការបង្កើតរូបារម្មណ៍នោះហៅថា "កាព្យរូបារម្មណ៍វិធី" ។ កាព្យរូបារម្មណ៍មានច្រើនយ៉ាងដូចជា :

## ក. បំរៀបន័យរូបារម្មណ៍

វិធីធ្វើសមានកម្មវត្ថុ ឬគំនិតទៅនឹងវត្ថុ ហើយនឹងបាតុភូតនៅក្នុងឥន្ទ្រិយ៍ភាព ឬសិល្បឧបមានទៅលើបាតុភូតពីរដែលមានលក្ខណៈក្រៅដូចគ្នា ដើម្បីបំភ្លឺសារៈខាងក្នុងនៃបាតុភូតមួយតាមរយៈបាតុភូតមួយទៀត ។

*ឧទាហរណ៍ :*

ភ្នំភ្លើង ស្ទឹងឈាម សមុទ្រមេឃា នាវាតណ្ហា គុកបេតី អន្លង់ស្នេហ៍ មាត់ស្ទឹង ជើងភ្នំ ។ល ។

## ខ. រូបារូប្បារម្មណ៍

ជារូបារម្មណ៍ដែលបង្កើតឡើងដោយកវីចេះប្រើពាក្យពេចន៍ទាក់ទងនឹងការបង្ហាញពីប្រព័ន្ធនៃជីវរូបារម្មណ៍ ដូចជា ៖

**ចក្ខុរូបារម្មណ៍ ៖** កវីប្រើពាក្យពេចន៍ទាក់ទាញហាក់ឃើញផ្ទាល់ភ្នែក

*ឧទាហរណ៍ ៖*

មាត់នាងញញឹម ភក្ត្រនាងសង្ឃឹម សម្ដីស្មោះសរ
ហត្ថាទាំងគូ គន់យូររឹតល្អ ម្រាមថ្លោសបវរ
សការងារល្បី ។

**សោតរូបារម្មណ៍ ៖** កវីប្រើពាក្យពេចន៍ទាក់ទងការបង្ហាញពីសូរសំឡេងរណ្ដំ ស្រះ រណ្ដំព្យញ្ជនៈ ទាក់ទងនឹងសូរសំឡេងធម្មជាតិ ដែលធ្វើឱ្យយើងស្ដាប់ឮមានចិត្តរំភើប ... ។

ភ្លៀងធ្លាក់ស្រិបៗមិនឈប់ឈរ ភ្លៀងហូរតាមទសូរតក់ៗ
កង្កែបកបៗតាមដើមកក់ ខ្យល់បក់ហ៊ឺៗតាមបង្អួច ។

*(ចិត្តក្រមុំ របស់លោក កេង វ៉ាន់សាក់)*

**ឃានជីវ្ហារូបារម្មណ៍ ៖** គឺជារូបារម្មណ៍ដែលកើតឡើងដោយការប៉ះទង្គិចរវាងក្លិនក្រអូប ស្អុយ ផ្អែះផ្អាប រសផ្អែម ជូរចត់ ... ទៅនឹងឃានច្រមុះនិងជីវ្ហា (ការដឹងដោយអណ្ដាត) ។

*ឧទាហរណ៍ ៖*

នឹកដល់ពេលយប់ ដូចផ្កាយីហ៊ុប ពិដោរន្ទួនល្អង
ក្រអូបជាប់ជិត ឈ្ងុយឈ្ងប់ជាប់ចង ក្លិនជាចំណង
ចងគុកតណ្ហា ។ [...]

ធុំហើយក្លិនគុក ផ្អេះផ្អាបគ្រប់មុខ តែធ្លាប់ធុំឆ្ងាញ់
ពិដោរកនិដ្ឋ ស្រវាខ្ជួលខ្ជាញ់ នឹកឡើងគ្នាន់ក្ដាញ់
ធុំចង់ចើបធួន ។

*(គុកកាមកិលេស របស់លោក កេង វ៉ាន់សាក់)*

កាយរូបារម្មណ៍ ៖ ជារូបារម្មណ៍ដែលកើតឡើង ដោយសារកវីប្រើពាក្យសម្ដី ឃ្លា ល្បះ ដើម្បីបង្កើតការរំភើបតាមរយៈសម្ផស្ស ។

*ឧទាហរណ៍ ៖*

បងចាំកេសីបីខ្មៅញាប់ ប្អូនក្រសោបចាប់ចងចារផ្កា
កែមក្អួតម្រួតមាលា អស់ផ្កាសារពើភ្ញី ។

*(រាមកេរ្តិ៍ ខ្សែទី ៤)*

facebook.com/moeys.gov.kh
khmer.moeys.gov.kh
youtube.com/moeys

## លំហាត់

ចូរអានវគ្គដកស្រង់ខាងក្រោម រួចបង្ហាញប្រភេទរូបារម្មណ៍ ដែលអ្នកនិពន្ធប្រើក្នុងវគ្គកាព្យខាងក្រោម ៖

១. មៀងមើលទឹកជ្រៅស្មៅត្រកៀត ចិត្តបងចង្អៀតរីងរិវេគ
ត្រកួនដូចខ្លួនបងឈប់ដេក ឈប់ដោយម្លប់មែកត្របែកព្រៃ ។
យាប្លងដូចបងភ្លាត់ឃ្លាតឆ្ងាយ ព្រៃព្រួយមកឱ្យយូរឃ្លាតឃ្លៃ
ស្រងេះស្រងូតរបូតដៃ ម្លេះសមប្អូនភ័យមមៃគិត ។

*(ទុំទាវ ភិក្ខុសោម)*

២. អ្នកមួយចៃចូវ រអែររអូវ វៀចវេរឫស្យា
បញ្ចើចបញ្ចើ ពាក្យពើមាយា ដូចកលផ្លែល្វា
ល្អល្អះតែក្រៅ ។
មួយដូចខ្ទុរណាំង សម្បកស្កោកស្គាំង បន្លាច្រូងនៅ
ឯក្នុងសឹងក្លែប ក្រអែបផ្អែមទៅ ទាល់ក្នុងឥតសៅ
រសសឹងពិសា ។

*(ច្បាប់កូនចៅ បណ្ឌិត មៃ)*

៣. ភ្លៀងធ្លាក់ស្រិបៗមិនឈប់ឈរ ភ្លៀងហូរតាមទសូរតក់ៗ
កង្កែបកបៗតាមដើមកក់ ខ្យល់បក់ហ៊ូៗតាមបង្អួច ។
បក់លើមែកឈើឮសូរប្រាវ រត់វ៉ាវទៅឆ្ងាយសូរគ្រលួច
រត់តាមប្រហោងហាក់ដូចហួច រត់កួចសក់នាងញ័ររញ្ជួយ ។

*(ចិត្តក្រមុំ លោកកេងវ៉ាន់សាក់)*

៤. ទាវអើយទាវស្រីសេចក្តីនេះ មាននេននោះចេះមើលសាស្ត្រា
សំឡេងស្រួយស្រាប់ស្តាប់ភាសា ដូចសត្វសារិកាពិសាចេក ។

*(ទុំទាវ ភិក្ខុសោម)*

៥. កបកាយក្រអូប ទោះទាំងរាងរូប
ប្រហើរពុំបាច់ រកផ្កាគ្រឿងអប់
ឈ្ងុយឈ្ងប់សព្វសាច់ ពិដោរបណ្តាច់
បណ្តូលអស់ស្រី ។

*(កាកីព្រះបាទអង្គឌួង)*

# ទុំទាវ



## ក. សិក្សាពាក្យពិបាក

- អធ្វា : ផ្លូវ ។
- វិតក្ក : សេចក្ដីត្រិះរិះ ការរំពឹងគិត ។
- ពិដោរ : ក្លិន ។
- ប្រស្រ័យ : ការស្រឡាញ់រាប់អាន ការទាក់ទង ។
- ហឫទ័យ : ដួងចិត្ត ទឹកចិត្ត ។
- បា : ពាក្យសម្រាប់ហៅកូនប្រុសឬមនុស្សមានអានុភាពតិចជាងខ្លួន ដែលទុកស្មើកូនប្រុសបង្កើត ។
- ប្រណិប័តន៍ : ការសម្ដែងសេចក្ដីគោរព ។
- ហត្ថ : ដៃ ។
- ព្រះទ័យ : ទឹកចិត្ត ។
- ពុទ្ធដីកា : ការសួរ និយាយរបស់ព្រះសង្ឃ ព្រះបន្ទូលព្រះពុទ្ធ ព្រះសង្ឃ ។
- ទូល : ប្រាប់ ឱ្យដំណឹង ។



facebook.com/moeys.gov.kh krou.moeys youtube.com/moeys

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយ និងសំណួរទាក់ទងក្នុងអត្ថបទ ដូចជា សេចក្ដីលំអិត ខ្លឹមសារអត្ថបទ និងកាព្យរូបារម្មណ៍ ... ។

## គ. អត្ថបទ

[...] ទុំថាឱទាវនឹមនួនល្អង    ថ្ងៃនេះអញបងឃ្លាឃ្លាតពិត
មិនបានរួមស្ថានដួងជីវិត    ម្ល៉េះសមឆោមស្និទ្ធនៅកំព្រា ។
ដើរហើយពុំស្បើយរឹងចង្អៀត    ខំឆ្លៀតរំពៃក្នុងអធ្វា
ទុំរាប់ដើមឈើផងនានា    ដុះខាងមាគ៌ាជាជួរជ្រំ ។
មើលមានជ្រៃជ្រៃសង្កែថ្ងាន់    ត្រៀលត្រស់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ទម្ព    ទ្រនំអាអូដូចង្កួរត្នោត ។
ដង្កោទ្រយឹងខ្ទឹងក្រសាំង    អំពិលភ្លងភ្លាំងទាំងភ្លូបាត
គួលែនទុរេនមៀនលាំងសាត    មាក់បាតបង្គោញ្ញៅចាន់ចារ ។
ត្របែកត្រសេកអំបែងថ្ងៃ    អង្គ្រងស្មាច់ស្នែររោគរកា
ក្រូចក្រាយស្វាតស្វាយត្រាចត្រៀលស្វា    សេដាសណ្ដាន់ថ្ងាន់ជ្រៃជ្រៃ ។
មានទាំងដកពាយវាយដកព    សង្ឃ័រពង្រពាក់រាំងស្ទឹ
ភ្នំភ្នែងផ្ដែស្រែងលោតលាំងដៃ    សន្ទៃក្រខុបងប់ក្រឡាញ់ ។
ច្រមាសបុស្សនាគច្រកែងទួយ    ប្រផេញគោមួយឈើទាលត្រាញ់
រាជផ្ចឹសធ្មេញត្រីរៃអញ្ចាញ    អង្កាញ់អង្គោលកណ្ដោលបាត ។
ត្រាចត្រៀកចង្រៀតច្រេសខ្ទឹងក្ទម្ព    គគីរវាំងភ្នំបេងបាយម៉ាត
ស្ពុកស្ពុរស្ដីស្ដៅត្រាវក្ដួចក្ដាត    លាំងសាតសត្បារកាស្រល់ ។
ទុំដើរក្នុងព្រៃរំពៃសត្វ    ស្រងូតស្រងាត់ក្នុងចិត្តសល់
វិតក្កក្នុងកាយគិតខ្វាយខ្វល់    នឹកដល់ទាវស្រីមិនមានស្បើយ ។
ទុំមៀងមើលយល់ផលបុប្ផា    ហើយសរសើរថាឱផ្កាអើយ
ផ្កាដុះនៅនិត្យជិតបង្កើយ    ពិដោរមកហើយក្លិនថ្មីៗ ។
ពិដោរផលាផ្កាកំភ្លឹង    ដូចបងនែបនឹងទាវពិសី
ពិដោរបុប្ផាផ្កាចំប៉ី    ដូចបងនែបស្រីទាវឥតហ្មង ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

ចម្ប៉ាចំពើបទើបជួបគ្នា
ឥឡូវឃ្លាតឃ្លាទាវនួនល្អង
រំដួលអន់អួលពេកកន្លង
ចិត្តបងអាល័យថ្លៃកនិដ្ឋា ។
ឱបងពិដោរផ្កាក្រវាន់
ដូចក្លិនទាវស្បាន់ជិតកាយា
ពិដោរថ្មីៗដូចក្លិនផ្កា
ជាប់នៅជាយផាហ៊ុមក្រវាត់ ។
ដើរដោយវាលវែងត្រែងដុះត្រា
ទន់ទាបសុរិយាយាត្រាកាត់
មៀងមើលមេឃមីរពពករសាត់
ដូចកលបងខ្ទាត់ពីទាវមក ។
កន្លង់ក្រឡឹងផ្កាក្រឡាញ់
ដូចខ្លួនអង្គអញត្រាច់ដើររក
ពពេចពពូលហើរចូលជ្រក
ដូចអង្គអញមកនៅរួមកាយ ។
គ្រលីងគ្រលោងគ្រលែងវែក
ក្រឡុះហើរបែកគូហ្វូងហ្វាយ
ដូចបងបែកទាវថ្លៃនោមឆាយ
មកដល់ឋានអាយអង្គឯកា ។
ឱបងស្រណោះសត្វតាវៅ
យំក្នុងព្រៃជ្រៅសព្ទភាសា
ហាក់មាត់ទាវស្ងួននួនកនិដ្ឋា
ចរចាសាសងបងស្រមៃ ។
ត្រយងយំឆ្លងឆ្លើយគូវា
ហើរហើយបែកគ្នានៅច្រៀវព្រៃ
ដូចខ្លួនអង្គអញបែកទាវថ្លៃ
យូរថ្ងៃពុំសុខទុក្ខឥតស្បើយ ។
បងស្តាប់សូរស័ព្ទរៃកណ្តឹង
មាន់ព្រៃប្រែប្រើងរងាវឆ្លើយ
បងនឹករលឹកទាវទៀតហើយ
ទាវអើយសមស្ងួននួនកំព្រា ។
ដើរដោយព្រៃជ្រងរំលងជ្រៅ
ទទាហើរទៅទំទឹមគ្នា
ត្រសិតត្រសងហើរវេរា
សេកនាំគូវាសសៀរទំ ។
សារិកាស្រែករកគូសប្បាយ
ហើរឆ្វាយនាំញីស៊ីស្រគំ
សព្វសត្វច្រវាត់ក្នុងព្រៃភ្នំ
យាសយំឆ្លើយឆ្លងសងសម័យ ។
ថ្លាថ្លែងសម្តែងទុំនិងពេជ្រ
ខំស្រូតដើរត្រាច់ទាំងយប់ថ្ងៃ
បានដល់ភូមិស្រុកទុក្ខអាល័យ
ជួបម្តាយប្រស្រ័យសួរទៅមក ។
ទុំបានសាស័ព្ទប្រាប់ម្តាយថា
ខ្ញុំកូនមានការស្តេចឱ្យយក
ខ្លួនខ្ញុំនិងពេជ្របួនពន្លក
ទ្រង់ភ្នកហាបូទ័យល្បីទៅដល់ ។
ជាអ្នកចម្រៀងល្បែងល្បីល្បាយ
ហេតុនេះលោកម្តាយសុំតម្កល់
កុំអាក់កុំអន់កុំឱ្យសល់
ស្តេចស្គាល់ក្រមានក្នុងឋានអាយ ។

នាងម្ដាយទុំស្ដាប់សព្ទសម្ដី
បើកូនអ្នកទៅប្រយ័ត្នកាយ
កុំបាធ្វេធ្វេសប្រហែសខ្លួន
ប្រយ័ត្នកម្មាត់នៅខាងល្បែង
ទុំក្រាបប្រណិប័តន៍ហត្ថសំពះ
ដើរទៅដល់វត្តប្រាកដថ្វាយ
ឱនអង្គក្រួញក្រាបទាំងពីរនាក់
មានពុទ្ធដីកាសួរចង់ដឹងដាន
ទូលថាស្ដេចចាត់បម្រើមក
ទៅគាល់បម្រើជាភីលៀង
ពុទ្ធដីកាថាអើបម្រើក្សត្រ
កុំបាចូលចិត្តស្និទ្ធនឹងស្រី
បានចូលគាល់ក្សត្រប្រយ័ត្នប្រាណ
កុំចូលពេលស្ងាត់ប្រយ័ត្នការណ៍

កូនប្រាប់គប្បីអ្នកមាសម្ដាយ
ចូរថ្វាយខ្លួនអ្នកឱ្យជាក់ស្ដែង ។
កុំឃើញស្រីយួនពួនប្រទ្បែង
ខំស្វែងខំស្វះលះពីអាយ ។
លាម្ដាយរហ័សទាំងពីរកាយ
បង្គំរ៉ាប់រ៉ាយដំណើរប្រាណ ។
លោកគ្រូស្មោះស្ម័គ្រព្រះទ័យក្សាន្ត
ទុំសោតទូលថ្កានមិនមានល្អៀង ។
ដល់ហើយរើសយកជាចម្រៀង
គ្រូផ្ទៀងស្ដាប់ជាក់ភ្ញាក់ស្មារតី ។
យប់ថ្ងៃប្រយ័ត្នខ្លួនកុំបី
ខ្លាចអង្គចក្រីយកទោសា ។
ដំណោកទីឋានអង្គក្សត្រា
គាល់អង្គក្សត្រាព្រះបពិត្រ ។

*(ដកស្រង់ពីសៀវភៅ រឿង ទុំទាវ របស់ព្រះបទុមត្ថេរសោម ទំព័រ ៤៨-៥១)*

## សំណួរ

១. តើអត្ថបទកាព្យខាងលើនេះមានប្រភពមកពីណា ? អ្នកណា ជាអ្នកនិពន្ធ ?
២. តើអត្ថបទកាព្យខាងលើនេះនិយាយពីអ្វី ?
៣. ចូរបង្ហាញពីខ្លឹមសារអត្ថបទជាពាក្យសម្រាយ ។
៤. ចូរបង្ហាញនិងគូសគំនូសតាងចំណាប់ចួន វគ្គទី ១ និងទី ២ ឱ្យបានត្រឹមត្រូវ ។
៥. ចូរបង្ហាញពីកាព្យរូបារម្មណ៍ក្នុងអត្ថបទ ។
៦. តើសោភ័ណភាសាឬសិល្បៈភាសានៅក្នុងអត្ថបទកាព្យខាងលើស្ថិតនៅត្រង់ណា ?

youtube.com/moeys kroo.moeys.gov.kh facebook.com/moeys.gov.kh



# ប្រភពនៃអក្សរខ្មែរ



## ក. សិក្សាពាក្យគន្លឹះ

- អក្ខរក្រម : លំដាប់នៃអក្សរ ។
- ទេវនាគរី : តួអក្សរមួយបែបរបស់ពួកព្រាហ្មណ៍ដែលមានកំណើតក្នុងប្រទេសឥណ្ឌា ។
- វិវត្តន៍ : ប្រែប្រួល ផ្លាស់ប្តូរ ។
- ចារ : សរសេរ ។
- សម័យនគរភ្នំ (ហ្វូណន) : រាជាណាចក្រខ្មែរក្នុងអំឡុងគ្រិស្តសតវត្សទី១-៦ ។
- សំយោគ : ផ្សំគ្នា , រួមគ្នា ... ។
- រចនា : តុបតែង រៀបរៀង ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះអ្នកត្រូវអានដោយយកចិត្តទុកដាក់ ហើយកំណត់ចំណាំសេចក្តីលម្អិតសំខាន់ៗនៅក្នុងអត្ថបទ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងសេចក្តីលម្អិត ខ្លឹមសារ និងគំនិតសំខាន់បង្កប់មួយចំនួននៅក្នុងអត្ថបទឱ្យបានត្រឹមត្រូវ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys

## គ. អត្ថបទ

ក្រោយពីបានបង្កើតភាសាសម្រាប់និយាយប្រាស្រ័យទាក់ទងគ្នាក្នុងការរស់នៅមក មនុស្សតែងរិះរកមធ្យោបាយបង្កើតសញ្ញាផ្សេងៗ សម្រាប់កត់ត្រាពាក្យសម្ដី រឿងរ៉ាវ ព្រឹត្តិការណ៍ផ្សេងៗថែមទៀត ។ សញ្ញានោះលុះក្រោយមកក៏កើតបានជាតួអក្សរ ។

តាមការស្រាវជ្រាវរបស់លោក យូស៊ី មានអក្សរពីរបែបបានកើតឡើងនៅប្រទេសឥណ្ឌាប្រមាណជា ១០០០ឆ្នាំមុនគ.ស គឺអក្សរ ព្រាហ្មីនិងខារោស្ដ្រី ។ បណ្ដាអក្សរទាំងពីរបែបនេះបានផ្ដល់ដើមកំណើតអក្សរឯទៀតជាច្រើននៅប្រទេសឥណ្ឌា ។ ឯតួអក្សរព្រាហ្មីនោះកើតចេញមកអំពីអក្ខរក្រមបុរាណអំបូរសេមីត ក្នុងចំណោមអក្សរឥណ្ឌាជាច្រើនដែលកើតចេញពីអក្សរព្រាហ្មី អក្សរទេវនាគរីឬនាគរីត្រូវបានគេស្គាល់ជាងគេ ហើយគេយកមកកត់ត្រាភាសាសំស្ក្រឹត ។ លុះក្រោយមកអក្សរទេវនាគរីក៏ក្លាយទៅជាអក្សរសម្រាប់ជនជាតិឥណ្ឌាប្រើជាផ្លូវការហូតដល់សព្វថ្ងៃនេះ ។

តើអក្សរខ្មែរមានដើមកំណើតពីអក្សរណាដែរ ?

នៅសម័យនគរភ្នំ (ហ្វូណន) គេបានរកឃើញសិលាចារឹកមួយនៅវ៉ូកាញ់ ក្នុងភូមិភាគញ៉ាត្រាង (យួនខាងត្បូង) ដែលគេបានចាត់ទុកថា ជាសិលាចារឹកខ្មែរដំបូងបង្អស់ ប៉ុន្តែសេចក្ដីក្នុងសិលាចារឹកនេះជាភាសាសំស្ក្រឹត ។ តាមការសិក្សាប្រៀបធៀបអក្សរខ្មែរបុរាណទៅនឹងអក្សរឥណ្ឌាប៉ែកខាងត្បូងគេបានដឹងថាមានទ្រង់ទ្រាយដូចគ្នា ។ ម្យ៉ាងទៀត គេបានរកឃើញប្រាក់កាក់របស់ឥណ្ឌានៅអូរកែវ (កំពង់ផែរបស់ខ្មែរនៅមាត់សមុទ្រកម្ពុជាក្រោម) ដែលប្រាក់កាក់នោះ គេចារអក្សរព្រាហ្មីមានទ្រង់ទ្រាយដូចតួអក្សរខ្មែរបុរាណដែរ ។ ស្របតាមសម័យនោះ ខ្មែរនិងឥណ្ឌាមានទំនាក់ទំនងគ្នាញឹកញាប់ផង គេក៏សន្និដ្ឋានថាខ្មែរបានខ្ចីយកតួអក្សរឥណ្ឌាព្រាហ្មីមកប្រើ ។

អក្សរដែលខ្មែរ យកគំរូតាមអក្សរឥណ្ឌាខាងត្បូងមកប្រើប្រាស់ក្នុងសម័យនោះពុំដូចគ្នានឹងអក្សរសម័យបច្ចុប្បន្ននេះទេ គឺត្រូវបានកែប្រែទ្រង់ទ្រាយចំនួន១០ដងរួចមកហើយ ទើបបានជារូបរាងពិតប្រាកដដូចតួអក្សរដែលយើងប្រើប្រាស់សព្វថ្ងៃ ។ ខាងក្រោមនេះ គឺជាដំណើរវិវត្តន៍នៃព្យញ្ជនៈខ្មែរបុរាណ ៣បែប :




បើយើងប្រៀបធៀបតួព្យញ្ជនៈទាំង ៣បែប ឃើញថាមានសណ្ឋានខុសគ្នាឆ្ងាយ ហើយកាន់តែឆ្ងាយណាស់ទៅទៀតនឹងតួព្យញ្ជនៈសម័យបច្ចុប្បន្ននេះ ។

ព្យញ្ជនៈសម័យមុនអង្គរ : មានរាងគ្រោតគ្រាត មិនស្មើ មិនសម សក់ខ្លី ជើងខ្លី ហើយមានចំនួនតិច ។

ព្យញ្ជនៈសម័យអង្គរ : មានរាងសង្ហាមានសក់ជាក្បាច់រចនា ជើងមានស្មើរតែគ្រប់តួ ។

ព្យញ្ជនៈសម័យក្រោយអង្គរ : មានរាងទ្រេត សក់និងជើងវែងៗមានរូបរាងកាន់តែច្បាស់ ។

ដំណើរវិវត្តន៍មានច្រើនលើកច្រើនគ្រា តួអក្សររឹតតែច្រើនឡើង រឹតតែងាយសរសេរឡើង ហើយរឹតតែល្អឡើងប្រកបដោយក្បូរក្បាច់យ៉ាងសមរម្យ ។ នេះហើយជាស្នាដៃនៃបុព្វបុរសខ្មែរ ដែលមានទេពកោសល្យខាងកែសម្រួលនិងខាងបង្កើតថ្មី ដើម្បីបំពេញនូវកង្វះខាតរបស់ខ្លួន ។

facebook.com/moeys krou.moeys.gov.kh youtube.com/moeys

ក្រោយដែលមានកំណើតមាំមួននិងវិវត្តន៍ពេញរូបរាងមែនទែនហើយ អក្សរខ្មែរមានលក្ខណៈពិសេសរបស់ខ្លួនពិតប្រាកដ ។

អក្សរពុំមែនជាសញ្ញាដាច់ដោចចេញពីគ្នា ដែលគេចេះតែយកមកកត់សម្គាល់សំឡេងក្នុងភាសានីមួយៗនោះឡើយ ប៉ុន្តែអក្សរ គឺជាកម្រងសញ្ញាដែលទាក់ទងគ្នាជាក្បួន ជាវិធីស្ថិតនៅលើមូលដ្ឋានឬគោលណាមួយជាដរាប ។ យ៉ាងណាមិញអក្សរខ្មែរក៏ដូចនោះដែរ ពោលគឺជាក្បួននៃតួសញ្ញាដែលទាក់ទងគ្នាទៅលើមូលវិធីដ៏សំខាន់មួយចំនួនគួរកត់សម្គាល់ ។

នៅក្នុងអក្សរខ្មែរ គេនិយមភ្ជាប់ស្រៈនិងព្យញ្ជនៈឱ្យជាប់ ដែលជាហេតុនាំឱ្យមានទំនាក់ទំនងទៅវិញទៅមករវាងស្រៈនិងព្យញ្ជនៈ ។ ទំនាក់ទំនងនេះបណ្ដាលឱ្យកើតមាន**ស្រៈកប់តួឬស្រៈអនុស័យ** ក្នុងព្យញ្ជនៈទាំងនេះ ។ ស្រៈកប់តួខ្មែរមានពីរប្រភេទគឺ **អ-អ៊** ។ ឯស្រៈកប់តួបាលីមានតែមួយគឺ **អៈ** ដោយមានស្រៈអនុស័យពីរបែបកប់នៅក្នុងព្យញ្ជនៈនេះហើយ ទើបនាំឱ្យមាន**ព្យញ្ជនៈអនុស័យ** ពីរបែបដែរ គឺព្យញ្ជនៈអនុស័យពួក **អ** ដូចជា **ក ខ ច ឆ ដ ឋ ...** និងព្យញ្ជនៈ អនុស័យពួក **អ៊** ដូចជា **គ ឃ ជ ឈ ទ ធ ...** ។

ចំណែកស្រៈនិស្ស័យដូចជា ា ិ ី ឹ ឺ ុ ូ ក៏ចែកជាពីរប្រភេទស្របទៅនឹងព្យញ្ជនៈអនុស័យពួក **អ** និងពួក **អ៊** ដូចនេះទៀត ប៉ុន្តែមានសញ្ញាសម្គាល់តែមួយបែប (ឧ. សញ្ញាសម្គាល់ **អា** ផង **អ៊ា** ផង) ។

អាស្រ័យដោយមានស្រៈអនុស័យក្នុងព្យញ្ជនៈបែបខាងលើនេះ ហើយទើបព្យញ្ជនៈអនុស័យមួយតួៗអាចទៅជាព្យាង្គមួយបាន ។

***ឧទាហរណ៍ :*** ត (តទល់) ខ (ខត្រី) ស(ពណ៌ស) ។

លក្ខណៈពិសេសនេះខុសប្លែកអំពីអក្សររ៉ូម៉ាំងមានអក្សរបារាំងជាដើម ដែលព្យញ្ជនៈមួយតួពុំអាចទៅជាព្យាង្គមួយបានទេ ដូចជាព្យញ្ជនៈ **b. k. p. l** ជាដើម និងអាចទៅជាព្យាង្គមួយបាន លុះត្រាតែមានស្រៈប្រកបជាមួយ ។

ឯអក្សរខ្មែរ ព្យញ្ជនៈពីរតួនៅរៀងគ្នា ក៏អាចទៅព្យាង្គមួយបានដែរដូចពាក្យ មក បង (តួ “ម” និងតួ “ប” ជាព្យញ្ជនៈដើមព្យាង្គ ឯតួ “ក” និងតួ “ង” ជាព្យញ្ជនៈប្រកប ។ ពិតមែនតែពុំមានសញ្ញាសម្គាល់ថាពុំមានស្រៈអនុស័យក្នុងព្យញ្ជនៈប្រកបដូចនេះក៏ដោយ ក៏ខ្មែរយើងពុំអាចច្រឡំបានទេ ព្រោះគេអាចដឹងបានដោយសារន័យរបស់ពាក្យនោះ ។ ***ឧទាហរណ៍*** ទូកង លើកដាក់លើក ពានាស ។

ចំណែកនៅក្នុងអក្សររ៉ូម៉ាំងដែលនិយមផ្ដាច់ស្រៈចេញអំពីព្យញ្ជនៈ ហើយដែលពុំនិយមប្រើស្រៈអនុស័យ ព្យញ្ជនៈអនុស័យដូចខ្មែរនោះព្យញ្ជនៈ ២ ឬ ៣ តួនៅជិតគ្នាពុំអាចទៅជាព្យាង្គបានទេ ប៉ុន្តែជាព្យញ្ជនៈសំយោគឬព្យញ្ជនៈផ្សំទៅវិញ ។ ***ឧទាហរណ៍ :*** tr ( trouver), sp (splendeur) ។

រីឯព្យញ្ជនៈសំយោគខ្មែរ ពុំសរសេរតួព្យញ្ជនៈរៀងគ្នាដូចនេះទេ គឺសរសេរត្រួតព្យញ្ជនៈលើគ្នាទៅវិញ ជាបុព្វហេតុមួយយ៉ាងសំខាន់បណ្តាលឱ្យមានការបង្កើតជា ជើង របស់ព្យញ្ជនៈឡើង។ ដូចនេះហើយបានជាយើងឃើញថា ព្យញ្ជនៈនីមួយៗនៅក្នុងសម័យបច្ចុប្បន្នសុទ្ធតែមានជើង ការបង្កើតជើងព្យញ្ជនៈនេះ គឺដើម្បីយកទៅសរសេរផ្ញើក្រោមព្យញ្ជនៈមួយទៀត ឱ្យមានសភាពត្រួតគ្នាផ្សំសំឡេងគ្នាព្យញ្ជនៈសំយោគ គឺព្យញ្ជនៈផ្សំនេះឯង។ ***ឧទាហរណ៍*** ខ្យ (ខ្យល់) ខ្ល (ខ្លី) ក្រ។

ក្រៅពីនេះ ជើងនៃព្យញ្ជនៈសម្រាប់ប្រើជាព្យញ្ជនៈដើមព្យាង្គ នៃព្យាង្គតម្រួតថែមទៀត។

***ឧទាហរណ៍ :*** ពន្យល់ : ពន់ (ព្យាង្គទី១) + យល់ (ព្យាង្គទី២)

ជើង "◌្យ" ក្នុងពាក្យ "ខ្យល់" និងជើង "◌្យ" ក្នុងពាក្យ "ពន្យល់" ពិតមែនតែមានរូបរាងដូចគ្នាក៏ដោយ ក៏ពុំមានមុខងារដូចគ្នាដែរ។ ក្នុងព្យញ្ជនៈសំយោគជើងព្យញ្ជនៈ គឺខ្យល់ផ្សំជាមួយនឹងព្យញ្ជនៈត្រួតលើ។ ចំណែកឯជើងព្យញ្ជនៈក្នុងព្យាង្គតម្រួតវិញ ពុំមែនជាសំឡេងផ្សំទេ គឺជាព្យញ្ជនៈដើមព្យាង្គតម្រួត នេះឯង។

យើងបានឃើញថា វិធីផ្ញើជើងនេះជាមែកធាងបែកចេញអំពីមូលវិធីអនុស័យស្រៈព្យញ្ជនៈ ហើយវិធីផ្ញើជើងនេះមានវិបាកសំខាន់ៗដែល ប្រព្រឹត្តទៅនៅលើក្បួនវិធីដ៏ច្បាស់លាស់ណាស់។

លក្ខណៈពិសេសមួយទៀតរបស់អក្សរខ្មែរយើង គឺព្យញ្ជនៈមាន សក់។ តើសក់នោះមានប្រយោជន៍យ៉ាងណាដែរ ?

រួចមកហើយយើងបានឃើញគេយកសក់ "◌៊"(អ្នកខ្លះហៅថាសក់ "ក") ដែលមានសណ្ឋានដូចជាលេខ ៣ ហើយដែលបាលីហៅថា ត្រីសព្ទមកប្រើដាក់លើ ព្យញ្ជនៈឯទៀតពុំឃើញយកមកប្រើផងទេ។ យើងយល់ថាការធ្វើឱ្យព្យញ្ជនៈមានសក់ពុំមែនជាការឥតប្រយោជន៍ឡើយ ផ្ទុយទៅវិញសក់ព្យញ្ជនៈ គឺជាក្បាច់ ដែលបុព្វបុរសយើងបានរចនាឡើងដើម្បីលំអព្យញ្ជនៈនីមួយៗឱ្យមានសភាពសមសួនឡើង។ ចំណែកអក្សរសៀម-ឡាវ ដែលយកលំនាំអក្សរតាមខ្មែរយើង ហើយយកទៅកែប្រែលុបសក់ចេញមើលទៅហាក់ដូចជាមនុស្សដែលមានក្បាល ប៉ុន្តែអត់សក់ដូចនោះដែរ។

ក្រោយដែលបានសិក្សាអំពីប្រភពវិវត្តន៍និងលក្ខណៈពិសេសនៃអក្សរខ្មែរមកយើងបានឃើញថាខ្មែរបានយកលំនាំតាមអក្សរឥណ្ឌាមកប្រើប្រាស់ជាលើកដំបូងក៏ពិតមែន ក៏ប៉ុន្តែបន្ទាប់មកខ្មែរមានទេពកោសល្យខាងច្នៃឱ្យបានសមសួនខាងបង្កើតថ្មីឱ្យសម្បូរគ្រប់គ្រាន់ព្រមទាំងឱ្យមានក្បួនខ្នាតមានវិធីច្បាស់លាស់សម្រាប់ជាតិខ្មែរ យកទៅប្រើការបានយ៉ាងងាយក្នុងការកត់ត្រាគំនិតសញ្ចេតនា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។ល។ [...]

*(ដកស្រង់ពីសៀវភៅអរិយធម៌ខ្មែររបស់អ្នកស្រី ត្រឹង ងា គ.ស ១៩៧៤)*

## សំណួរ

១. តើអត្ថបទខាងលើនេះនិយាយពីអ្វី ?

២. តើអក្សរខ្មែរមានប្រភពមកពីណា ?

៣. តើអក្សរខ្មែរមានការវិវត្តប៉ុន្មានលើកមកហើយ ? ហើយមានលក្ខណៈពិសេសដូចម្ដេចខ្លះ ?

៤. តើអក្សរខ្មែរមានលក្ខណៈខុសពីអក្សរឡាវនិងសៀមត្រង់ណាខ្លះ ?

៥. ចូរបង្ហាញខ្លឹមសារនៃអត្ថបទ ។

៦. ចូររកគំនិតសំខាន់បង្កប់នៅក្នុងអត្ថបទ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# ការនិយាយប្រៀបធៀប

ការប្រៀបធៀប គឺជាការប្រដូច ឬប្រៀបផ្ទឹមគ្នានូវរបស់ពីរវត្ថុពីរ ទស្សនៈ យោបល់ ឬគំនិតពីរ ។ល ។ ដើម្បីបង្ហាញពីលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា ។

ដើម្បីងាយស្រួលក្នុងការប្រៀបធៀប អ្នកត្រូវស្គាល់សំនួនមួយចំនួននិងរបៀបប្រើប្រាស់សំណួរប្រៀបធៀបនេះជាមុនសិន ។ សំនួនប្រៀបធៀបមានពីរ គឺសំនួនប្រៀបធៀបលក្ខណៈដូចគ្នានិងសំនួនប្រៀបធៀបលក្ខណៈខុសគ្នា ។

## ១ . សំនួនប្រៀបធៀបលក្ខណៈដូចគ្នា

ចូរពិនិត្យឧទាហរណ៍ខាងក្រោម

- ប្រទេសណាក៏មានភាសានិងវប្បធម៌អរិយធម៌របស់ខ្លួនដែរ ។
- ព្រះពុទ្ធសាសនាមានពន្លឺ ភ្លឺថ្លាដូចពេជ្រពណ្ណរាយ ។
- តោថ្មឈររទ្រឹងនឹងដូចគល់ឈើ ។
- គាត់យំដូចកូនក្មេង ។
- អ្នកប្រាជ្ញខ្លះចាត់ទុកសម្ដីថ្លៃស្មើនឹងមាស ។

តាមឧទាហរណ៍ខាងលើនេះ យើងឃើញថាពាក្យ ក៏...ដែរ ប្រហាក់ប្រហែល ឬប្រហាក់ប្រហែលនឹង ដូច នឹង ស្មើនឹង ... គឺជាសំនួនប្រៀបធៀបលក្ខណៈដូច ។

ដូចនេះដើម្បីប្រៀបធៀបលក្ខណៈដូចគ្នា គេត្រូវប្រើសំនួន : ក៏ ... ដែរ ដូច នឹង ស្មើនឹង ប្រហាក់ប្រហែលនឹង ... ។

## ២ . សំនួនប្រៀបធៀបលក្ខណៈខុសគ្នា

ចូរពិនិត្យឧទាហរណ៍ខាងក្រោម

- ផ្ទុយពីខ្ញុំ សុធាចូលចិត្តចម្រៀងបរទេស ។
- ខុសស្រឡះពី សុធា ខ្ញុំចូលចិត្តចម្រៀងខ្មែរ ។
- ពូសននិយាយច្រើន រីឯមីងសាន បែរជានិយាយតិចទៅវិញ ។
- ប្រាសាទព្រះវិហារល្អស្អាត សង់នៅលើភ្នំ ប៉ុន្តែប្រាសាទអង្គរវត្តសង់លើផ្ទៃរាប ។
- សុខារៀនអក្សរពូកែលេខមួយ ។ ផ្ទុយទៅវិញប្អូនរបស់វារៀនបានលេខក្រោយគេ ។
- ភាសាខ្មែរមិនដូចភាសាអង់គ្លេស ហើយក៏មិនដូចភាសាបារាំងដែរ ។
- កូនមីងផងមានមុខមាត់មិនដូចគាត់សោះ ។

- តម្លៃសៀវភៅនេះមិនប្រហាក់ប្រហែលនឹងសៀវភៅដែលខ្ញុំទិញមុនសោះ ។

តាមល្បះនីមួយៗខាងលើយើងឃើញថាមានពាក្យ ៖ ផ្ទុយពី ខុសស្រឡះ បែរជា ... ទៅវិញ ផ្ទុយទៅវិញ មិនដូច មិនប្រហាក់ប្រហែលនឹង ប៉ុន្តែ មិនស្មើនឹង ។ល។ គឺជាសំនួនប្រៀបធៀបលក្ខណៈខុសគ្នា ។

ដូចនេះ ដើម្បីប្រៀបធៀបលក្ខណៈខុសគ្នា គេប្រើសំនួន ៖ ផ្ទុយពី ខុសស្រឡះពី បែរជា ... ទៅវិញ ប៉ុន្តែ ផ្ទុយទៅវិញ មិនដូច មិនស្មើនឹង មិនប្រហាក់ប្រហែលនឹង ។ល។

**កំណត់សម្គាល់ ៖** ការប្រៀបធៀបអាចមានទំហៀបផ្តាច់ ។

*ឧទាហរណ៍ ៖*

- គំនិតនេះសមរម្យជាងគំនិតនោះ ។
- ប្រាសាទនេះមានក្បាច់រចនាល្អលើសកល ។
- យុវជននេះច្រៀងពីរោះគ្មានគូប្រៀប ។

ពាក្យ " ជាង លើសគេ គ្មានគូប្រៀប " ជាសំនួនប្រៀបធៀបលក្ខណៈផ្តាច់គេ ឬទំហៀបផ្តាច់ ។ សំនួនទំហៀបផ្តាច់មាន "លើសគេ ជាង គ្មានប្រៀប ផ្តាច់ បំផុត ..." ។

## លំហាត់

ចូរអ្នកប្រៀបធៀបការវិវត្តនៃតួព្យញ្ជនៈខ្មែរទាំងបីដំណាក់កាលធំៗ ដែលអ្នកបានសិក្សារួចហើយនោះគឺ សម័យមុនអង្គរ សម័យអង្គរ និងក្រោយអង្គរ ។ បន្ទាប់មក ចូរអ្នកប្រៀបធៀបមើលថា ព្យញ្ជនៈសម័យកាលណាមួយដែលមានលក្ខណៈដូចគ្នាច្រើនជាងគេទៅនឹងព្យញ្ជនៈខ្មែរយើងបច្ចុប្បន្ននេះ ។ ការប្រៀបធៀបនេះត្រូវផ្តោតទៅលើចំណុចសំខាន់ៗខាងក្រោម ៖

- ចំនួនតួព្យញ្ជនៈសរុប
- ចំនួនតួព្យញ្ជនៈតាមវគ្គ
- ទម្រង់តួព្យញ្ជនៈនីមួយៗ
- ជើងព្យញ្ជនៈមួយចំនួន ។

youtube.com/moeys grou.moeys.gov.kh facebook.com/moeys.gov.kh

# សំណេរសំយោគ

ប្អូនបានសិក្សារួចហើយអំពីសំណេរពន្យល់ សំណេរបំពេញ លិខិតផ្លូវការ កិច្ចសន្យា ជួល លក់ សំណេរវិភាគអត្ថបទ និងសំណេរសំយោគលើទស្សនៈមតិយោបល់អ្វីមួយ ។

ក្នុងមេរៀននេះ ប្អូននឹងសិក្សាពីសំណេរសំយោគទៅលើទស្សនៈស្តីពីបញ្ហាភាសាខ្មែរ ។

ចូរអានអត្ថបទគំរូខាងក្រោម ៖

បញ្ហាដើមកំណើតជាតិខ្មែរ ជាប្រធានបទសំខាន់មួយសម្រាប់អ្នកសិក្សាស្រាវជ្រាវអំពីអរិយធម៌ខ្មែរ ។ ជាយូរមកហើយ អ្នកសិក្សាស្រាវជ្រាវពីខ្មែរ បានខិតខំដោះស្រាយនូវបញ្ហាដ៏សំខាន់នេះ ហើយបានបញ្ចេញជាយោបល់ប្លែកៗគ្នា ហើយជួនកាលក៏ផ្ទុយគ្នាស្រឡះតែម្តង ។ ប៉ុន្តែ យើងអាចប្រមូលយោបល់ទាំងនោះបានជាពីរក្រុម ：

**យោបល់ក្រុមទី ១ ：** គេយល់ថាជាតិខ្មែរជាជាតិអន្តោប្រវេសន៍ចេញពីប្រទេសឥណ្ឌា ហើយលុកលុយដណ្តើមយកទឹកដីរបស់ជាតិដើមមួយ គឺជនជាតិក្នុងអំបូរម៉ាឡាយូ-ប៉ូលីណេស៊ីយាង ។ ទស្សនៈនេះត្រូវបានលើកឡើងមុនគេ ដោយលោក **Hendrick kerns** ។ បន្ទាប់មកទៀតក៏មានអ្នកស្រាវជ្រាវខ្លះយល់ស្របតាម ដូចលោក **Adhémard Letére** និងលោក **Pierre Gourou** ជាដើម ។ លោក **Pierre Gourou** បានទាំងបញ្ជាក់ថាជនជាតិ មន-ខ្មែរ ប្រហែលជាត្រូវពួកទ្រាវិឌ ដែលពួកអារ្យច្រានចេញពីប្រទេសឥណ្ឌា ហើយដោយមាននៅសេសសល់ក្រុមខ្លះដូចជាពួកមុណ្ឌបានមកលុកលុយប្រទេសភូមា ប្រទេសសៀម និងប្រទេសកម្ពុជា ។ គេអាចបញ្ចូលទៅក្នុងក្រុមអ្នកស្រាវជ្រាវទីមួយនេះដែរដូចជា លោក **Etienne Aymonier** ដែលយល់ថាក្រុម មន-ខ្មែរមុណ្ឌ មានទីតាំងដើមនៅជើងភ្នំទីបេ ហើយក្រោយមកបានបំបែកជាពីរក្រុម មួយក្រុមគឺ "មន-ខ្មែរ" ចូលមកតាំងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ឯមួយក្រុមទៀតគឺ "មុណ្ឌ" ចូលទៅនៅក្នុងប្រទេសឥណ្ឌារហូតដល់សព្វថ្ងៃ ។

**យោបល់ក្រុមទី ២ ：** គេទទួលស្គាល់ថា ជាតិខ្មែរជាជាតិពិសេសមួយ ស្ថិតនៅក្នុងក្រុម មន-ខ្មែរ ហើយបានមកកកើតឡើង នៅភូមិភាគអាស៊ីអាគ្នេយ៍នេះតាំងពីបុរាណមកម្ល៉េះ នេះគឺជាយោបល់របស់លោក **Bernad philippe Grosier** (កាលពីមុនជាអភិរក្សអង្គរ) និងលោក **Marcel Talabol** ជាដើម ។ លោកទាំងពីរនេះយល់ឃើញថា ក្នុងសម័យបុព្វប្រវត្តិសាស្ត្រដ៏យូរលង់មកហើយ មានមនុស្សជាច្រើនក្រុមបានធ្វើដំណើរពីខាងជើងចុះមកភូមិភាគអាស៊ីអាគ្នេយ៍ ដូចជាពួកអូស្ត្រាឡូអ៊ីដ មេឡាណេស៊ីយាង និងឥណ្ឌូណេស៊ីយាង ។ អំបូរ មន-ខ្មែរ បានកើតឡើងដោយការកាត់ផ្សំរវាងពួកឥណ្ឌូណេស៊ីយាងនិងពួកមេឡាណេស៊ីយាង ហើយបានរស់នៅរាយប៉ាយលើទឹកដី ដែលលាតសន្ធឹងពីឥណ្ឌូចិន ជ្រោយម៉ាឡាយូ ដល់ព្រំប្រទល់ប្រទេសឥណ្ឌា ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

**សំយោគ :** យោបល់នៃក្រុមទីពីរនេះមានលក្ខណៈស្របទៅនឹងទស្សនៈរបស់ខ្មែរ ពីព្រោះបើយើងសម្អាងទៅលើរឿងព្រេងខ្មែរក៏ដោយ លុះត្រាតែមាននាងនាគនៅស្រុកខ្មែរនេះឯងទើបព្រះថោង (ដែលគេថាមកពីស្រុកឥណ្ឌា) បានជួបភប់ប្រសព្វគ្នាដោយបានគ្រប់គ្រងស្រុកគោកធ្លកនេះដែរ ។ បានសេចក្តីថា លុះត្រាតែមានជាតិខ្មែរនៅលើកោះគោកធ្លកនេះដែរ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះចូលក្នុងស្រុកខ្មែរ ។

**សន្និដ្ឋាន :** សេចក្តីក្នុងរឿងព្រេងនេះសឱ្យឃើញទៀតថា ចំពោះខ្មែរយើង ជាតិខ្មែរមានប្រភពនៅក្នុងស្រុកខ្មែរនេះឯង ។

ចំពោះបញ្ហាដើមកំណើតនៃជាតិសាសន៍ខ្មែរនេះអ្នកប្រាជ្ញអន្តរជាតិ បានបញ្ចេញសម្មតិកម្មច្រើនបែបច្រើនយ៉ាងណាស់ តែលោកបានស្របយោបល់គ្នាត្រង់ចំណុចដែលថាខ្មែរជាជាតិមួយស្ថិតនៅក្នុងអំបូរពិសេសមួយ គឺអំបូរមន-ខ្មែរ ឬខមនេះឯង ។

## សំណួរ

១. តើអត្ថបទខាងលើនេះនិយាយពីអ្វី ?

២. តើយោបល់ក្រុមទី១មានន័យដូចម្តេច ?

៣. តើយោបល់ក្រុមទី១និងទី២ យោបល់ណាមួយត្រឹមត្រូវជាងគេ ?

៤. ចំពោះប្អូនវិញ តើប្អូនយល់ថាជនជាតិខ្មែរមានដើមកំណើតពីណា ?

៥. តើយោបល់ក្រុមទាំងពីរមានចំណុចរួមត្រង់ណាខ្លះ?

## លំហាត់

ប្អូនបានសិក្សារួចមកហើយអំពីភាសានិងលក្ខណៈពិសេសរបស់ភាសាខ្មែរនៅមេរៀនទី ៣ ។

ចូរប្អូនសរសេរសំណេរសំយោគលើទស្សនៈដូចខាងក្រោម មានមតិមួយពោលថា "ភាសាខ្មែរមានប្រភពពីភាសាបាលីសំស្ក្រឹត" ។ ឯមតិមួយទៀតពោលថា"ភាសាខ្មែរស្ថិតក្នុងអំបូរភាសាខ្មែរ-មន" ។

ពេលប្អូនសរសេរត្រូវអនុវត្តសំណេរតាមគម្រោងដូចខាងក្រោម

### ១ . សេចក្តីផ្តើម : (សរសេរនាក់ខខ)

- បញ្ហាទូទៅនៃភាសាខ្មែរ
- ការចាប់អារម្មណ៍រួមទៅលើប្រភពនៃភាសាខ្មែរ ។

## ២ . តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី
- ការបង្ហាញពីមតិទី ១និងអំណះអំណាង
- ការបង្ហាញមតិទី ២និងអំណះអំណាង
- សំយោគមតិទី ១និងទី ២ រកលក្ខណៈរួម
- សន្និដ្ឋាន : តើមតិណាមួយត្រឹមត្រូវនិងសមហេតុផលជាង

## ៣ . សេចក្ដីបញ្ចប់

- យោបល់ចំពោះមតិដែលត្រឹមត្រូវនិងការវាយតម្លៃ
- បញ្ចេញទស្សនៈផ្ទាល់ខ្លួនចំពោះមតិដែលត្រឹមត្រូវរបស់ប្រធានដែលលើកឡើង ។

ពេលសរសេរប្អូនត្រូវធ្វើសេចក្ដីព្រាង ហើយពេលធ្វើសេចក្ដីព្រាងចប់មុននឹងសរសេរសម្រេច ចូរអ្នកពិនិត្យឡើងវិញថា ៖

- តើសំណេររបស់អ្នកមានបង្ហាញពីចំនួនពាក្យពេចន៍ ឃ្លា ល្បះ បានត្រឹមត្រូវ និងមានកំហុសអក្ខរាវិរុទ្ធដែរឬទេ ?
- តើសំណេររបស់អ្នកមានលំដាប់លំដោយ គំនិតសមហេតុផល និងមានអំណះអំណាងគ្រប់គ្រាន់សម្រាប់ការពារឬគាំទ្រមតិនីមួយៗហើយឬនៅ ?
- តើសំណេររបស់អ្នកត្រឹមត្រូវតាមចំណុចណែនាំក្នុងគម្រោង (ផ្ដើមសេចក្ដី តួសេចក្ដី សេចក្ដីបញ្ចប់) គ្រប់ចំណុចដែរឬទេ ?
- តើការសំយោគនិងវាយតម្លៃលើទស្សនៈប្រធាន មានអំណះអំណាងគ្រប់គ្រាន់ត្រឹមត្រូវដោយផ្អែកលើមូលដ្ឋានណាមួយច្បាស់លាស់ហើយឬនៅ ?

មេរៀនទី ៦

# ការទទួលស្គាល់ការពិត





ការទទួលស្គាល់ការពិត គឺជាការទទួលស្គាល់នូវរឿងរ៉ាវ ហេតុការណ៍ ឬអ្វីៗដែលកើតមានឡើងប្រាកដជាក់ស្តែង ទោះជារឿងរ៉ាវ ហេតុការណ៍ទាំងនោះកើតឡើងពីអតីតកាល ឬក៏បច្ចុប្បន្នកាលក្តី។ គេមិនអាចបិទបាំង ឬគេចវេះពីការពិតបានជារៀងរហូតនោះទេ។ ដូចនេះយើងត្រូវតែទទួលយកការពិត ឬក៏ហ៊ានប្រឈមនឹងការពិត ដើម្បីជាបទពិសោធសម្រាប់បច្ចុប្បន្ននិងអនាគត។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់ពីរឿងរ៉ាវ ហេតុការណ៍មួយចំនួនដែលកើតឡើងពីអតីតកាលនិងបច្ចុប្បន្នកាល។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីលក្ខណៈសម្គាល់អត្ថបទល្ខោននិងប្រភេទល្ខោនមួយចំនួន បុរេនិច្ឆ័យ ផ្អាក់និងឈ្នាប់ បំណកស្រាយអត្ថន័យពាក្យស្លោក សុភាសិត និងសំណោរប្រៀបធៀប។

# មាគ៌ាជីវិតរបស់មាលា



## ក. សិក្សាពាក្យគន្លឹះ

- ទ្រុស្តមិត្ត : មិត្តអាក្រក់ មិត្តសាមាន្យ មិត្តឃោរឃៅ ។
- ដំបៅជីវិត : បញ្ហាដ៏សោកសៅរបស់ជីវិត ។
- សុភមង្គល : សេចក្តីសុខទាំងផ្លូវកាយនិងផ្លូវចិត្ត ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងរចនាបថល្ខោន ទំនាស់ ។

## គ. អត្ថបទ

ស្ថានភាពរឿង ៖

ក្រោយពីជួបគ្រោះថ្នាក់ក្នុងការធ្វើដំណើរតាមសំពៅហើយមិនស្លាប់ ភូរិន្ទបានវិលត្រឡប់មកឧត្តរបូរីវិញ គេក៏នាំដំណឹងនេះមកប្រាប់មាលាថា ប្តីនាងឈ្មោះចំរុងនិងអ្នកដែលនៅក្នុងសំពៅទាំងប៉ុន្មានស្លាប់អស់ទៅហើយ ។ ដោយអស់សង្ឃឹមនិងដោយបានការជួយទំនុកបម្រុងសព្វបែបយ៉ាងពីភូរិន្ទ មាលាក៏សម្រេចចិត្តរៀបការជាមួយភូរិន្ទដែលត្រូវជាមិត្តភក្តិប្តីនាងរហូតមានគភ៌បានប្រាំខែ ។

ថ្ងៃមួយស្រាប់តែលេចមុខចំរុងវិលត្រលប់មកវិញ ហើយនិយាយរឿងរ៉ាវទាំងអស់ ដែលរូបគេជួបប្រទះនៅពេលលិចសំពៅនោះឱ្យនាងមាលាស្ដាប់ ។ បន្ទាប់មកចំរុងដឹងថា មាលានិងភូរិន្ទជាប្ដីប្រពន្ធនឹងគ្នាក៏មានការខឹងសម្បារយ៉ាងខ្លាំង ឈានចូលដល់ការប្រយុទ្ធគ្នាជាមួយភូរិន្ទដោយកម្លាំងបាយថែមទៀត ... ។

- មាលា : បងចំរុង អូនពិតជាខុសមែន សូមបងជេរស្ដីតិះដៀលឱ្យអស់ចិត្តចុះ ឱ្យសមនឹងកំហុសរបស់អូន (យំ) ។
- ភូរិន្ទ : អូនមាលា ! តាមពិតរវាងយើងទាំងបីនាក់សុទ្ធតែគ្មានកំហុសទាំងអស់គ្នាមិនអាចនរណាបន្ទោសអ្នកណាបានទេ គឺមាគ៌ាជីវិតនាំឱ្យយើងបត់បែនអ៊ីចឹងណ៎ា ... ។
- ចំរុង : វាគ្មានមាគ៌ាជីវិតស្អីទេ តាមពិតឯងនេះមនុស្សទ្រុស្តមិត្ត ឆ្លៀតពេលដែលយើងមានគ្រោះថ្នាក់ ឯងមកឆក់ប្លន់សេចក្ដីស្នេហារបស់យើង ។ (និយាយដោយកំហឹង)
- ភូរិន្ទ : មិនអ៊ីចឹងទេចំរុង មកពីគ្នាស្មានថាឯងស្លាប់បាត់ទៅហើយណ៎ា ...
- ចំរុង : អូនមាលា
- មាលា : ចាស៎បង ! (កំពុងយំ)
- ចំរុង : ឥឡូវនេះ អូនបានឃើញស្រាប់ហើយថា បងនៅរស់ទេណាអូន បងបានវិលត្រឡប់មកផ្ទះសម្បែងវិញហើយ ដូច្នេះបើអូនបោះបង់ភូរិន្ទជាប្ដីក្រោយនេះចោល បងនៅតែទទួលអូនជាភរិយា ហើយស្រឡាញ់ថ្នាក់ថ្នមឱ្យដូចពីដើមដដែល ។
- មាលា : បងចំរុង ... បងចំរុង ... បងល្អនឹងអូនណាស់ ប៉ុន្តែ ... ប៉ុន្តែ ...
- ចំរុង : ប៉ុន្តែ ... យ៉ាងម៉េច ?

មាលា : (ច្រៀង) អូនសែនអើយស្រណោះអើយ អើយ អាលោះអើយឱអាល័យអើយ រូបប្រុសឱចរណៃ អើយ ស្វាមីអើយឱកម្សត់ ។ បងអើយឱចិត្តអូន អើយ អើយមិនមែនឱផិតក្បត់ ស្នេហ៍យើងត្រូវព្រាត់ អើយ អើយដោយព្រេងវាសនា ។ ពេលនេះឱហួសអើយ អូនវែងអើយឱសោកាអើយសូមម្ចាស់ឱជីវ៉ាអើ អើយមេត្តាអូនផង ។

- ចំរុង : ហេតុអ្វី ? ហេតុអ្វី ? បានជាអូនពុំព្រម (ស្រែក) តើគេមានអនុស្សាវរីយ៍ច្រើនជាងបង ហ្អែ ?
- មាលា : មិនមែនដូច្នេះទេបងចំរុង ចិត្តអូនដែលធ្លាប់ស្រឡាញ់បងប៉ុណ្ណានៅតែស្រឡាញ់ដដែលអត់ស្រែកស្រុតឡើយ ប៉ុន្តែឥឡូវនេះ អ្វីៗកន្លងហួសអស់ទៅហើយពុំអាចវិលត្រឡប់បានទេ បង ... លើសពីនេះ អូនថែមទាំងមានផ្ទៃពោះជាមួយនឹងបងភូរិន្ទទៅហើយ អូនមិន

ចង់ឱ្យអនាគតរបស់កូនវាធ្លាក់ក្នុងភាពច្របូកច្របល់អាស្រូវដូចអូនទៀតទេ សូមបងយល់ចិត្តអូនផង ។

- ចំរុង : រវាងបងនិងភូរិន្ទ តើអូនស្រឡាញ់នរណា ?
- មាលា : អូនស្រឡាញ់ ... អូនស្រឡាញ់បង ប៉ុន្តែ ... ប៉ុន្តែអូនអាណិតបងភូរិន្ទដែរ ។ អូនពុំអាចលះបង់គាត់បានទេ ។
- ចំរុង : ហ៊ឺស ! (ពោលដោយកំហឹង) ចិត្តសាវាមែន ។ ចុះចេញពីផ្ទះរបស់យើងភ្លាមទៅស្រីថោកទាប ។
- មាលា : អូននឹងចុះចេញ ប៉ុន្តែសូមបងកុំខឹងនឹងអូន ។
- ចំរុង : យើងអនុញ្ញាតឱ្យនាងឯងយកសម្លៀកបំពាក់ទៅតាមទាំងអស់ ឆាប់ចុះភ្លាមទៅ !
- មាលា : ចាស៎ !
- ចំរុង : ភូរិន្ទ ! អ្វីដែលជាសម្បត្តិរបស់ឯង ចូរឯងយកទៅចុះ ហើយឆាប់នាំគ្នាចុះចេញពីមុខពីមាត់អញភ្លាម ។
- ភូរិន្ទ : ជិតមួយឆ្នាំមកនេះ គ្នាគ្មានទ្រព្យសម្បត្តិអ្វីមកដម្កល់ដាក់ទុកនោះទេ មានតែកូនរទេះតូចដែលដាក់តាំងនៅលើតុនោះ គ្នាសុំវាយកទៅហើយ ។
- ចំរុង : អើ ! យកទៅ ! យកកូនរទេះហ្នឹងនាំប្ដីប្រពន្ធក្បត់លីលារបស់ឯងជិះទៅ ជិះទៅកាន់ឋាននរក ។
- មាលា : បងចំរុង ... បងចំរុង ... (យំ)
- ចំរុង : អើ ! រួចរាល់អស់ហើយឬនៅ ? យកបង្វេចហ្នឹង ចុះឱ្យផុតពីផ្ទះរបស់យើងភ្លាម ចុះឱ្យផុតភ្លាម ស្រីថោកទាប ។
- មាលា : ក្នុងមួយជីវិតរបស់អូន នេះជាលើកទី៤ ហើយដែលត្រូវគេបណ្ដេញចុះពីផ្ទះ ហើយជេរស្ដីថាជាមនុស្សថោកទាប ហេតុអី ... ហេតុអីក៏ពាក្យថោកទាបហ្នឹងតែងអន្ទោលតាមរូបខ្ញុំឥតឈប់ឈរ ប៉ុន្តែលើកនេះ អូនមិនខឹងពាក្យត្មះតិះដៀលរបស់បងទេ ព្រោះតាមការពិត បងគួរតែជេរ ... បងគួរតែជេរ ... បងចំរុងអូនសូមលាបងហើយ (យំផងនិយាយផង) ។
- ចំរុង : អញលែងចង់ស្ដាប់ទៀតហើយ ចុះភ្លាមទៅ ... ចុះភ្លាមទៅ ...
- ភូរិន្ទ : សម្លាញ់គ្នាលាឯងសិនហើយណា៎ ...

- ចំរុង : គ្មានសម្លាញ់គ្មានមិត្ត ចុះឱ្យឆាប់ ... ចុះឱ្យឆាប់ ... ន្ទាលអញគិតគូរ អញមិនចង់ឃើញមុខពួកឯងទៀត (ស្រែក)

ស្គររោទិ៍ គ្រឹមៗ ...

- ចំរុង : ព្រះអើយ គេដឹកដៃគ្នាទៅហើយ គេជាប្ដីប្រពន្ធនឹងគ្នា ចុះរូបខ្ញុំ ? រូបខ្ញុំជាស្អីទៅវិញ ? (ចំរុងស្រែក)

អ្នកចម្រៀងអមពីក្នុង : មេឃខ្មៅងងឹតហា អឺ អឹងអើយ ហា អឺ អឹងអើយ ជុំជិតពពក (ពីរដង) ភ្លៀងអើយ បង្អុរមក ហា អឺ អឹងអើយ នាំយកខ្លោចផ្សា (ពីរដង)។

- ភូរិន្ទ : ទទឹកប្រពន្ធអស់ទៅហើយ (និយាយម្នាក់ឯង) អូនរងាទេ ?
- មាលា: អូនហាក់ដូចជាលែងរងាហើយបង !
- ភូរិន្ទ : ភ្លៀងធំណាស់ ភ្លៀងនេះជួយលាងជម្រះអតីតកាលជូរចត់របស់យើង ។
- មាលា : មិនមែនដូច្នេះទេបង ទោះជាភ្លៀងដល់លិចផែនដីទាំងមូល ក៏វាពុំអាចផ្សះដំបៅជីវិតរបស់យើងបានដែរ ប៉ុន្តែអតីតកាលជាស្រមោល បច្ចុប្បន្នជាការពិត អនាគតជារឿងដែលត្រូវដោះស្រាយ អ្វីៗដែលកន្លងហួសទៅហើយ វាពុំអាចវិលត្រឡប់មកវិញបានទេ !
- ភូរិន្ទ : ឱ្យតែអូនមានគំនិតប្ដេជ្ញាបែបនេះ ទោះជាក្រលំបាកយ៉ាងណាក៏ដោយ ក៏ជីវិតនិងស្នេហ៍របស់យើងពោរពេញទៅដោយសុភមង្គលដែរណា៎អូន ។
- មាលា : ចាស៎ ... ចាប់ពីថ្ងៃនេះទៅជីវិតរបស់អូនផ្ញើលើបងហើយណាបង ... ។

*(ដកស្រង់ចេញពីឃីកេរឿង ក្បួនជីវិតរបស់លោក ទី ជីហួត)*

## សំណួរ

១. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី ? សំអាងលើអ្វី ?

២. ចូរបង្ហាញពីទំនាស់ក្រៅខ្លួនតាមរយៈអត្ថបទនេះ ។

៣. តើការសម្រេចចិត្តរបស់មាលាក្នុងការជ្រើសរើសយកភូរិន្ទជាស្វាមីនេះជាកំហុសដែរឬទេ ? ព្រោះអ្វី ?

៤. តើមាលាត្រូវគេបណ្ដេញចុះចេញពីផ្ទះចំនួនប៉ុន្មានលើក ? អ្វីខ្លះ ?

៥. មាលានិយាយថា “អតីតកាលជាស្រមោល បច្ចុប្បន្នជាការពិត អនាគតជារឿងត្រូវដោះស្រាយ” ។ តើវាមានអត្ថន័យដូចម្ដេច ?

៦. តើចំរុងព្រមទទួលស្គាល់ការពិតដែរឬទេ ? ចូរស្រង់ឃ្លាបញ្ជាក់នូវចម្លើយរបស់អ្នក ? បើសិនជាអ្នកវិញ តើអ្នកគួរធ្វើដូចម្ដេច ?

# ចំណងផ្ទាក់និងចំណងឈ្នាប់

## ១ . ចំណងធ្នាក់ ឬធ្នាក់

ដូចម្ដេចដែលហៅថាផ្នាក់ ? តើផ្នាក់មាននាទីដូចម្ដេច ?

ចូរពិនិត្យឧទាហរណ៍ខាងក្រោម ៖

១. ខ្ញុំទៅរៀនដើម្បីអនាគតភ្លឺស្វាង ។

២. កិច្ចការនេះសម្រេចលើលោកពូ ។

៣. គាត់ឈប់ជក់បារីព្រោះខ្លាចកើតជំងឺសួត ។

៤. ស្រែរបស់ជីតាខ្ញុំឆ្នាំនេះទទួលបានផលច្រើនណាស់ ។

តាមឧទាហរណ៍ខាងលើយើងឃើញថា ៖

ល្បះទី ១ : ពាក្យ "ដើម្បី " ជាផ្នាក់ ។ "ដើម្បីអនាគតភ្លឺស្វាង " ជាកន្សោមមានផ្នាក់ ។

ល្បះទី ២ : ពាក្យ "លើ " ជាផ្នាក់ ។ "លើពូ " ជាកន្សោមមានផ្នាក់ ។

ល្បះទី ៣ : ពាក្យ "ព្រោះ " ជាផ្នាក់ ។ "ព្រោះខ្លាចជំងឺសួត " ជាកន្សោមមានផ្នាក់ ។

ល្បះទី ៤ : ពាក្យ "របស់ " ជាផ្នាក់ ។ "របស់ជីតាខ្ញុំឆ្នាំនេះទទួលបានផលច្រើនណាស់ " ជាកន្សោមមានផ្នាក់ ។

ល្បះទាំងបួនខាងលើនេះបញ្ជាក់ថា នៅក្នុងល្បះចាប់ពីផ្នាក់ទៅ គឺជាកន្សោមមានផ្នាក់ ។

*ផ្នាក់ គឺជាពាក្យចំណងសម្រាប់ប្រើក្នុងកន្សោមពាក្យ ឬឃ្លាដើម្បីបង្កើតកន្សោមមានផ្នាក់នៅក្នុងល្បះ ។*

ចំណងផ្នាក់មានច្រើនដូចជា ក្នុង ក្រៅ លើ ក្រោម ចំពោះ ជាមួយ ដើម្បី ដោយ ត្រង់ នូវ នៃ ពីព្រោះ អំពី ខាង ជិត ក្បែរ ក្រោយ មុខ ដល់ ... ។

## ២ . ចំណងឈ្នាប់ ឬឈ្នាប់

ដូចម្ដេចហៅថា ឈ្នាប់ ? តើឈ្នាប់មានអ្វីខ្លះ ? ហើយមានតួនាទីដូចម្ដេចខ្លះ ?

### ក. ឈ្នាប់ចង

ចូរពិនិត្យឧទាហរណ៍ :

- រឿងរ៉ាវនេះកើតឡើងយូរហើយ តែខ្ញុំនៅចាំច្បាស់ណាស់ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

- ថ្ងៃនេះខ្ញុំរៀនគណិតវិទ្យានិងភាសាខ្មែរ ។
- តើយើងនៅក្នុងថ្នាក់ ឬទៅបណ្ណាល័យ ?

ឧទាហរណ៍ខាងលើនេះ ពាក្យ " តែ និង ឬ " ជាឈ្នាប់ចង ។

ពាក្យ " តែ " សម្រាប់ចងភ្ជាប់ " រឿងរ៉ាវនេះកើតឡើងយូរហើយ " ជាមួយនឹង "ខ្ញុំនៅចាំច្បាស់លាស់ "។

ពាក្យ " និង " សម្រាប់ចងភ្ជាប់ " ថ្ងៃនេះខ្ញុំរៀនគណិតវិទ្យា " ជាមួយនឹង " ភាសាខ្មែរ "។

ពាក្យ " ឬ " សម្រាប់ចងភ្ជាប់ " តើយើងនៅក្នុងថ្នាក់ " ជាមួយនឹង " ទៅបណ្ណាល័យ "។

*ឈ្នាប់ចង គឺជាពាក្យចំណងសម្រាប់សម្គាល់ទំនាក់ទំនងរវាងល្បះនិងល្បះ ឬរវាងធាតុផ្សេងៗក្នុងល្បះ ។*

ឈ្នាប់ចង មានច្រើនដូចជា ៖

- សម្រាប់សម្គាល់ " ការបូកគ្នា " : និង ហើយនិង ... ។
- សម្រាប់សម្គាល់ " ការបំបែកគ្នា " : ឬ ឬក៏ ពុំនោះ ពុំនោះសោត ... ។
- សម្រាប់សម្គាល់ " ទំនាស់" : តែ ប៉ុន្តែ ...។

## ខ. ឈ្នាប់ឃ្លា

ចូរពិនិត្យឧទាហរណ៍ ៖

១. គាត់ប្រាប់ខ្ញុំ ថាប្រាសាទនេះ សាងមុនប្រាសាទអង្គរវត្ត ។

២. ខ្ញុំមកទីនេះ ដើម្បីប្រាប់រឿងពិតដល់លោក ។

៣. ថ្វីត្បិតតែកន្លងហួសទៅជាច្រើនឆ្នាំ តែខ្ញុំនៅចងចាំព្រឹត្តិការណ៍ដែលកើតឡើងកាលនោះយ៉ាងច្បាស់ ។

៤. ប្រសិនបើលោកឈប់ជក់បារី នោះលោកនឹងមានសុខភាពល្អ ។

ល្បះទី១ : យើងអាចចែកជាពីរឃ្លា ដែលឃ្លាទាំងពីរភ្ជាប់គ្នាដោយ " ថា "

- គាត់ប្រាប់ខ្ញុំ : ឃ្លាទីមួយ
- ថាប្រាសាទនេះសាងមុនប្រាសាទអង្គរវត្ត : ឃ្លាទីពីរ

ឃ្លាទីពីរនេះមាននាទីដូចជា កន្សោមនាមកម្មបទ នាំឱ្យពាក្យ " ថា " បង្ហាញមុខងារ " ឃ្លារណបកម្មបទ "។

ល្បះទី ២ : ពាក្យ " ដើម្បី " មាននាទីដូច " ថា " ដែរ គឺវាបង្ហាញមុខងារ " ឃ្លារណបកម្មទេសកាល " ។

ល្បះទី ៣និងទី ៤ : ពាក្យ " ថ្វីត្បិតតែ "និង" ប្រសិនបើ " គេប្រើនៅដើមល្បះ ដើម្បីបង្ហាញពីទំនាក់ទំនងនៃឃ្លាទាំងពីរក្នុងល្បះនីមួយៗ ហើយក៏បង្ហាញពីមុខងារ " ឃ្លារណបកម្មទេសកាល "ដែរ ។

*ឈ្នាប់ឃ្លា គឺជាពាក្យចំណងសម្រាប់សម្គាល់ទំនាក់ទំនងគ្នារវាងឃ្លានិងឃ្លាផង ហើយនិងសម្រាប់បង្កើតឃ្លារណបថែមទៀតផង ។*

ឈ្នាប់ឃ្លាមាន ៖

- ឈ្នាប់ឃ្លាសម្រាប់ប្រើក្នុងឃ្លារណបកម្មបទ ឬគុណប្រធាន : ថា ជា
- ឈ្នាប់ឃ្លាសម្រាប់ប្រើក្នុងឃ្លារណបកម្មទេសកាល :

ហេតុ : ព្រោះ ពីព្រោះ

បំណង : ដើម្បី ដើម្បីនឹង

លក្ខខណ្ឌ : បើ ប្រសិនបើ

កាល : លុះ កាលណា

ទំនាស់ : ទោះបី ថ្វីត្បិតតែ ... ។

## លំហាត់

១. ចូរតែងល្បះដោយប្រើធ្នាក់ : ក្នុង ចំពោះ ជាមួយ ពីព្រោះ អំពី ដោយ ឱ្យបានមួយល្បះក្នុងមួយពាក្យៗ ។

២. ចូរតែងល្បះដោយប្រើឈ្នាប់ : និង ប៉ុន្តែ ថា ពីព្រោះ ទោះបី កាលណា ប្រសិនបើ ឱ្យបានមួយល្បះក្នុងមួយពាក្យៗ ។

៣. ចូរអានអត្ថបទខាងក្រោម រួចស្រង់ពាក្យដែលជា ធ្នាក់និងឈ្នាប់

ការស្រូបចូលនៃផ្សែងបារីធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព ។ កុមារជាមុខសញ្ញាងាយរងគ្រោះជាងគេ ។ ទោះបីយើងមិនបានជក់បារីក៏ដោយ ការស្រូបចូលផ្សែងបារីអ្នកដទៃក៏មានគ្រោះថ្នាក់ដូចអ្នកជក់បារីដែរ ។ ចំពោះកុមារ ការស្រូបចូលនៃផ្សែងបារីនេះបណ្តាលឱ្យមានជំងឺដូចជាជំងឺផ្លូវដង្ហើម ជំងឺហឺត មហារីកឈាម មហារីកខួរក្បាល ផលវិបាកលើសរសៃឈាម និងបេះដូង ។ មិនតែប៉ុណ្ណោះ វាថែមទាំងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការលូតលាស់នៃមុខងាររបស់សួត សរសៃប្រសាទ និងភាពឆ្លាតវាងវៃទៀតផង ។

*(ដកស្រង់និងសម្រួលពីកម្រងឯកសារថ្នាំជក់ ឬសុខភាពរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)*



krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

# បុរេនិច្ឆ័យ

ដូចម្ដេចហៅថា បុរេនិច្ឆ័យ ?

ចាស់បុរាណមួយចំនួនតែងតែពោលពាក្យអារកាត់ ឬដោះស្រាយបញ្ហាផ្សេងៗមួយចំនួន ដោយការកត់ចំណាំ ឬកត់សម្គាល់ទៅតាមទម្លាប់ដោយមិនបានវិនិច្ឆ័យរកហេតុផល ឬរកការពិតឡើយ ។ ជួនកាលគ្រាន់តែឃើញភ្លាម ឬហេតុការណ៍មិនទាន់កើតឡើងផង ក៏មានការវាយតម្លៃទុកជាមុនស្រេចទៅហើយ ។

*ឧទាហរណ៍ ទី ១:*

- ឪពុកយ៉ាងណា កូនក៏យ៉ាងនោះដែរ ។
- ត្រីមួយត្រកស្អុយមួយ ស្អុយទាំងអស់ ។
- គ្រាន់តែឃើញមុខវា ខ្ញុំដឹងថាជាមនុស្សខិលខូចបាត់ទៅហើយ ! ... ។
- កូនមិនដឹងទេឬ ? ពូជវាក្រណាស់ណាំ !
- ទាកុំចង់ឡើងទ្រនំ !

*ឧទាហរណ៍ ទី ២:*

[...] ចៅ ចិត្រ សង្កេតដឹងច្បាស់ថា លោកនេះហើយដែលថា "ហ្លួងរតនសម្បត្តិ" ដែលខ្លួនត្រូវការជួប ទើបរំកិលខ្លួនចុះពីកៅអី បន្ទន់ខ្លួនសំពះដោយសេចក្ដីគោរពគួរសម ។

ឯហ្លួងរតនសម្បត្តិ ជាអ្នកជំនួញលក់ត្បូង ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកបប៉ៃលិន ក៏អង្គុយលើកៅអីមួយ ចៅ ចិត្រ សង្កេតតាមឫកពាររបស់លោកនេះយល់ថាជាអ្នកមានអធ្យាស្រ័យល្អ ចិត្តសប្បុរស គួរជាទីគោរពរាប់អានមែន ។

"ទានប្រោសមាន !" ចៅ ចិត្រ ឆ្លើយដោយឱនលំទោនហើយថា "លោកគ្រូពេទ្យ ស្អាត បានផ្ញើសំបុត្រ ១ច្បាប់មកជូនព្រះតេជព្រះគុណ" ។

"អើ ! ពេទ្យស្អាត ក្មួយខ្ញុំនោះឬ !" លោកនិយាយទាំងញញឹមតាមដោយលោកជាអ្នកមានអធ្យាស្រ័យរីករាយជានិច្ច ហើយសួរថា "សំបុត្រនោះនៅឯណា" ។

ចៅ ចិត្រ លូកដៃទៅក្នុងហោប៉ៅ យកសំបុត្រនោះជូនទៅលោកហ្លួងទទួលយកទៅអានដោយសេចក្ដីត្រេកអរ លុះមើលចប់ហើយ ក៏បែរមកពិចារណាមើលលក្ខណៈចៅ ចិត្រ ម្ដងទៀត ។

ហ្លួង : "ក្មួយឯងមែនទេឬអី ឈ្មោះ ចៅ ចិត្រ ដែលពេទ្យស្អាត បានបញ្ជូនខ្លួនមកឱ្យខ្ញុំ ?"

ចិត្រ : "ទានប្រោស ខ្ញុំបាទនេះហើយ"

**ហ្លួង ៖ "ចុះក្មួយធ្វើការនេះបានដែរឬ ? ការរបស់ខ្ញុំនេះ វាធ្ងន់ណាស់ តោងទ្រាំជីកដីក្នុងមួយថ្ងៃ ៥-៦ម៉ោង ទើបស៊ុះរួច រូបរាងស្អាតបាតដូចជាក្មួយនេះ ខ្ញុំយល់ថាទ្រាំទ្រការងារមិនបានយូរប៉ុន្មានទេ មុខជារត់ទៅផ្ទះវិញហើយ !"។**

"មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាងណា ឯខ្ញុំបាទគង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណកុំព្រួយឱ្យសោះ !" ថៅ ចិត្រ ពោលរ៉ាប់រងយ៉ាងម៉ឺងម៉ាត់។ ពាក្យនេះហើយដែលធ្វើឱ្យ ហ្លួងរតនសម្បត្តិ មានសេចក្តីពេញចិត្តណាស់ ហើយថៅ ចិត្រ និយាយតទៅទៀតថា ទានប្រោស ! មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនប្រកាន់ការស្រាលៗស្រួលៗទេ ខ្ញុំបាទមិនដែលគិតដូច្នេះទេ កាលបើខ្ញុំបាទមានកម្លាំងពលំដរាបណា ខ្ញុំបាទនឹងខិតខំធ្វើការដរាបនោះ ទោះបីធ្ងន់ក្តីស្រាលក្តី។

"អ្នកឯងនិយាយត្រូវណាស់" លោកហ្លួង និយាយសរសើរហើយថា ណ្ហើយចុះ ឯខ្ញុំតែងមានការ មនុស្សដែលចង់ធ្វើជានិច្ច វេលានេះ អណ្តូងត្បូងទិសខាងកើត ខ្ញុំកំពុងឱ្យចាប់ផ្តើមជីកត្បូងមានតម្លៃមួយអន្លើ ព្រឹកស្អែកនេះ ខ្ញុំនឹងបញ្ជូនអ្នកឯងឱ្យទៅធ្វើការនៅទីនោះ ធ្វើការក្នុងគ្រាដំបូងនេះ ខ្ញុំនឹងតាំងប្រាក់ខែឱ្យអ្នកឯងត្រឹម ៣០រៀលសិន[(១)] ប៉ុន្តែអ្នកឯងអាចបានប្រាក់ខែច្រើនជាងនេះទៅទៀត បើខំយកចិត្តទុកដាក់ធ្វើការដោយម៉ឺងម៉ាត់ហើយម៉ត់ចត់ផង។

ថៅ ចិត្រ ឱនក្បាលទទួលយល់ព្រម ដោយសេចក្តីគោរពម្តងទៀត។

ក្នុងខណៈនោះ មានសូរស្បែកជើង លាន់ឮពីខាងក្រោមឡើងមកលើផ្ទះ ព្រមទាំងមានសំឡេងយ៉ាងឆ្នារតូចលាន់រំពងមកពីខាងក្រោយ ថៅ ចិត្រ។ ថៅ ចិត្រ ក៏ចោលភ្នែកក្រឡេកមើលទៅប្រទះនឹងភ្នែកទាំងគូកំពុងសម្លឹងចំត្រង់មក ជាដួងភ្នែកប្រកបដោយទឹកដម គួរជាទីចាប់ចិត្តស្នេហា តែមានឫកពាឆ្មើងឆ្មៃបន្តិចមានកិរិយាក្និកក្នក់ញ៉ែងញ៉ង លោសលន់ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ដូចវង់ព្រះចន្ទ្រា សូរសំឡេងស្រួយស្រស់ដូចសូររគាំងប្រាក់ ដំណើរលោសលន់ដូចផ្កាកុលាប ដែលត្រូវខ្យល់មកលិចៗ នៅកណ្តាលសួនច្បារដូច្នោះ ឱ ល្អអី ល្អម្ល៉េះ ! នេះប្រហែលជាអញយល់សប្តិឃើញទេដឹង ?

ថៅ ចិត្រ ភ្ញាក់ស្មារតី លែងសម្លឹងស្រឡាំងកាំង ក្នុងពេលដែលលោកហ្លួងស្រែកហៅកូនស្រីនោះ ឱ្យឡើងមកខាងលើផ្ទះ "មកឯណេះ នារី ! ថ្ងៃនេះ ប៉ាបានមនុស្សចូលមកធ្វើការម្នាក់ទៀតហើយ"។ នាងក្រមុំ នារី ឈានជើងឡើងជណ្តើរមួយៗ ភ្នែកមើលថៅ ចិត្រ ដោយកិរិយាឆ្មើងឆ្មៃបន្តិចដែលជាទំនៀមរបស់ស្ត្រីក្រមុំរូបស្រស់ ហើយសួរទៅឪពុក ៖ "ប៉ា ! នេះឬអ្នកចូលមកធ្វើការថ្មីរបស់យើង ?"

---

*(១) ៣០ រៀលក្នុងសម័យនោះ ប្រហែល ១៥០០រៀល ទៅ ២០០០រៀល ក្នុងសម័យនេះ (១៩៦០) ហើយថោកផង។*

លោក ហ្លួង ញាក់មុខទទួលហើយងាកទៅនិយាយនឹងថៅ ចិត្រថា ថៅ ចិត្រ ! នេះ នារី កូនស្រីតែមួយរបស់ខ្ញុំ ។

ថៅ ចិត្រ លើកដៃសំពះសួរនាង នារីងក់ក្បាលទទួលគំនាប់ដោយកិរិយាឆ្មើងៗតាមនិស្ស័យរបស់នាង ។

នាង នារី សម្លឹងមើលកម្មករថ្មីរបស់ឪពុក តាំងពីក្បាលរហូតដល់ចុងជើង មើលហើយមើលទៀត នៅទីបំផុតក៏លាន់មាត់ ៖ **"កម្មករនេះ ស្គមដូចអ្នកញៀនអាភៀននឹងមានកម្លាំងជីកដីបានឬប៉ា ?"** ។

ថៅ ចិត្រ កាលត្រូវស្រីក្រមុំស្តីដាក់មុខដូច្នេះ ក៏នឹកអៀនខ្មាសណាស់ ក្រឡេកចោលកន្ទុយភ្នែកទៅនាងមួយភ្លែត ហើយតបទៅ ៖ "មនុស្សត្រង់ គេមិនដែលសម្គាល់ថាជាមនុស្សល្ងង់ទេ ឯមនុស្សស្គមក៏គេមិនសម្គាល់ថា ជាមនុស្សខ្សោយដែរ ស្គមយ៉ាងខ្ញុំបាទនេះ មានកម្លាំងខ្លាំងដូចមនុស្សធាត់មាំដែរ គ្រាន់មិនសូវមានសាច់ឈាមធាត់បរិបូណ៌ប៉ុណ្ណោះទេតើ !" ។

នាង នារី ធ្វើមុខក្រញូវទំនងខឹងបន្តិចៗផង ដោយនាងមិននឹកនាថា ថៅ ចិត្រហ៊ានឆ្លើយដូច្នេះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងផ្ទះ ហ៊ាននិយាយលេងសម្តីរោហារនឹងនាងឡើយ ។

លោក ហ្លួង ឃើញកូនខឹងដូច្នោះក៏បញ្ឈប់ថា ថៅ ចិត្រ ! ណ្ហើយឈប់ស្លេះប៉ុណ្ណឹងសិនចុះឯងកំពុងនឿយហត់អស់កម្លាំង ទៅរកសម្រាកខ្លួនឱ្យបាត់នឿយហត់សិនទៅ ។ [...]

*(ដកស្រង់ពីរឿង កុលាបប៉ៃលិន អ្នកនិពន្ធ ញ៉ុក ថែម គ.ស ១៩៦០)*

ពំនោលក្នុងឧទាហរណ៍ទាំងពីរខាងលើ សុទ្ធតែបង្ហាញពីពំនោលដែលមិនទាន់មានហេតុផល ឬអំណះអំណាងច្បាស់លាស់ ឬពំនោលដែលពុំទាន់ស្វែងរកការពិត ។

*បុរេនិច្ឆ័យ គឺជាការសន្និដ្ឋាន ការវិនិច្ឆ័យ ឬការវាយតម្លៃទុកជាមុនដោយមិនទាន់ស្វែងយល់រកការពិតឱ្យបានច្បាស់លាស់នៅឡើយទេ ។ ការសន្និដ្ឋាន ឬការវាយតម្លៃទាំងនោះមិនទាន់ត្រឹមត្រូវល្អិតល្អន់គ្រប់ជ្រុងជ្រោយនោះទេ គឺមានភាពលម្អៀង ។*

facebook.com/moeys.gov.kh khmer.moeys.gov.kh youtube.com/moeys

## លំហាត់

ចូរអានពំនោលខាងក្រោម រួចបង្ហាញបុរេនិច្ឆ័យ ។

១. ឈើកោងវល្លិព័ទ្ធ មនុស្សខ្នាត់ព្រាត់កុំយកខ្លួនបៀត !

២. សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា ។

៣. ដឹងឆ្លើយត្បិតដង    កូនប្រុសវែងឆ្គង    ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី    ចេះរៀបដាក់ទុក    ផ្ទះធំស្រណុក
ត្បិតភរិយាជា ។

*(ក្រម ង៉ុយ)*

៤. ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់ឡើយ ។

៥. អនិច្ចាតោថ្មលោកកសាង    មើលថាថាងយ៉ាងរស់ស្ទុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ទាត់ខ្ចាយ    ស្ដាយអើយស្ដាយមិនគួរមកពិការ ។
មានអ្នកព្រៃចង្រៃឥតគំនិត    ទៅសំលៀងកាំបិតគ្រឿងប្រហារ
ឱ្យខូងខូចខាតសាច់បង់អសារ    មិនស្ដាយការស្នាដៃបុរាណសោះ ។

*(សុតន្តប្រីជាឥន្ទ)*



# ជីវិតខ្មែរក្នុងនរកអវិចី



## ក. សិក្សាពាក្យគន្លឹះ

- មច្ចុរាជ : ការស្លាប់ ស្តេចនៃសេចក្តីស្លាប់ ។
- អ្នកថ្មី : ប្រជាជនខ្មែរដែលរស់នៅក្នុងទីក្រុងហើយត្រូវខ្មែរក្រហមបង្ខំឱ្យចាកចេញទៅចូលតំបន់ជនបទក្រោយ ថ្ងៃ១៧ មេសា ១៩៧៥ ។
- អ្នកចាស់ : ប្រជាជនខ្មែរដែលរស់នៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហមមុនឆ្នាំ ១៩៧៥ ។
- សាលាកាលេស : អនុវិទ្យាល័យ ។
- កសាង : វិសុទ្ធកម្ម ណែនាំអប់រំគោលជំហរមាគ៌ាបក្ស (សម្លាប់) ។
- អង្គការ : អ្នកដឹកនាំខ្មែរក្រហមតាមលំដាប់ថ្នាក់ ឬរចនាសម្ព័ន្ធចាត់តាំងរបស់ពួកខ្មែរក្រហម ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងគំនិតសំខាន់បង្កប់ ។

## គ. អត្ថបទ

[...] កាលបញ្ជាឱ្យវិលត្រឡប់ទៅលើកទំនប់ ជីកប្រឡាយ ជាមុខងារត្រូវប្រើកម្លាំងបាយដ៏សែននឿយចំពោះរូបខ្ញុំដែលនៅវេលានោះទើបតែមានវ័យ ១៤ឆ្នាំ ។ មុននឹងខ្ញុំបានទៅដាំដំឡូងនៅព្រៃកប់រស់ ខ្ញុំធ្លាប់បានពិសោធនឹងកិច្ចការដែលមិនចេះចប់ មិនចេះហើយនោះជាស្រេចមកហើយ ។

facebook.com/krou.moeys.gov.kh

ជាពិសេស ខ្ញុំមានការលំបាកនឹងការអត់ធ្មត់ ចំពោះអាកប្បកិរិយាអ្នកភូមិដែលជាអ្នកចាស់មកលើអ្នកថ្មី ដូចរូបខ្ញុំជាដើម ។

ពួកឯងអ្នកថ្មីដែលមិនអាចធ្វើការបាន "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ! ពាក្យសម្ដីរបស់ពួកគេមួយម៉ាត់ៗ ហាក់បីដូចជាមានមច្ចុរាជចូលមកសណ្ឋិត ដែលពោរពេញទៅដោយគំនុំគុំគួន ប៉ុនប៉ងសងសឹកមកលើពួកយើងអ្នកថ្មី ដែលនៅវេលានោះ គេចាត់ទុកថាជាសត្រូវ ដោយមិនរើសមុខ ។ ចាប់តាំងពីខ្ញុំបានផ្លាស់ប្ដូរការងារពីព្រៃកប់រស់មក ខ្ញុំតែងតែទទួលពាក្យដ៏ទ្រគោះបោះបោកដោយពុំមានអាការៈអៀនខ្មាស ខ្វះក្ដីមេត្តាពីអ្នកចាស់ជាដរាប ។

ខែសីហា ឆ្នាំ ១៩៧៨ ពួកខ្ញុំប្ដូរការងារ លើកទំនប់ជីកប្រឡាយ ទៅធ្វើនៅទល់មុខនៅម៉ុំសាលាកាលេសស្របនឹងផ្លូវជាតិលេខ ៦ ដែលនៅទីនោះ អង្គការបានដាក់ទុកជាទីឃុំឃាំង ។ ជារៀងរាល់ថ្ងៃខ្ញុំតែងឃើញអង្គការនាំអ្នកទោសជាពិសេសបុរសៗដែលអាចសន្មតថាជាអ្នកថ្មី (ដោយសម្លៀកបំពាក់គាត់កណ្ដាច ហើយមិនមែនពណ៌ខ្មៅ) ក៏ប៉ុន្តែយើងមិនអាចសន្និដ្ឋានថា គេនាំពួកគាត់មកពីភូមិណាខ្លះទេ ដើរសំដៅចូលទៅសាលាកាលេស ។

តែគួរឱ្យចម្លែកណាស់ ដោយយើងបានឃើញអង្គការនាំមនុស្សឱ្យចូលទៅជារឿយៗ តែផ្ទុយទៅវិញ យើងមិនដែលបានឃើញ ជនណាមួយបានចេញពីទីនោះមកវិញទាល់តែសោះ ។

ដោយមានការបារម្ភខ្លាចប្រជាជនបះបោរ នៅវេលាជនណាមួយត្រូវបានអង្គការចោទប្រកាន់ថាជាអ្នកទោសនិងយកទៅផ្ដន្ទាទោស គេតែងប្រើពាក្យថា :

- "យកទៅសាលាកាលេស"
- "យកទៅកសាងឡើងវិញ"
- "ឱ្យទៅដាំដំឡូង" ។ល ។

ក៏ប៉ុន្តែប្រយោគទាំងឡាយនេះ គឺសុទ្ធតែមានន័យជំនួសពាក្យ "ពិឃាដ" នៅវេលាពួកយើងអ្នកថ្មីណាម្នាក់ មានកំហុសអ្វីបន្តិចបន្តួច អ្នកចាស់តែងពោលពាក្យគំរាម ព្រមទាំងលាយឡំនិងភាពចំអកឡកឡឺយមកលើយើងថា :

- ប្រយ័ត្នអង្គការ "យកទៅកសាងឡើងវិញ" រ៉ឺយ !
- ឯងចង់ទៅសាលាកាលេសឬ ? គឺនៅជំនាន់នោះ អង្គការចាត់ទុកជីវិតពួកយើងអ្នកថ្មី ពុំមានតម្លៃទាល់តែសោះហើយស្រាលជាងសំឡីទៅទៀត ។ ក៏ប៉ុន្តែទោះបីខ្ញុំទើបតែមានអាយុ ១៤ឆ្នាំ ខ្វះខាតនូវជីវជាតិសព្វបែបយ៉ាង យ៉ាងណាក៏ដោយ ខ្ញុំអាចយល់ជាក់ថា

ជីវិតមនុស្សមានតម្លៃលើសអ្វីៗដែលមាននៅក្នុងលោក ព្រមទាំងមានទម្ងន់ធ្ងន់ជាងផែនដីទៅទៀត ... ។ ខ្ញុំសង្កេតឃើញថា ពួកគេហាក់បីដូចជារំភើបនឹងឃើញក្តីវេទនារបស់ពួកយើងអ្នកថ្មី ព្រមទាំងប៉ុនប៉ងឱ្យជីវិតយើងប្រកបទៅដោយអពមង្គល ។

ជាពិសេសពួកយើងអ្នកថ្មី ទាំងខ្ញុំទាំងគេ ម្នាក់ៗខ្សោះកម្លាំងពីខ្លួនស្ទើរតែលើកចបកាប់មិនរួច ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក្តីយើងត្រូវតែបំពេញការងារ ដែលអង្គការផ្តល់ឱ្យធ្វើប្រចាំថ្ងៃ ដោយពុំមានជនណាម្នាក់ហ៊ានបដិសេធឡើយ ។

ពួកយើងរាល់គ្នាជាអ្នកថ្មីដាច់ពោះ ពីព្រោះគ្មានអាហារហូបឱ្យបានបរិបូរ ក៏ចាប់ផ្តើមប្រជែងគ្នាដេញចាប់សត្វល្អូនដូចជា ពស់ បង្កួយ ដែលយើងបានជួបប្រទះនៅវេលាកាប់គាស់គល់ឈើ ។ មិនត្រឹមតែប៉ុណ្ណោះ យើងថែមទាំងដេញចាប់ដល់ទៅសត្វល្អិតដូចជា ចង្រិត កណ្តូប រហូតដល់ទៅសត្វពិស ដូចជា ក្អែប ខ្ទួយ ជាដើម ។ល។ វេលាឃើញព្រឹត្តិការណ៍បែបនោះ ពួកអ្នកចាស់តែងតែចំអកហៅយើងថា ជាអាប !

ប៉ុន្តែ យើងរាល់គ្នាគ្មានកម្លាំងពលំនឹងរវីរវល់ ចំពោះការមាក់ងាយបែបនោះសោះឡើយ ។ បន្ទាប់មក យើងយកសត្វទាំងនោះមកអាំង ឬដុតដើម្បីហូបជាមួយនឹងបបរយ៉ាងតិចតួចស្តួចស្តើងជាចំណែកក្នុងមួយថ្ងៃដែលមានតែពីរដងតែប៉ុណ្ណោះ ។

ក្រោយវេលាបញ្ចប់ការងារប្រចាំថ្ងៃ ទោះបីជាយើងរាល់គ្នានឿយហត់ អត់ងងុយ ទន់ប្រាណសឹងទប់មិនរួចយ៉ាងណាក្តី គេតែងតែប្រមូលយើងឱ្យអង្គុយបញ្ឈរក្បាលជង្គង់ម្ខាងជារង់ (ជំនាន់នោះគេមិនអនុញ្ញាតឱ្យអង្គុយបត់ជើង ឬពែនភ្នែនទេ) ដើម្បីធ្វើមិទ្ទិញ (ប្រជុំ) ជារៀងរាល់យប់ មិនដែលអាក់ខានឡើយ ។ ការចាប់ផ្តើមធ្វើមិទ្ទិញ ជាដំបូងប្រធានក្រុមតែងពោលថា

សូមគោរពអង្គប្រជុំនិងសមមិត្តទាំងអស់ ដែលបានមកចូលរួមក្នុងអង្គប្រជុំ តើមិត្តណាមានយោបល់អ្វី ? ដូចជាការមិនពេញចិត្តនឹងវិន័យអង្គការ ការមិនពេញចិត្តនឹងការងារ ដែលធ្វើក្នុងមួយឆ្នាំមានដល់ទៅ ៣៦៥ថ្ងៃ ការងារដែលប្រើកម្លាំងបាយនឿយហត់លើសកម្រិត បបររាវកក្លូកដូចទឹកហើយហូបមិនដែលបានឆ្អែត ។ល។ ទោះជាយើងរាល់គ្នាយល់ឃើញដូចពាក្យខាងលើក្តី តែតាមធម្មតា ពុំដែលមានជនអ្នកថ្មីណាមួយរូបហ៊ានបញ្ចេញយោបល់ឡើយ ។ ក៏ប៉ុន្តែមិនដឹងជាមូលហេតុអ្វីស្រាប់ តែថ្ងៃនោះ មិត្តអ្នកថ្មីមួយរូបបានបញ្ចេញយោបល់ដូចខាងលើយ៉ាងក្លាហាន ។ យើងរាល់គ្នាភ្ញាក់ព្រមទាំងសែនបារម្ភនឹងអាកប្បកិរិយារបស់គាត់ ដែលអាចសន្និដ្ឋានបានយ៉ាងជាក់ថា គាត់អស់សមត្ថភាព ដើម្បីតស៊ូនឹងជីវិតតទៅមុខទៀត ... ។

ដូចការដែលខ្ញុំបារម្ភមែន មូលហេតុដោយនៅវេលាព្រឹកថ្ងៃបន្ទាប់ប្រធានក្រុមបានចាប់មិត្តអ្នកថ្មីនោះ ចងខ្លួនផ្ដោបទៅនឹងគល់ឈើ ដែលពោរពេញទៅដោយសម្បុកស្រមោចភ្លើង ។ ដោយត្រូវហ្វូងស្រមោចភ្លើងខាំ គ្មានត្រាប្រណី គាត់ពត់កាយរើបម្រះ ដោយការឈឺពើតផ្សា ហើយបណ្ដាលឱ្យគាត់រាកនោមនៅនឹងកន្លែងតែម្ដង ។ ហើយទោះបីជាគាត់ស្រែកទ្រហោយំ ព្រមទាំងប្រឹងអង្វរករយ៉ាងអាសូរថា :

ជួយខ្ញុំផង ! ជួយខ្ញុំផង ! ក៏ប៉ុន្តែទោះបីជាយ៉ាងណាក្ដី ពុំមាននរណាម្នាក់ស៊ូទទួលទារុណកម្មជំនួសគាត់ឡើយ ។ នៅថ្ងៃនោះពួកខ្ញុំត្រូវចេញទៅធ្វើការដូចប្រក្រតី ។ ក៏ប៉ុន្តែនៅវេលាវិលត្រឡប់មកសម្រាកហូបបបរថ្ងៃ ប្រធានក្រុមនាំគ្នាស្រាយចំណងគាត់ នាំចូលទៅក្នុងព្រៃជ្រៅ សម្លាប់ចោលដោយអយុត្តិធម៌ ... ។

នៅក្នុងព្រៃជ្រៅនោះសម្បូរទៅដោយមូសដែកគោលដែលបណ្ដាលនាំឱ្យឆ្លងរោគគ្រុនចាញ់ ។ ដោយយើងអ្នកថ្មី ពុំមាននរណាម្នាក់មានមុងចង មិត្តខ្ញុំអ្នកថ្មីដូចជាអាឃីមជាដើម ចាប់ផ្ដើមកើតរោគគ្រុនចាញ់បណ្ដាលឱ្យឆ្លងពីមួយទៅមួយ ។ អ្នកដែលមានរោគគ្រុនចាញ់តែងស្រែកថ្ងូរបណ្ដាក់គ្នា មិនថាថ្ងៃ ឬកណ្ដាលអធ្រាត្រឡើយ ។ ប៉ុណ្ណឹងទៅហើយក្ដី ក៏នៅតែពួកអ្នកចាស់ និយាយពាក្យចំអកចំអន់ថា : គ្រុនញាក់គ្រុនញ័រ គ្រុនត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍... ។

*(ដកស្រង់ចេញពីសៀវភៅផ្ទៃមេឃពណ៌ឥន្ទធនូ និពន្ធដោយ អ្នកស្រី ប៉ែន ប៉ុណ្ណារ៉េត គ.ស ២០០៨)*

## សំណួរ

១. តើអត្ថបទនេះឆ្លុះបញ្ចាំងពីទិដ្ឋភាពនាសម័យកាលណា ? សម័យកាលនោះ ចាប់ពីថ្ងៃ ខែ ឆ្នាំណាដល់ ថ្ងៃ ខែ ឆ្នាំណា ?

២. ចូរបង្ហាញពីបុរេនិច្ឆ័យក្នុងអត្ថបទនេះ ។

៣. តើអង្គការរបស់ ខ្មែរក្រហម ប្រើពាក្យដូចម្ដេចខ្លះក្នុងការយកប្រជាជនខ្មែរទៅសម្លាប់ចោល ?

៤. តើអង្គការរបស់ ខ្មែរក្រហម មានមនុស្សធម៌និងយុត្តិធម៌ដែរឬទេ ? ព្រោះអ្វី ?

៥. តើជីវិតមនុស្សរាល់រូបក្នុងសម័យខ្មែរក្រហមមានតម្លៃដែរឬទេ ? ដើម្បីជីវិតរស់នៅ តើប្រជារាស្ត្រខ្មែរអ្នកថ្មី បានប្រព្រឹត្តអំពើមិនគប្បីដូចសត្វធាតុយ៉ាងដូចម្ដេចខ្លះ ?

៦. តាមយោបល់អ្នក តើសម័យខ្មែរក្រហម មានការរើសអើងដែរឬទេ ? ចូរបង្ហាញអំណះអំណាងបញ្ជាក់ ។

# ការនិយាយបកស្រាយសុភាសិត

ដូចម្ដេចហៅថា សុភាសិត ? តាមន័យរបស់ពាក្យ សុភាសិត គឺជាពំនោលល្អ ពំនោលត្រឹមត្រូវ ឬជំបូន្មានដ៏មានខ្លឹមសារនិងសម្ផស្សបរិបូរទៀតផង ។ សុភាសិត កើតឡើងពីការកំណត់ចំណាំរបស់បុព្វបុរស បញ្ញវ័ន្តដែលបានពិនិត្យ ពិចារណា កត់សម្គាល់ហេតុការណ៍ផ្សេងៗក្នុងជីវភាពរស់នៅក្នុងសង្គម ក្នុងសម័យកាលដែលខ្លួនរស់នៅទុកជាគ្រឿងសម្គាល់ កត់ចំណាំចរិតលក្ខណៈមនុស្ស សត្វនិងធម្មជាតិ ។ ការកត់សម្គាល់និងការចំណាំនេះ ជាបំណងរបស់បុព្វបុរសក្នុងការផ្ដល់ជាបទពិសោធផ្ដល់ការទូន្មានដល់ជនប្រុសស្រីគ្រប់វ័យ គ្រប់ជំនាន់ ឱ្យទទួលបានសេចក្ដីសុខសុភមង្គល ។

សុភាសិតខ្លះមានន័យ ខ្លឹមសារត្រឹមត្រូវគ្រប់សម័យកាល ពេលវេលា ឬគ្រប់មនុស្ស បុគ្គល ឬហេតុការណ៍ ឬក៏មានតម្លៃជាសាកល ។ ចំណែកសុភាសិតខ្លះមានន័យ ខ្លឹមសារប្រែប្រួលទៅតាមសម័យកាល ពេលវេលា ឬទីកន្លែង ... ។ សុភាសិតខ្មែរយើងភាគច្រើនមានន័យពីរយ៉ាងគឺ

## ១ . ន័យជាអត្ថានុរូប (ន័យចំ)

ន័យចំ ជាន័យត្រង់ ន័យផ្ទាល់ មិនមែនជាន័យប្រដូច ឬន័យធៀបឡើយ ។

## ២ . ន័យជាអត្ថបដិរូប (ន័យធៀប)

ន័យធៀបជាន័យប្រដូចឬន័យប្រៀបធៀប ។

ចូរពិនិត្យឧទាហរណ៍ : សុភាសិត : "ងើយស្កុក ឱនដាក់គ្រាប់"

- ន័យចំរបស់សុភាសិតនេះ គឺសំដៅទៅលើស្រូវ ។ ស្រូវនៅពេលផ្លែដាក់គ្រាប់កួរស្រូវតែងតែឱន ។ ចំណែកកួរស្រូវណាដែលងើប ឈរត្រង់ទៅលើ គឺពុំមានគ្រាប់ទេ គេហៅថាស្រូវស្កុកគ្មានប្រយោជន៍ឡើយ ។
- ន័យធៀប : ងើយស្កុកសំដៅទៅលើមនុស្ស គេប្រៀបធៀបនឹងមនុស្ស ដែលមិនគោរពចាស់ទុំព្រហើនកោងកាច គ្មានសុជីវធម៌ ឬកូនដែលមិនស្ដាប់ដំបូន្មានចាស់ទុំ ឪពុកម្ដាយលោកគ្រូ អ្នកគ្រូ ហើយបង្កបញ្ហាដល់គ្រួសារ សាលារៀន និងសង្គម ។ មនុស្សបែបនេះជាមនុស្សគ្មានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិឡើយ ។

***កំណត់សម្គាល់ :*** សុភាសិតខ្លះមានតែន័យចំតែម្ដង ដោយមិនមានន័យធៀបទេ ។

***ឧទាហរណ៍ :*** "ចេះពីរៀន មានពីរក" " ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"... ។

ដូចនេះ ដើម្បីបកស្រាយសុភាសិតបានត្រឹមត្រូវ យើងត្រូវបង្ហាញការអះអាងទៅតាមន័យរបស់សុភាសិតនោះឱ្យបានច្បាស់លាស់ (ន័យចំ ន័យធៀប) ហើយអាចលើកយកឧទាហរណ៍មកបញ្ជាក់ថែមទៀតបើចាំបាច់។

## លំហាត់

ចូរអ្នកបកស្រាយសុភាសិតខាងក្រោមនេះ ៖

១. " តក់ៗពេញបំពង់ "

២. " ចេះពីរៀន មានពីរក "

៣. " ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់ "

៤. " សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា "។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh



# សំណេរតែងសេចក្ដីពន្យល់សុភាសិត

អ្នកបានសិក្សារួចហើយអំពីការនិយាយបកស្រាយរបស់សុភាសិត។ ឥឡូវនេះ អ្នកនឹងសរសេរបកស្រាយអត្ថន័យរបស់សុភាសិត។ សុភាសិតខ្លះមានន័យចំនិងន័យធៀប ឯសុភាសិតខ្លះទៀតមានតែន័យចំប៉ុណ្ណោះ។ ដូចនេះ ដើម្បីធ្វើតែងសេចក្ដីពន្យល់ន័យរបស់សុភាសិត អ្នកគប្បីស្វែងយល់អត្ថន័យរបស់សុភាសិតឱ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយទាំងន័យចំនិងន័យធៀប។ ខាងក្រោមនេះជាគម្រោងតែងទូទៅ ៖

## ១ . សេចក្ដីផ្ដើម

- លំនាំបញ្ហា : លើកយកបញ្ហាទូទៅទាក់ទងនឹងអត្ថន័យសុភាសិត
- ចំណូលបញ្ហា : បញ្ចូលសុភាសិត
- ចំណោទបញ្ហា : លើកយកបញ្ហាក្នុងសុភាសិតនេះមកចោទជាបញ្ហា

## ២ . តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី
- ពន្យល់ពាក្យគន្លឹះក្នុងសុភាសិត (បើចាំបាច់)
- ពន្យល់ប្រធាន
- បកស្រាយសុភាសិត
  - បំណកស្រាយន័យចំរបស់សុភាសិត ដោយលើកយកហេតុផល អំណះអំណាងនិងឧទាហរណ៍មកបញ្ជាក់។
  - បំណកស្រាយតាមន័យធៀប (បើមាន) ដោយលើកហេតុផលអំណះអំណាងនិងឧទាហរណ៍មកបញ្ជាក់។
- សរុបមតិ : សរុបគំនិតរបស់សុភាសិតឡើងវិញទាំងន័យចំនិងន័យធៀប (បើមាន) ។

## ៣ . សេចក្ដីបញ្ចប់

- បង្ហាញពីតម្លៃរបស់សុភាសិត
- ចំណាប់អារម្មណ៍របស់អ្នកសរសេរ។

ចូរពិនិត្យឧទាហរណ៍ ៖

**ប្រធាន :** សុភាសិតមួយថែងថា “ ចេះពីរៀន មានពីរក ”

តើសុភាសិតនេះមានអត្ថន័យដូចម្ដេច ? ចូរពន្យល់ដោយលើកឧទាហរណ៍មកបញ្ជាក់ផង។

# សេចក្ដីអធិប្បាយ

ចំណេះវិជ្ជានិងទ្រព្យសម្បត្តិជារបស់ពីរយ៉ាងដែលមនុស្សម្នាក់ៗ ចាត់ទុកជាសម្បត្តិដ៏មានតម្លៃសម្រាប់អត្ថិភាពនិងសុភមង្គលក្នុងជីវិត ។ ប៉ុន្តែមនុស្សយើងម្នាក់ៗកើតមកមិនបានវេចខ្ចប់មកជាមួយខ្លួននូវសម្បត្តិទាំងនោះទេ ។ មានន័យថាប្រសិនបើយើងម្នាក់ៗមិនខិតខំប្រឹងប្រែងស្វាធ្យាយរិះរកទេ គឺយើងមិនបានទទួលសម្បត្តិទាំងពីរនេះឡើយ សមដូចសុភាសិតមួយថែងថា "ចេះពីរៀន មានពីរក"។ តើសុភាសិតនេះមានខ្លឹមសារយ៉ាងណាខ្លះ ?

ជាការពិតណាស់ អ្វីៗគ្រប់យ៉ាងអាចកើតឡើងបាន អាស្រ័យដោយយើងខិតខំប្រឹងប្រែងតស៊ូអំណត់ព្យាយាមគ្រប់យ៉ាងនិងគ្រប់វេលា ។ ចំណេះវិជ្ជាគ្រប់យ៉ាង សុទ្ធតែបានមកពីការរៀនសូត្រសន្សំមួយថ្ងៃបន្តិចៗរាប់សិបឆ្នាំ ឬពេញមួយជីវិត មិនមាននរណាម្នាក់ចេះឯង ដោយមិនបានរៀនសូត្រនោះឡើយ ។ ជាក់ស្តែង សិស្សានុសិស្ស និស្សិត ទាំងឡាយបានខិតខំប្រឹងប្រែងក្រេបជញ្ជក់យកចំណេះវិជ្ជាគ្រប់បែបយ៉ាងពីគ្រូដើម្បីជាប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ ។ មន្ត្រីរាជការថ្វីត្បិតតែធ្វើការងារបម្រើសង្គមជាតិ ពួកគេក៏នៅតែព្យាយាមសិក្សាបង្កើនចំណេះដឹងបន្ថែមទៀតដោយមិនធ្វេសប្រហែសឡើយ ។ ការរៀនសូត្រនេះសោតទៀត លុះត្រាតែអ្នកសិក្សាម្នាក់ៗខំប្រឹងប្រែងត្រិះរិះពិចារណា ព្រមទាំងធ្វើការអនុវត្តជាក់ស្តែងនិងស្វ័យសិក្សាបន្ថែមទៀត ទើបទទួលបានចំណេះដឹងពិតប្រាកដ ។ ថៅចិត្រ ក្នុងរឿងកុលាបប៉ៃលិន បានក្លាយជាអ្នកគ្រប់គ្រងបញ្ជីជំនួសលោកហ្លួងរតនសម្បត្តិក៏ដោយសារថៅចិត្រមានចំណេះវិជ្ជា ហើយគេបានខិតខំរៀនសូត្របន្ថែមទៀតពីការងារជីកត្បូងនេះដែរ ។

ចំណែកខាងទ្រព្យសម្បត្តិវិញ ក៏មិនខុសពីចំណេះវិជ្ជាដែរ គឺលុះត្រាតែមនុស្សម្នាក់ៗប្រឹងប្រែងរក ឬប្រកបរបរផ្សេងៗ សន្សំសំចៃទុកដាក់បន្តិចម្តងៗ រាប់ខែ រាប់ឆ្នាំ ទើបមានទ្រព្យសម្បត្តិ ។ ជាក់ស្តែង ថៅចិត្រ ក្នុងរឿងកុលាបប៉ៃលិន ក្រោយពីឪពុកស្លាប់ទៅថៅចិត្រក្លាយជាមនុស្សគ្មានទីពឹង គ្មានទ្រព្យធនអ្វីបន្តិចសោះឡើយ ប៉ុន្តែក្រោយពីខ្លួនបានទៅធ្វើកម្មករជីកត្បូងនៅផ្ទះហ្លួងរតនសម្បត្តិ ថៅចិត្របានខិតខំប្រឹងប្រែងធ្វើការងារគ្រប់យ៉ាង មិនរើសអើងការងារឡើយ ។ ការខិតខំប្រឹងប្រែង តស៊ូអំណត់ព្យាយាមនេះ ទីបំផុតថៅចិត្របានក្លាយទៅជាកូនប្រសាហ្លួងរតនសម្បត្តិ គ្រប់គ្រងទ្រព្យសម្បត្តិដ៏ច្រើនស្តុកស្តម្ភថែមទៀត ។ នេះដោយសារការខិតខំប្រឹងប្រែង តស៊ូ អំណត់គ្រប់ការងាររបស់ថៅចិត្រ ។

តាមការបកស្រាយខាងលើ យើងឃើញថា ទាំងចំណេះវិជ្ជា ទាំងទ្រព្យសម្បត្តិសុទ្ធតែកើតឡើងពីការខិតខំប្រឹងប្រែងដោយមនុស្សយើងម្នាក់ៗទទួលបានចំណេះវិជ្ជាពីការខិតខំប្រឹងប្រែងតស៊ូព្យាយាម និងជម្នះគ្រប់ឧបសគ្គទើបមនុស្សយើងម្នាក់ៗទទួលបានចំណេះវិជ្ជានិងទ្រព្យសម្បត្តិ ដែលជាកត្តាជំរុញឱ្យជីវិតមានសុភមង្គល ។

សុភាសិតខាងលើមានអត្ថន័យទូលំទូលាយ សមស្របទៅតាមតថភាពនៃដំណើរជីវិតមនុស្សម្នាក់ៗ ។ ដើម្បីញ៉ាំងឱ្យជីវិតយើងម្នាក់ៗទទួលបានសុភមង្គលពិតប្រាកដ លុះត្រាតែខ្លួនយើងមានចំណេះវិជ្ជា ហើយបើមានទ្រព្យសម្បត្តិថែមទៀតរឹតតែប្រសើរ ។ ដូចនេះយើងជាសិស្សានុសិស្សនិស្សិតគ្រប់រូបត្រូវខិតខំអំណត់ព្យាយាមតស៊ូគ្រប់ឧបសគ្គ ដើម្បីក្រេបយកចំណេះគ្រប់យ៉ាង មិនត្រូវបណ្តែតបណ្តោយពេលវេលាឱ្យកន្លងហួសទៅដោយឥតប្រយោជន៍នោះឡើយ ។ យើងទាំងអស់គ្នាជាយុវជន គឺជាសសរទ្រូងរបស់ប្រទេសជាតិ ។

## សំណួរ

១. តើសំណោរខាងលើមានប៉ុន្មានកថាខណ្ឌ ?

២. តើកថាខណ្ឌទីមួយនិយាយពីអ្វី ?

៣. តើកថាខណ្ឌទីពីរបង្ហាញពីអ្វី ? ចុះចំណែកកថាខណ្ឌទីបី ?

៤. ចូរបង្ហាញពីទម្រង់របស់សំណោរតែងសេចក្តីខាងលើ ។

## លំហាត់

១. ប្រធាន ៖ សុភាសិតមួយថែងថា " ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ "
តើសុភាសិតនេះមានអត្ថន័យយ៉ាងដូចម្តេចខ្លះ ? ចូរពន្យល់ ដោយលើកឧទាហរណ៍មកបញ្ជាក់ ។

២. ប្រធាន ៖ សុភាសិតមួយថែងថា " ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក " តើសុភាសិតនេះមានអត្ថន័យយ៉ាងណា ?
ចូរបកស្រាយដោយលើកឧទាហរណ៍មកបញ្ជាក់ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

គម្រោងតែង ប្រធានទី ២ " ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក " ។

## ១ . សេចក្ដីផ្ដើម

- លំនាំបញ្ហា : ផ្ដើមទាក់ទងនឹងន័យចំ គឺឈើមានវៀចនិងត្រង់
  ផ្ដើមទាក់ទងនឹងន័យធៀប គឺមនុស្សរស់នៅក្នុងសង្គម
- ចំណូលបញ្ហា : បញ្ចូលប្រធាន "ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក"
- ចំណោទបញ្ហា : តើសុភាសិតនេះមានន័យដូចម្ដេចខ្លះ ?

## ២ . តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី
- ពន្យល់ពាក្យគន្លឹះ
  - កង់ : សំដៅលើកង់រទេះ ។ កង់រទេះរាងជារង្វង់ មានកាំ ធ្វើពីឈើ ... ។
  - ទូក : សំដៅលើទូករទេះ ។ ទូករទេះធ្វើពីឈើត្រង់ពីរ គេច្រើនយកឈើត្រង់ស្រាប់ទៅធ្វើ ... ។
- ពន្យល់ន័យប្រធាន : ដោយសារកង់រទេះមានរាងជារង្វង់ កោង មូលដូចនេះគេអាចយកឈើដែលវៀចទៅធ្វើកង់តែម្ដង ចំណែកឯឈើត្រង់ពីរដែលជាទូករទេះនោះ គេយកឈើដែលត្រង់ទៅធ្វើទើបត្រង់ល្អ ហើយងាយស្រួល ។ មនុស្សក្នុងសង្គមក៏ដូចនេះដែរ គឺគេប្រើមនុស្សទៅតាមប្រភេទនិងសមត្ថភាពរបស់មនុស្ស ។
- បំណកស្រាយប្រធាន
  - ន័យចំ :កង់រទេះ គេប្រើឈើវៀច ... ទូករទេះធ្វើពីឈើត្រង់ ... ។
  - ន័យធៀប :មនុស្សក្នុងសង្គមសុទ្ធតែជាកោសិការបស់សង្គម អាចបម្រើប្រទេសជាតិប្រជាជនបានដូចគ្នាទៅតាមសមត្ថភាព លទ្ធភាពរៀងៗខ្លួន ... ។ ***ឧទាហរណ៍ :*** ... ។
- សរុបមតិ : ឈើក្ដីមនុស្សក្ដីសុទ្ធតែមានប្រយោជន៍ដូចគ្នាទៅតាមប្រភេទនិងសមត្ថភាពរៀងៗខ្លួន... ។

## ៣ . សេចក្ដីបញ្ចប់

- ការវាយតម្លៃគំនិតរបស់សុភាសិត
- ចំណាប់អារម្មណ៍របស់អ្នកតែង ។

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី
៧

# ភាពជាពលរដ្ឋ



ពលរដ្ឋម្នាក់ៗ ជាកោសិការបស់ប្រទេសជាតិ ។ ប្រទេសជាតិមួយ អាចស្ថិតស្ថេរគង់វង្សនិងមានការអភិវឌ្ឍ អាស្រ័យដោយប្រទេសនោះសម្បូរដោយពលរដ្ឋល្អនិងពលករជំនាញ ។ យើងម្នាក់ៗបានធ្វើខ្លួនឱ្យក្លាយជាពលរដ្ឋល្អហើយឬនៅ ? តើពលរដ្ឋល្អត្រូវមានតួនាទីនិងកាតព្វកិច្ចដូចម្ដេចខ្លះចំពោះជាតិមាតុភូមិ ?

មេរៀននេះ បានបង្ហាញពីភារកិច្ចនិងតួនាទីនៃពលរដ្ឋប្រុសស្រីទាំងអស់ ក្នុងការរួមចំណែកការពារនិងកសាងជាតិ ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀត ប្រផ្នូលនិងរំលឹករឿងដើម តម្លៃអប់រំរបស់អត្ថបទ ល្បះទោលនិងការតែងល្បះ ការតែង និងការសូត្រកំណាព្យ ។

## ប្រផ្នូលនិងការរំលឹករឿងដើម

បុព្វបុរសខ្មែរយើងគេតែងលើកយកបាតុភូតផ្សេងៗមកបង្ហាញ ដើម្បីទុកជាការយល់ដឹងខ្លះៗអំពីជំនឿរបស់ខ្មែរពីសម័យបុរាណមក ។

### ក. ប្រផ្នូល

ក្នុងរឿងខ្លះអ្នកនិពន្ធបានបង្ហាញហេតុភេទអ្វីមួយតាមជំនឿមុននឹងកើតមានព្រឹត្តិការណ៍អ្វីមួយ ។ ហេតុដែលឱ្យដឹងមុននេះ គេហៅថាប្រផ្នូល ។

ចូរអ្នកអានវគ្គដកស្រង់រឿងភូមិតិរច្ឆាន ៖

[...] នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ១៩២១ វេលាយប់នៅលើផ្ទៃអាកាសស្រាប់តែពពកប្រមូលផ្តុំគ្នាឡើង ហើយផ្លេកបន្ទោរ រន្ទះឆុងឆាំងហាក់ដូចជាសន្មតគ្នាទុកជាមុន ។ អ្នកស្រុកភិតភ័យឱបកូនថៅដោយសារខ្លាចស្នូររន្ទះ ។ នៅវេលាម៉ោង ៩យប់ស្រាប់តែមានផ្លេកបន្ទោរភ្លែតៗ ដូចជាពុះមេឃ ហើយបន្តិចមកស្នូរស្ទើរកក្រើកធរណី ។ មិនយូរប៉ុន្មានសំឡេងពីមាត់មួយទៅមាត់មួយថា រន្ទះបាញ់ចេតិយព្រះវិហារព្រះកែវមរកតខាងត្បូង ។ ហេតុនេះធ្វើឱ្យប្រជារាស្ត្រ នាម៉ឺនមានចិត្តស្រណោះ ព្រោះតាមជំនឿថានឹងមានចលាចលឬមានកើតទុរភិក្សក្នុងស្រុក ។ [...]

តាមអត្ថបទ តើប្រផ្នូលអ្វីដែលនាំឱ្យគេជឿថាមានចលាចល ឬមានកើតទុរភិក្សក្នុងស្រុក ?

### ខ. ការរំលឹករឿងដើម

ក្នុងរឿងខ្លះអ្នកនិពន្ធបានផ្អាកដំណើររឿង ហើយត្រឡប់ទៅលើកយកការសន្ទនាឬព្រឹត្តិការណ៍ដែលកើតឡើងពីមុនយកមកបរិយាយ ។ ការបរិយាយនេះគេហៅថាការរំលឹករឿងដើម ។

ចូរអ្នកអានវគ្គដកស្រង់រឿងគ្រូបង្រៀនស្រុកស្រែ ៖

ពូហំរត់គេចពីចំណាប់ប៉ូលីស ។ មីងសនជាប្រពន្ធព្រួយបារម្ភពីប្តីគាត់ ហើយគាត់និយាយប្រាប់នាងសុនជាក្មួយ ៖

[...] តាំងពីប្រសព្វគ្នាមកពូហាងមិនដែលល្អនឹងអញដូចឆ្នាំនេះទេ ។ កាលឆ្នាំមុនៗផ្តេសផ្តាសដើរតែស៊ីផឹក ។ តាំងពីឈប់ធ្វើការមកគិតតែពីអាវាសែ បន្តិចតាមលោកនេះ បន្តិចតាមមានស្រីជាមួយលោកនោះ កន្លះខែអើតផ្ទះម្តង ... ។ តែតាំងពីបងសែមភូមិងជើងមកលេងផ្ទះញឹក មាហាងបានឈប់ទៅកំពង់ បានឃ្លាតឆ្ងាយពីអស់លោកខ្លះ ... ។ អញឃើញគាត់បានមើលសៀវភៅតូចៗ ហើយចេះគិតប្រពន្ធកូន ផ្ទះសម្បែង ... ។ គាត់ចេះជួយរកស៊ីយើង ។ ពេលព្រឹកៗ គាត់បានឆ្លៀតទៅជួយលើកអង្ករយើងទៀត ។ [...]

១. តើពាក្យសម្ដីអ្វីខ្លះ ដែលបញ្ជាក់ថាជាការរំលឹករឿងដើម ?

២. តើមីងសនរំលឹករឿងដើមរបស់ពូហាមដូចម្ដេចខ្លះ ?

*ប្រផ្នូល គឺជាហេតុភេទដែលគេដឹងមុនថានឹងកើតមានព្រឹត្តិការណ៍អ្វីមួយ ។*

*ការរំលឹករឿងដើម គឺជាការផ្អាកដំណើររឿង ហើយត្រឡប់ទៅលើកយកការសន្ទនា ឬព្រឹត្តិការណ៍ដែលកើតឡើងពីមុនយកមកបរិយាយ ។*

## លំហាត់

ចូរអ្នកបង្ហាញពីប្រផ្នូល និង ការរំលឹករឿងដើមតាមរយៈរឿងមួយចំនួនដែលអ្នកបានអាន ឬ សិក្សាកន្លងមក ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh



# ពេជ្រនឹងត្រូវច្នៃ



## ក. សិក្សាពាក្យគន្លឹះ

- មេសង្វៀន : មេខ្លោង អ្នកការពារព្រំប្រទល់បឹង ឬការពារឡូត៍នេសាទ ។
- សហករណ៍ : ក្រុមហ៊ុន ឬអង្គការដែលប្រមូលផ្ដុំជនអ្នកបង្កើតផលផ្សេងៗ ។
- កង់ប្រវត្តិសាស្ត្រ : ដំណើរវិវត្តរបស់ប្រវត្តិសាស្ត្រ ។
- បើកភ្នែក : ស្វែងយល់ពីការពិត ។
- អ្នកលេង : ក្រុមអ្នកដៃដល់ ។
- ចិញ្ចឹមឆ្នាំង : មុខរបរមួយពេលសម្រាប់តែមួយពេល ។
- ថៅកែហាងឆេង : មេជំនួញដែលជាអ្នកកំណត់តម្លៃ ។
- កប់ក្ដោង : សន្ធឹកសន្ធាប់ ច្រើនហួសពីការស្មាន ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអ្នកត្រូវយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងអ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាស ទំនាស់ វិធីតែងនិពន្ធ និងតម្លៃអប់រំ ។

## គ. អត្ថបទ

[...] អាចារ្យសមបានកាត់ ៖

"មើល៍ ! ហាមឯងបាននិយាយថា ភូមិឫស្សីបានបើកភ្នែកខ្លួន តើមានអ្វីខ្លះ ? ខ្ញុំនៅជិតភូមិនេះដែរ តែដូចជាវាមិនឃើញមានអ្វីខុសគេ ?"

"លោកបងអាចារ្យមិនដែលទៅបានជាអ៊ីចឹង ។ កាលពីខែមុនខ្ញុំនិងប្អូនម៉ៅព្រមទាំងគ្រូៗប្អូនប្រាំនាក់ទៀត ជិះកង់លើភ្លឺទៅភូមិនោះ ។ អ្នកស្រុកក្រហៅមហាក្រ បានទទួលយើងដូចស្គាល់គ្នាប៉ុន្មានឆ្នាំមកហើយអ៊ីចឹង ។ គេនិយាយប្រាប់យើងគ្រប់គ្នា ។ គេមិនដែលបានស្គាល់នាម៉ឺនមកភូមិគេទេ ។ រាល់ឆ្នាំគេមានរឿងតែជាមួយមេសង្វៀនបឹង ។ បងអាចារ្យដឹងទេ មេសង្វៀនបឹងបានចាត់អ្នកលេងប៉ាវបឹងឱ្យមកលើកទ្រូ កាប់លបអ្នកស្រុក ។ ថៅកែបឹងមានអ្នកលេងកាប់ចាក់ សម្លុតអ្នកស្រុក ដែលដាក់ទ្រូដាក់លបបន្តិចបន្តួចគ្រាន់នឹងចិញ្ចឹមឆ្នាំង ។ ថៅកែបឹងរំលោភអស្ចារ្យហើយ ។ គេបានប្រកាន់ថា បឹងគេមានព្រំត្រឹមត្រូវ ទឹកឡើងរហូតមកដល់មាត់ភូមិអ្នកស្រែ អ្នកស្រុក ... ។ រាល់ឆ្នាំអ្នកភូមិត្រូវមេសង្វៀនធ្វើបាប ហើយអ្នកលេងបឹងនោះ កាចសាហាវមានអំណាចអស្ចារ្យ ។ គេអាចសម្លាប់អ្នកភូមិបានដោយគ្មានទោស ។ គេបង្វែងដានបានទាំងអស់ ។ ថៅកែគេបានស្គាល់អស់នាម៉ឺននៅខេត្តស្រុកស្រេច ..." ។

"ខ្ញុំគ្មានដឹងសោះ" (អាចារ្យសមលាន់មាត់) ។

"យើងគិតដូចម្ដេច ជួយដោះទុក្ខអ្នកភូមិផង" (ឡឹងបានចោទ) ។

"ការដោះទុក្ខកែប្រែការរស់នៅពិបាក ហើយយូរផង ។ យើងមិនអាចពិភាក្សាគ្នាផងដើរផងទេ ព្រោះយើងដល់ផ្លូវបែកគ្នាហើយ ..." ។

"យើងឈប់និយាយគ្នាមួយស្របក់ទៅ យើងកំពុងតែជក់មាត់" (ឡឹងបានស្នើ) ។

"ឈប់ក៏ឈប់" (អាចារ្យសមយល់ព្រម) "តុះ ! យើងទៅឈប់នៅមាត់អូរ ...." ។

អ្នកទាំងបីបានឈប់ ។ ឡឹងអង្គុយមុនគេ ។ អាចារ្យសមបានជក់បារី ។ បងហាមបត់ជើងតូចរួចក៏ត្រឡប់ទៅអង្គុយជាមួយគេ ។ បន្ទាប់មកគាត់ចាប់និយាយ ៖

ការដោះទុក្ខកែប្រែការរស់នៅរបស់ប្រជាជនយើងគ្រប់គ្នាជាការពិបាក ជាការយូរមិនឆាប់ដូចមាត់ទេ ។ ដោយមនុស្សធ្វើមិនមែនទេវតាឯណាធ្វើជួយយើងទេ... ។ យើងត្រូវអប់រំខ្លួនយើងនិងអប់រំអ្នកភូមិឱ្យយល់ជឿលើកម្លាំងខ្លួន ហើយឱ្យដឹងថា ទាល់តែយើងរួមកម្លាំងគ្នាសាមគ្គីបានយើងអាចទប់ទល់នឹងអ្នកលេងដៃជើងថៅកែមេសង្វៀនបាន ។ នៅស្រុកស្រែជាមួយយើងគេអាងអ្នកលេង នៅទីក្រុងគេអាងទឹកប្រាក់ ... ។ បើដូច្នេះ បើចង់រួចខ្លួន ចង់បានស្រួល ចង់បានយុត្តិធម៌ ទាល់តែអ្នកភូមិ

នេះស្គាល់ពីកាពត្វកិច្ចខ្លួន ចេះកែប្រែខ្លួនឡើង ។ ការរៀបចំភូមិឃុំ ជាការចាំបាច់មុនគេបង្អស់ចំពោះក្រុមយើង ។ ដោយហេតុនេះបានជាខ្ញុំយល់ឃើញថា ដល់រួចរាល់ឆ្នាំក្រោយៗនេះ យើងត្រូវតែបើកឱ្យមានសិទ្ធិប្រជាជនបោះឆ្នោតជ្រើសរើសមេឃុំ ដែលតំណាងឱ្យប្រជារាស្ត្រក្នុងឃុំ តែមិនមែនជាអ្នកគាបសង្កត់លើរាស្ត្រ ដូចអាណានិគមនិយមបារាំងបង្កបង្កើតនោះទេ ហើយមានភារៈកែប្រែអ្នកភូមិពីក្តីវេទនា គ្មានអាវពាក់ ពីអំពើចោរកម្ម ពីការគម្រាមកំហែង ។ យើងត្រូវមានគ្រោងការណ៍ដូចតទៅ ៖

១. ខាងនយោបាយការពារនិងពង្រីកសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យពិតៗឱ្យប្រជាជនអ្នកស្រែមានអំណាចបោះឆ្នោតជ្រើសរើសរបៀបគ្រប់គ្រងភូមិឃុំរបស់ខ្លួន ។

២. ខាងសេដ្ឋកិច្ចបង្កើតផ្នែកសហគមន៍ ឬសមាគមកសិករនៅក្នុងភូមិឃុំ ការពារផលដំណាំ ពោត ស្រូវ ស្ករ កុំឱ្យពួកថៅកែហាងឆេងមកវាយបន្ថោក យកចំណេញកប់ក្តោងដូចសព្វថ្ងៃ ។ ម្យ៉ាងទៀតខាងបឹងព្រៃវិញ ប្រមូលប្រជាជនធ្វើសមាគម ការពារផលធម្មជាតិទាំងនោះទុកចែកសម្រាប់គ្រប់គ្នាមិនឱ្យមេសង្វៀនក្តាប់ចំណេញរាប់សែនយកទៅជួលអ្នកលេងឱ្យមកធ្វើបាបអ្នកភូមិដូចសព្វថ្ងៃនេះ ... ។

៣. ខាងសង្គមកិច្ចចាត់តាំងឱ្យមានផ្នែកសមាគមនារី សមាគមយុវជន សមាគមអ្នកស្រែចំការបង្កើតផ្ទះពេទ្យ ... ។

៤. ខាងវប្បធម៌ ពង្រីកនិងបង្កើនសាលារៀននៅគ្រប់ភូមិគ្រប់វត្ត ឱ្យមានចំនួនគ្រប់គ្រាន់ ដើម្បីគ្រប់ក្មេងបានរៀនសូត្រ បង្កើតសាលារៀនមនុស្សចាស់ប្រុសស្រីមិនចេះអក្សរ ឧបត្ថម្ភលោកគ្រូបង្រៀនឱ្យជួយរៀបចំដាក់កម្មវិធីសិក្សា របៀបប្រជាធិបតេយ្យពិតប្រាកដ បង្កើតបណ្ណាល័យទិញសៀវភៅឱ្យប្រជាជនខ្មីមើល ។

"គ្រោងការណ៍ទាំងនេះខ្ញុំពេញចិត្តណាស់ ។ តើយើងធ្វើបានឬទេ ?" (ឡឹងបានកាត់) ។

"បាន ! ប្រាកដជាបាន ។ គ្រាន់តែយូរនិងឆាប់ ។ កង់ប្រវត្តិសាស្ត្រសង្គមមនុស្សកំពុងតែវិលសំដៅទៅលទ្ធិប្រជាធិបតេយ្យ ។ បើមិនឆ្នាំនេះ ឆ្នាំក្រោយ ។ បើយើងធ្វើមិនទាន់បាន កូនយើងធ្វើបាន ។ បើកូនយើងធ្វើមិនសម្រេច ចៅយើងមុខជាសម្រេច ។ បើភូមិឃុំយើងមិនទាន់កើត ក៏ភូមិឃុំផ្សេងទៀតធ្វើបាន" ។

"សប្បាយហើយក្មេងជាន់ក្រោយ" (ឡឹងបានសាទរ) "ខ្ញុំមុខតែទៅនិយាយប្រាប់អ្នកភូមិឬស្សីទាំងយប់នេះហើយ" ។

"ខែវះហើយ តុះ! យើងទៅ" ។ (អាចារ្យសមបានបញ្ចប់) ។

រួចគាត់ក្រោកឈរ បងហាមក្រោកតាម ក្រោយបំផុតឡឹងក្រោកទៀត ។ អ្នកទាំងបីបានបែកគ្នា ឡឹងឆ្លងអូរទៅភូមិឫស្សី ។ អាចារ្យសមនិងបងហាមដើរតាមដងអូរទៅត្បូងសំដៅពាម ។

*(ដកស្រង់និងកែសម្រួលចេញពីរឿងគ្រូបង្រៀនស្រុកស្រែ ទំព័រទី ១៧ដល់១៩ បោះពុម្ពឆ្នាំ ១៩៨៧)*

## សំណួរ

១. តើអត្ថបទនេះមានចំណងជើងដូចម្ដេច ? ដកស្រង់ចេញពីរឿងអ្វី ? និពន្ធនៅក្នុងឆ្នាំណា ? ហើយអ្នកនិពន្ធមានឈ្មោះអ្វី ?

២. ចូរបង្ហាញលក្ខណសម្បត្តិតួអង្គពូហាម ។

៣. ចូរបង្ហាញពីទស្សនៈសុទិដ្ឋិនិយមរបស់តួអង្គ ។

៤. តើនៅក្នុងអត្ថបទនេះអ្នកនិពន្ធប្រើវិធីតែងនិពន្ធដូចម្ដេចខ្លះ ?

៥. តើនៅក្នុងអត្ថបទរឿងគ្រូបង្រៀនស្រុកស្រែអ្នកនិពន្ធបានធ្វើការរំលឹករឿងដើមនៅត្រង់វគ្គណា ?

៦. ចូររកតម្លៃអប់រំនៅក្នុងអត្ថបទនេះ ។

៧. តាមរយៈអត្ថបទ តើចំណុចត្រង់ណាខ្លះដែលបង្ហាញពីគំនិតពលរដ្ឋល្អ ?

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ទម្រង់ល្បះទោល

ពីមុនមកអ្នកបានសិក្សាអំពីផ្កាក់និងឃ្នាប់រួចហើយ ។ ឥឡូវនេះអ្នកនឹងសិក្សាអំពីល្បះកើតពីកន្សោមនាមនិងកន្សោមកិរិយាដែលមានទម្រង់ខុសៗគ្នា ។

ចូរអ្នកពិនិត្យល្បះខាងក្រោម ៖

១. ឆ្កែព្រុស ។
២. ខ្ញុំមិនជក់បារីទេ ។
៣. ខ្ញុំមកដល់ក្បែរចំណតរថភ្លើង ។
៤. គាត់ឈប់ជក់បារីដើម្បីសុខភាព ។
៥. បុប្ផាជានិស្សិត ។
៦. ពូខ្ញុំអាយុ ៤០ឆ្នាំ ។

យើងសង្កេតឃើញថា ល្បះទាំងប្រាំមួយខាងលើ ផ្សំឡើងដោយកន្សោមនាមបូកនឹងកន្សោមកិរិយា ។

- ល្បះទី១ ផ្សំឡើងដោយកន្សោមនាម "ឆ្កែ" កិរិយា "ព្រុស" ។
  ល្បះនេះមានទម្រង់ ៖ កន + កកិ ។
- ល្បះទី២ ផ្សំឡើងដោយនាមទីមួយ "ខ្ញុំ" កិរិយា "មិនជក់" និងកន្សោមនាមទីពីរ "បារីទេ" ។
  ល្បះនេះមានទម្រង់ ៖ កន$_{១}$ + កិ + កន$_{២}$ ។
- ល្បះទី៣ ផ្សំឡើងដោយនាមទីមួយ "ខ្ញុំ" កិរិយា "មកដល់" និងកន្សោមមានផ្កាក់ "ក្បែរចំណតរថភ្លើង" ។
  ល្បះនេះមានទម្រង់ ៖ កន$_{១}$ + កិ + កមផ ។
- ល្បះទី៤ ផ្សំឡើងដោយនាមទីមួយ "គាត់" កិរិយា "ឈប់ជក់" និងកន្សោមនាមទីពីរ "បារី" + កន្សោមមានផ្កាក់ "ដើម្បីសុខភាព" ។
  ល្បះនេះមានទម្រង់ ៖ កន$_{១}$ + កិ + កន$_{២}$ + កមផ ។
- ល្បះទី៥ ផ្សំឡើងដោយនាមទីមួយ "បុប្ផា" កិរិយា "ជា" និងកន្សោមនាមទីពីរ "និស្សិត" ។
  ល្បះនេះមានទម្រង់ ៖ កន$_{១}$ + កិ + កន$_{២}$ ។
- ល្បះទី៦ ផ្សំឡើងដោយនាម "ពូខ្ញុំ" និងកន្សោមកិរិយាដែលមាននាមទីពីរគ្មានកិរិយាទេ ។
  ល្បះនេះមានទម្រង់ ៖ កន$_{១}$ + $0$ + កន$_{២}$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# គំនូសតាងល្បះ


១.
ល
កន
កកិ
ន
កិ
ផ្កែ
ព្រុស ។
ល
កន
កកិ
ផ្កែ
ព្រុស
ន
កិ
២.
ល
កន១
កកិ
កិ
កន២
ខ្ញុំ
មិនជក់
បារីទេ ។
ល
កន១
កកិ
កិ
កន២
ខ្ញុំ
មិនជក់
បារីទេ
សព្វនាម
៣.
ល
កន១
កកិ
កិ
កមធ
ធ
កន២
ខ្ញុំ
មកដល់
ក្បែរ
ចំណតរថភ្លើង ។
ល
កន១
កកិ
កិ
កមធ
ធ
កន២
ខ្ញុំ
មកដល់
ក្បែរ
ចំណតរថភ្លើង
សព្វនាម
៤.
ល
កន១
កកិ
កិ
កន២
កមធ
គាត់
ឈប់ជក់
បារី
ដើម្បីសុខភាព ។
ល
កន១
កកិ
គាត់
ឈប់ជក់
បារី
ដើម្បីសុខភាព
កិ
កន២
កមធ
សព្វនាម
៥.
ល
កន១
កកិ
កិ (ជា)
កន២
បុប្ផា
ជា
និស្សិត ។
ល
កន១
កកិ
កិ(ជា)
កន២
បុប្ផា
ជា
និស្សិត
នាម
៦.
ល
កន១
កកិ
កិ
កន២
ពូខ្ញុំ
∅
អាយុ៤០ឆ្នាំ ។
ល
កន១
កកិ
កិ
កន២
ពូខ្ញុំ
∅
អាយុ៤០ឆ្នាំ

តាមឧទាហរណ៍ខាងលើនេះ យើងឃើញថាល្បះទាំងនោះ ជាល្បះដែលកើតឡើងពីកន្សោមនាមប្រធាន និងកន្សោមកិរិយា ។ ល្បះទាំងនោះមិនទាន់មានភាពសាំញ៉ាំ ទាក់ទងនឹងការពង្រីកឬល្បះដទៃទៀតឡើយ ។

*ល្បះទោល គឺជាល្បះដែលកើតឡើងពីការផ្សំរវាងកន្សោមនាមប្រធាននិងកន្សោមកិរិយាដែលមិនទាន់មានភាពសាំញ៉ាំឡើយ ។*

ទម្រង់ល្បះទោលមានដូចជា ៖

- ល → កន + កកិ ។
- ល → $កន_{១}$ + កិ + $កន_{២}$ ។
- ល → $កន_{១}$ + កិ + កមធ ។
- ល → $កន_{១}$ + កិ + $កន_{២}$ + កមធ ។
- ល → $កន_{១}$ + កិ(ជា...) + $កន_{២}$ ។
- ល → $កន_{១}$ + 0 + $កន_{២}$ ។

## លំហាត់

ចូរប្រាប់ពីទម្រង់ល្បះខាងក្រោម ហើយគូសគំនូសតាងល្បះទាំងនោះជាមែកធាងនិងប្រអប់ ។

១. ហាមនិយាយពីភូមិឫស្សី ។

២. យើងត្រូវជួយអប់រំអ្នកភូមិអំពីការងារនេះ ។

៣. អាចារ្យហាមនិយាយកាត់ ។

៤. យើងជួយការពារផលប្រយោជន៍អ្នកភូមិ ។

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

# សញ្ញាពិសេសរបស់កំណាព្យ

កាព្យ ជាប្រភេទអក្សរសិល្ប៍មួយបែបដែលមានជាយូរលង់ណាស់មកហើយក្នុងប្រវត្តិអក្សរសិល្ប៍មនុស្សជាតិ ។ កំណាព្យកើតឡើងក្នុងតំណរយៈកាលនៃការងារផលិតកម្មរបស់មនុស្ស ។ វាមានលក្ខណៈប្រជាប្រិយយ៉ាងជ្រាលជ្រៅនិងត្រូវបានមហាពលករចូលចិត្តជាទីបំផុត ។ វាមានមុខងារឆ្លុះបញ្ចាំងការសប្បាយរីករាយ ការទុក្ខព្រួយ ការស្រមៃ និងបំណងស្វែងរកសុភមង្គលនៃប្រជាពលករក្នុងការតស៊ូដ៏ខ្លាំងក្លា ដើម្បីយកជ័យជម្នះលើធម្មជាតិនិងប្រឆាំងរាល់អំពើគាបសង្កត់ កេងប្រវ័ញ្ចនៅក្នុងសង្គមមានវណ្ណៈ ។

កំណាព្យមានលក្ខណៈជាប់ស្អិតទៅនឹងវប្បធម៌ អរិយធម៌របស់ជនជាតិនីមួយៗ ហើយមានវិសេសភាពផ្ទាល់ខ្លួនថែមទៀតផង ។ គេមិនអាចចាត់ថា កំណាព្យជនជាតិណាមួយល្អប្រសើរ ឬវិសេសជាងជនជាតិណាមួយបានឡើយ ។

## សញ្ញាប្រើលើកំណាព្យខ្មែរ

### ក. គំនូសលើព្យាង្គ

- ចួន :

*ឧទាហរណ៍ :*

កុលាបរីកស្រស់ មានរូបសម្ផស្ស ឥតខ្ចោះប្រណីត
កន្លង់ទាំងពួង លួងលោមផ្ដេកផ្ដិត ចងចោមកៀកកិត
ស្និទ្ធស្នាលស្នេហា ។

- ផ្ងួន :

*ឧទាហរណ៍ :*

អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងធាក់ អាងគុកច្រវាក់
អាង .............. ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

• រណ្តំ

- រណ្តំព្យញ្ជនៈ

*ឧទាហរណ៍ :*

កុលាបរីកស្រស់ មានរូបសម្ផស្ស ឥតខ្ចោះប្រណីត
កន្លង់ទាំងពួង លួងលោមផ្ដេកផ្ដិត ចងចោមក្បៀកកិត
ស្និទ្ធស្នាលស្នេហា ។

រណ្តំព្យញ្ជនៈ “ល ផ ច ក”

- រណ្តំស្រៈ

*ឧទាហរណ៍ :*

អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងធាក់ អាងគុកច្រវាក់
អាង ............ ។

រណ្តំស្រៈ អា “ា” ។

## ខ. សញ្ញាអធិប្បាយពន្យល់ ឬបកស្រាយ

ចួន : |══════|

ផ្ទួន : |≡≡≡≡≡≡|

រណ្តំ : |──────|

*តាមឧទាហរណ៍ខាងលើ ៖*

ចួន : ព្យ.៤.ឃ.១ ល.១ |══════| ព្យ.៤.ឃ.២ ល.១ ។

ផ្ទួន : ព្យ.១.ឃ.១ ល.១ |≡≡≡≡≡≡| ព្យ.៣.ឃ.១ ល.១ ។

រណ្តំ : ព្យ.១.ឃ.៥ ល.១ |──────| ព្យ.២.ឃ.៥ ល.១ ។ (រណ្តំព្យញ្ជនៈ)

ព្យ.១.ឃ.១ ល.១ |──────| ព្យ.៣.ឃ.២ ល.១ ។ (រណ្តំស្រៈ)

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## គ. គំនូសតាង



ព្យ.៤.ឃ.១ ល.១ ព្យ.៤.ឃ.២ ល.១

ព្យ.៤.ឃ.៣ ល.១ ព្យ.៤.ឃ.៥ ល.១ ព្យ.៤.ឃ.៦ ល.១ ។

- *ចួន : ជាពាក្យទាំងឡាយដែលមានព្យាង្គកើតឡើងដោយសូរស្រះដូចគ្នាឬព្យញ្ជនៈប្រកបដូចគ្នា ឬសូរស្រៈ និងព្យញ្ជនៈប្រកបដូចគ្នា ។*

  *សញ្ញាចួន : សម្រាប់បកស្រាយ សម្រាប់គូសលើព្យាង្គ*
- *ផ្ទួន : កវីជ្រើសរើសព្យាង្គដដែលៗមកប្រើក្នុងឃ្លាកាព្យ ។ ផ្ទួន គឺជាវិធីដែលកវីប្រើដើម្បីសង្កត់ន័យលើគំនិតណាមួយ ឬបង្កើតសញ្ចេតនាអ្វីមួយ ។*

  *សញ្ញាផ្ទួន : សម្រាប់បកស្រាយ សម្រាប់គូសលើព្យាង្គ*
- *រណ្ដំ : ការប្រើព្យញ្ជនៈតែមួយ ស្រៈតែមួយ ច្រើនដងក្នុងឃ្លាឬវគ្គ ។ រណ្ដំមានរណ្ដំព្យញ្ជនៈ និងរណ្ដំស្រៈ គឺការប្រើព្យញ្ជនៈដដែលៗ ឬស្រៈដដែលៗក្នុងឃ្លាឬវគ្គ ។*
- *សញ្ញារណ្ដំ : សម្រាប់បកស្រាយ សម្រាប់គូសលើព្យាង្គ*

youtube.com/moeys
facebook.com/moeys.gov.kh

## លំហាត់

ចូរប្អូនរកពាក្យគួន ផ្ទួន រណ្ដំ ព្រមទាំងបង្ហាញសញ្ញាអធិប្បាយពន្យល់ បកស្រាយនៅក្នុងអត្ថបទកាព្យខាងក្រោម ៖

១. របបអាពតខ្មៅអប្រិយ ខ្មែររងអវិចីក្រុងស្រុកស្រែ
វាខំសម្លាប់បំបាត់ខ្មែរ រស់បន្តខ្សែពីអង្គរ ។
ទុក្ខខ្មែរទុក្ខរស់ទុក្ខរងកម្ម រស់ជាងបីឆ្នាំចាំថ្ងៃមរណ៍
ក្រញ៉ាំបិសាចអន្ទងរក៍ ហេតុអ្វីខ្មែរមរណ៍គរដូចនេះ ។
ក្រញ៉ាំបិសាចក្រចកដែក ក្រចកចាប់ហែកហែកប្រលេះ
ជញ្ជក់ឈាមខ្មែរខាំសំឡេះ ខាំបោចខាំបេះប្រលេះខ្មែរ ។
អ្នករស់នៅរស់ទាំងរងកម្ម រស់ជាងបីឆ្នាំទុក្ខគ្មានល្ហែ
អ្នកស្លាប់ក៏ស្លាប់ឥតន័យដែរ បីឆ្នាំប្រាំបីខែបីលានប្លាយ ។
ខ្មែររស់រស់ក្នុងសំណាញ់ដែក មិនដឹងជាស្រែកអភិប្រាយ
រស់អស់សង្ឃឹមអស់នឿយណាយ ទឹកភ្នែកស្រូបបាយលាយជុំក្រួស ។

*(ដកស្រង់ពីសៀវភៅ កំណាព្យខ្មែរដោយ លី សុមុនី)*

២. មើលមានប្រាសាទ ប្រាំស្អាងប្រាង្គស្អាត ប្រសើរឆើតឆាយ
កម្ពស់កំពូល ត្រសូលត្រសាយ ត្រសែងពណ្ណរាយ
ពព្រាតគួរស្ញែង ។
គាងឃ្វាយកាងសម មុខព្រហ្មសុទ្ធព្រហ្ម ត្រីសូល៍ឯកឯង
គ្រុឌឆក់នាគជុំ គ្រប់មុំត្រលែង កែងតខ្វាត់ខ្វែង
ដងក្ដារជបគូ ។
សឹងមានពិចិត្រ មណីរតន៍ដាំជិត មុខដាច់រចនា
ប្រក់ប្រាក់ប្រុះព្រាត ស្អាងស្អាតថ្លៃថ្លា ដូចស្ថានសួគ៌ា
ទិព្វទេពនិម្មិត ។

*(កាកី ទំព័រទី ៣ អ្នកនិពន្ធ ហាវិរក្សរាមា អង្គ ឌួង)*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh



# ច្បាប់កូនចៅ



## ក. សិក្សាពាក្យគន្លឹះ

- វង្សា : ពូជ ត្រកូល ។
- ទូន្មាន : អប់រំ ប្រៀនប្រដៅ ។
- ប៉ោវៀ្ឡ : ដែលព្រហើន ចចេ្ឡាងខាម ។
- ខ្លោះ : កំលោះ ។
- សត្យ : សេចក្តីពិត ដំណើរទៀង ទៀងទាត់ ។
- និន្ទា : ការរិះគន់ ដំណើរតិះដៀល ចចណែន ... ។
- មធូរ : ផ្អែម ពីរោះ ឆ្ងាញ់ ។
- ពុំជូកាល : ដែលខុសកាល ដែលកើតមាននៅក្នុងកាលដ៏ប្លែកខុសធម្មតា ។
- វុឌ្ឍី : សេចក្តីចម្រើន ការលូតលាស់ ដុះដាល បរិបូរណ៍ ការកើតកាលវាលគុម្ព ។
- សម្មាយ : សាមញ្ញ ដែលជាធម្មតា ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទអ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងចំណាប់ចួន ផ្ទួន រណ្តំ រង្វាស់កាព្យ និងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ

ហៃអស់កូនចៅ តំណក្រោយទៅ ត្រកូលវង្សា
ចូរចេះរាប់រក ស្រករគ្នីគ្នា ខុសគាប់កាចជា
អត់ឱនត្រងរង ។

ឱកូនចៅអើយ អាពុកចាស់ហើយ ពុំបាននៅផង
នរណានឹងនៅ ប្រដៅបាហោង នរណានឹងស្នង
អាពុកនេះបាន ។

តែខ្លួនទៅបាត់ ទុកពាក្យមួយម៉ាត់ ប្រដៅទូន្មាន
ពាក្យនេះអាពុក សង់ទុកជាស្ពាន ឱ្យកូនចៅបាន
ឆ្លងទៅត្រើយនាយ ។

ពាក្យមួយនេះមិញ ហេតុមិនស្រឡាញ់ មានពាក្យថាឆ្ងាយ
ទោះទូកបែកបាក់ សំពៅធ្លុះធ្លាយ ទាល់លង្កានាយ
សឹងមករកបាន ។

កូនចៅអើយគិត ផ្គត់ផ្គង់គំនិត រក្សាខ្លួនប្រាណ
កុំអាងសក្តិបុណ្យ លោភលន់ចង់បាន បំពារបំពាន
ពុំធ្វើដោយធម៌ ។

ធម្មតាជាមនុស្ស ឱ្យដឹងគាប់ខុស បុណ្យបាបឱ្យស្គាល់
ថ្វីមិនចង់បាន ចង់គ្មានអង្កាល់ ឱ្យបានដោយធម៌
នោះទើបយឺនយូរ ។

បើបានីងខំ លោកាវាយដំ សន្សំចាក់ចូល
ចំណេះទ្រព្យនោះ នៅពុំបរិបូរណ៍ ស្មើរកប្រមូល
ទុកឱ្យគេទេ ។

youtube.com/moeys
www.moeys.gov.kh
facebook.com/moeys.gov.kh

កូនចៅអើយអត់ គិតក្ដីកម្សត់ កុំធ្វើប៉ោឡែ
កុំអាងមានទ្រព្យ កុំត្រាប់ពុតគេ ចូរចេះរិះរេ
សាយសព្វសារពើ ។

ធម្មតាជាស្រី កុំចង់មេត្រី សាយសព្វអន្លើ
យកម្ដេចខ័ណ្ឌស្ករ មកគរទុកលើ ស្រមោចហើយតើ
អត់ម្ដេចមិនស៊ី ។

មួយដូចប្រុសខ្លោះ ពាលពេញកំលោះ ចិត្តចោរចង់ស្រី
កលមួយដូចក្អែក ចេញលួចរកស៊ី មិនដឹងឬអ្វី
យកពងមាន់ផ្ញើ ។

កលមួយសោតណា នេះនឹងឧបមា អណ្ដើកឯងតើ
ពងលាក់ជាហើយ ម្ដេចឡើយទៅផ្ញើ អស់ពាក្យពេចន៍លើ
អាអួតមហាចោរ ។

ប្រើប្រុងប្រយ័ត្ន ពាក្យពេចន៍សួរសត្យ សារស័ព្ទពំនោល
ពីរោះមធូរ បរិបូរណ៍ពាក្យពោល កុំអាលខឹងឃោរ
ចាចែងភាសា ។

កុំអាលកន្ទ្រើង កុំស្កិតខិតឡើង លើលោកព្រឹទ្ធា
គិតការជំនៀល លោកដៀលនិន្ទា អង្គឱ្យកើតជា
និន្ទាអាស្រូវ ។

ទោះប្រុសទោះស្រី កើតនាលោកិយ លោកឱ្យគាប់គ្រូ
ក្រែងមានផ្អេះផ្អាប ស្រឡាបត្រង់ត្រូវ ក្រែងជួពុំជូ
កាលកម្មវេរា ។

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា
ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា
ឆ្កួតក្រៃកន្លង ។

ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងផ្គង
លោកពុំឱ្យសេព ឱ្យវាងជាម្ដង វាតែងឱ្យហ្មង
ភ្លេចភ្លាំងស្មារតី ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

ឱ្យភ្លេចក្តីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្ត្រសួស្តី
ភ្លេចសីលភ្លេចទាន ភ្លេចញាណវុឌ្ឍិ ភ្លេចច្បាប់ប្រក្រតី
ឆ្កួតបីប្រការ ។ [...]

ក្តីច្បាប់នេះក្រ នរណាអាចយក៏ ទុកខ្លួនសម្មាយ
ដ៏លោកនេះគាប់ នៅបានពណ្ណរាយ ដល់បរលោកនាយ
សោយសុខស្រេចស្រាប់ ។

ឪពុកចាស់ហើយ អស់កូនចៅអើយ នាំគ្នាស្តែងស្តាប់
ពាក្យពិតទូន្មាន ប្រធានគ្រាន់គ្រប់ ស្មើទ្រព្យសម្រាប់
ទុកឱ្យគ្រប់គ្នា ។

ចូរចាំកុំភ្លេច ទូន្មាននេះស្រេច ស្មើខ្លួនហើយណា
ចាំចងឱ្យខ្ជាប់ ជាច្បាប់អាត្មា សូរេចអក្ខរា
សុភាសិតហោង ។

*(ដកស្រង់ពីសៀវភៅច្បាប់កូនចៅ បណ្ឌិត ម៉ៃ រៀបរៀង)*

## សំណួរ

១. តើអត្ថបទកាព្យខាងលើជាបទអ្វី ?
២. តើពាក្យ "អាពុក" ក្នុងអត្ថបទនេះសំដៅលើនរណា ?
៣. ចូរបង្ហាញចំណាប់ចួន ផ្ទួន រណ្តំ និងរង្វាស់កាព្យរបស់អត្ថបទកាព្យខាងលើនេះ ។
៤. វគ្គទីមួយរបស់កំណាព្យនេះអ្នកនិពន្ធចង់អប់រំដូចម្តេចខ្លះ ?
៥. តើអត្ថបទនេះអប់រំដូចម្តេចខ្លះ ដើម្បីឱ្យក្លាយជាពលរដ្ឋល្អ ?
៦. តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឱ្យក្លាយជាពលរដ្ឋល្អ ?

youtube.com/moeys krou.moeys.gov.kh facebook.com/moeys

# ច្បាប់ក្រមង៉ុយ



ចូរអ្នកយកចិត្តទុកដាក់ស្តាប់អត្ថបទកាព្យ “ច្បាប់ក្រមង៉ុយ” ដែលគ្រូរបស់អ្នកអាន រួចឆ្លើយនឹងសំណួរខាងក្រោម ។

## សំណួរ

១. តើអត្ថបទកាព្យនេះតែងជាបទអ្វី ? នរណាជាអ្នកនិពន្ធ ?

២. ចូរប្រាប់រង្វាស់កាព្យ ឬកាព្យមាត្ររបស់អត្ថបទកាព្យនេះ ។

៣. ចូរអ្នកប្រាប់ពី រណ្តំនៅក្នុងអត្ថបទកាព្យនេះតាមដែលអ្នកស្តាប់បាន ។

៤. ចូរបង្ហាញពីតម្លៃអប់រំរបស់អត្ថបទកាព្យនេះ ។

# ការតែងកំណាព្យបទកាកគតិ

បទកាកគតិមានឈ្មោះពិតប្រាកដជាដំបូងនៅក្នុងល្បើកអង្គរវត្តរបស់អ្នកប៉ាង ។ បទនេះមានន័យថា ដំណើរក្អែក ៖

## ក. រង្វាស់កាព្យ

មួយវគ្គមាន៧ឃ្លានិងមួយឃ្លាមាន៤ព្យាង្គ ។

## ខ. ចំណាប់ចួន



- ចួនក្នុងវគ្គ : ព្យាង្គទី៤ នៃឃ្លាទី១ វគ្គ១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី២
  ព្យាង្គទី៤ នៃឃ្លាទី៣ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៥
  ព្យាង្គទី៤ នៃឃ្លាទី៤ ចួននឹងព្យាង្គទី២ នៃឃ្លាទី៥ វគ្គ១
- ចួនឆ្លងវគ្គ : ព្យាង្គទី៤ នៃឃ្លាទី៧ ក្នុងវគ្គទី១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៣ វគ្គ២ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៥ វគ្គ២ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៦ នៃវគ្គទី២ ។

## គ. ចង្វាក់

បទនេះមានចង្វាក់ស្មើមិនលើក មិនដាក់ តែរន្ថើនៗមានទំនងដូចជា ដំណើរក្អែកហើយទម្លាក់សំឡេងលើព្យាង្គទី២ រៀងរាល់ឃ្លា ។

## ឃ. បរិយាកាស

បទនេះគេប្រើសម្រាប់ពណ៌នាទីកន្លែង តួអង្គ ធម្មជាតិ ពិសេសគេយកបទនេះទៅប្រើក្នុងពិធីផ្ដើមរឿង ។ ពេលខ្លះកវីក៏បានយកបទនេះទៅប្រើក្នុងការសម្ដែងទុក្ខសោកផងដែរ ។

## លំហាត់

**ក.** ចូរអ្នកតែងកំណាព្យបទកាកគតិនេះ ចំនួន ៥វគ្គដែលរៀបរាប់ពី ៖

១. ការថែរក្សាសុខភាព

២. ការគោរពច្បាប់ចរាចរណ៍

៣. គុណវិបត្តិនៃការជក់បារី

៤. ការការពារបរិស្ថាន

៥. ការថែរក្សាសម្បត្តិវប្បធម៌ជាតិ

**ខ.** ចូរតែងកំណាព្យបទភុជង្គលីលា ព្រហ្មគីតិ និងបទពាក្យ ៧ តាមប្រធានបទខាងលើឱ្យបានចំនួន ៥វគ្គ ក្នុងមួយបទ ។

ក្នុងការតែងកំណាព្យអ្នកត្រូវធ្វើតាមការណែនាំដូចខាងក្រោម ៖

- ចំនួនវគ្គ(ល្បះ) ជាកំណាព្យបទអ្វី ?
- ចំនួនឃ្លាក្នុងវគ្គ
- ចំនួនព្យាង្គក្នុងឃ្លា
- ចួនត្រឹមត្រូវក្នុងវគ្គឬទេ ?
- ខ្លឹមសាររៀបរយឬទេ ? (ឃ្លា-វគ្គ)
- តើខ្លឹមសារទាក់ទងនឹងប្រធានបទឬទេ ?

ខាងក្រោមនេះជាឧទាហរណ៍និងគំនូសតាងចំណាប់ចួនរបស់បទមួយចំនួន ៖

## ១ . បទភុជង្គលីលា

| | | |
|---|---|---|
| ប្អូនអើយនោះហើយក្រសាំង | ក្រសារសំកាំង | សំកុលកន្ទុយ ។ |
| ប្អូនមាសវរវាសមើលគុយ | មើលតួកហើរព្រុយ | ហើរព្រាតរៀងរាយ ។ |
| ប្អូនពៅមើលទៅប្រពាយ | ពពេចប្រញ្ញាយ | ប្រញាប់ទំផ្កាស ។ |
| ប្អូនថ្លៃរំពៃមើលទាស | មើលទៀវទំជ្រាស | ជ្រៀវជ្រើមជ្រប់ជ្រង ។ |

*(ដកស្រង់ពីរឿង កាកី ទំព័រទី៣៧ហរិរក្សរាមា អង្គឌួង ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ)*



- ចួនក្នុងវគ្គ

ព្យ.៦.ឃ.១ វ.១ ══ ព្យ.៤.ឃ.២ វ.១

- ចួនឆ្លងវគ្គ

ព្យ.៤.ឃ.៣ វ.១ ══ ព្យ.៦.ឃ.១ វ.២ ══ ព្យ.៤.ឃ.២ វ.២ (ចួនឆ្លងវគ្គ) ។

## ២ . បទព្រហ្មគីតិ

ក. ក្សិណនោះឯមច្ឆា ហៅបុត្រភ្ជាមកឆាប់ៗ
កូនមកហើយទូញប្រាប់ ថាឱពៅពន្លកម្ដាយ ។
ខ្លួនម្ដាយនឹងស្លាប់ហើយ កុំកូនអើយនៅរៀងអាយ
ទៅរកស៊ីឱ្យឆ្ងាយ ពីទីនេះផុតមនុស្ស ។

*(ល្បើកជុចនិងត្រី វិសេសដួង)*



- ចួនក្នុងវគ្គ

ព្យ.៥.ឃ.១ វ.១ ══ ព្យ.៣.ឃ.២ វ.១

ព្យ.៦.ឃ.២ វ.១ ══ ព្យ.៥.ឃ.៣ វ.១

- ចួនឆ្លងវគ្គ

ព្យ.៥.ឃ.៣ វ.១ ══ ព្យ.៣.ឃ.៤ វ.១

ព្យ.៦.ឃ.៤ វ.១ ══ ព្យ.៦.ឃ.២ វ.២ ══ ព្យ.៥.ឃ.៣ វ.២

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

ខ. ព្រះអង្គឈប់សម្រាន្ត លង់លុះបានស្រាងសុរិយា
ព្រះអង្គតែងសោកា និត្យនៅលើគ្រើយថ្នាក់ថ្កល់ ។
គន់គិតរាជបុត្រ នៅកំព្រាព្រាត់ទុព៌ល
ព្រះអង្គសោកាសល់ នូវនាងរាជទេពី ។

*(ឧកញ៉ាកោសាកៅ ក្រុងសុភមិត្រ ទំព័រទី ៣៦)*

## ៣ . បទពាក្យ ៧

យាប្លងដូចបងភ្លាត់ឃ្លាតឆ្ងាយ ព្រៃព្រួយមកអាយយូរឃ្លាតឃ្លៃ
ស្រងេះស្រងូតរហូតវៃ ម្លេះសមប្អូនភ័យមមៃគិត ។
ហើយអ្នកពីរប្រាណបានដល់ព្រៃ ដល់ព្រឹករំពៃព្រួយរឹងរិត
ទុំរាប់ដើមឈើប្រើបណ្ឌិត ពេជ្រឱ្យឈោងឃិតត្បិតស្រេកឃ្លាន ។

*(ទុំទាវ ភិក្ខុសោម ទំព័រ ៣២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១៤)*



- ចួនក្នុងវគ្គ

ព្យ.៧.ឃ.១ វ.១ ═══ ព្យ.២ឬ៤.ឃ.២ វ.១

ព្យ.៧.ឃ.២ វ.១ ═══ ព្យ.៧.ឃ.៣ វ.១ ═══ ព្យ.២ឬ៤.ឃ.៤ វ.១

- ចួនឆ្លងវគ្គ

ព្យ.៧.ឃ.៤ វ.១ ═══ ព្យ.៧.ឃ.៤.វ.២

ព្យ.៧.ឃ.២ វ.២ ═══ ព្យ.៧.ឃ.៣.វ.២ ═══ ព្យ.២ឬ៤.ឃ.៤.វ.២

youtube.com/moeys edu.moeys.gov.kh facebook.com/moeys.gov.kh

# ការសូត្រកំណាព្យ

អ្នកបានសិក្សារួចហើយពីកំណាព្យបទមូលដ្ឋានជាច្រើនដូចជា បទកាកគតិ ពំនោល ភុជង្គលីលា បន្ទោលកាក ព្រហ្មគីតិ ពាក្យប្រាំពីរ ... ។ បទទាំងអស់នោះមានលក្ខណៈខុសៗគ្នាតាំងពីកាព្យមាត្រ ចំណាប់ចួន បរិយាកាស ចង្វាក់ និងរបៀបសូត្រ ។

ឥឡូវនេះ ចូរអ្នកសូត្រកំណាព្យបទកាកគតិដែលអ្នកទើបនឹងតាក់តែងរួចហើយទៅតាមបទឱ្យបានត្រឹមត្រូវ ។

បទកាកគតិមានរបៀបសូត្រច្រើនបែបដូចជា ៖ ក្អែកលោត ពណ៌នា កាកកាត់ត្រើយ ទំនួញពិលាប ក្អែកបួល ក្មេង រាស់ ផ្កាញ់មារ (សម្រាយនិងសំស្រ៊ឹត)... ។

## លំហាត់

ចូរអ្នកសូត្រកំណាព្យបទផ្សេងទៀត ដែលអ្នកចេះដោយធ្វើបទឱ្យបានត្រឹមត្រូវ ។

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

មេរៀនទី
៨

# ការសម្រេចចិត្ត



ពលរដ្ឋល្អ ត្រូវធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយគតិបណ្ឌិត។ មានន័យថា មុននឹងធ្វើការសម្រេចធ្វើអ្វីមួយយើងត្រូវគិតពិចារណា វិភាគ ពិគ្រោះយោបល់ជាមួយអ្នកដែលគួរពិគ្រោះឱ្យបានម៉ត់ចត់។ ម្យ៉ាងទៀតមុននឹងសម្រេចចិត្ត យើងក៏ត្រូវគិតទៅដល់លទ្ធផលដែរ គឺធ្វើយ៉ាងណាឱ្យការសម្រេចចិត្តរបស់យើងមានតម្លៃ មានកិត្តិយស និងមានប្រយោជន៍សម្រេចខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ក្នុងមេរៀននេះ អ្នកនឹងបានឃើញពីសេចក្ដីសម្រេចចិត្តមួយចំនួនទាក់ទងនឹងការហ៊ានលះបង់ការតស៊ូប្រឈមនឹងបញ្ហាផ្សេងៗ ដើម្បីការពារជីវិតមនុស្ស។ល។ អ្នកនឹងបានសិក្សាបន្ថែមទៀតពីៈ ខ្លឹមសារអត្ថបទ ល្បះផ្សំ ឆ្លើយតបការបញ្ចុះបញ្ចូល និងសំណេរអត្ថាធិប្បាយបញ្ចុះបញ្ចូល។

# ការសម្រេចចិត្តរបស់អាគីរ៉ា



## ក. សិក្សាពាក្យគន្លឹះ

- ចៅអធិការ : មេវត្ត ព្រះសង្ឃដែលជាអ្នកគ្រប់គ្រងវត្ត ។
- បូជាយញ្ញ : ការយកមនុស្ស ឬសត្វទៅដុតទាំងរស់ ដើម្បីបូជាថ្វាយអាទិទេពក្នុងគោលបំណងសុំ ឬសំណូមពរពីរឿងអ្វីមួយចំពោះអាទិទេព ។
- ថ្មកួតគ្នា : ការកកិតគ្នានៃថ្មពីរដុំចេញផ្កាភ្លើង ឬការយកថ្មពីរដុំទៅគោះគ្នា ដើម្បីបង្កើតផ្កាភ្លើង ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹង វិភាគតួអង្គនិងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

### ស្ថានភាពរឿង ៖

នៅក្នុងសហគមន៍មួយនៃប្រទេសជប៉ុន តាំងពីបុរាណកាលមក ប្រជាជនតែងតែត្រូវមេសហគមន៍ចាប់ស្ត្រីម្នាក់យកនៅបូជាយញ្ញថ្វាយអាទិទេពនៅឯត្រពាំងបិសាច នៅពេលណាដែលស្រុកភូមិរបស់គេគ្មានភ្លៀងធ្លាក់ ។

ង៉ាគីអិន : យើងឬ ? យើងជាពួកម៉ាកដ៏ល្អរបស់ ហាឌីវ៉ាវ៉ា ។ ហ្នឹងហើយអញនេះជាសង្ឃ ។ សង្ឃដែលមានវត្តនៅទីក្រុងក្យូតុ ។ អញមានសញ្ញាប័ត្រខាងអក្សរសាស្ត្រជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ។ ឈ្មោះយើង គឺ "យ៉ាម៉ាសាវ៉ា ង៉ាគីអិន" ។ យើងខ្មាសខ្លួនណាស់ដោយនិយាយអួតពីខ្លួនឯងបែបនេះ ។ បើរឿងព្រះពុទ្ធសាសនា គឺវត្តយើងនៅក្យូតុ ជាមាតាបិតាគេហើយ ។ នៅក្នុងចំណោមពួកឯងនេះ គឺមិនលែងមានអ្នកដែលកាន់ព្រះពុទ្ធសាសនាទេ ។ ដូច្នេះប្រហែលជាស្ដាប់គ្នាបានហើយ ។ (និយាយទៅគ្រូសាលារៀនបឋមសិក្សា) ឯងនេះជាគ្រូមែនទេ យើងជាអ្នកអប់រំដូចគ្នា មិនមែនអ្នកក្រៅទេ ស្ដាប់យើង ! (និយាយទៅតំណាងចៅអធិការ) អ្នកឯងក៏ជាញាតិសន្តាននឹងគ្រូបង្រៀនដែរ ។ (និយាយទៅមេភូមិ) ខ្ញុំសូមរំពឹងលើកិត្តិយសរបស់លោកមេភូមិហើយ ។ ... (និយាយទៅអ្នកចំបាប់) ឯងអ្នកចំបាប់ គឺសមតែជាអ្នកមានចិត្តមេត្តា ចិត្តករុណា ខ្ញុំអង្វរសូមឈប់ធ្វើបូជាយញ្ញទៅ ។ (ឮដូច្នេះ ពួកអ្នកភូមិក៏វារែកមួយភ្លែត) ពេលនោះតំណាងរាស្ត្រឈ្មោះ កូសូ ជក់បារីស៊ីហ្គារហើយដើរអ៊ឹកអ៊ាកចូលមក) ។

កូសូ : អាកំភរ ទោះជាឯងមិនភរក៏ដោយ ស្អីពូជស្ដេចស្អី ? សាស្ត្រាចារ្យស្អី ? ម៉េចមិនគិតរឿងជីវភាពប្រជាជន គិតពីជីវិតប្រជាជនផង ? គ្នាជាអ្នកទទួលខុសត្រូវអ្វីៗទាំងអស់នៅទីនេះ ! ទៅពួកឯងគ្រប់គ្នា ទោះពួកយើងសម្រាតនរណាក៏ដោយ ដកឆ្អឹងនរណាក៏ដោយ ស្រីម្នាក់ទេវ៉ឺយ ! ដើម្បីជីវិតមនុស្ស ប្រាំបីពាន់នាក់ ។ កុំមកជជែកវែកញែកស្អី ! ទៅពួកយើង ប្រុងប្រៀបពិធីបូជាយញ្ញភ្លាម ! (អ្នកចំបាប់ចេញមកមុនគេ ក្រោយមកអ្នកឯទៀតៗក៏ក្រោកស្រមក) ។

ង៉ាគីអិន : ចាប់យើងចង (គេដោះអាវធំចោល) បើយើងអង្វរហើយមិនព្រមស្ដាប់សំណូមពរយើងមិនដឹងធ្វើម៉េចទេ ចងយើងដាក់លើគោជំនួសយូរីទៅ !

អាគីរ៉ា : (ចោលកណ្ដៀវព្រួស) ទេកុំ ! ចងយើងជំនួសយូរីទៅ ។ យើងមិនរត់ទេ ដាក់យើងលើគោ ហើយដឹកទៅត្រពាំងបិសាចទៅ ។ យកយើងទៅបូជាយញ្ញទៅ ដើម្បីឱ្យភ្លៀងធ្លាក់ ! យើងនឹងទៅចរចាជាមួយស្ដេចនាគរាជឱ្យឯង ។

យូរី : ទេ បងអាគីរ៉ា ! ទុកឱ្យខ្ញុំទៅចុះ ។ សូមលោកទាំងអស់យកខ្ញុំទៅ !

អាគីរ៉ា ៖ មិនបានទេ ! ទោះជាភ្នាល់ជីវិតក៏ខ្ញុំមិនលក់ប្រពន្ធខ្ញុំដែរ ស្អីស្ដេចនាគស្អី ? ប្រាំបីពាន់នាក់ស្អី ? ខ្ញុំមិនលក់ស្នេហាខ្ញុំឱ្យអាទិទេព ឱ្យព្រះណាជាដាច់ខាត ។ ទោះប្រពន្ធខ្ញុំសុខចិត្តធ្វើពលិកម្ម ឬយល់ពីសេចក្ដីត្រូវការរបស់ពួកឯង ក៏ខ្ញុំត្រូវតែហាមឃាត់ដែរ ។

កូសូ ៖ (ដើរចូលមករបៀបដូចជាមេអំបៅហោះស្រាលៗ រេរាៗ ហើយគោះឈើច្រត់ប៉ូកៗ)កុំនិយាយឆ្កួតៗ បើឆ្កួតក៏កុំឆ្កួតដល់នេះពេក ! បើពួកអ្នកឯងចេះស្រឡាញ់ជាតិ ពីដើមគេសុខចិត្តចាក់សម្លាប់ប្រពន្ធកូន ហើយចេញទៅច្បាំងណា៎ មនុស្សប្រុសទ្រូងប្រាំហត្ថ គឺអ៊ីចឹង ! នេះគឺជាស្មារតីរបស់ស្រុកជប៉ុនយើង គឺប៊ីស៊ីដូ (ស្មារតីសាមូរ៉ៃ ពូជអ្នកចម្បាំង) ការជួយមនុស្ស ជួយភូមិ ការធ្វើពលិកម្មដើម្បីប្រទេសជាតិ គឺជាការស្រឡាញ់ជាតិមាតុភូមិ ។ គេម្នាក់ៗត្រូវតែស្រឡាញ់មាតុភូមិ ។ គ្រាន់តែដាក់ស្រីកញ្ចាស់ម្នាក់លើខ្នងគោមួយយប់ វាអាក្រក់អីដល់ថ្នាក់ហ្នុងទៅ ! អាក្មេងហៀរសំបោរ នេះបានអញចិត្តល្អទេ បើតាមធម្មតាពួកឯងត្រូវចាត់ទុកជាមនុស្សក្បត់ជាតិហើយ ! អញនេះ កូសូ ! អញនៅទីនេះ គឺដើម្បីប្រជាជនតែប៉ុណ្ណោះទេ ។ អញសុខចិត្តបូជាជីវិតគ្រប់ពេលវេលា ... ។ (អ្នកភូមិនាំគ្នាលើកដៃគំនាប់ មេភូមិអង្អែលចង្កាហើយសភាភូមិបង្ហាញនូវមោទនភាព)

អាគីរ៉ា ៖ ស្លាប់ទៅ (រើសកណ្ដៀវដែលធ្លាក់ ហើយបុកសំដៅទៅកូសូ)

កូសូ ៖ ប៉ែ (ថយដោយមិនដឹងខ្លួន)

អាគីរ៉ា ៖ ស្លាប់ទៅ ! ស្លាប់ទៅ ! ឯងត្រូវតែស្លាប់ទៅ ដើម្បីប្រជាជន ! បើឯងស្លាប់យ៉ាងអស្ចារ្យ ហើយអញស្លាប់ទើបអញសុខចិត្តឱ្យយូរីទៅឯង ។ ស្លាប់ទៅ ! ម៉េចមិនស្លាប់ ! (វេលាអាគីរ៉ាកន្ធើញមកជិត វេលានោះកូសូថយក្រោកៗ យូរីឱបដៃរបស់អាគីរ៉ា ធ្វើឱ្យអាគីរ៉ាញ័រដៃ) ម៉ុះ ! ចូលម៉ុះ ! ម៉ុះ តទល់ជាមួយអញ ! (អ្នកភូមិរត់ស្រមក ...អាគីរ៉ាទប់ទល់) កុំមកជិតយើងមាត់ពួកឯងស្អុយណាស់ ។ ពួកឯងឱ្យវាទិញក្បាលបានហើយ ។ ពួកឯងចាំទេរឿងនាងព្រិលស ? នាងព្រិលសដែលជាក្មេងស្រីបរិសុទ្ធនៅភូមិនេះ ។ ពួកឯងបានចាប់បង្ខំនាងដោយអំណាចនិងការសង្កត់សង្កិន សម្រាតនាងចងនាងលើគោ ទោះជានាងប្រកែក តវ៉ាយ៉ាងណាក៏ដោយ ។ ពួកឯងបានដេញគោដែលដឹកនាងទាំងស្រាតននលគកឱ្យរត់ឡើងទៅលើភ្នំ ឱ្យទៅមាត់ត្រពាំងបិសាច ។ តើនាងខ្មាសអៀន ក្ដៅក្រហាយសោកស្ដាយប៉ុនណា អាម៉ាស់ប៉ុនណា ពួកឯងដែលនឹកឃើញពីចិត្តនាងទេ ។ អញបានឮនាងក្រមុំយកដៃអង្អែលច្រមុះគោ យកស្មៅស្ងួតគរលើខ្នងវា ហើយយកថ្មក្បួតគ្នាបង្កាត់ភ្លើងដុតឱ្យ ហើយចង្អុលទៅភូមិ និយាយថា "គោឯងត្រូវរត់ទៅដុតរំលាយភូមិនេះឱ្យអស់ ដើម្បីសងជីវិតដែលមានតម្លៃស្មើគ្នានោះមកវិញ" ។ អស្ចារ្យណាស់សូម្បីតែគោក៏វាក្ដៅក្រហាយដែរ គ្រាន់តែនាងក្រមុំលើកដៃចង្អុលទៅភូមិមិនទាំងបានស្រួលបួលផង វាបានរត់ស្ទុះដូចរន្ទះសំដៅទៅភូមិ ហើយដុតភូមិនៅជើងភ្នំ

ទាំងមូលឡើងឆេះក្រហមរងាលហុយធូលីក្រហមឆ្អៅ។ នាងព្រិលសលបញ្ញឹម ហើយក៏លោតទឹកត្រពាំងបិសាច សម្លាប់ខ្លួនបាត់ទៅ។ តើពួកឯងដឹងរឿងនេះទេ ? ឬក៏ភ្លេចហើយ ? ពួកអាចោលម្សៀត ធ្វើដាក់ពួកអញលមើល ភ្លៀងក៏មិនធ្លាក់ ហើយស៊ីកាមីនេះនឹងត្រូវឆេះហ្មត់។ អាពួកមុខក្រាស់គ្មានខ្មាសអៀន។

កូសូ : កុំនិយាយប៉ប៉ាច់ប៉ប៉ោចរឿងឆ្កួតៗ នោះអាក្មេងឆ្កួត ! ភូមិបានដុតឆេះឆាបឆួល ដោយការហួតហែងបាត់ទៅហើយ ហេតុនេះហើយបានជាយើងធ្វើពិធីបន់ស្រន់សុំទឹកភ្លៀង ភ្លើទេហ្អែ! ទៅពួកយើង ! នៅយឺតណាស់លឿនឡើងឱ្យស្វាហាប់ឡើង ! លេងវាទៅ (មើលឃើញអ្នកភូមិ រេរាអត់ព្រមចូលសោះ) ទៅកុំរេរា ! អាដេង គីជី ក៏ចូលទៅ (ស្រែក) ដេងគីជី បញ្ចាំងដាវវែងផ្លេកៗមកគ្រវីដាវចេញមក។ [...]

*(ដកស្រង់ពីល្ខោនរបស់ជប៉ុនរឿង ត្រពាំងបិសាច បកប្រែដោយ ប៉ែន សេដ្ឋារិន បោះពុម្ពឆ្នាំ២០០២)*

## សំណួរ

១. តើអត្ថបទខាងលើនេះចាត់ទុកជាអត្ថបទល្ខោនបានដែរឬទេ ? ព្រោះអ្វី ?

២. ចូរវិភាគតួអង្គកូសូ ព្រមទាំងបង្ហាញអំណះអំណាងតាមរយៈអត្ថបទ។

៣. តើអត្ថបទខាងលើនេះផ្ដល់តម្លៃអប់រំយ៉ាងដូចម្ដេចខ្លះ ?

៤. តើការសម្រេចចិត្តរបស់អាគីរ៉ា មិនឱ្យគេយកប្រពន្ធ (នាងយូរី) ទៅបូជាយញ្ញនេះត្រឹមត្រូវដែរឬទេ ? ព្រោះអ្វី ?

៥. តើអត្ថបទនេះ បានបង្ហាញពីជំនឿនិងផ្នត់គំនិតរបស់ប្រជាជនជប៉ុនសម័យបុរាណយ៉ាងដូចម្ដេចខ្លះ ?

៦. តើការយកជីវិតមនុស្សម្នាក់ទៅបូជាយញ្ញបែបនេះចាត់ទុកជាអំពើរំលោភសិទ្ធិមនុស្សដែរឬទេ ? ព្រោះអ្វី ? ចូរបង្ហាញអំណះអំណាងតាមរយៈអត្ថបទ។

# ល្បះផ្សំ

អ្នកបានសិក្សារួចហើយពីល្បះទោល ។ ល្បះទោលមានទម្រង់ ៖

- ល → កន + កកិ
- ល → កន១ + កកិ + កន២
- ល → កន១ + កិ + កមធ
- ល → កន១ + កិ + កន២ + កមធ
- ល → កន១ + កិ(ជា) + កន២
- ល → កន១ + 0 + កន២

ដូចម្ដេចដែលហៅថា ល្បះផ្សំ ? តើល្បះផ្សំមានទម្រង់ដូចម្ដេចខ្លះ ?

ចូរពិនិត្យឧទាហរណ៍ ៖

១. ដារិនដឹងថា ជីតាគេឈប់ជក់បារីហើយ ។

២. យើងជួយឧបត្ថម្ភ កងទ័ពដែលការពារទឹកដីយើង ។

៣. ពុកខ្ញុំ ខំធ្វើការងារ ដើម្បីគ្រួសារនិងប្រទេសជាតិ ។

## គំនូសតាងល្បះ







youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

**៣.**




ឧទាហរណ៍ទាំងបីខាងលើបញ្ជាក់ថាក្នុងល្បះផ្សំមាន ៖

- ឃ្លា (ឃ) រណប កន្សោមនាម (កន) ឬឃ្លានាម
- ឃ្លារណបបែបកន្សោមគុណនាម ឬឃ្លាគុណនាម
- ឃ្លារណបបែបកន្សោមមានធ្នាក់ (កមធ) ទេសកាល ឬឃ្លាទេសកាល ។

*ល្បះផ្សំ គឺជាល្បះកើតឡើងពីការពង្រីកនៃល្បះទោល ដែលមានធាតុសំណង់ណាមួយនៃល្បះជាឃ្លាឬជាល្បះសម្រាប់ពង្រីកល្បះដើម ។*

*ឃ្លារណបអាចជា ឃ្លានាម ឃ្លាគុណនាម ឃ្លាទេសកាល ... ។*

## លំហាត់

ចូរតែងល្បះខាងក្រោមជាមែកធាងនិងប្រអប់ ៖

១. បុប្ផាសង្ឃឹមថា គេនឹងប្រលងជាប់នៅឆ្នាំនេះ ។

២. យើងត្រូវថែរក្សាប្រពៃណី ដែលជាកេរដំណែលរបស់ដូនតា ។

៣. យុទ្ធជនខិតខំការពារបូរណភាពទឹកដី ដើម្បីប្រជាជនរស់នៅសុខសាន្ត ។

youtube.com/moeys kou.moeys.gov.kh facebook.com/moeys.gov.kh

# ពិធីរៀបការរបស់ជនជាតិឥណ្ឌាបុរាណ



## ក. សិក្សាពាក្យគន្លឹះ

- វេទ : ជាគម្ពីររបស់ព្រាហ្មណ៍សម្រាប់សូត្រ ស្តុតិចំពោះទេវៈ។ គម្ពីរវេទមាន ឫគវេទ សាមវេទ យជុរវេទ អថរវេទ។ ពាក្យ វេទ មានន័យថាការចេះដឹង ។
- ឫក្សវេលា : វេលាមានជោគ មានមង្គល មានសួស្តី ដែលកំណត់តាមហោរាសាស្ត្រ ។
- មនុ : ឈ្មោះរបស់បុរសដែលជាបិតាដើមរបស់ពួកមនុស្សក្នុងបឋមកប្ប ឬជាព្រះនាមរបស់ព្រហ្មជាអ្នកបង្កើតសត្វលោក ។
- ព្រះអគ្គិ : ព្រះអគ្គី ភ្លើង ។
- ព្រះគណេស : ឈ្មោះទេពតាខាងឧបសគ្គ ក្នុងសាសនាព្រាហ្មណ៍ ។

## ខ. អភិវឌ្ឍន៍បំណិន

ពេលអ្នកអានអត្ថបទ អ្នកគប្បីកត់ចំណាំសេចក្តីលម្អិតសំខាន់ៗនៃអត្ថបទ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទ ទំនាក់ទំនងរវាងប្រពៃណីមួយចំនួនរបស់ឥណ្ឌានិងខ្មែរយើង ដែលមានតាំងពីបុរាណមកដល់បច្ចុប្បន្ន ។

facebook.com/moeys krou.moeys.gov.kh

## គ. អត្ថបទ

ពិធីមង្គលការ ហៅថា "វិវាហៈ"។ ពិធីនេះសំខាន់បំផុតជាងពិធីឯទៀតទាំងអស់។ គេត្រូវធ្វើក្នុងពេលដែលធីតាចូលក្នុងតរុណវ័យដល់ធីតាមានរដូវហើយ មាតាបិតាត្រូវប្រាប់ដល់សង្គមទាំងមូលថា ធីតាខ្លួនល្មមរៀបចំការបានហើយ តែគេទុកស្ត្រីភាពក្នុងពេលមានរដូវនេះថាជាស្ត្រីមិនបរិសុទ្ធ។ ស្ត្រីព្រាហ្មណ៍ក្នុងពេលដែលខ្លួនមិនទាន់បានធ្វើឱ្យបរិសុទ្ធ មិនត្រូវឱ្យនៅលាយឡំក្នុងសង្គមបរិសុទ្ធទេ មិនត្រូវឱ្យចូលទៅក្នុងផ្ទះបាយចំអិនអាហារ ឬពាល់មនុស្សបរិសុទ្ធទេ ត្រូវឱ្យនៅតែម្នាក់ឯងដោយឡែកហូបចុកតែម្នាក់ឯង។ ការធ្វើវិវាហមង្គលជាភារៈមាតាបិតា សាមីខ្លួនទាំងពីរមិនត្រូវឱ្យជួបគ្នាទេ វៀរលែងតែជួបដោយមិនដឹងខ្លួន ព្រោះគេទុកថាជាការមិនបរិសុទ្ធ។ សព្វថ្ងៃនេះ វិវាហៈ ជាពិធីដែលជនជាតិហិណ្ឌូនិយមទូទៅ គេរៀបចំធ្វើធំណាស់ ធំក្រៃលែងធំ មិនមានពិធីណាប្រសើរជាងទេ មានក្បួនហែសម្បើមអស្ចារ្យ។

តាមគម្ពីរមនុ ស្ត្រីដែលល្មមរៀបមង្គលការបាន គឺស្ត្រីមិនវិកលរាងកាយ មានឈ្មោះគួរសេពគប់ មានដំណើរល្អាយល្អងដូចដំរី រោមខ្លួន ឬសក់ឱ្យមានចំនួនតិច ធ្មេញល្អិតរឹមបបូរមាត់ល្អ។ ស្ត្រីក្រមុំមានសក់ក្រហមព្រឿងៗ មានអវយវៈ មិនសមរម្យ ឧស្សាហ៍ឈឺច្រើន និយាយច្រើន ឬភ្នែកក្រហម ពុំនោះឥតមានរោម ឬក៏មានរោមច្រើនពេក ទាំងអស់នេះត្រូវវៀរបង់។ រដូវរៀបមង្គលការបាន គឺខែមាឃ ផល្គុន វិសាខ ត្រូវឱ្យហោរគន់គូរមើលឫក្សពេលាដូចខ្មែរយើងដែរ។ មានពិធីមង្គលការផ្សេងៗគ្នានៅតាមជនបទ តែគោលសំខាន់នោះដូចគ្នា គឺត្រូវយកព្រះអគ្និជាសាក្សី ព្រោះអគ្និជាទេពតាសក្តិសិទ្ធិពិតរបស់ជនហិណ្ឌូ ត្រូវយកព្រះអគ្និទៅដុតនៅកណ្តាលល្វែងដែលរៀបមង្គលត្រូវយកខ្លាញ់ទឹកដោះដុតជានិច្ចតទៅកុំឱ្យរលត់។ សព្វថ្ងៃនេះ គេយកចង្កៀងប្រេងទៅដុតជំនួសវិញ កូនស្រីប្រុសត្រូវអង្គុយក្បែរគ្នា ត្រូវតែងខ្លួនទាំងពីរនាក់ឱ្យបានល្អ។ កូនស្រីត្រូវយកសំពត់បាំងមុខ ហើយព្រាហ្មណ៍អ្នកធ្វើពិធីគោរពព្រះគណេសជាទេពតាខាងឧបសគ្គ ដើម្បីការពារឱ្យមានមង្គល ដោយយកសំពត់មួយទៅចងនឹងជាយសំពត់កូនស្រីប្រុសទាំងពីរ ទៅដាក់លើសំពត់ពិធីនេះ សូត្រគាថាវេទព្រាហ្មណ៍ម្នាក់ទៀតជាអ្នកជួយ យកខ្សែទៅចងកណ្តូកូនស្រីប្រុសទៀត ហើយបង្គាប់ឱ្យកូនស្រីប្រុសយកបាយ ដូងបោះទៅក្នុងជើងក្រានអគ្និ។ របៀបមង្គលការនេះរញ៉ិករញ៉ុកណាស់ មានការប្រោះព្រំទឹក បាចម្សៅក្រហម ដើរប្រាំពីរជំហានហៅថា "សប្តបទិ" គឺកូនស្រីប្រុសត្រូវដើរជុំវិញជើងក្រានអគ្និ ប្រាំពីរជុំតាមបង្គាប់ព្រាហ្មណ៍ កូនប្រុសដើរមុន កូនស្រីដើរតាមក្រោយ។ តាមគម្ពីរនិយាយថា "ជំហានទីមួយទុកជាអំណាច ជំហានទីពីរទុកជាកម្លាំង ជំហានទីបីទុកជាសេចក្តីសុខ ជំហានទីបួនទុកជាសេចក្តីចម្រើន ជំហានទីប្រាំទុកជាកូនចៅ ជំហានទីប្រាំមួយទុកជារដូវ ជំហានទីប្រាំពីរទុកជា

មិត្រសម្លាញ់" ឯកូនប្រុសត្រូវពោលទៅកាន់ស្រីថា "សូមសម្រេចដល់ខ្ញុំ សូមឱ្យមានកូនច្រើន សូមឱ្យអាយុវែងដល់ចាស់ជរា"។

តាមគម្ពីរមនុ ការរៀបចំកូនប្រុសស្រីឱ្យជាស្វាមីភរិយានេះ ហៅថា "វិវាហៈ" ន័យដើម "ការពង្រត់យក ឬការចាប់ដោយកម្លាំង" ពោលដោយសង្ខេបមានប្រាំបីប្រការ។ វិវាហៈ ៤ ប្រការដើម សំដែងឱ្យឃើញថា ជាទំនៀមបរមបុរាណនៃវណ្ណៈអ្នកបួស ជាពិធីការដែលប្រពន្ធស្លាប់ទៅហើយបានទៅកើតឋានសួគ៌ ឯប្តីត្រូវបានទ្រព្យខាងស្ត្រីហៅថា ស្ត្រីធនៈជាមត៌កគី :

១. ព្រហ្មវិវាហៈ = ការរៀបការដោយកូនស្រីពេញចិត្តធ្វើជាភរិយា

២. ទៃវិវាហៈ = ការរៀបការដោយស្វាមីជាអ្នកបួសយជ្ញៈ ហៅថា ឫត្វិជ

៣. អាសវិវាហៈ = ការរៀបការដោយមាតាបិតានៃកូនស្រី បានទទួលគោមួយនឹមដោយសន្មត

៤. ប្រាជាបត្យវិវាហៈ = ការរៀបការដោយការស្នើមកពីខាងកូនប្រុស

៥. អាសុរវិវាហៈ = សម្រាប់វណ្ណៈ វៃស្យៈនិងសូទ្រៈ

៦. គាន្ធវ៌វិវាហៈ = ការរៀបការដោយមាតាបិតាទាំងសងខាងពេញចិត្ត

៧. រាក្សសវិវាហៈ = ការរៀបការដោយពួកអារក្ស គឺចាប់ពង្រត់ ដូចអ្នកចម្បាំងជាដើមបែបនេះនឹងហៅថា ក្សត្រវិវាហៈក៏បាន (ការរៀបការ បីប្រការ គឺទី៥ ៦ ៧ នេះទុកជាការថោកទាប)

៨. បៃគាបវិវាហៈ = ការរៀបការបែបបិសាច គឺចង់បំផ្លាញដោយស្រវឹងស្រាជាដើម បែបទី ៨ នេះ ទាបថោកបំផុត។

រៀបការប្តីប្រពន្ធ មានប្រពៃណីផ្សេងៗច្រើនណាស់ ភរិយាអាចមានប្តីច្រើនក៏បាន តាមទំនៀមបុរាណនៅប្រទេសឥណ្ឌា ហៅថា ពហុបតិភាព (Polyandrie) ដូចនាងទ្រៅបតីក្នុងរឿងមហាភារតយុទ្ធមានស្វាមីប្រាំនាក់ គឺបងប្អូនបាណ្ឌវទាំងប្រាំ។ ការនេះ មិនទំនាស់នឹងច្បាប់សាសនាព្រាហ្មណ៍ដែលហាមប្រាមការយកញាតិសន្តានសាច់ជិត ជាប្តីប្រពន្ធទេ។ ឯប្តីក៏អាចមានប្រពន្ធច្រើនបានដែរហៅថា ពហុភរិយាភាព (Polygamie)។ តែប្រទេសឥណ្ឌាជាប្រទេសក្រីក្រ ការយកប្រពន្ធច្រើនជាភារៈធ្ងន់ណាស់ ប្តីមានឋានៈក្រីក្រមិនអាចនឹងទ្រភារៈនេះបានទេ មានតែជនដែលមានឋានៈខ្ពង់ខ្ពស់ទេទើបអាចមានប្រាសាទសម្រាប់ដាក់ស្រីជាភរិយាច្រើនបាន។ ក្នុងយុគគម្ពីរវេទ ស្ត្រីភាពមានសិទ្ធិជ្រើសប្តីបាន ហៅថាស្វយម្វរៈ តែសព្វថ្ងៃ ទំនៀមនេះមិនមានទេ។ ក្នុងគម្ពីរធម៌សូត្រនៃលោកគោត្តមអនុញ្ញាតឱ្យរៀបចំការជាមួយស្ត្រី ដែលមិនទាន់គ្រប់ការបាន គឺរៀបការតាំងតែពីកូនប្រុសស្រីនៅកុមារភាព ស្ត្រីអាយុ ១១ឬ១២ឆ្នាំ ហើយឱ្យទៅផ្ទះខាងប្តី។ ហេតុដូច្នេះហើយបានជា មានស្ត្រីមេម៉ាយច្រើនឋិតនៅក្នុងវ័យក្មេង។ ស្ត្រីមេម៉ាយដែលមិនមានកូន រៀបការម្តងទៀតបាន តែមតិមហាជន

ចូលចិត្តយកស្ត្រី ដែលតាំងចិត្តនៅជាមេម៉ាយរហូតមកធ្វើជាប្រពន្ធ បើទុកជាប្តីស្លាប់ចោល ៣ឬ៤ឆ្នាំ ដោយរោគអុតឬរោគរបេងក៏ដោយ ។ មួយទៀតមតិមហាជន តែងដឹកនាំឱ្យស្ត្រីលោតនៅក្នុងជើងថ្ករស្លាប់ជាមួយប្តី ។ ក្នុងគម្ពីរ អថិវេទ (អថវិវេទ) មានកត់ត្រាទុកនូវទំនៀមចូលស្លាប់ជាមួយប្តីនេះ តែតាមមតិរបស់យើងគ្រប់គ្នាឃើញថា ទំនៀមនេះមិនប្រពៃសោះសម្រាប់មនុស្សទូទៅ ព្រោះជំនឿថា លោតស្លាប់ទៅជាមួយប្តី ហើយបានទៅកើតក្នុងឋានសួគ៌ មិនមែនជាសច្ចធម៌ទេ ។ មួយវិញទៀតស្ត្រីដែលប្តីស្លាប់ចោលទៅហើយ មិនមានករណីយកិច្ចនឹងត្រូវធ្វើអ្វីតាមលទ្ធិសាសនាឡើយ បើថាស្លាប់ត្រូវស្លាប់ទៅជាមួយប្តី ទើបបានទៅកើតនៅក្នុងឋានសួគ៌ ។ ក្នុងគម្ពីរមនុនិយាយថា ស្ត្រីទាំងអស់មិនមាន សិទ្ធិតាមទំនើងខ្លួនឯងទេ" ។ តាមច្បាប់ ប្រុសមិនត្រូវយកភរិយាដែលជាញាតិសោះ ខ្មែរយើងក៏កាន់តាមទំនៀមនេះដែរ បើទុកជាត្រូវរៀបការជាមួយវណ្ណៈខ្លួន ក៏ត្រូវហាមឃាត់ការរៀបការជាមួយស្ត្រីសបិណ្ឌ គឺស្ត្រីដែលមានបិតា ឬបងប្រុសគោរពបុព្វបុរសដូចប្តីក្នុងអនាគត ។

*(ដកស្រង់ពីវប្បធម៌ អរិយធម៌ខ្មែរឥណ្ឌា ប៉ាង ខាត់ ១៩៧០)*

## សំណួរ

១. តាមគម្ពីរមនុ តើស្ត្រីពេញវ័យមានលក្ខណសម្បត្តិបែបណាទើបអាចរៀបការបាន ?

២. ដូចម្តេចហៅថា "សប្តបទិ" ? ហើយវាមានន័យដូចម្តេចខ្លះ ?

៣. ចូរបង្ហាញអត្ថន័យ "វិវាហៈ" តាមគម្ពីរមនុ ។

៤. តាមទម្លាប់អាពាហ៍ពិពាហ៍របស់ជនហិណ្ឌូ គេយកអ្វីជាសាក្សី ? ព្រោះអ្វី ?

៥. ដូចម្តេចហៅថា "ពហុបតិភាព" ?

៦. តាមរយៈអត្ថបទនេះ តើទំនៀមទម្លាប់ណាមួយដែលខ្មែរយើងប្រកាន់យកដូចឥណ្ឌាដែរ ?

# ការឆ្លើយតបនឹងការបញ្ចុះបញ្ចូល

ការបញ្ចុះបញ្ចូល គឺជាការអូសទាញ ការហៅអន្ទង ការទាក់ទាញទឹកចិត្ត ... ដោយមធ្យោបាយផ្សេងៗ ដើម្បីឱ្យអ្នកដទៃទទួលយកឬសម្រេចបំណងណាមួយ ។ អ្នកបញ្ចុះបញ្ចូល គេមានវិធីច្រើនយ៉ាងណាស់ក្នុងការអូសទាញអ្នកដទៃដូចជា ការលួងលោម អួតសរសើរ លើកទឹកចិត្ត បញ្ឆោររហូតដល់ការទិញទឹកចិត្តថែមទៀត ។ ការបញ្ចុះបញ្ចូលមានដូចជា ការអូសទាញយើងទៅរកផ្លូវល្អមានកិត្តិយសនិងមានប្រយោជន៍ ។ ការអូសទាញមួយទៀត គឺនាំយើងឱ្យទៅរកផ្លូវអាក្រក់គ្មានប្រយោជន៍និងមានគ្រោះថ្នាក់ ។ ការអូសទាញខ្លះទៀតធ្វើឱ្យយើងប្រឈមមុខនឹងភាពប្រថុយប្រថានឬផ្សងព្រេង នេះក៏ជាប្រការមួយនាំយើងទៅរកគ្រោះថ្នាក់ដែរ ។

ដូចនេះដើម្បីចៀសវាងការចាញ់បោកគេ ឬគ្រោះថ្នាក់ដោយប្រការផ្សេងៗនោះយើងត្រូវ ៖

- ពិចារណារកហេតុផលឱ្យបានច្បាស់លាស់ជាមុន
- វិភាគទៅលើផ្លូវច្បាប់
- ស្វែងយល់ ពិចារណាទៅលើបំណងរបស់ការបញ្ចុះបញ្ចូលនោះ
- វិភាគទៅលើភាពពិត ប្រាកដប្រជា និងភាពជឿទុកចិត្តបាន
- ស្វែងយល់ពីស្ថានភាពសង្គមនិងមនុស្សភាគច្រើនដែលនៅជុំវិញ
- ពិគ្រោះយោបល់ជាមួយអ្នកដែលគួរពិគ្រោះ
- ឆ្លើយតបនិងរកដំណោះស្រាយសមស្របទៅតាមស្ថានភាពជាក់ស្តែង ... ។

ខាងក្រោមនេះ ជាបំណិនខ្លះៗដើម្បីឆ្លើយតបនឹងការបញ្ចុះបញ្ចូល ដែលប្រឈមនឹងភាពប្រថុយប្រថាននិងគ្រោះថ្នាក់ ។

១. ឆ្លើយតបដើម្បីពន្យាពេល ៖

- ខ្ញុំមិនទាន់ប្រាកដក្នុងចិត្ត ...
- ខ្ញុំសុំគិតមើលសិន ...
- ខ្ញុំនឹងផ្តល់ដំណឹងពេលក្រោយ ...
- ខ្ញុំសុំពេលសួរយោបល់ ... សិន
- ចាំពេលក្រោយចុះ ... ។

២. ឆ្លើយតបដោយការបដិសេធ ៖

- ខ្ញុំមិនហ៊ានទេ ...
- ខ្ញុំខ្លាចមានគ្រោះថ្នាក់ ...

- សុំទោសខ្ញុំមិនអាច ...
- ធ្វើដូចនេះខុសច្បាប់ ...
- ខ្ញុំមិនជឿទេលើ ...
- ខ្ញុំមិនប្រថុយទេ ...
- ធ្វើដូចនេះ ខ្ញុំខ្លាចចាញ់បោកគេ ... ។

៣. ឆ្លើយតបដោយការអូសទាញនិងបញ្ជាក់ហេតុផលទៅគេវិញ ៖

- ធ្វើដូចនេះនាំឱ្យមានគ្រោះថ្នាក់ណាស់ ...
- មិត្តដឹងទេធ្វើនេះនាំឱ្យយើង ...
- ច្បាប់មិនអនុញ្ញាតឱ្យយើងធ្វើដូចនេះទេ ព្រោះ ...
- ឈប់សិន ... ! កុំទាន់ជឿគេព្រោះខ្លាច ...
- ធ្វើដូចនេះនាំឱ្យបាត់បង់ ...
- យើងគួរ ... ទើបត្រឹមត្រូវ ...
- ពិចារណាឱ្យល្អិតល្អន់សិនសឹម ...
- កុំប៉ះពាល់ ... កុំសាកឱ្យសោះ ...
- ខ្វះអ្វី ... គួរតែយើង ...
- ស្រុកយើងសម្បូរណាស់ ... ហេតុអ្វីចាំបាច់ទៅ ... ។

## លំហាត់

ចូរអ្នកឆ្លើយតបទៅនឹងការបញ្ចុះបញ្ចូលរបស់អ្នកដទៃក្នុងបំណងឱ្យអ្នក ៖

១. ឈប់រៀនដើម្បីទៅដើររកការងារធ្វើ ។

២. ជក់បារី ។

៣. គេចវេះពីការសិក្សាដើម្បីទៅដើរលេង ។

៤. ប្រើប្រាស់គ្រឿងញៀន ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ការបញ្ចុះបញ្ចូល

ការបញ្ចុះបញ្ចូល គឺជាការអូសទាញ អន្ទង លួងលោម ទាក់ទាញ ឃោសនា ដោយមធ្យោបាយផ្សេងៗ ដើម្បីសម្រេចគោលបំណងណាមួយ ។ ការបញ្ចុះបញ្ចូល មានគោលបំណងផ្សេងៗគ្នា ។ ការបញ្ចុះបញ្ចូលខ្លះមានបំណងអូសទាញយើងឱ្យដើរផ្លូវល្អ គ្មានគ្រោះថ្នាក់ មានប្រយោជន៍ ប្រព្រឹត្តអំពើល្អត្រឹមត្រូវ រីឯការបញ្ចុះបញ្ចូលខ្លះ មានបំណងអូសទាញយើងដើរផ្លូវអាក្រក់ មានគ្រោះថ្នាក់ គ្មានប្រយោជន៍ ឬប្រព្រឹត្តអំពើអបាយមុខខុសច្បាប់ជាដើម ។ ដូចនេះមុននឹងជឿតាមការបញ្ចុះបញ្ចូលណាមួយ យើងគួរពិចារណាឱ្យបានច្បាស់លាស់ល្អិតល្អន់ជាមុន ចៀសវាងគ្រោះថ្នាក់ដោយប្រការផ្សេងៗ ។ ប៉ុន្តែប្រសិនបើយើងជាឃោសនិក(អ្នកបញ្ចុះបញ្ចូល) គឺយើងគប្បីគិតដល់មធ្យោបាយ និងសំនួនវោហារ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សទូទៅ ។

ខាងក្រោមនេះ ជាសំណេរបញ្ចុះបញ្ចូលមួយដើម្បីបំភ្លឺការយល់ច្រឡំរបស់ប្រជាជនមួយចំនួនចំពោះភ្លេងពិណពាទ្យខ្មែរ ។

ប្រជាជនខ្មែរយើងមួយចំនួនតែងហៅភ្លេងពិណពាទ្យដោយភ័ន្តច្រឡំថា "ភ្លេងសៀម" ។ ការហៅដោយការភ័ន្តច្រឡំបែបនេះ នាំឱ្យមានការខាតបង់យ៉ាងខ្លាំងចំពោះខ្មែរ ។ តាមពិតភ្លេងនេះជារបស់ខ្មែរតាំងពីបុរាណកាលមកម្ល៉េះ ។

លោកឧកញ៉ា ឈឹម ក្រសេម បានសរសេរទុកថា គ្រឿងតូរ្យតន្ត្រីរបស់ខ្មែរយើងដែលលេងសព្វថ្ងៃនេះ បានបែកមកអំពីប្រទេសឥណ្ឌាតាំងពីសម័យព្រេងនាយ លុះដល់មកសម័យក្រោយ វិជ្ជាតូរ្យតន្ត្រីរបស់ខ្មែរបានផ្សាយចេញទៅប្រទេសសៀមក្នុងសម័យក្រុងស្រីអយុធ្យា គឺក្នុងរវាង (ព.ស ១៨៩៣-២៣១០) ។ លោកបានសរសេរថែមទៀតថា ការពោលបែបនេះ សូម្បីតែសៀមខ្លួនឯងក៏ទទួលសារភាពដូច្នេះដែរ ។ លោកបានសរសេរតទៅទៀត ៖ " ក្នុងតម្រានាដសាស្ត្ររបស់ឥណ្ឌាមួយនិយាយថា ភ្លេងពិណពាទ្យក្នុងសម័យដើមមានត្រឹមតែបួនគ្រឿងទេ គឺខ្លុយ ពិណ សម្ភោរ និងឈិង " ។

ចំនួនគ្រឿងប៉ុណ្ណោះ សមតាមពាក្យក្នុងតម្រានាដសាស្ត្រថា សម័យមួយព្រះឥសូរទ្រង់គង់កណ្តាលទេវសភា ដែលឋិតនៅលើកំពូលភ្នំកៃលាស មានបំណងនឹងសម្តែងពិធីរាំឱ្យមើលទុកជាបែបច្បាប់សម្រាប់លោក ទើបស្តេចត្រាស់បង្គាប់ឱ្យព្រះនាងឧមាទេវី គង់លើសុវណ្ណបល្ល័ង្ក ឱ្យនាងសរស្វតីជាទេពី ព្រះព្រហ្មដេញពិណ ឱ្យព្រះឥន្ទផ្លុំខ្លុយ ឱ្យព្រះព្រហ្មគោះឈិង ឱ្យព្រះនាងលក្ស្មីជាទេពីព្រះនារាយណ៍ច្រៀង ឱ្យព្រះនារាយណ៍វាយថូន ឯព្រះឥសូរខ្លួនឯងទ្រង់រាំ ដើម្បីឱ្យទេវតា គន្ធព្វយក្សទាំងឡាយដែលឡើងទៅគាល់ព្រះអង្គមើលគ្រប់គ្នា ។

ក្រោយអំពីបានចម្លងបែបភ្លេងតាមរបៀបឥណ្ឌាមកជាយូរឆ្នាំ ជនជាតិខ្មែរក៏បានគិតកែប្រែផ្លាស់ប្តូរនិងថែមថយគ្រឿងភ្លេងពិណពាទ្យនោះឱ្យក្លាយទៅជាភ្លេងរបស់ខ្មែរ អាស្រ័យដោយសេចក្តីចម្រើន និងការលូតលាស់នៃបញ្ញាស្មារតីរបស់ខ្មែរក្នុងសម័យនោះ ។

សព្វថ្ងៃនេះ ភ្លេងពិណពាទ្យដែលមានប្រើក្នុងប្រទេសខ្មែរ ពិតមែនតែមានការផ្លាស់ប្តូរគ្រឿងភ្លេងជាច្រើន តែគង់នៅសល់បែបចាស់ខ្លះនៅឡើយ ហើយទោះបីមិនមានពិណក្នុងចំណោមគ្រឿងភ្លេងនោះសោះក៏ដោយ គេក៏នៅតែនិយមហៅថា ពិណពាទ្យៗដដែល ។ ភ្លេងពិណពាទ្យដែលយើងធ្លាប់ឃើញនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ មានរនាតឯកមួយ គងវង់ធំមួយ ស្គរធំពីរ សម្ភោរមួយ ស្រឡៃមួយ ។ ប៉ុន្តែខ្មែរបានរៀបចំបន្ថែមគ្រឿងភ្លេងច្រើនយ៉ាងទៀតនៅក្នុងគ្រឿងភ្លេងជាន់ដើម ហើយឱ្យឈ្មោះថា ពិណពាទ្យវង់ធំ ។ ឯវង់ភ្លេងដែលមានប្រដាប់តែប្រាំគ្រឿងនោះហៅថា ពិណពាទ្យវង់តូច ។ពិណពាទ្យវង់ធំមាន រនាតឯកមួយគ្រឿង រនាតធុងតូចមួយគ្រឿង រនាតដែកមួយគ្រឿង សម្ភោរមួយគ្រឿង ស្គរធំពីរ ស្រឡៃមួយ ឈិងមួយគូ គងវង់ធំមួយ គងវង់តូចមួយ ។

នៅក្នុងព្រះបរមរាជវាំង មានគ្រឿងភ្លេងពិណពាទ្យពិសេសមួយបែបមានគ្រឿងចម្រុះច្រើនយ៉ាង ហៅថា "ក្រុមមហោរីព្រះរាជទ្រព្យ" ប្រដាប់ក្រុមភ្លេងនេះមានដល់ទៅ ១៦គ្រឿង គឺ រនាតឯក រនាតធុង គងវង់តូច គងវង់ធំ ទ្រខ្សែបី ទ្រឆេ ឬទ្រឯកខ្សែពីរ ខ្លុយរន្ធប្រាំបី ស្គរដូចស្គរអារក្ស ចាប៉ីដងវែងខ្សែបួន ទ្រអ៊ូខ្សែពីរ តាខេឯកខ្សែបី តាខេធុង ថូន ក្រាប់ ឈិង ។

បណ្តាវង់ភ្លេងខ្មែរទាំងអស់មានតែភ្លេងពិណពាទ្យមួយទេ ដែលមានរបៀបរៀបចំគ្រឿងភ្លេងក្នុងទីដ៏សមសួន នៅពេលលេងម្តងៗ ។ ឯភ្លេងដទៃទៀត គ្រាន់តែអង្គុយឈមមុខរកគ្នា ហើយប្រគំលេងទៅពុំមានកំណត់កន្លែងឱ្យច្បាស់លាស់ឡើយ ។ ប៉ុន្តែតាមស្រាវជ្រាវរបស់ក្រុមទំនៀមទម្លាប់បានឃើញរបៀបរៀបគ្រឿងភ្លេងមានប្លែកគ្នាបន្តិចៗ តាមទម្លាប់របស់គ្រូម្នាក់ៗ តែទោះបីយ៉ាងណា ក៏ស្គរធំនិងសម្ភោរត្រូវនៅមុខនៃគ្រឿងឯទៀតដរាប ។ ឯរបៀបដែលដាក់ជូនក្នុងទីនេះ គ្រាន់តែជាតួយ៉ាងមួយបែបប៉ុណ្ណោះ គឺគេដាក់តាមលំដាប់ពីមុខទៅក្រោយដូចនេះ ៖ សម្ភោរ ស្គរធំ រនាតឯក រនាតធុង រនាតដែក ឈិង ស្រឡៃ គងតូច គងធំ ។

តាមការបកស្រាយបង្ហាញខាងលើ បញ្ជាក់យ៉ាងច្បាស់ថា ភ្លេងពិណពាទ្យ គឺពិតជាភ្លេងរបស់ដូនតាខ្មែរដែលបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយពិតប្រាកដ ។ បងប្អូនដែលតែងយល់ច្រឡំត្រូវតែភ្ញាក់រលឹកឡើង ។ ពិណពាទ្យជាឈ្មោះពិតប្រាកដរបស់ភ្លេងខ្មែរមិនមែនភ្លេងសៀមឡើយ ។ រូបចម្លាក់នៅតាមជញ្ជាំងប្រាសាទអង្គរវត្តជាភស្តុតាងជាក់ស្តែង គឺភ្លេងពិណពាទ្យពិតជារបស់ខ្មែរ ។ ដូចនេះយើងជាកូនខ្មែរត្រូវរួមកម្លាំងគ្នា ថែរក្សាការពារ ឱ្យតម្លៃ និងលើកកម្ពស់កេរដំណែលវប្បធម៌ខ្មែរឱ្យបានស្ថិតស្ថេរគង់វង្សនិងល្បីល្បាញខ្ទរខ្ទារលើសកលលោក ។

## សំណួរ

១. ដូចម្ដេចហៅថាការបញ្ចុះបញ្ចូល ?

២. តើសំណេរនេះមានប្រធានបទដូចម្ដេច ?

៣. តើលោកឧកញ៉ា ឈឹម ក្រសេម បង្ហាញទស្សនៈដូចម្ដេចខ្លះចំពោះភ្លេងពិណពាទ្យ ?

៤. តាមតម្រានាដសាស្ត្រភ្លេងពិណពាទ្យមានប្រវត្តិដូចម្ដេច ?

៥. តើក្រុមភ្លេងព្រះរាជទ្រព្យមានឧបករណ៍ភ្លេងអ្វីខ្លះ ?

៦. តើចុងបញ្ចប់នៃសំណេរនេះ គេបានបញ្ជាក់ដូចម្ដេចខ្លះ ?

## លំហាត់

ចូរអ្នកសរសេរអត្ថបទបញ្ចុះបញ្ចូលតាមប្រធានបទខាងក្រោម ៖

១. បញ្ចុះបញ្ចូលមិត្តភ័ក្តិរបស់អ្នកឱ្យឈប់ជក់បារី ។

២. បញ្ចុះបញ្ចូលមិត្តភ័ក្តិដែលបោះបង់ចោលការសិក្សាត្រឡប់មកសិក្សាវិញ ។

៣. បញ្ចុះបញ្ចូលមហាជនឱ្យចូលរួមនិងលើកកម្ពស់ស្មារតីថែរក្សាកេរដំណែលវប្បធម៌ជាតិ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី ៩

# សោភ័ណសិល្បៈ



ប្រទេសកម្ពុជា ជាប្រទេសដែលធ្លាប់មានខឿនវប្បធម៌ អរិយធម៌រុងរឿង នៅជ្រោយឥណ្ឌូចិនយើងនេះ តាំងពីយូរយារណាស់មកហើយ ។ ភាពចំណាស់និងកិត្តិសព្ទដ៏ល្បីល្បាញនៃសិល្បៈខ្មែរក៏បានស្តែងចេញតាមរយៈទឹកដៃសិល្បៈរបាំ ចម្រៀង កំណាព្យ ចម្លាក់ សំណង់ស្ថាបត្យកម្មប្រាសាទនានាផងដែរ ដែលសុទ្ធតែមានតម្លៃខ្ពង់ខ្ពស់ វិសេសវិសាលថ្លៃថ្លា ជាហេតុញ៉ាំងឱ្យពិភពលោកទាំងមូលទទួលស្គាល់ និងកោតសរសើរស្ងប់ស្ងែងនូវទេពកោសល្យដ៏ប៉ិនប្រសប់របស់បុព្វបុរសខ្មែរយើងយ៉ាងក្រៃលែង ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអ្វីៗដែលទាក់ទងនឹងសោភ័ណសិល្បៈខ្មែរ ។ ទន្ទឹមនេះ អ្នកនឹងសិក្សាផងដែរអំពីខ្លឹមសារនៃអត្ថបទ អ្នកនិពន្ធនិងកាលកំណត់តែងនៃរឿង សង្គមបរិយាកាសនិងទំនាស់ក្នុងរឿង វិធីតែងនិពន្ធរឿងបែបបុរាណនិងតម្លៃអប់រំរឿង ជំនួយកិរិយា ការច្រៀងចម្រៀងប្រជាប្រិយ និងសំណេររឿងប្រឌិតដែលមានភាពសាំញ៉ាំ ។

# អំពីជំនួយកិរិយានិងប្រភេទនៃជំនួយកិរិយា

អ្នកធ្លាប់សិក្សារួចមកហើយអំពីនាម គុណនាម សព្វនាម កិរិយា និងគុណកិរិយា ។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីជំនួយកិរិយានិងប្រភេទនៃជំនួយកិរិយាថែមទៀត ។ ចំពោះល្បះខ្លះ ការប្រើកិរិយាបង្គោលតែមួយមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ យើងត្រូវប្រើជំនួយកិរិយាផងដែរ ទើបធ្វើឱ្យល្បះមានន័យសេចក្តីពេញលេញ ។

ចូរប្អូនសង្កេតឧទាហរណ៍ខាងក្រោម ៖

- ខ្ញុំចង់រៀបចំបន្ទប់ឱ្យស្អាត ។
- គាត់អាចច្រៀងបានពីរោះ ។
- សុខាដេកលក់ ។
- ពូសំស្តាប់ឮយ៉ាងច្បាស់ ។
- តារារៀនចេះគ្រប់មុខវិជ្ជា ។

តាមឧទាហរណ៍ខាងលើ យើងឃើញថា ល្បះនីមួយៗមានប្រើកិរិយាសព្ទចំនួនពីរ គឺកិរិយាបង្គោលនិងកិរិយាបំពេញ ។

កិរិយាបង្គោលមានដូចជា ពាក្យ “ចង់ អាច ដេក ស្តាប់ មើល រៀន” ។

កិរិយាបំពេញ គឺពាក្យ “រៀបចំ ច្រៀង លក់ ឮ ចេះ ឃើញ” ដែលបំពេញន័យសេចក្តីឱ្យកិរិយាបង្គោល “ចង់ អាច ដេក ស្តាប់ រៀន និងមើល” ឱ្យមានន័យសេចក្តីពេញលេញគ្រប់គ្រាន់ស្តាប់បាន ហៅថា ជំនួយកិរិយា ។

## ប្រភេទជំនួយកិរិយា

ចូរពិនិត្យឧទាហរណ៍ខាងក្រោម

- ខ្ញុំទៅបាន ។
- គាត់មើលឃើញយើង ។
- សៅដេកពុំលក់ទេ ។
- ក្នុងសម័យអង្គរ វប្បធម៌សិល្បៈខ្មែរឈានឡើងដល់កម្រិតកំពូល ។
- គាត់ដើរមកហើយ ។
- គាត់ចង់ធ្វើអ្នកចម្រៀង ។
- តាសំចូលចិត្តឆ្លាក់រូបចម្លាក់ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

តាមឧទាហរណ៍ខាងលើនេះ យើងឃើញថាល្បះនីមួយៗមានកិរិយាសព្ទចំនួនពីរ ហើយមានលក្ខណៈខុសៗគ្នា ។

- ល្បះទី ១,២,៣ : មានកិរិយា "បាន ឃើញ លក់" ជាកិរិយាបំពេញដែលប្រើសម្រាប់បង្គ្រប់ន័យសេចក្ដីកិរិយាបង្គោល "ទៅ មើល និងដេក" ។
- ល្បះទី ៤,៥ : មានកិរិយា "ឡើង មក" ជាកិរិយាទិសដៅ ដែលប្រើសម្រាប់បង្គ្រប់ន័យសេចក្ដីកិរិយាបង្គោល "ឈាន ដើរ" ។
- ល្បះទី ៦,៧ : មានកិរិយា "ចង់ ចូលចិត្ត" ជាកិរិយាខាងដើម (នៅខាងឆ្វេងកិរិយាបង្គោល) ប្រើសម្រាប់បង្គ្រប់ន័យសេចក្ដីកិរិយាបង្គោល "ធ្វើ ឆ្លាក់" ។

*ដូចនេះ* យើងឃើញថា ជំនួយកិរិយា ឬកិរិយាជំនួយមានច្រើនប្រភេទ គឺកិរិយាបំពេញ កិរិយាទិសដៅ និងកិរិយាខាងដើម ។

*ជំនួយកិរិយា ជាកិរិយាសម្រាប់ប្រើបង្គ្រប់ន័យសេចក្ដីរបស់កិរិយាសព្ទបង្គោលណាមួយក្នុងល្បះ ។*

*ជំនួយកិរិយា ជាធាតុវេយ្យាករណ៍សម្រាប់ប្រាប់លទ្ធផល ទិសដៅ កាល និងតម្លៃទិដ្ឋភាពរបស់កិរិយាសព្ទបង្គោល ។*

ជំនួយកិរិយាមានច្រើនប្រភេទ ។

- **កិរិយាបំពេញ :** ប្រើសម្រាប់បង្គ្រប់ន័យសេចក្ដីរបស់កិរិយាបង្គោលលើចំណុចពីរ គឺលទ្ធផលនៃអំពើនិងលទ្ធផលសម្រេចនៃអំពើ មានដូចជា " ឃើញ ភាន់ លក់ ឮ ចេះ បាន កើត រួច ក៏មាន ក៏បាន ... " ។
- **កិរិយាទិសដៅ :** សម្រាប់ប្រើជាមួយកិរិយាបង្គោលសម្រាប់ប្រាប់ទិសដៅនៃអំពើរបស់កិរិយាបង្គោលនោះ ។ កិរិយាទិសដៅមានដូចជា " ឡើង ចុះ នៅ មក ចេញ ចូល កាត់ តាម ជូន ឱ្យ "។ល។
- **កិរិយាខាងដើម :** នៅខាងឆ្វេងកិរិយាបង្គោល (កិរិយា ឬគុណនាមកិរិយា) សម្រាប់ប្រាប់តម្លៃនៃភាព តម្លៃទិដ្ឋភាព ឬតម្លៃកាលនៃអំពើ ។ កិរិយាខាងដើមមានដូចជា " ចង់ ចូលចិត្ត ប៉ង ប្រាថ្នា អាច បាន មាន ត្រូវ ធ្លាប់ ឧស្សាហ៍ ចេះ ក្រ ក្លាយជា នៅ "។ល។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

## លំហាត់

១. តើពាក្យណាខ្លះក្នុងល្បះខាងក្រោម ដែលជាកិរិយាបំពេញ ?

ក. ពូផាដើរខ្លួនឯងកើត ។

ខ. ខ្ញុំស្ដាប់ពូវានិយាយ ។

គ. វុទ្ធីរៀនចេះ ។

២. តើពាក្យណាខ្លះក្នុងល្បះខាងក្រោម ដែលជាកិរិយាទិសដៅ ?

ក. ខ្ញុំសុំសៀវភៅមួយមក ។

ខ. សូមក្រោកឡើង ។

គ. សុខាយកនង្គ័លចូលផ្ទះ ។

៣. តើពាក្យណាខ្លះក្នុងល្បះខាងក្រោម ដែលជាកិរិយាខាងដើម ?

ក. តើបងមានស្គាល់បុរាណវត្ថុអ្វីខ្លះ ?

ខ. គាត់ចង់ឆ្លាក់រូបអប្សរា ។

គ. ម្សិលមិញខ្ញុំបានទៅលេងអង្គរ ។

៤. ចូរតែងល្បះដោយប្រើ ៖

ក. កិរិយាបំពេញ : បាន ក៏បាន ចេះ កើត ។

ខ. កិរិយាទិសដៅ : ជូន ចេញ កាត់ តាម ។

គ. កិរិយាខាងដើម : បាន មាន ចូលចិត្ត អាច ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# រំលឹកបញ្ញត្តិ

## ១ . លក្ខណៈសម្គាល់របស់រឿងបែបព្រាហ្មណ៍និយម

អក្សរសិល្ប៍ព្រាហ្មណ៍និយម សម្គាល់អត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍។ អក្សរសិល្ប៍នេះតែងលើកយកអច្ឆរិយបុគ្គល ទេវតា អាទិទេព ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ យក្ស ដោយរួមផ្សំនឹងមន្តអាគមគាថាអួមអាម បែងភាគ កាឡាខ្លួន ចេះជប ចេះហោះហើរ ដើរលើអាកាសជាដើម។

លក្ខណៈសម្គាល់អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយមមាន ៖

### ក. ផ្ដើមរឿង

ការផ្ដើមរឿងនៃស្នាដៃអក្សរសិល្ប៍ប្រភេទនេះ គឺចាប់ផ្ដើមឡើងដោយការបង្ហាញពីឈ្មោះរបស់អាទិទេពធំៗ ទាំងបីដូចជាព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ ពិធីបូជាយញ្ញ ឬពិធីផ្សេងៗទៀត។

*ឧទាហរណ៍ :* ផ្ដើមរឿងរាមកេរ្តិ៍ ៖ ដងនោះមានអសុរសា មានឲ្យមួយនាមា ហៅកាកនាសូរស្ដែង។ ឮស័ព្ទសង្ខធុជថ្កើងថ្កែងព្រតព្រះគម្ដែង ឥសូរដ៏រាមឫទ្ធា។ អសុរនោះនិរ-មិត្ររូបាជាកាកមួយសា ហោះហើរនូវតេជបីពន្លឹក។ មកចឹកហោមសាស្ត្រាធម្មិក ឮស័ព្ទគឹក ស្លឹកស្មីភ្ញីញ័ររុះរោយ។ ស្រែកស័ព្ទកាកនោះឮឆ្ងាយ ធុជធោងព្រាត់ព្រាយ ក៏ភិតពួនពឹងនៅនិត្យ ... ។

### ខ. តួរឿង

- តួអង្គ : ជាអាទិទេព ឬអវតារនៃព្រះវិស្ណុមកយោនយកកំណើតជាមនុស្ស ជាបុរសអស្ចារ្យនិងជានារីអស្ចារ្យ ឯតួអង្គផ្សេងទៀតមានឥសី ទេវតា យក្ស គ្រុឌ ... ។ល។
- ដំណើររឿង : ច្បាំងមិនចេះចប់ប្រកបដោយសិល្ប៍សាស្ត្រអស្ចារ្យ។ ដំណើររឿងមានភាពអច្ឆរិយៈដូចជា ជប ប្រស់ ហោះហើរ ផ្លែងសរ ... ។
- ទីកន្លែង : ព្រៃហេមពាន្ត ក្រុងឰយុធ្យា ស្ថានសួគ៌ ក្រុងបាតាល ស្ថានសិម្ពលី ពោល គឺឋានទាំងបី។
- បញ្ហាដោះស្រាយ : ដោយសិល្ប៍មន្ត ឫទ្ធិអំណាច សងសឹកធ្វើចម្បាំងនឹងគ្នាដោះស្រាយដោយយុទ្ធវិធី។
- ស្នេហា : អ្នកឈ្នះ ឬអ្នកខ្លាំង គឺបានទទួលស្នេហា។
- ទំនាស់ : កើតឡើងដោយវិបត្តិទំនាស់រវាងសភាវៈល្អ និងសភាវៈអាក្រក់ ច្បាំងទាស់ទែងគ្នាមានទារុណកម្មខាងផ្លូវចិត្តឬផ្លូវកាយ។
- ឧត្តមគតិរឿង ៖
  - អប់រំមនុស្សឱ្យជឿលើអាទិទេព

- អប់រំឱ្យមនុស្សឱ្យមានជំនឿថា ទុក្ខសោក សំណាងល្អអាក្រក់របស់ខ្លួនបានមកពីអាទិទេព ទាំងនោះធ្វើឱ្យមនុស្សខ្វះការតស៊ូ ខ្វះការជឿជាក់លើខ្លួនឯង ។

### គ. បញ្ចប់រឿង

ការបញ្ចប់រឿងបែបព្រាហ្មណ៍និយម គឺតួអង្គតំណាងអាទិទេព (សភាវៈល្អ) មានជ័យជម្នះលើសភាវៈអាក្រក់ យក្ស គ្រុឌ អសុរៈ ។ល ។

## ២ . លក្ខណៈសម្គាល់របស់រឿងបែបពុទ្ធនិយម

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមសម្គាល់អត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា គឺលើកយកសកម្មភាពពោធិសត្វក្នុងការកសាងបារមី ឬដែលបានលើកយកទស្សនៈសំខាន់ៗក្នុងពុទ្ធសាសនាមានបញ្ហាកម្មផល បុណ្យ បាប ជាដើមមកបង្ហាញ ៖

### ក. ផ្ដើមរឿង

រឿងផ្ដើមឡើងដោយធ្វើបទនមស្ការមានតំណាលថា ព្រះពុទ្ធគង់នៅក្នុងអារាមណាមួយទ្រង់សម្ដែងឡើងនូវរឿងអតីតជាតិរបស់ព្រះអង្គទៅកាន់ពុទ្ធបរិស័ទ ។ល ។

### ខ. តួរឿង ឬដំណើររឿង

- តួអង្គ : តួអង្គប្រុសជាពោធិសត្វ ឯតួអង្គស្រីជាកន្ញែសារពេជ្ញ ។ តួអង្គរងមានមនុស្ស ទេវៈ អសុរៈ ... ។
- ទីកន្លែង : ដំណើររឿងប្រព្រឹត្តទៅនៅនគរពារាណសី តក្កសិលា ព្រៃហេមពាន្ត ឋានទាំងបី ... ។
- បញ្ហាចោទ : ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស ទំនៀមទម្លាប់ កម្មពៀរ អំពើ បាប ... ។
- បញ្ហាដោះស្រាយ : ព្យាយាមតស៊ូប្រឹងប្រែងដោយយកសីលធម៌ទៅអប់រំដោយសន្តិវិធី ខន្តីសន្ដោសប្រណី មិនប្រើហិង្សា ដើម្បីដោះស្រាយបញ្ហាជានិច្ច ។
- ស្នេហា : គឺស្នេហារវាងព្រះពោធិសត្វនិងកន្ញែសារពេជ្ញជាស្នេហាបរិសុទ្ធ ។
- ឧត្ដមគតិរឿង : អប់រំមនុស្សឱ្យស្គាល់បុណ្យបាប ឱ្យធ្វើអំពើល្អខំប្រឹងតស៊ូព្យាយាមដោយជឿជាក់លើខ្លួនឯង ។

### គ. បញ្ចប់រឿង

ការបញ្ចប់រឿងដោយមានការសរជាតិរបស់តួអង្គព្រះពោធិសត្វនិងកន្ញែសារពេជ្ញ ។



# រឿងសុបិនកុមារ



## ក. សិក្សាពាក្យគន្លឹះ

- វិយវឌ្ឍនាការ (ន) : វិយចម្រើនធំធាត់ ពេញរូប ពេញរាង ។
- អនិច្ចកម្ម (ន) (បា.សំ) : សេចក្ដីស្លាប់ ។
- ឋាននរក (ន) (សំ.បា) : កន្លែងដែលមានរណ្ដៅជាលំនៅនៃសត្វមានបាបរងទុក្ខតាមកម្លាំងកម្មដែលខ្លួនធ្វើ ។
- សាមណេរ (ន) (បា.សំ) : បព្វជិត ពុទ្ធសាសនិក អ្នកកាន់សីល១០ (លោកនេន) ។
- យមបាល (ន) (សំ.បា) : អ្នករក្សាទ្វារនរក ។
- យមរាជ (ន) (សំ.បា) : ស្ដេចត្រួតត្រាឋាននរក ។
- អានិសង្ស (ន) (បា) : ផលនៃកុសល ផលនៃបុណ្យដែលបានធ្វើល្អ ។
- ចីវរ (ន) (សំ.បា) : គ្រឿងស្លៀកដណ្ដប់សម្រាប់អ្នកបួសក្នុងពុទ្ធសាសនា ។
- កុសលកម្ម (ន) (បា) : បុណ្យ ផលបុណ្យដែលបានធ្វើល្អ ។
- មរណកាល (ន) (សំ.បា) : កាលកំណត់ដែលត្រូវស្លាប់ ពេលស្លាប់ ។
- ឋានសួគ៌ (ន) (សំ) : ឋាន ឬកន្លែងពពួកទេវៈ ឬទេវតា ។
- ឋានកណ្ដាល (ន) : ឋានមនុស្សលោក ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទសង្ខេបរឿង "សុបិនកុមារ" ខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងក្នុងអត្ថបទ ដោយវិភាគឱ្យឃើញខ្លឹមសារសំខាន់នៃអត្ថបទ អ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាសនៃរឿង ទំនាស់ វិធីតែងនិពន្ធ និងតម្លៃអប់រំនៃរឿង ។

## គ. អត្ថបទ

កាលដើមឡើយមានអ្នកនេសាទប្ដីប្រពន្ធពីរនាក់ មានកូនប្រុសមួយរូបឈ្មោះ សុបិនកុមារ ។ កាលកុមារមានវ័យវឌ្ឍនាការ ឪពុកក៏បានអនិច្ចកម្មចោលទៅ ហើយត្រូវធ្លាក់ទៅរងទុក្ខទោសក្នុងឋាននរកដោយសារបាបកម្មរបស់ខ្លួនក្នុងការនេសាទ ។

ចំណេរកាលក្រោយមក ចៅសុបិនកុមារក៏សុំម្ដាយទៅបួស ។ ប៉ុន្តែ ម្ដាយពុំព្រមឱ្យទៅបួសតាមសំណូមពរឡើយ ។ ចៅសុបិនពុំអស់ចិត្ត ក៏លបលួចទៅបួសជាសាមណេរដោយខ្លួនឯងទាល់តែបានសម្រេចដូចបំណងប្រាថ្នា ។

លុះថ្ងៃក្រោយ នាងជាម្ដាយបានសម្រាន្តលក់ទៅ ក៏ត្រូវយមបាលមកចាប់អូសទាញយកព្រលឹងទៅជំនុំជម្រះ នាឋានយមរាជ ។ ដោយកំហុសរបស់នាងជាម្ដាយពុំព្រមឱ្យកូនទៅបួស ពពួកយមបាលក៏ចាប់ព្រលឹងនាងបោះចូលទៅក្នុងភ្លើង ។ ខណៈនោះ ដោយសារគុណបុណ្យអានិសង្សផ្នួសរបស់សុបិនជាកូន ក៏មានផ្កាឈូកផុសឡើងទ្រនាងម្ដាយផុតពីភ្លើង ពុំឱ្យក្ដៅឡើយ ។ ពេលនោះពពួកយមបាលឆ្ងល់ក៏សួរនាងថា "តើធ្វើបុណ្យអ្វីដែរ" ។ នាងម្ដាយសុបិនកុមារក៏រលឹកនឹកឃើញដល់ពណ៌ចីវរលឿងដូចគ្នានឹងអណ្ដាតភ្លើងក៏ឆ្លើយថា "កូនខ្ញុំបានបួសជាសាមណេរ" ។ ខណៈនោះពពួកយមបាលយល់ថា នាងពិតជាមានកុសលកម្ម ក៏នាំព្រលឹងនាងមកឋានកណ្ដាល ហើយបញ្ចូលទៅក្នុងរូបដើមវិញ ទើបរស់រានមានជីវិតវិញទៅ ។

ដោយសារអានិសង្សផ្នួសនេះទៀត ព្រលឹងនាយនេសាទ ជាឪពុកដែលបានធ្វើមរណភាពអស់ពេលដ៏យូរហើយរងទុក្ខក្នុងរណ្ដៅនរក ក៏បានរួចរំដោះផុតពីរណ្ដៅកម្មនោះនិងបានទៅសោយសុខក្នុងឋានសួគ៌វិញហោង ។

*(ដកស្រង់និងកែសម្រួលពីសៀវភៅសិក្សាអត្ថបទរបស់លោក លាង ហាប់អាន ទំព័រទី២០៧-២០៩ បោះពុម្ពឆ្នាំ ១៩៦៦)*

## សំណួរ

១. ហេតុអ្វីបានជាឪពុករបស់កុមារធ្លាក់ទៅរងទុក្ខទោសនៅឋាននរក ?
២. ហេតុអ្វីបានជាយមបាលយកព្រលឹងម្ដាយសុបិនកុមារទៅឋាននរក ?
៣. តើមានហេតុការណ៍កើតឡើងដូចម្ដេចខ្លះ នៅពេលយមបាលធ្វើទារុណកម្មព្រលឹងម្ដាយសុបិនកុមារ ?
៤. តើអានិសង្សសាងផ្នួសរបស់សុបិនកុមារហុចផលដូចម្ដេចខ្លះ ?
៥. ចូរបង្ហាញពីកាលអាកាសរបស់រឿងនេះ ។
៦. តើរឿងនេះអាចចាត់ទុកជាអក្សរសិល្ប៍បែបពុទ្ធនិយម ព្រាហ្មណ៍និយម ឬខេមរនិយម ? ចូរបង្ហាញអំណះអំណាង ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# ប្រាសាទបន្ទាយស្រី



## ក. សិក្សាពាក្យគន្លឹះ

- បូព៌ាទិស : ទិសបូព៌ ឬទិសខាងកើត ។
- គោបុរៈ : ខ្លោងទ្វារប្រាសាទ ។
- វិចិត្រ : ភាពល្អវិសេសវិសាល ។
- ទេវរូប : រូបតំណាងទេវៈ ។
- ឧទ្ទិស : បញ្ជូនផលដល់ ថ្វាយដល់ ។
- ធម្មមន្ទីរ : បណ្ណាល័យតម្កល់គម្ពីរផ្សេងៗ ឬកន្លែងតម្កល់ធម៌ ។
- ស្ថាបត្យកម្ម : ការស្ថាបនា ការសាងសង់ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងក្នុងអត្ថបទដូចជា សេចក្ដីលម្អិត ខ្លឹមសារនៃអត្ថបទ និងតម្លៃអប់រំក្នុងអត្ថបទជាដើម ។

facebook.com/moeys krou.moeys.gov.kh

## គ. អត្ថបទ

[...] បណ្តាប្រាសាទនៅតំបន់អង្គរ ប្រាសាទបន្ទាយស្រី ជាប្រាសាទល្អវិសេសមួយមានឈ្មោះល្បីជាងគេ មានក្បាច់ល្អិតឆ្មាររស់រវើកជាងប្រាសាទនានា។ គេសាងបែរមុខទៅបូព៌ាទិស។ តាមសិលាចារឹកប្រាសាទនេះឈ្មោះឥស្វរបុរៈ ឈ្មោះត្រីភុវតមហេស្វរ ប្រែថា ជាធំក្នុងត្រៃភព។ នៅគ.ស ៩៦៧ ព្រះគ្រូជូវរាហៈបានសាងប្រាសាទបន្ទាយស្រី ដែលស្ថិតនៅខាងជើងក្រុងយសោធបុរៈ។ ប្រាសាទនេះមានកំពែងថ្មបាយក្រៀមព័ទ្ធបីជាន់ មានទីលានក្រាលថ្មវែងទៅទិសខាងកើត មានគោបុរៈប្រកបដោយក្បាច់ដ៏វិចិត្រ។ នៅចំពាក់កណ្តាលទីលាន មានរោងទងខ្វាត់ខ្វែងជាក្រឡាចត្រង្គ ចេញទៅខាងជើងមួយ ចេញទៅខាងត្បូងបី សុទ្ធសឹងប្រកបដោយក្បាច់រចនាល្អវិចិត្រ។ សព្វថ្ងៃនេះ បាក់ធ្លាក់អស់ហើយ សល់តែសសរច្រូងច្រាងគួរឱ្យស្តាយ។ បើចង់មើលទីលាន ត្រូវចូលទៅតាមគោបុរៈ។ ខាងកើតនៃកំពែងខាងក្រៅ មានទីលានកាត់ពីខាងកើតចូលទៅដល់ខាងលិច មានសិន្ធុអមខាងជើងនិងខាងត្បូង។ ត្រង់នេះ អ្នកនឹងមើលឃើញប្រាសាទជាច្រើននិងគោបុរៈមានហោជាងប្រកបដោយក្បាច់រចនាមានសន្លឹកភ្ញីវល្លិវិលវង់គួរឱ្យស្ញើច។ ប្រាសាទនេះ កាលពីដើមមានដើមឈើដុះស្រោបព័ទ្ធជុំវិញ បណ្តាលឱ្យបាក់បែកអស់ តែឥលូវនេះគេកាប់ឆ្ការព្រៃរុះរើរៀបចំជាថ្មីវិញបានល្អដូចដើម។ គេសង់ជាតួប្រាង្គបីខ្នងតាមសាសនាព្រាហ្មណ៍ ដែលមានទេវរូបជាទីគោរព។ ហេតុនេះបានជាគេកសាងប្រាសាទថ្មសុទ្ធបីឧទ្ទិសថ្វាយ គឺព្រះឥសូរកណ្តាល ព្រះនារាយណ៍ខាងជើង ព្រះព្រហ្មខាងត្បូងជាប់ទន្ទឹមគ្នាពីខាងជើងទៅត្បូង។ ប្រាសាទថ្មសុទ្ធនីមួយៗមានទ្វារចូលបីទិស ជាទ្វារបញ្ឆោត ប្រាសាទកណ្តាលមានយ៉ូលយចេញមកខាងកើត។ ខាងមុខមានធម្មមន្ទីរមួយគូនៅទិសឦសានមួយទិសអាគ្នេយ៍មួយ។ ធម្មមន្ទីរនេះបែរមុខទៅទិសខាងលិច។ ប្រាសាទបន្ទាយស្រីជាប្រាសាទមួយដែលមានក្បាច់រចនាយ៉ាងបញ្ចង់ឆើតឆាយ មានសន្លឹកភ្ញីវល្លិវិលវង់ល្អិតឆ្មារល្អស្រស់រស់រវើក។ សន្លឹកក្បាច់មួយទងៗវិលវង់មូលក្រឡង់អាចទាញភ្នែកឱ្យគយគន់មៀងមើលម្តងហើយម្តងទៀតនិងឈរទ្រឹងភាំងភ្លេចខ្លួន។ ប្រសិនបើទស្សនាវួចហើយ យើងពិតជាជញ្ជក់មាត់ដោយសេចក្តីស្ញើចថ្ងៃដ៏អស្ចារ្យនេះ សម័យកសាងប្រាសាទបន្ទាយស្រីនេះជាសម័យនៃការចេះដឹងស្ទាត់ជំនាញយ៉ាងខ្លាំងក្លា ពិសេសផ្នែកស្ថាបត្យកម្ម។ [...]

*(ដកស្រង់និងកែសម្រួលពីមគ្គុទ្ទេសក៍នគរ ភាគ ២ ប៉ាង ខាត់ និងប្រវត្តិសាស្ត្រខ្មែរ ត្រឹង ងា)*

## សំណួរ

១. តើប្រាសាទបន្ទាយស្រីមានសោភណភាពដូចម្ដេចខ្លះ ?

២. តើនរណាជាអ្នកកសាងប្រាសាទនេះ ?

៣. ហេតុអ្វីបានជាយើងចាត់ទុកប្រាសាទបន្ទាយស្រីជាវត្ថុមានតម្លៃ ?

៤. តើចម្លាក់ប្រាសាទបន្ទាយស្រីមានតម្លៃអ្វីខ្លះ ចំពោះជាតិនិងអន្តរជាតិ ?

៥. តើអ្នកមានទស្សនៈបែបណាខ្លះចំពោះទឹកដៃចម្លាក់ស្ថាបត្យកម្ម សំណង់ប្រាសាទខ្មែរ ?

៦. តើអត្ថបទខាងលើនេះឆ្លុះបញ្ចាំងនូវសោភ័ណសិល្បៈដូចម្ដេចខ្លះ ?

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh



# របាំគោះអង្រែ

នៅពេលស្តាប់អត្ថបទ "របាំគោះអង្រែ" អ្នកត្រូវស្តាប់ដោយយកចិត្តទុកដាក់ កត់ចំណាំសេចក្តីលំអិតសំខាន់ៗក្នុងអត្ថបទ ដើម្បីត្រៀមឆ្លើយសំណួរមួយចំនួនទាក់ទងខ្លឹមសារអត្ថបទ ។



## សំណួរ

១. តើរបាំគោះអង្រែ ជារបាំប្រភេទណា ?

២. តើរបាំនេះ មានប្រភពមកពីណា ?

៣. តើគេលេងរបាំនេះ នៅពេលណា ?

៤. តើរបាំនេះមានតម្លៃអប់រំដូចម្តេចខ្លះ ចំពោះសិល្បៈវប្បធម៌ខ្មែរនាសម័យបច្ចុប្បន្ន ?

៥. តើរបាំនេះមានទំនុកច្រៀងដូចម្តេច ? ចូរច្រៀងឡើងវិញម្តងទៀត ។

facebook.com/moeys.gov.kh youtube.com/moeys



# ការច្រៀងចម្រៀងរបាំគោះអង្រែ

អ្នកបានស្ដាប់រួចមកហើយពីការអធិប្បាយអត្ថបទនិងទំនុកច្រៀងនៃរបាំគោះអង្រែ ។

ឥឡូវនេះ ចូរអ្នកអានទំនុកច្រៀងនៃរបាំគោះអង្រែខាងក្រោមនេះឡើងវិញ រួចរៀបជាក្រុមតូចៗ ដើម្បីច្រៀងចម្រៀង "របាំគោះអង្រែ" នេះឱ្យបានត្រឹមត្រូវទាំងអស់គ្នា ។

១. សារិកាកែវអើយ សារិកាកែវកើច
បងលោមឱ្យសើច ចង់មើលធ្មេញខ្មៅ ។

២. ស្រីស្រស់ប្រហើរ ស្រីស្រស់ប្រហើរ
ប្រយ័ត្នជើងដើរ ក្រែងអង្រែដំជើង ។

៣. ទន់អើយស្រីទន់ ទន់អើយស្រីទន់
លើកដៃល្វាសល្វន់ ស្រីរាំលោតអង្រែ

**បន្ទរ.** មែនហើយ អាដែងមែនហើយ !

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# រឿងប្រឌិតដែលមានភាពសាំញ៉ាំ

អ្នកបានសិក្សារួចមកហើយអំពីសំណេរពន្យល់ សំណេរបំពេញលិខិតផ្លូវការ កិច្ចសន្យាជួលលក់ សំណេរវិភាគអត្ថបទ សំណេរសំយោគលើទស្សនៈ មតិ យោបល់ និងអ្វីមួយ ។ល ។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីសំណេរប្រឌិតរឿងដែលមានភាពសាំញ៉ាំនិងខុសប្លែកពីសំណេរមុនៗ ។

ចូរអ្នកអានរឿងប្រឌិតខាងក្រោមនេះឡើងវិញ

## រឿងឃ្មោកអស្ចារ្យ

កាលពីព្រេងនាយ យូរអង្វែងណាស់មកហើយ មេឃនិងដី មិនមែនដាច់ស្រឡះដូចសព្វថ្ងៃនេះទេ ។ ព្រះទេវៈនិងមនុស្សលោកតែងជួបគ្នាជាញឹកញាប់ ហើយជួនកាលស្កាត់ទៅសួរសុខទុក្ខគ្នាទៀតផង ។ ប្រជាជននៅមឿងលុម[(១)] អាចឡើងទៅកាន់ដែនមឿងថែន[(២)] បានយ៉ាងងាយ ។ នៅដែននោះព្រះផាញ៉ាថែនលួងជាអ្នកកាន់អំណាចកំពូល គ្រប់គ្រងលើទេវៈដទៃទៀត ។ ដែនមឿងលុមមានប្រធានបីនាក់កាន់កាប់ យុនខាន យុនខេត ឬយុនឡេត ហើយនឹងភូឡាំងសាន ។

នៅសម័យនោះ ដែនមឿងលុមសម្បូររុងរឿងណាស់ ។ ព្រះផាញ៉ាថែនលួងបានបញ្ជាឱ្យមនុស្សរៀបតង្វាយបូជាចំពោះព្រះអង្គរាល់ពេលបាយព្រឹក ល្ងាច ។ តង្វាយត្រូវមានម្ហូបឆ្ងាញ់ៗ ចំពោះសត្វប្រមាញ់ត្រូវកាត់ទុកថ្វាយព្រះអង្គមួយភ្លៅគ្រប់សត្វ ត្រីក៏ត្រូវទុកមួយចំនួនជាដាច់ខាត ដើម្បីរៀបចំរណ្តាប់បូជានេះ ព្រោះថាព្រះទេវៈដ៏មានឬទ្ធិនិងក្រុមគ្រួសារព្រះអង្គសព្វព្រះទ័យសោយបាយត្រីសាច់ដែលបានមកពីដែនមឿងលុមណាស់ ។

ពីដំបូង គេគោរពតាមរាជបញ្ញត្តិបានយ៉ាងប្រពៃ ប៉ុន្តែបន្តិចក្រោយមក មនុស្សភ្លេចបូជាកាន់តែច្រើនឡើងៗ ។ ព្រះផាញ៉ាថែនលួង បានឱ្យនីរសារមកស្តីបន្ទោសប្រជាជនមឿងលុមជាច្រើនដង ច្រើនសា ប៉ុន្តែគ្មាននរណាម្នាក់គោរពតាមទេ ។ ដោយខ្ញាល់ខ្លាំង ព្រះអង្គក៏បើកឱ្យភ្លៀងធ្លាក់ចុះមកយ៉ាងខ្លាំងក្រៃលែង ។ ទឹកឡើងលិចរហូតបាត់ផ្ទៃផែនដី ។ មនុស្សម្នានៅដែនមឿងលុមស្លាប់អស់គ្មានសល់នៅរស់តែប្រធានបីនាក់ប៉ុណ្ណោះ ។ អ្នកទាំងនោះចេះនាំគ្នាកាប់ឫស្សីយកមកធ្វើផ្ទះក្បូនម្នាក់មួយៗដែលអណ្តែតលើទឹកជានិច្ច ទោះទឹកចេះតែឡើងឥតឈប់ឈរយ៉ាងណាក្តី ។ ដោយសារហេតុនេះហើយបានជាអ្នកទាំងបីនៅរស់ ។

---

(១) មឿងលុម : អ្នកស្រុកដែនអាយ

(២) ស្ថានទេវៈ

ទឹកឡើងរហូតដល់ពិភពនៃព្រះទេវៈ។ ប្រធានទាំងបីក៏បានឡើងទៅដល់ទីនោះដែរ ពួកគេស្កាត់ទៅថ្វាយព្រះផាញ៉ាថែនលួង។ គ្រាន់តែឃើញពួកគេភ្លាម ព្រះសក្កទេវរាជមានបន្ទូលដោយក្រេវក្រោធ "ពួកឯងឡើងមកទីនេះធ្វើអ្វី ? ពួកឯងល្មើសនឹងរាជបញ្ជារបស់យើង ពួកឯងទៅជាស៊ីក៏ទៅៗ" ប្រធានទាំងបីនាំគ្នាពណ៌នាពីការខូចខាតធំធេង ដែលបណ្ដាលមកពីទឹកជំនន់នៅមឿងលុម។ ការនេះបានធ្វើឱ្យកំហឹងព្រះទេវៈស្ងប់រំងាប់បានខ្លះៗដែរ ហើយព្រះអង្គក៏អនុញ្ញាតឱ្យអ្នកទាំងបីជ្រកកោននៅក្នុងអាណាចក្រព្រះអង្គលើភ្នំថែនឡា។ ទឹកជំនន់ក៏ស្រកចុះជាលំដាប់។ បន្តិចក្រោយមកប្រធានទាំងបីចាប់ផ្ដើមអផ្សុកនឹងជីវិតនៅស្ថានសួគ៌ជាខ្លាំង គេនឹករលឹកតែដែនមឿងលុមរបស់គេ។ ដូចនេះអ្នកទាំងបីនាំគ្នាទៅថ្វាយបង្គំព្រះផាញ៉ាថែនលួង ៖ "ទូលបង្គំទាំងឡាយ មិនធ្លាប់នៅក្នុងព្រះរាជាណាចក្រស្ថានសួគ៌របស់ព្រះទេវៈទេ។ សូមព្រះអង្គមេត្តាអនុញ្ញាតឱ្យទូលបង្គំទាំងឡាយបានវិលត្រឡប់ទៅដែនមឿងលុមស្រុកកំណើតវិញចុះ។ ទូលព្រះបង្គំដឹកនាំគ្នាសង់ផ្ទះតាមរបៀបផែនដី រួចភ្ជួររាស់ដីដាំដំណាំនានា យើងនឹងបានត្រីបរិភោគដូចពីដើមឡើងវិញ។

ព្រះថែនលួងក៏យល់ព្រម ព្រះអង្គថែមទាំងប្រទានក្របីស្នែងខ្លីមួយដល់ពួកគេផង។ អ្នកទាំងបីចុះចាកកំពូលភ្នំថែនឡា ហើយនាំក្របីមកកាន់ដែនមឿងលុម។ គេនាំគ្នាតាំងលំនៅស្ថាន នៅណាណួយ អយន្ទូ ហើយប្រើប្រាស់ក្របីភ្ជួររាស់ដី។ តាមរបៀបនេះ គេក៏អាចបន្តការរស់នៅបាន។ ប៉ុន្តែក្របីមិនធ្លាប់រស់នៅមឿងលុមក៏រត់បាត់។ អ្នកទាំងបីខំដើររកវាគ្រប់កន្លែងក្នុងភូមិភាគរបស់ខ្លួន តែរកមិនឃើញសោះ ព្រោះសត្វនេះវានឹករលឹកភ្នំស្ថានសួគ៌របស់វា ហើយវាចង់វិលត្រឡប់ទៅវិញ។ ប្រធានទាំងបីដើររកទាល់តែឃើញហើយនាំមកវិញ។ ប៉ុន្តែសត្វពាហនៈនេះ នៅតែចង់រត់គេចរាល់តែដង។ ការតាមចាប់វាយកមកវិញជាកិច្ចមួយពិបាកណាស់។ ដូចនេះ អ្នកទាំងបីនាំគ្នាវេញខ្សែយ៉ាងមាំមួយយកមកចងវា។ ចាប់តាំងពីពេលនោះមក ក្របីមិនអាចទៅកាន់ភ្នំនៅស្ថានសួគ៌វិញបានទេ។ ហើយចាប់ពីពេលនោះមក មនុស្សក៏ឡើងទៅស្ថានសួគ៌លែងរួចទៀតដែរ។

ក្រោយពីប្រកបការងារបានបីឆ្នាំមក ក្របីក៏ស្លាប់។ បន្ទាប់ពីនោះមក មានវល្លិមួយដើមដុះចេញពីច្រមុះខ្មោចក្របី ដែលដួលដេកនៅណាណួយ អយន្ទូនោះ។ វល្លិនេះលូតលឿនណាស់ ហើយចេញផ្លែឃ្លោកមួយមានទំហំធំប្លែកពីឃ្លោកធម្មតា។ កាលបើផ្លែនោះទុំ គេឮសូរសំឡេងអ៊ូអែយ៉ាងចម្លែកលាន់ចេញមកពីក្នុងផ្លែ ស្ដាប់សូរទៅហាក់ដូចជាសំឡេងមាត់មនុស្ស។ ពូឡាងសឺនយកជន្លួញដែកស្រួចមួយទៅដុតទាល់តែក្រហម រួចហើយទើបយកទៅចាក់ទំលុះផ្លែឃ្លោក។ មនុស្សក៏ដើរចេញតាមរន្ធទើបនឹងចោះ បន្តគ្នាជាប់ឥតដាច់សោះ។ ប៉ុន្តែរន្ធនោះតូចពេកនាំឱ្យការចេញមកមានការពិបាក ហើយយឺតយូរផង។ ខាន់ ខាន់ ក៏ទៅយកដែកខួងមកពង្រីកមាត់រន្ធ។ ធ្វើដូចនេះ អាចឱ្យ

មនុស្សទាំងនោះចេញមកបានយ៉ាងស្រួលហើយឆាប់រហ័សទៀត ។ ការចេញមកនេះប្រព្រឹត្តទៅឥតអាក់ អស់រយៈពេលបីថ្ងៃ បីយប់ ទើបអស់មនុស្សពីក្នុងផ្លែឃ្លោកទិព្វ ។

អ្នកចេញមកមុនគេ គឺពួកឡាវធុង ។ ពួកនេះជារៀមច្បង បន្ទាប់មកទៀត គឺពួកឡាវលុមដែលជាប្អូនប្រុសស្រី ។ ទីបញ្ចប់ គឺពួកឡាវ ស៊ុង ដែលជាប្អូនពៅ ។

ពូឡាង សឹន បានបង្ហាត់បង្ហាញឱ្យពួកនោះចេះធ្វើដីដាំដំណាំ ឬសាបព្រោះគ្រាប់ ចេះធ្វើផ្ទះ ចេះរៀបការគ្នាបង្កើតជាគ្រួសារ បង្កើតកូនប្រុសស្រី ។ ចាប់តាំងពីពេលនោះមក មនុស្សជាតិកាន់តែរីកចម្រើនច្រើនឡើងៗជាលំដាប់ ។ មឿងលុមមានជីវភាពកាន់តែសកម្ម កាន់តែរីកចម្រើនឡើង ។

ពូឡាង សឹន ក៏បានបង្ហាត់បង្ហាញឱ្យពួកនោះចេះស្រឡាញ់ឪពុកម្ដាយ ចេះគោរពចំពោះចាស់ទុំ មានភាតរភាពចំពោះអ្នកដែលនៅក្នុងភូមិជាមួយគ្នា នៅក្នុងប្រទេសជាមួយគ្នា មានសញ្ជាតិដូចគ្នា ឱ្យថែរក្សាកេតនភណ្ឌ ដែលបុព្វបុរសបានទុកឱ្យ ។ ពូឡាង សឹននិងប្រធានបីនាក់ទៀតអប់រំស្មារតីស្នេហាជាតិដ៏ធំធេង ដូចនេះហើយឡាវទាំងប្រុស ទាំងស្រីក៏មានកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះប្រធានទាំងនោះ ហើយលើកតម្កើងពួកគេទុកជាបុព្វបុរសរបស់ខ្លួន ។

*(ទេវកថា ឡាវ ដកស្រង់ពីសៀវភៅអក្សរសិល្ប៍ក្រសួងអប់រំ ឆ្នាំ ១៩៨៣ )*

តាមរយៈរឿងខាងលើនេះ យើងឃើញថា រឿង "ឃ្លោកអស្ចារ្យ" គឺជារឿងប្រឌិតបែបទេវកថាដែលមានភាពសាំញ៉ាំ ព្រោះអ្នកនិពន្ធបង្ហាញពីព្រឹត្តិការណ៍កើតឡើងក្នុងចំណោទបញ្ហារឿងច្រើនបន្តបន្ទាប់គ្នា តាំងពីតួរឿងរហូតដល់ចប់ ។ ពិសេសបានបង្ហាញពីទំនាស់ដែលកើតឡើងពីបញ្ហា "តង្វាយព្រះ" មិនទៀងទាត់ ដែលបង្កើតឱ្យមានបញ្ហាពេញផ្ទៃរឿង ។ ក្នុងនោះមានតាំងពីការបង្ហាញស្ថានភាពដើមនៃរឿង ដែលមានបង្ហាញតួអង្គ ទីកន្លែងរឿង លើមេឃ (ឋានទេវៈ) លើដី (ឋានកណ្ដាល) លើភ្នំ ។ល ។ ការបង្ហាញភាពសាំញ៉ាំនៃរឿង ស្ថិតនៅត្រង់តួអង្គទាំងបីនៅឋានមឿងលុម តែឆ្លងផុតពីទឹកភ្លៀងជន់លិច បានខិតខំតស៊ូរស់និងសុំសិទ្ធិជ្រកកោនពីព្រះផាញ៉ាថែនលួងនៅឋានទេវៈ ( យុនខាន យុនខេត យុនឡេត ) ប្រឹងរស់តាមបែបឋានទេវៈ ។ ប៉ុន្ដែ ជាការពិបាករស់នៅ ។ នេះជាចំណងបញ្ហាដែលអ្នកនិពន្ធបង្ហាញនិងត្រូវរកវិធីដោះស្រាយយ៉ាងណា ដើម្បីឱ្យអ្នកទាំងបីត្រឡប់មករស់នៅស្រុកកំណើតវិញ ។ គឺជាការស្រាយបញ្ហាដោយការយល់ព្រមពីព្រះផាញ៉ាថែនលួង ឱ្យអ្នកទាំងបីត្រលប់មកវិញ ដោយប្រទានក្របីស្នែងខ្លីមួយមកជាមួយដើម្បីប្រកបរបរធ្វើស្រែចំការចិញ្ចឹមជីវិត ។ ដូចនេះ អ្នកនិពន្ធបញ្ចប់រឿងដោយគំនិតសុទិដ្ឋិតាមរយៈក្របីដែលស្លាប់ ហើយដុះចេញជាផ្លែឃ្លោកអស្ចារ្យមួយដែលបង្កើតបានជាគ្រួសារថ្មី រស់នៅប្រកបរបរចិញ្ចឹមជីវិតនៅលើទឹកដីភូមិផងរបងជាមួយគ្នា ជាប្រទេសតែមួយ មានសាមគ្គីភាព ទឹកចិត្តស្នេហាជាតិទឹកដីនិងបុព្វបុរសដើមរបស់គេជារៀងរហូតមក ។

## ១ . ផ្ដើមរឿង

អ្នកនិពន្ធផ្ដើមដោយប្រើឃ្លា ៖ "កាលពីព្រេងនាយ យូរអង្វែងណាស់មកហើយមេឃនិងដី ..." ភ្ជាប់ទៅដំណើររឿងតែម្ដង ។

## ២ . តួរឿង ឬដំណើររឿង

**ចំណោទបញ្ហា :** ការបង្ហាញពីព្រឹត្តិការណ៍ជាច្រើនក្នុងរឿងដែលកើតចេញមួយហើយមួយទៀតបន្តបន្ទាប់គ្នារហូតដល់បញ្ចប់រឿង ដោយសារតែទំនាស់ ។ ទំនាស់ដែលមានប្រភពពីការតស៊ូលោភលន់ និន្ទាឈ្នានីស ... ។ល ។ ចំណោទបញ្ហានៅក្នុងរឿងខាងលើនេះគឺ ៖

**ក. ស្ថានភាពដើម :** ព្រះផាញ៉ាថែនល្អងចូលចិត្តសោយបាយ ត្រី សាច់ និងម្ហូបដទៃទៀតរបស់ប្រជាជនដែនមឿងលុមណាស់ ហើយប្រជាជនក៏មានភាពរុងរឿងផងដែរ ។

**ខ. ភាពសាំញ៉ាំ :**

- ព្រះផាញ៉ាថែនល្អងបញ្ជាឱ្យមនុស្សនៅមឿងលុមរៀបតង្វាយថ្វាយព្រះអង្គរាល់ពេល
- ចំណេរក្រោយមកមនុស្សភ្លេចនិងលះបង់ការគោរពបូជាដោយតង្វាយនេះ ទោះជាព្រះផាញ៉ាថែនល្អងបញ្ជាឱ្យគេមកប្រាប់ជាច្រើនសាយ៉ាងណាក៏ដោយ ។
- ព្រះផាញ៉ាថែនល្អង (អ្នកគ្រប់គ្រងលើទេវៈទាំងអស់) ខ្ញាល់យ៉ាងខ្លាំងចំពោះការរឹងរូសរបស់ប្រជាជននៅមឿងលុមនេះ ។

**គ. ចំណងបញ្ហា :** ការបង្ហាញពីវិធីបង្កើតបញ្ហាឱ្យផ្ទៃរឿងយ៉ាងណាឱ្យឈានដល់កម្រិតខ្ពស់បំផុតនៃទំនាស់ក្នុងរឿង ហើយកាន់តែមានភាពតឹងតែងទៅៗ ហើយក៏នឹងត្រូវស្រាយមកវិញនៅពេលទំនាស់ត្រូវបានបញ្ចប់ផងដែរ ។ ចំណងបញ្ហាក្នុងនេះ គឺទឹកជំនន់លិចដែនមឿងលុម ធ្វើឱ្យប្រជាជនស្លាប់អស់នៅសល់តែប្រធានបីនាក់ប៉ុណ្ណោះ ។

**ឃ. ដំណោះស្រាយ :** នោះគឺដំណោះស្រាយរបស់រឿង ដើម្បីឈានដល់ចំណុចបញ្ចប់នៃព្រឹត្តិការណ៍ ឬចំណោទបញ្ហានីមួយៗ ។ រឿងនេះបានដោះស្រាយដោយព្រះផាញ៉ាថែនល្អងយល់ព្រមឱ្យប្រធានទាំងបីរស់នៅដែនមឿងលុម រួចប្រគល់ក្របីស្នែងខ្លីមួយក្បាលឱ្យប្រធានទាំងបីវិលមកដែនមឿងលុមវិញ ។

## ៣ . ការបញ្ចប់រឿង

ការបញ្ចប់រឿង គឺការបង្ហាញពីដំណោះស្រាយនៅទីបញ្ចប់នៃរឿង នៅពេលចំណងបញ្ហាត្រូវបានដោះស្រាយហើយ រឿងក៏ត្រូវបញ្ចប់ដោយគតិបណ្ឌិត ឬដោយគំនិតសុទិដ្ឋិ គំនិតអប់រំល្អៗ។ រឿងនេះបានបញ្ចប់ដោយបង្ហាញប្រវត្តិបុព្វបុរសជនជាតិឡាវនិងជំនឿ ទំនៀមទម្លាប់ ព្រមទាំងភាពរុងរឿងប្រកបដោយសុទិដ្ឋិនិយមនៃជនជាតិឡាវ ។

### លំហាត់

ចូរជ្រើសរើសប្រធានបទ "រឿងប្រឌិតមួយដែលមានភាពសាំញ៉ាំ" មកសរសេរប្រឌិតតាមលំនាំរឿងខាងលើជា ៖

- រឿងប្រឌិតបែប ទេវកថា
- រឿងប្រឌិតបែប ព្រេងកថា
- រឿងប្រឌិតបែប និទានកថា

### ការណែនាំអនុវត្តសំណេរ

មុនពេលប្អូនសម្រេចសរសេរ ប្អូនត្រូវអនុវត្តតាមលំណែនាំដូចខាងក្រោម ៖

## ១ . ផ្ដើមរឿង

នៅចំណុច ផ្ដើមរឿង ផ្ដើមដោយប្រើពាក្យពេចន៍ ឃ្លា ល្បះ :

- កាលពីព្រេងនាយ នៅ ...
- កាលដើមឡើយ មាន ...
- តាំងពីយូរលង់ណាស់មកហើយ ... ។

## ២ . តួរឿង ឬដំណើររឿង

នៅចំណុចនេះ អ្នកតាក់តែងរឿង ត្រូវគិតទៅលើគោលសំខាន់ៗដូចខាងក្រោម ៖

### ក. តួអង្គ

- តើត្រូវមានតួអង្គប៉ុន្មាន ? នរណាជាតួអង្គឯក ? រង ? បន្ទាប់បន្សំ ?
- តើតួអង្គជាអ្វីខ្លះ ? (មនុស្ស សត្វ រុក្ខជាតិ ធម្មជាតិ ... ? )
- រចនាសម្ព័ន្ធ តួអង្គដូចម្ដេច ? (បងប្អូន ឪពុកម្ដាយ មិត្តភក្តិ គូទំនាស់ ...? )
- សកម្មភាពតួអង្គ តើតួអង្គនីមួយៗធ្វើអ្វីខ្លះ ?

## ខ. កាលអាកាស

តើតួអង្គធ្វើសកម្មភាពនៅកន្លែងណាខ្លះ ? ពេលណា ?

- ទីកន្លែង : អាចនៅភូមិស្រុក ក្នុងព្រៃ ស្ថានមនុស្សលោក ទេវតា ...?
- ពេលវេលា : ថ្ងៃ យប់ រដូវ ឆ្នាំ ... រយៈពេលប៉ុន្មាន ?

## គ. ទំនាស់

បង្ហាញពីភាពមិនចុះសម្រុងនឹងគ្នា ឬទំនាស់ ។

តើតួអង្គមានទំនាស់ជាមួយនឹងអ្វី ? (តួអង្គផ្សេងទៀត ធម្មជាតិ ខ្លួនឯង ...? )

តើក្នុងដំណើររឿងទាំងមូលត្រូវបង្កើតឱ្យមានប៉ុន្មានទំនាស់ ? ប៉ុន្មានព្រឹត្តិការណ៍ ធំ តូច ?

## ឃ. ចំណោទបញ្ហា

ជាបញ្ហាដែលកើតឡើងពីទំនាស់ ហើយបង្កើតបានជាព្រឹត្តិការណ៍ជាបន្តបន្ទាប់ទៅតាមទំនាស់ ។ ចំណោទបញ្ហាមាន ៤ដំណាក់ ៖

- ស្ថានភាពដើម : តើត្រូវបង្កើតបុព្វហេតុដូចម្ដេច ដើម្បីបង្កើតទំនាស់ ? នៅពេលណា ? កន្លែងណា ? រវាងនរណា ? តើជំរុញបញ្ហាទំនាស់ដូចម្ដេច ដើម្បីឱ្យទំនាស់កាន់តែរីករាលដាល គឺមានភាពសាំញ៉ាំ ។
- ភាពសាំញ៉ាំ : តើនរណាខ្លះជាអ្នកចូលរួមពាក់ព័ន្ធក្នុងទំនាស់នោះ ? តើបញ្ហាអ្វីខ្លះដែលចោទឡើង ? តើបញ្ហាចោទឡើងចំពោះនរណាខ្លះ ?
- ចំណាងបញ្ហា : បញ្ហាទំនាស់ឈានដល់ខ្ពស់ ឬទំនាស់ស្រួចស្រាល់ ?
- ដំណោះស្រាយ : តើដោះស្រាយទំនាស់តាមវិធីណា ? នរណាចូលរួមដោះស្រាយ ? តើមានអន្តរាគមន៍ពីនរណា ? ដូចម្ដេច ?

# ៣ . ការបញ្ចប់រឿង

ជាដំណោះស្រាយរួមនិងចុងក្រោយបំផុតនៃរឿង ។ តើអ្នកត្រូវឱ្យតួអង្គណាជាអ្នកទទួលជ័យជម្នះ ? តួអង្គដែលចាញ់ ទទួលផលដូចម្ដេច ? អំពើល្អឈ្នះអំពើអាក្រក់ យុត្តិធម៌ឈ្នះអយុត្តិធម៌ ។

(ផ្ដើមដោយមានការបង្ហាញ ស្ថានភាព តួអង្គ ទីកន្លែង ... ភ្ជាប់នៅដំណើររឿងតែម្ដង)

ពេលសរសេររឿងប្រឌិតដែលមានភាពសាំញ៉ាំនេះរួច ចូរប្អូនពិនិត្យឡើងវិញអំពីកំហុសអក្ខរាវិរុទ្ធ លំដាប់លំដោយខ្លឹមសាររឿង ចំណោទ និងបញ្ហារឿងត្រឹមត្រូវសមហេតុផល បញ្ចប់រឿងដោយមានទស្សនៈអប់រំ ឬគំនិតសុទិដ្ឋិនិយម តម្លៃរឿងសមស្របនឹងស្ថានភាព និងតថភាពសង្គម ។



youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

១០

# ជំនឿ



ជំនឿ ជាផ្នែកមួយនៃអត្តសញ្ញាណជាតិ ។ ជំនឿផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃរបស់មនុស្ស ។ ដោយសារតែការរស់នៅរបស់មនុស្សបានឆ្លងកាត់ឧបសគ្គនានា ពិសេសបាតុភូតធម្មជាតិ ហើយពួកគេពុំអាចយកជ័យជម្នះបាន ក៏កើតចេញជាជំនឿផ្សេងៗរាប់មិនអស់ ។ មូលហេតុខាងលើនេះ នាំឱ្យមនុស្សសម័យដើមតែងនឹកសង្ស័យថា ពិតជាមានកម្លាំងដ៏មហិមាណាមួយ ដែលជាកម្លាំងខាងក្រៅខ្លួនមកជួយឱ្យពួកគេរស់នៅបានសុខ ឬបានទុក្ខ ។ ឥទ្ធិពលដ៏អាថ៌កំបាំងនៃកម្លាំងដ៏អស្ចារ្យនេះក៏ក្លាយទៅជាប្រពៃណីនៃក្ដីសង្ឃឹមរបស់ពួកគេ ដែលគេតែងតែជឿ ហើយគោរពបូជាតាំងពីដើមតរៀងមក ។

ក្នុងមេរៀននេះ អ្នកនឹងបានស្គាល់ជំនឿរបស់ខ្មែរមួយចំនួន ហើយនឹងបានសិក្សាពីតម្លៃអប់រំរបស់អត្ថបទ ខ្លឹមសារអត្ថបទ តួអង្គ សញ្ញាកត់សូរអន្តរជាតិ សម្របសម្រួលក្នុងក្រុមពិភាក្សា និងសំណេរតែងសេចក្ដីពន្យល់ ។

youtube.com/moeys
facebook.com/moeys.gov.kh

# រឿងបណ្ដែតប្រទីប សំពះព្រះខែ អកអំបុក




## ក. សិក្សាពាក្យគន្លឹះ

- ភទ្ទកប្បឬភទ្រកល្ប (ន) : កប្ប ឬកល្បដ៏ចម្រើន (ឈ្មោះកប្ប ឬកល្បដែលមានព្រះពុទ្ធត្រាស់ ប្រាំព្រះអង្គ គឺព្រះពុទ្ធកកុសន្ធៈ កោនាគមនៈ កស្សបៈ គោតមៈ អរិយមេត្តាយ្យៈ) ។
- ក្លួច (កិ) : ធ្វើជាកំណួច ចងដោយខ្ទួច ។
- របាត់របាយ (កិ.វិ) : រតាត់រតាយ រាត់រាយ ។
- មាណព (ន) : ប្រុសកំលោះ ។
- តាបស (ន) : អ្នកបួសខាងក្រៅព្រះពុទ្ធសាសនា កាន់ព្រាហ្មចរិយាធម៌វៀរចាកមេថុនធម៌ ។
- ព្រះឆាយាលក្ខណ៍ (ន) : រូបថត ។

## ខ. អភិវឌ្ឍន៍បំណិន

ដើម្បីទទួលលទ្ធផលល្អ ក្នុងការអានអ្នកគប្បីយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទ តម្លៃអប់រំ តថភាពសង្គមតាមរយៈ ជំនឿរបស់ជនជាតិខ្មែរ ។

facebook.com/moeys.gov.kh krou.moeys youtube.com/moeys

## គ. អត្ថបទ

កាលពីព្រេងនាយ នាខាងដើមនៃភទ្ទកប្បយើងនេះ មានសត្វក្អែកសញ្ជីឈ្មោលបានកាច់សម្បុកពងនៅឈើមួយដើម ដែលដុះនៅឆ្នេរសមុទ្រ ហើយបានបញ្ចេញពងតាមធម្មជាតិជាសត្វនោះចំនួនប្រាំ ។ ថ្ងៃមួយ ជាទេសកាលបណ្ដាលឱ្យមានភ្លៀងបោកបក់ ក្ដួចយកសម្បុកបក្សី ព្រមទាំងពងឱ្យធ្លាក់ចុះទៅក្នុងទឹកកំពុងហូរ ។

លុះពេលល្ងាច ក្អែកញីឈ្មោលហើរត្រឡប់មកពីរកចំណីអាហារវិញ ស្រាប់តែបាត់សម្បុកព្រមទាំងពង ហើយឃើញស្នាមបាក់របាត់របាយអាចឱ្យយល់បាន "ពិតជាការអន្តរាយបណ្ដាលអំពីព្យុះ" ។ ប៉ុន្តែក្អែកសញ្ជីឈ្មោលនោះនៅមិនអស់ចិត្តចេះតែសញ្ជប់សញ្ជឹងគិតក្រៃងដូច្នេះក៏វិយោគបោកប្រាណព្រោះស្ដាយស្រណោះពង ទាល់តែស្លាប់ទាំងគូទៅ ហើយទៅកើតជាព្រះឥន្ទ្រាធិរាជ នៅនាត្រៃត្រឹង្សសួគ៌ទេវលោក ។

និយាយអំពីពងក្អែកទាំង៥ ដែលធ្លាក់ទៅក្នុងទឹក ហើយត្រូវខ្សែទឹកហូរនាំយកទៅនោះ ក៏ទៅធ្លាក់នៅក្នុងដៃនៃសត្វមាន់ ស្ដេចនាគ អណ្ដើក គោ និងខ្លា ដែលបានរើសមួយម្នាក់ៗ យកទៅបីបាច់ថែរក្សានៅទីអាស្រ័យរៀងៗខ្លួន ។ ពងនោះលុះដល់កំណត់ពេលនឹងញាស់ហើយ ស្រាប់តែកើតកូនចេញមក សុទ្ធតែមនុស្សប្រុសទាំង៥ ។ ឯសត្វជាអាណាព្យាបាល ឃើញសេចក្ដីអស្ចារ្យពេកក៏ខំថែរក្សាចិញ្ចឹម ដោយយកចិត្តទុកដាក់ជាទីបំផុត ។

លុះទារកទាំង៥នោះ មានវ័យវឌ្ឍនាការធំឡើង ក៏មានចិត្តគិតឃើញរៀងខ្លួនថា "ខ្លួនអញជាមនុស្សសោះ ចុះហេតុអ្វីបានជាមាតាបិតាសុទ្ធតែជាជាតិតិរច្ឆានដូច្នេះ !" ។ ដោយគិតសព្វគ្រប់ហើយទើបរកមធ្យោបាយរៀងៗខ្លួន លាមាតាបិតាចិញ្ចឹមទីទៃៗរបស់ខ្លួន ដើម្បីដើរស្វែងរករៀនសិល្បវិជ្ជាសន្សំកុសលកសាងពុទ្ធភូមិរៀងៗខ្លួន ។ សត្វជាអាណាព្យាបាលទាំង៥ មានបណ្ដាំតែមួយដូចគ្នា "បើកូនចេញទៅធ្វើការកសាងពុទ្ធភូមិ បានសម្រេចនៅថ្ងៃណា វេលាណា យើងសុំផ្ញើឈ្មោះរបស់យើងឱ្យនៅជាប់នឹងឈ្មោះអ្នកផង !" ។

ដោយហេតុនោះឯង បានជាក្នុងភទ្ទកប្បយើងនេះមានព្រះពុទ្ធ ៥ព្រះអង្គ ទ្រង់ព្រះនាម "កកុន្ធោ (មាន់) កោនាគមនោ (នាគ) កស្សបោ (អណ្ដើក) គោតមោ (គោ) សិរីអារ្យមេត្តេយ្យោ (ខ្លា)" ដែលបានត្រាស់តាមលំដាប់បងប្អូននិងបារមី ហើយយកនាមសត្វទាំង ៥ ដែលជាអ្នកចិញ្ចឹមមកប្រកបភ្ជាប់នឹងព្រះនាមព្រះអង្គតាមបណ្ដាំក្នុងរឿងតំណាលដូចពោលនេះ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

មាណពទាំង៥ កាលចេញចាកឋានមាតាបិតាចិញ្ចឹមរៀងខ្លួន មកក៏បានមកជួបគ្នាទាំង ៥ នាក់នៅកន្លែងមួយ លុះសាកសួរគ្នា ឃើញថាមានគំនិតព្រមទាំងហេតុភេទដូចគ្នា ក៏សុំគ្នាធ្វើជាបងប្អូនរួមរស់ជាមួយគ្នារហូតទៅ ។

ថ្ងៃមួយ នៅវេលាដែលមាណពទាំង ៥ កំពុងតែជជែកគ្នារកមាតាបិតាដើមនោះ ព្រះឥន្ទ្រព្រមទាំងអគ្គមហេសីដែលជាមាតាបិតាដើម ក៏និម្មិតខ្លួនជាក្អែកសញ្ជីឈ្មោល ហើរមកទំលើមែកឈើជិតនោះ ហើយសាស័ព្ទប្រាប់មាណពទាំង៥ ឱ្យបានជឿប្រាកដ : ខ្លួននេះឯងហើយ ជាមាតាបិតាដើម ។ មាណពទាំង៥ ក៏លុតជង្គង់ថ្វាយបង្គំ ចំពោះបុព្វបុរសទាំងពីរ ថ្លែងសេចក្តីស្តាយចំពោះការមិនបានទៅនៅបម្រើឪពុកម្តាយនោះ ព្រោះក្អែកសទាំងគូ មិនអនុញ្ញាតឱ្យទៅនៅជាមួយទេ គ្រាន់តែផ្តាំ "បើកូនរាល់គ្នារលឹកអាល័យយើងណាស់ ហើយចង់បូជាអ្វីដល់យើងទាំងពីរនាក់ ចូរកូនគូសខ្វែងជើងក្អែកនៅគ្រប់វត្ថុដែលជាសំណែននោះ ហើយឧទ្ទិសឱ្យយើងទៅអំពីនេះ មុខជានឹងបានផ្សាយផលដល់យើងជាមិនខានឡើយ "ថាតែប៉ុណ្ណោះ ក៏អន្តរធានបាត់ទៅ" ។

មាណពទាំងប្រាំបានចាំបណ្តាំហើយ ក៏នាំគ្នាទៅរករៀនសិល្បវិជ្ជាបួសជាតាបសចម្រើនព្រតក្នុងព្រៃ ខាងក្រោយមកក៏នាំគ្នាធ្វើបុណ្យសុន្ទរ៍ទានរំលឹកគុណតាមបណ្តាំនោះ ជាដរាបព្រមទាំងគូសខ្វែងជើងក្អែកនៅលើវត្ថុសំណែន សែនរួចបណ្តែតតាមខ្សែទឹកហូរទៅ ដើម្បីបូជាក្អែកសញ្ជីឈ្មោលរហូតជាប់ជាទំនៀមទម្លាប់មកដល់សព្វថ្ងៃនេះ ។

ប៉ុន្តែតាមមតិអ្នកស្រុកខ្លះសំអាងថា "គេធ្វើពិធីបណ្តែតប្រទីបនេះ ដើម្បីឧទ្ទិសបូជាដល់ស្នាមព្រះពុទ្ធបាទនិងព្រះចង្កូមកែវ ដែលប្រតិស្ឋាននៅនាពិភពនាគ" ។ រួមសេចក្តីមក ឃើញថាទោះបីអាចារ្យដែលពោល "ការធ្វើពិធីនេះ ដើម្បីឧទ្ទិសបូជាដល់ស្នាមព្រះពុទ្ធបាទក្តី ដល់ព្រះចង្កូមកែវក្តី ដល់ក្អែកសញ្ជីឈ្មោលក្តី ឬថាដល់ព្រះចុល្លាមណីចេតិយក្តី" ក៏សុទ្ធតែមានហេតុផលល្អចំពោះពុទ្ធសាសនាដូចគ្នាគឺមានសេចក្តីស្របគ្នាជាច្រើន មិនមានជាទំនាស់ប៉ុន្មានទេ ។ ឯគម្ពីររតនសង្រ្គោះក្តី សាស្ត្រាក្អែកសក្តី គម្ពីរពុទ្ធវង្សក្តី ពុំមានបង្គាប់ "ឱ្យធ្វើបុណ្យយ៉ាងនេះ ឬយ៉ាងនោះឡើយ" ប៉ុន្តែអាស្រ័យរឿងរ៉ាវទាំងនេះ បុរាណាចារ្យចេះតែផ្សំថែមធ្វើមករហូតទាល់តែជាប់ជាទំនៀមទម្លាប់ដល់សព្វថ្ងៃ ។

មានតំណាលថា ក្នុងកាលពីព្រេងនាយ កាលព្រះពុទ្ធបរមគ្រូនៃយើងទាំងឡាយ ត្រាច់រង្គាត់អន្ទោលជាតិ ក្នុងវាលវដ្តសង្សារនៅឡើយនោះ ក្នុងជាតិមួយព្រះអង្គទ្រង់យោនយកកំណើតជាសត្វទន្សាយ ។ នៅរាល់ថ្ងៃពេញបូណ៌មី ទន្សាយពោធិសត្វតែងសមាទានរក្សាឧបោសថសីលដោយឧទ្ទិសជីវិតព្រះអង្គជាទានបរមត្ថបារមី ដើម្បីបំពេញព្រះពោធិសម្ភារ ឱ្យបានត្រាស់ដឹងជាព្រះពុទ្ធ ។ នៅថ្ងៃ

ពេញបូណ៌មីមួយ ព្រះឥន្រ្ទទ្រង់ជ្រាបក៏កាឡាខ្លួនជាព្រាហ្មណ៍ចាស់ មកសុំសាច់ព្រះអង្គជាអាហារ ។ ព្រះពោធិសត្វសុខចិត្តបូជាជីវិត ដើម្បីឱ្យសាច់ដល់ព្រាហ្មណ៍ចាស់ ប៉ុន្តែព្រាហ្មណ៍ចាស់ទូលព្រះអង្គ "ខ្លួនគាត់កាន់សីលមកយូរហើយ មិនអាចនឹងសម្លាប់សត្វបានទេ" ទើបទន្សាយពោធិសត្វបង្គាប់ឱ្យព្រាហ្មណ៍បង្កាត់ភ្លើងឡើង រួចក៏លោតចូលសម្លាប់ខ្លួន ដើម្បីឱ្យបានសាច់ដល់ព្រាហ្មណ៍បរិភោគ ។ ប៉ុន្តែមុននឹងលោតចូលភ្នក់ភ្លើងនោះ ព្រះអង្គទ្រង់អធិដ្ឋាន សុំឱ្យព្រះឆាយាលក្ខណ៍នៃព្រះអង្គ ទៅប្រតិស្ឋានផ្ដិតជាប់នៅនឹងមណ្ឌលព្រះចន្ទរហូតលុះទីបំផុតកប្ប ដោយអនុភាពនៃទានបារមីនោះ ។

អាស្រ័យដោយរឿងខាងលើនេះហើយ ទើបបានជារូបទន្សាយ មានប្រាកដនឹងមណ្ឌលព្រះចន្ទ ដូចដែលយើងមើលឃើញសព្វថ្ងៃនេះ ។ លុះចំណេរក្រោយមក ទើបបណ្ដាជននាំគ្នារំលឹកកំណើតទន្សាយពោធិសត្វនេះ ធ្វើពិធីបុណ្យ ដែលហៅថា "អកអំបុក សំពះព្រះខែ" គឺយើងសំពះព្រះឆាយាលក្ខណ៍ព្រះពោធិសត្វនោះឯង ។ ដោយហេតុនេះទើបគេនាំគ្នាជ្រើសរើសចំណីណាដែលជាទីគាប់ចិត្តតម្រូវនឹងអធ្យាស្រ័យ នៃសត្វទន្សាយមាន "ចេក អំបុក ដំឡូង ដូង ត្រាវ" ជាដើម យកមកឧទ្ទិសថ្វាយផង ជាហូរហែជាប់ទំនៀមទម្លាប់មករហូតដល់សព្វថ្ងៃ ។

*(ដកស្រង់ចេញពីប្រជុំរឿងព្រេងភាគ ៩ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥៤៧ គ.ស ២០០៣)*

## សំណួរ

១. តើព្រះពុទ្ធទាំងប្រាំអង្គក្នុងអត្ថបទរឿងនេះ ព្រះនាមអ្វីខ្លះ ? ហេតុដូចម្ដេច បានជាមានព្រះនាមបែបនេះ ?

២. តើប្រវត្តិនៃតួអង្គព្រះពុទ្ធទាំងប្រាំអង្គនេះ បានផ្ដល់តម្លៃអប់រំយ៉ាងណាខ្លះ ? ចូរបញ្ជាក់ ?

៣. ហេតុដូចម្ដេច បានជាប្រជារាស្ត្រខ្មែរនិយមពិធីអកអំបុក សំពះព្រះខែ ។

៤. តើកត្តាចម្បងអ្វីខ្លះ ដែលនាំឱ្យទន្សាយពោធិសត្វសុខចិត្តលះបង់អាយុជីវិតឱ្យដល់ព្រាហ្មណ៍ ? តើការលះបង់បែបនេះ មាននៅក្នុងទ្រឹស្ដី ឬលទ្ធិណាមួយ ?

៥. ចូរអ្នកឆ្លុះបញ្ចាំងតាមរយៈអត្ថបទនេះ អំពីជំនឿរបស់ជនជាតិខ្មែរ ។

facebook.com/moeys.gov.kh youtube.com/moeys

# សញ្ញាកត់សូរអន្តរជាតិ

ចូរអ្នកអានសូរព្យញ្ជនៈ សូរស្រៈក្នុងតារាងដូចខាងក្រោម និងសរសេរពាក្យជាសញ្ញាកត់សូរអន្តរជាតិ ( API ) ៖

| សូរព្យញ្ជនៈ | សូរស្រៈ | សូរស្រៈ |
|---|---|---|
| សញ្ញាកត់សូរជាខ្មែរនិងជា API | សញ្ញាកត់សូរជាខ្មែរនិងជា API | សញ្ញាកត់សូរជាខ្មែរនិងជា API |
| + ក - គ [ k ] | + អ [ ɒ: ] | + អ់ [ ɒ ] |
| + ខ - ឃ [ kh ] | + អា [ ɑ: ] | + អ់ា [ a ] |
| + ច - ជ [ c ] | + អឺ [ œ: ] | + អិ [ ẹ ] |
| + ឆ - ឈ [ ch ] | + អូ [ o: ] | + អី [ ɛi ] |
| + ដ - ឌ [ d ] | + អើ [ aə: ] | + អឹ [ œ ] |
| + ត - ទ [ t ] | + អេ [ ẹ: ] | + អុ [ ọ ] |
| + ថ - ធ [ th ] | + អែ [ aɛ: ] | + អៃ [ ai ] |
| + ប - ប៊ [ b ] | + អោ [ ao: ] | + អៅ [ au ] |
| + ប៉ - ព [ p ] | + អ៊ឺ [ ə: ] | + អ៊ិ់ [ ə ] |
| + ផ - ភ [ ph ] | + អ៊ា [ i:ə ] | + អ៊ា់ [ iə ] |
| + អ - អ៊ [ ? ] | + អុី [ i: ] | + អុិ [ i ] |
| + ង៉ - ង [ ŋ ] | + អុឺ [ *w*: ] | + អុឹ [ *w* ] |
| + ញ៉ - ញ [ ɲ ] | + អ៊ូ [ u: ] | + អ៊ុ [ u ] |
| + ណ - ន [ n ] | + អុើ [ δ: ] | + អ៊ែ [ ɛ ] |
| + ម៉ - ម [ m ] | + អ៊េ [ e: ] | + អ៊ៃ [ ei ] |
| + យ៉ - យ [ j ] | + អ៊ែ [ ɛ: ] | + អ៊ៅ [ əu ] |
| + រ៉ - រ [ r ] | + អ៊ោ [ o: ] | |
| + ឡ - ល [ l ] | + អ៊័ [ oa: ] | |
| + វ៉ - វ [ v ] | + អួ [ u:ə ] | |
| + ស - ស៊ [ s ] | + អឿ [ *w*:ə ] | |
| + ហ - ហ៊ [ h ] | + អៀ [ i:e ] | |

krou.moeys.gov.kh
youtube.com/moeys
facebook.com/moeys.gov.kh

***ឧទាហរណ៍ :*** ដោយ ទើប លើ ជា ជន ថ្វាយ ធ្វើ ក្រោយ រឿង គ្នា ប្រាកដ រូបភាព ។

| | | |
|---|---|---|
| - ដោយ **[ dao:j ]** | ទើប **[ tδ:b ]** | លើ **[ lδ: ]** |
| - ជា **[ ci:ə ]** | ជន **[ cən ]** | ថ្វាយ **[ tva:j ]** |
| - ធ្វើ **[ tvδ: ]** | ក្រោយ **[ krao:j ]** | រឿង **[ rw:əŋ ]** |
| - គ្នា **[ kni:ə ]** | ប្រាកដ **[ bra ][ kɒt ]** | រូបភាព **[ rub ][ phi:əb ]** |

តាមឧទាហរណ៍ខាងលើនេះ ជាការកត់សូរផ្សំគ្នា ដោយសូរព្យញ្ជនៈនិងសូរស្រៈ ជាសូរវិទ្យាអន្តរជាតិ :

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| - "ដោយ" ផ្សំឡើង : | ដ | + | [ អោ ] | | | + | យ | = | **[ d + ao: + j ]** |
| - "ទើប" ផ្សំឡើង : | ទ | + | [ អើ ] | | | + | ប | = | **[ t + δ: + b ]** |
| - "លើ" ផ្សំឡើង : | ល | + | [ អើ ] | | | | | = | **[ l + δ: ]** |
| - "ជា" ផ្សំឡើង : | ជ | + | [ អ៊ា ] | | | | | = | **[ c + i:ə ]** |
| - "ជន" ផ្សំឡើង : | ជ | + | [ អ៊ ] | | | + | ន | = | **[ c + ə + n ]** |
| - "ថ្វាយ" ផ្សំឡើង : | ថ | + | វ | + | [ អា ] | + | យ | = | **[ t +v + a: + j ]** |
| - "ធ្វើ" ផ្សំឡើង : | ធ | + | វ | + | [ អ៊ើ ] | | | = | **[ t + v + δ: ]** |
| - "ក្រោយ" ផ្សំឡើង : | ក | + | រ | + | [ អោ ] | + | យ | = | **[ k + r + ao: + j ]** |
| - "រឿង" ផ្សំឡើង : | រ | + | [ អឿ ] | | | + | ង | = | **[ r + w:ə + ŋ ]** |
| - "គ្នា" ផ្សំឡើង : | គ | + | ន | + | [ អ៊ា ] | | | = | **[ k + n + i:ə ]** |
| - "ប្រាកដ" ផ្សំឡើង : | ប | + | រ | + | [ អា ] | | | = | **[ b + r + a ]** |
| | ក | + | [ អ់ ] | | | + | ដ | = | **[ k + ɒ + t ]** |
| - "រូបភាព" ផ្សំឡើង : | រ | + | [ អ៊ូ ] | | | + | ប | = | **[ r + u + b ]** |
| | ភ | + | [ អ៊ា ] | | | + | ប | = | **[ ph + i:ə + b ]** |

*សញ្ញាកត់សូរអន្តរជាតិ ( API ) មាននាទីសំខាន់ក្នុងការបញ្ជាក់ពីសូរនៃភាសា ។*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## លំហាត់

១. ចូរអ្នកសរសេរជាសូរវិទ្យា ( **API** ) នូវពាក្យទាំងនេះ ព្រះចន្ទ ដែល យើង រំលឹក កំណើត ទន្សាយ ពោធិសត្វ បុណ្យ អកអំបុក សំពះព្រះខែ ព្រះឆាយាលក្ខណ៍ តម្រូវ ដំឡូង ដូង ត្រាវ ឧទ្ទិស ។

២. ចូរអ្នកសរសេរជាសូរវិទ្យាអន្តរជាតិ ( **API** ) តាមវគ្គដកស្រង់ខាងក្រោមនេះ ៖

[...] លុះចំណេរក្រោយមក ទើបបណ្ដាជននាំគ្នារំលឹកកំណើតទន្សាយពោធិសត្វនេះ ធ្វើពិធីបុណ្យ ដែលហៅថា "អកអំបុក សំពះព្រះខែ" សំពះព្រះឆាយាលក្ខណ៍ ព្រះពោធិសត្វនោះឯង ដោយនាំគ្នាជ្រើសរើសចំណីណា ដែលជាទីគាប់ចិត្តតម្រូវនឹងអធ្យាស្រ័យនៃសត្វទន្សាយមាន "ចេក អំបុក ដំឡូង ត្រាវ" ជាដើម យកមកឧទ្ទិសថ្វាយផង ជាហូរហែ ហើយក្លាយជាទំនៀមមករហូតដល់សព្វថ្ងៃ ។ [...]

# តថភាពនាសម័យអាណានិគមនិយម



## ក. សិក្សាពាក្យគន្លឹះ

- រ៉េស៊ីដង់ (ន) : អ្នកតំណាង ជាតិបារាំង ។
- រ៉េស៊ីដង់ស៊ុប៉េរីយើរ (ន) : អ្នកតំណាងជាន់ខ្ពស់ ជាតិបារាំង ។
- ថែវ (ន) : រោងជួរមានសណ្ឋានវែង បរិវេណ ។
- ឡែឡ (គុឬកិ.វិ) : ក្អេងក្អាងខ្លាំងៗឥតប្រយោជន៍ ឥតគោរពកោតក្រែង (និយាយឡែឡ សម្តីឡែឡ) ។
- ពិធីសូមខមាទោស (ន) : ពិធីសុំឱ្យអត់ទោស ការសុំឱ្យអត់ទោសពីសំណាក់វត្ថុសក្តិសិទ្ធិ ។
- រណែងរណោង (គុឬកិ.វិ) : ដែលព្យួរ ឬសំយុងចុះដូចគេចងបន្តោង ។
- ពរសព្វសាធុការ (ន) : ការជូនពរជ័យ ។
- ទុរភិក្ស (គុ) : ដំណើរអត់បាយ ឬអត់ឃ្លាន ។

## ខ. អភិវឌ្ឍន៍បំណិន

ដើម្បីទទួលលទ្ធផលល្អ ក្នុងការអានអ្នកគប្បីយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរ ទាក់ទងនឹង : តថភាពនាសម័យកាលណាមួយ សង្គមបរិយាកាសនៃរឿង ទំនាស់ វិធីតែងនិពន្ធដែលអ្នកនិពន្ធបានប្រើក្នុងអត្ថបទ ការសរសេរជាសញ្ញាកត់សូរអន្តរជាតិ ( API ) ។

facebook.com/moeys.gov.kh

## គ. អត្ថបទ

[...] បារាំងរើសទាហានខ្មែរបានល្មមគ្រប់ចំនួនហើយ នាយទាហានស្ម័គ្រចិត្តទៅនៅក្នុងថែវព្រះវិហារព្រះកែវមរកត ហើយនិងហាត់វិធីយុទ្ធសាស្ត្រខ្លះផង ។ ទាហានទាំងនោះមានចិត្តក្លាហានណាស់រហូតដល់លែងដឹងស្គាល់ទំនៀមទម្លាប់ខ្មែរ លែងគោរពទំនៀមខ្មែរ អ្នកខ្លះស្រែកឡេឡ ធ្វើឫកតាមបារាំងឱ្យហើយ ព្រោះជិតបានទៅស្រុកបារាំង ។

អ្នកខ្លះហាត់រៀនដើរពើងទ្រូងឱ្យហើយ ដើម្បីទៅដល់ស្រុកបារាំងកុំឱ្យឈ្លើយពេក រីឯអ្នកខ្លះទៀតហាត់និយាយបារាំង ។ ទាហានជាច្រើននៅក្នុងព្រះវិហារព្រះកែវ ធ្វើឱ្យទីវត្តអារាមបាត់សេចក្ដីស្ងប់ស្ងាត់ ។ តាមជំនឿរបស់អ្នកធ្លាប់តែជឿ ទាហានបារាំងដែលនៅក្នុងថែវវិហារព្រះកែវ មានខ្លះចុះអាចម៍ ខ្លះគ្រុនញាក់ញ័រ ព្រោះទាហានទាំងនោះមិនជឿវត្ថុសក្ដិសិទ្ធិ ។ តាមការសង្កេតមើលទៅនៅពេលនោះទាហានដែលចុះរាករូស គ្រុនញញីញញ័រច្រើនតែទាហានរប៉ិលរប៉ូច ឯទាហានដែលចេះគោរពស្គាល់ខុសត្រូវទំនៀមខ្មែរបានសុខសប្បាយរហូតច្បាំងឈ្នះបានត្រឡប់មកស្រុកវិញ ។ នៅពេលដែលទាហានចុះរាក ឈឺពោះជាដើមនោះ ទាល់តែមានធ្វើរៀបពិធីសូមខមាទោសវត្ថុសក្ដិសិទ្ធិ ទើបទាហាននោះលែងឈឺពោះ លែងមានគ្រុនរងា ។

ទាហាននាំគ្នាហាត់ដើរ ហាត់គំនាប់ ហាត់កាន់កាំភ្លើង រាល់ល្ងាចនៅថែវព្រះវិហារព្រះកែវនិងនៅខាងមុខបរមរាជវាំងរហូតដល់ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩១៦ ទើបនាំគ្នាចុះកប៉ាល់ទៅស្រុកបារាំង ។ ទាហានស្ម័គ្រចិត្តនាំគ្នាស្ពាយអីវ៉ាន់រណែងរណោងដើរចុះកប៉ាល់ ដោយមានញាតិមិត្តឈរមើលត្រៀបត្រា អ្នកខ្លះមកឈរឱ្យពរសព្ទសាធុការ អ្នកខ្លះឈរមើលកប៉ាល់ ។ ចំណែកនារីមានសង្សារត្រូវទៅដែរនោះ បានបង្ហូរទឹកភ្នែកបក់ដៃហៅសង្សារឱ្យត្រឡប់មកវិញឆាប់ៗ ហើយជាពិសេសលួចនិយាយនឹងអ្នកតាដងកើ ៖ “ សូមលោកតាជួយមើលសង្សារកុំឱ្យបាត់មរតកនៅស្រុកបារាំង ” ។ កប៉ាល់ផ្លុកទ័ពហើយ ទាញសញ្ញាបីដង ទើបស្ទូរយន្តធាក់ទឹកធ្វើឱ្យកប៉ាល់រេបត់មុខទៅតាមទន្លេមេគង្គ ឆ្ពោះទៅរកសមុទ្រ ។

[...] បន្ទាប់ពីកំណែននិងការទារពន្ធ នាម៉ឺនប្រជារាស្ត្រតាំងចាប់ក្ដៅចិត្តបន្តិចម្ដងៗ ជាហេតុនាំឱ្យកើតហេតុភេទខ្លះ ។ បារាំងធ្វើឱ្យខ្មែរក្ដៅក្រហាយតាំងពីប្រជារាស្ត្រ នាម៉ឺន ព្រះសង្ឃ ដូចនេះហើយបានជានៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩២១ វេលាយប់ នៅលើផ្ទៃអាកាសស្រាប់តែពពកប្រមូលផ្ដុំគ្នាឡើងខ្មៅ ហើយផ្លេកបន្ទោរឆុងឆាំងហាក់ដូចជាសន្មតគ្នាទុកជាមុន ។ អ្នកស្រុកភិតភ័យឱបកូនថៅដោយសារខ្លាចស្នូររន្ទះ ។ នៅវេលាម៉ោង ៩ យប់ ស្រាប់តែមានផ្លេកបន្ទោរភ្លែត ដូចជាគេពុះមេឃហើយបន្តិចមកស្នូរកញ្ជ្រើកធរណី ។ មិនយូរប៉ុន្មានសំឡេងពីមាត់មួយទៅមាត់មួយថា រន្ទះ

បាញ់ចេតិយព្រះវិហារព្រះកែវមរកតខាងត្បូង ។ ហេតុភេទនេះធ្វើឱ្យប្រជារាស្ត្រនាម៉ឺនមានចិត្តស្រពោន ព្រោះតាមជំនឿថានឹងមានកើតចលាចលឬមានកើតហេតុទុរភិក្សក្នុងស្រុក ។ បន្ទាប់ពីបះបោរមិនសុខចិត្តនឹងរឿងពន្ធ មានហេតុភេទមួយទៀត គឺផ្កាយដុះកន្ទុយជាយូរថ្ងៃ ។

[...] រីឯនៅលើកូនភ្នំតាបាំង ដែលលាតសន្ធឹងតាមបណ្ដោយព្រំប្រទល់ឃុំពង្រនិងឃុំក្រាំងលាវ ហាក់ដូចជាផ្ទះមួយខ្នងដំបូលប្រក់មេឃ ដែលចាំទទួលពួកអ្នកភៀសខ្លួនមកស្នាក់នៅ ។ ពេលយប់សន្ធិយា នៅលើកំពូលភ្នំនេះដូនចាស់ខ្លះ ដែលមានអាយុប្រមាណចិតសិបប្លាយឡើងលើខំប្រឹងអុជធូបថ្វាយបង្គំបន់ព្រះសំពះទេពតា សុំឱ្យជួយថែរក្សាកូនចៅផៅសន្ដានរបស់ខ្លួន ឱ្យបានផុតពីការចាប់ធ្វើបាបនៃពួកទាហានអាណានិគម ។ ដូនចាស់ខ្លះទៀតខំប្រឹងខ្វេះកកាយដីតាមចង្កេះភ្នំ យកមករោយលើក្បាលបួងសួងនឹកគុណព្រះនាងគង្ហីងធរណី សុំឱ្យជួយបង្វែងដានបំបាំងភ្នែកពួកទាហានកុំឱ្យចោលភ្នែកមកឃើញភ្នំតាបាំងនិងកុំឱ្យដើរមកចំភ្នំតាបាំង ។ [...]

*(ដកស្រង់ចេញពីរឿង ភូមិតិរច្ឆាន វគ្គទី២-៣ និង ៧ ឆ្នាំ ១៩៦៤-៦៥ អ្នកនិពន្ធ ឌឹក គាម និងឌឿក អំ បោះពុម្ពជាសាធារណៈនៅឆ្នាំ ១៩៧១ បោះពុម្ពដោយក្រសួងអប់រំនៅ ឆ្នាំ ១៩៨៧)*

## សំណួរ

១. តើអត្ថបទនេះ បានបង្ហាញពីសង្គមខ្មែរនាសម័យកាលណាមួយ ?

២. ដោយផ្អែកលើសង្គមបរិយាកាសនៃរឿង តើកត្តាអ្វីដែលនាំឱ្យអាណានិគមបារាំង កេណ្ឌរាស្ត្រខ្មែរយកទៅធ្វើជាទាហាន ? ទង្វើបែបនេះត្រឹមត្រូវឬទេ ? ហេតុអ្វី ?

៣. ដោយឆ្លុះតាមរយៈអត្ថបទដកស្រង់នេះ តើក្នុងសម័យកាលនោះ ប្រជារាស្ត្រមានជំនឿទៅលើអ្វីខ្លះ ?

៤. ដូចម្ដេចដែលហៅថា ទំនាស់ ? ចូរសិក្សាពីទំនាស់និងវិភាគតួអង្គក្នុងអត្ថបទដកស្រង់នេះ ។

៥. ចូរអ្នកសិក្សាពីវិធីតែងនិពន្ធសំខាន់ៗ ដែលអ្នកនិពន្ធបានប្រើក្នុងអត្ថបទដកស្រង់នេះ ។

៦. ចូរជ្រើសរើសពាក្យមួយព្យាង្គ ដែលមានថ្នាក់ពាក្យជានាម ក្នុងអត្ថបទនេះ ដើម្បីសរសេរជាសញ្ញាកត់សូរអន្តរជាតិ ( API ) ចំនួន ១០ពាក្យ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

# រឿងពិធីសុំទឹកភ្លៀង



ក្នុងការស្ដាប់អត្ថបទ ចូរអ្នកកត់ត្រាព្រឹត្តិការណ៍សំខាន់ៗដែលមាននៅក្នុងអត្ថបទនោះពីព្រោះព្រឹត្តិការណ៍ទាំងនោះបានជួយយើង ឱ្យយល់ពីខ្លឹមសារអត្ថបទ ។

តទៅនេះចូរអ្នកស្ដាប់អត្ថបទ "រឿងពិធីសុំទឹកភ្លៀង" ដើម្បីត្រៀមឆ្លើយសំណួរដូចខាងក្រោមនេះ ៖

## សំណួរ

១. បើតាមចំណងជើងខាងលើនេះ តើរឿងនេះនិយាយពីអ្វី ?

២. តើមានព្រឹត្តិការណ៍អ្វីខ្លះដែលនាំឱ្យមានពិធីនេះកើតឡើង ?

៣. តើព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់យោនយកកំណើតជាសត្វអ្វី ? នៅកន្លែងណា ?

៤. ឆ្លៀតឱកាសនៃការរីងស្ងួតបឹងត្រពាំង តើសត្វកុក ត្មាត និងក្រសារមានឥរិយាបថយ៉ាងណាខ្លះ ?

៥. ដើម្បីទប់ស្កាត់នឹងអំពើរបស់សត្វកុក ត្មាត និងក្រសារ តើស្ដេចត្រីរ៉ស់ មានវិធានការយ៉ាងដូចម្ដេចខ្លះ ? ចូរបង្ហាញ ។

៦. បើតាមអត្ថបទនេះ តើប្រជារាស្ត្រខ្មែរមានជំនឿយ៉ាងណាខ្លះ ? ចូរគូសបញ្ជាក់ ។

# សម្របសម្រួលក្នុងក្រុមពិភាក្សា ឬអង្គពិធីសំខាន់

សម្របសម្រួល គឺជាការរៀបចំចាត់ចែងសម្រួលនៅក្នុងដំណើរនៃការប្រជុំ ការពិភាក្សា សិក្ខាសាលា ឬពិធីផ្សេងៗ។ ដើម្បីញ៉ាំងឱ្យពិធីប្រព្រឹត្តទៅដោយភាពរលូននិងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុកនោះ គឺទាមទារឱ្យមានអ្នកសម្របសម្រួលប្រកបដោយសមត្ថភាពខ្ពស់។

សមត្ថភាពសម្របសម្រួលទាំងនោះមានដូចជា ៖

- ចាត់ចែងកម្មវិធី
- មានចំណេះដឹងទូទៅនិងចំណេះដឹងលើប្រធានបទទូលំទូលាយ
- មានឥរិយាបថសមសួន
- សម្ដីសំដៅសមរម្យម៉ត់ចត់
- មានបំណិនក្នុងការសម្របសម្រួល ។

បំណិនសម្របសម្រួលមាន :

## ១ . ការប្រើពាក្យសម្ដី

### ក. ការប្រើពាក្យសម្ដី

- សូមអធ្យាស្រ័យ ខ្ញុំបាទ ឬនាងខ្ញុំសូមជួយបន្ថែមត្រង់ចំណុច ............
- ក្នុងនាមជាអ្នកសម្របសម្រួល ខ្ញុំបាទ ឬនាងខ្ញុំសូមរំលឹកថា ប្រធានបទយើងថ្ងៃនេះ ......
- ជាការសមស្របហើយ !ប្រសិនបើយើង (អស់លោក ...) ធ្វើការពិចារណាតទៅទៀត ...
- មិនថ្វីទេត្រង់ចំណុចនេះ ! ព្រោះបើតាមរបៀបវារៈអង្គប្រជុំនៅថ្ងៃនេះ ........
- តាងនាមឱ្យអ្នកសម្របសម្រួល ខ្ញុំបាទ ឬនាងខ្ញុំសូមឱ្យអង្គពិធី (អង្គប្រជុំ ...) មេត្តាងាកមករកប្រធានបទខាងដើម ហើយសូមសមាជិកឡើងបញ្ចេញយោបល់ ...................
- ............................................................................ ។

### ខ. សំនួនយល់ព្រម

- គំនិតនេះពិតជាត្រឹមត្រូវ .............................
- ជាការពិតណាស់ ប្រសិនបើ .........................
- មែនហើយ ការពិតនៅតែជាការពិត ព្រោះ ........
- ខ្ញុំសូមគាំទ្រ ..........................................
- ត្រឹមត្រូវហើយ .......................................
- ............................................................................ ។

### គ. សំនួនមិនយល់ព្រម

- ប្រសើរណាស់ប៉ុន្តែ ......................
- យើងគួរពិចារណាលើចំណុចផ្សេងវិញ ...............
- យើងគួរងាកមករកប្រធានបទយើងវិញ ..............
- តាមគំនិតអស់លោក លោកស្រីលើកខាងលើនេះ សមម្យ៉ាងដែរ តែ ...........
- តាមមតិលោក លោកស្រីក៏ត្រឹមត្រូវដែរ តែគំនិតលោក-លោកស្រីខាងនេះច្បាស់លាស់ជាង .................
- ............................................................. ។

## ២ . ការប្រើប្រាស់ពេលវេលា

គឺមានការបែងចែកឱ្យបានសមស្របទៅតាម ៖

- ទំហំនៃខ្លឹមសារប្រធានបទ
- កាលវេលានៃការបកស្រាយ
- ការសាកសួរខ្លឹមសារ ឬបន្ថែមលើខ្លឹមសារប្រធានបទ ពីសំណាក់អ្នកចូលរួមស្តាប់
- ................................................................... ។

## ៣ . សំយោគ

គឺជាការប្រមូលខ្លឹមសារកិច្ចពិភាក្សាដោយ ៖

- បញ្ចូលគ្នានូវគំនិត ឬទស្សនៈវិជ្ជមានក្នុងប្រធានបទ
- បង្ហាញពីមូលហេតុនៃការទទួលយក ឬមិនទទួលយកគំនិតណាមួយនោះ

## ៤ . សន្និដ្ឋាននិងសរុប

- ទាញយកអត្ថន័យសំខាន់ពីកិច្ចពិភាក្សាលើប្រធានបទនោះ (ក្នុងសង្គម សហគមន៍ គ្រួសារ)
- លើកទឹកចិត្តនិងថ្លែងអំណរគុណអ្នកចូលរួមគ្រប់និន្នាការសមាសភាព (ទាំងគំនិតគាំទ្រនិងទាំងគំនិតមិនគាំទ្រ) ។

### លំហាត់

បន្ទាប់ពីបានស្តាប់សំនួនខាងលើនេះហើយ ចូរអ្នកបែងចែកជាក្រុមដើម្បីពិភាក្សាគ្នា ដោយក្រុមនីមួយៗ ត្រូវមានអ្នកសម្របសម្រួលម្នាក់ ក្នុងការដឹកនាំពិភាក្សា ។

# តែងសេចក្ដីពន្យល់

អ្នកបានសិក្សាអំណានទី ២ "តថភាពនាសម័យអាណានិគមនិយម" រួចមកហើយ ។ តទៅនេះ ចូរអ្នកលើកអត្ថបទខាងលើមកធ្វើសំណេរតែងសេចក្ដីពន្យល់ ដែលមានប្រធានបទដូចខាងក្រោម :

**ប្រធាន :** មានពំនោលមួយឃ្លាថែង ៖ "ក្នុងអត្ថបទ តថភាពនាសម័យអាណានិគមនិយមបានឆ្លុះឱ្យឃើញពីផ្នត់គំនិតជំនឿខ្មែរ" ។ ចូរអ្នកធ្វើការពន្យល់ ដោយរកឧទាហរណ៍ក្នុងអត្ថបទមកបញ្ជាក់ ។

ដោយស្ថិតក្រោមឥទ្ធិពលនៃធម្មជាតិនាសម័យបុរាណ មនុស្សតែងតែព្យាយាមបកស្រាយរាល់បាតុភូតធម្មជាតិ ស្របទៅតាមការយល់ដឹងរបស់ខ្លួន ។ រាល់បំណកស្រាយនីមួយៗ ពេលខ្លះក៏មានលក្ខណៈវិទ្យាសាស្ត្រ តែពេលខ្លះទៀតពុំអាចបកស្រាយបាន ហើយនាំឱ្យគេមានជំនឿថានឹងមានកម្លាំងអានុភាពណាមួយជំរុញឱ្យកើតមានជាបាតុភូតនោះឡើង ។ តើក្នុងអត្ថបទ "តថភាពនាសម័យអាណានិគមនិយម " បានឆ្លុះឱ្យឃើញពីជំនឿរបស់ខ្មែរដូចម្ដេចខ្លះ ?

តើជំនឿដែលមាននៅក្នុងអត្ថបទខាងលើនេះ ខ្មែរយើងនិយមជឿទៅលើអ្វីខ្លះ ?

ដើម្បីជាគុណប្រយោជន៍ ដល់ការបកស្រាយគំនិតប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុនសិន ។ ពាក្យ "ជំនឿ" មានន័យថា ជាការជឿជាក់ទៅលើអ្វីមួយ ដែលស្ដែងចេញតាមរយៈ ការយល់ដឹងរបស់បុគ្គលនីមួយៗ ឬជាតិនីមួយៗ ។ តាមគំនិតប្រធាន មានន័យថា ក្នុងអត្ថបទអំណានទីពីរ ដែលមានចំណងជើងថា តថភាពនាសម័យអាណានិគមនិយម បានឆ្លុះឱ្យឃើញពីការជឿរបស់ខ្មែរ មានតាំងពីដើមរៀងមក ។

ជាការពិត បើនិយាយពីជាតិសាសន៍ដែលមានក្នុងលោកយើងនេះ គ្មានជាតិសាសន៍ណាមួយគ្មានការជឿទៅលើអ្វីមួយនោះឡើយ ។ ដោយហេតុថា វិស័យជំនឿជាការឆ្លុះបញ្ចាំងពីផ្នត់គំនិតជាតិសាសន៍នោះ ក្នុងទិដ្ឋភាពអរិយធម៌ជាតិខ្លួនយ៉ាងច្បាស់អំពីទស្សនៈ ចិត្តគំនិត ការរស់នៅពីបុរាណកាលជាដើម ។ យ៉ាងនេះហើយ ទើបអ្នកនិពន្ធយើង បានតាក់តែងជាអត្ថបទ "តថភាពនាសម័យអាណានិគមនិយម" ដោយភ្ជាប់មកនូវជំនឿផ្សេងៗរបស់ប្រជារាស្ត្រខ្មែរ នាសម័យអាណានិគមនិយមបារាំង មកបង្ហាញស្របទៅតាមតថភាពនាសម័យកាលនោះ ។ តួយ៉ាង ខ្មែរយើងនិយមគោរពនិងមានជំនឿទៅលើវត្ថុដែលមាននៅតាមទីអារាមនានា ។ បើគេប្រព្រឹត្តល្មើសដោយប្រការណាមួយមិនគោរពវត្ថុសក្ដិសិទ្ធនោះគេនឹងទទួលផលអាក្រក់ជាមិនខាន គឺត្រូវគ្រុនញាក់ញ័រ ឬមួយត្រូវរាកចុះជាដើម ។ ដោយហេតុនេះហើយ ទើបនៅក្នុងអត្ថបទខាងលើគេឃើញថា ក្រោយពីបារាំងរើសទាហានខ្មែរបានល្មមគ្រប់ចំនួន គេក៏បានបញ្ជូនទាហានស្ម័គ្រចិត្តទាំងនោះ ទៅនៅក្នុងថែវព្រះកែវមរកត ។ ពួកគេបានស្រែកឡូឡាធ្វើឱ្យទីវត្តអារាមបាត់សេចក្ដីស្ងប់ស្ងាត់ "ខ្លះចុះអាចម៍ ខ្លះគ្រុនញាក់ញ័រ ព្រោះទាហានទាំងនោះមិនជឿវត្ថុសក្ដិសិទ្ធ ..." ។ តាមជំនឿរបស់អ្នកស្រុក បើចង់ជាសះស្បើយ

ទាល់តែធ្វើពិធីសូមខមាទោសចំពោះវត្ថុសក្តិសិទ្ធ ។ ចំពោះជំនឿនេះ ត្រូវបានប្រជារាស្ត្រខ្មែរប្រកាន់ត រៀងមករហូតបច្ចុប្បន្ន ហើយតែងតែមានប្រគំភ្លេងពិណពាទ្យ ថ្វាយដល់វត្ថុសក្តិសិទ្ធ ហៅថាលា បំណន់ថែមទៀត ។ ជាមួយគ្នានេះដែរ ខ្មែរយើងនៅមានជំនឿទៅលើអ្នកតាថែមទៀត ។ ជាក់ស្តែង ពេលសាច់ញាតិមកជូនដំណើរក្រុមទាហានខ្មែរកំណែនទៅប្រទេសបារាំង មាននារីខ្លះបានបង្ហូរទឹក ភ្នែកអាលោះអាល័យ ខ្លះលួចបន់ស្រន់នឹងអ្នកតាដងកើ "សូមលោកតាជួយមើលសង្សារកុំឱ្យបាត់ មរកតនៅស្រុកបារាំង" ។ ក្រៅពីជំនឿខាងលើនេះ គេនៅនិយមជឿទៅលើអព្ភូតហេតុធម្មជាតិ ដែល មានផ្កាយដុះកន្ទុយ ឬរន្ទះបាញ់ជាដើម ។ ជំនឿនេះ ក៏បានចាក់ចូលទៅក្នុងផ្នត់គំនិតខ្មែរដែរ ។ ក្នុងករណីដែលពួកអាណានិគមនិយមបារាំង បានគាបសង្កត់ក្នុងការទារពន្ធ ធ្វើឱ្យរាស្ត្រ នាម៉ឺនមិន សប្បាយចិត្ត ព្រោះពួកគេពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរកប្រាក់បង់ពន្ធឱ្យបានគ្រប់គ្រាន់នោះទេ ។ ស្របជាមួយគ្នានោះនៅវេលាម៉ោង ៩ យប់ស្រាប់តែមានផ្លេកបន្ទោរ ដូចគេពុះមេឃហើយបន្លិចមក ស្ទួរស្ទើរតែកក្រើកធរណី ។ តាមជំនឿ " ...នឹងមានកើតចលាចល ឬមានកើតហេតុទុរភិក្សក្នុងស្រុក" ជាមួយគ្នានោះក៏កើតមានផ្កាយដុះកន្ទុយទៀតផង ។ បើយោលទៅតាមអត្ថបទដដែលនេះ គេឃើញ មានជំនឿមួយទៀតរបស់ខ្មែរ គឺការគោរពចំពោះទេវតា ឬអាទិទេព ដោយចាស់ៗដែលគាត់បានគេច ខ្លួនទៅសំងំលើភ្នំតាបាំង ព្រោះភិតភ័យនឹងទាហានបារាំងដេញតាមប្រមាញ់ចាប់នោះ ក៏បានយកដីមក រោយលើក្បាល ដើម្បីឱ្យព្រះធរណីមកជួយបិទបាំងភ្នែកសត្រូវកុំឱ្យមើលពួកគាត់ឃើញ ឬឱ្យគេច ចេញពីសត្រូវ ។ សមដូចអ្នកនិពន្ធបានបរិយាយ "ដូនចាស់ខ្លះទៀតខំប្រឹងខ្វេះកកាយដីតាមចង្អៀកថ្មភ្នំ យករោយលើក្បាលបួងសួងនឹកគុណព្រះនាងគង្ហីងធរណី សុំឱ្យជួយបង្វែងដានបំបាំងភ្នែកពួកទាហាន កុំឱ្យចោលភ្នែកមក ..." ។

សរុបសេចក្តីមកចំណុចសំខាន់ៗខាងលើនេះ សុទ្ធសឹងជាជំនឿរបស់ប្រជារាស្ត្រខ្មែរនាសម័យ អាណានិគមនិយមបារាំង ។ ជំនឿទាំងនេះ បានចាក់ឫសចូលជ្រៅទៅក្នុងផ្នត់គំនិតខ្មែររហូតសព្វថ្ងៃ នេះទៀតផង ។

ឆ្លងតាមការបកស្រាយខាងលើនេះ គេឃើញថា ទស្សនៈប្រធានពោរពេញទៅដោយអត្ថន័យ សំខាន់ឆ្លុះឱ្យឃើញពីតថភាពសង្គមខ្មែរ ដែលតែងតែប្រកាន់ខ្ជាប់នូវជំនឿផ្សេងៗ ខុសពីជាតិដទៃលើ លោកយើងនេះ ។ បន្ថែមពីនេះទៀត គំនិតប្រធានក៏កាន់តែធ្វើឱ្យគេបានស្គាល់ពីវប្បធម៌ជាតិខ្មែរនិង បានស្គាល់ពីផ្នត់គំនិតខ្មែរ ដែលមានតាំងពីយូរណាស់មកហើយនោះ ។

facebook.com/krouyeng.moeys.gov.kh youtube.com/moeys krou.moeys.gov.kh

## សំណួរ

១. តើអត្ថបទសំណេរនេះមានប៉ុន្មានកថាខណ្ឌ ?

២. តើកថាខណ្ឌនីមួយៗ និយាយពីអ្វី ?

៣. ចូរអ្នកសិក្សាគម្រោងតែងសេចក្ដីនេះឡើងវិញ ក្រោយពីអ្នកបានអានរួចមក ។

## លំហាត់

ចូរអ្នកសរសេរតែងសេចក្ដីប្រធានពន្យល់តាមប្រធានបទណាមួយ ដែលអ្នកពេញចិត្ត :

១. មានទស្សនៈមួយថែង ៖ "ក្នុងរឿងបណ្ដែតប្រទីប សំពះព្រះខែ អកអំបុក បានបង្ហាញពីជំនឿរបស់ជនជាតិខ្មែរ" ។ ចូរពន្យល់ដោយលើកឧទាហរណ៍មកបញ្ជាក់ ។

២. គំនិតជាតិនិយមមួយឃ្លាយល់ ៖ "តាមរយៈវិស័យជំនឿ នាំគេឱ្យស្គាល់ពីលក្ខណៈជាតិ" ។ ចូរពន្យល់ដោយលើកយកឧទាហរណ៍មកបញ្ជាក់ ។

៣. តាមទស្សនៈរបស់បុព្វបុរសខ្មែរ មួយឃ្លាថែង ៖ "ផ្នត់គំនិតជាតិ គឺជាអត្តសញ្ញាណជាតិ" ។ ចូរពន្យល់ដោយរកអំណះអំណាងមកបញ្ជាក់ ។

ដើម្បីជំរុញឱ្យសំណេរតែងសេចក្ដីពន្យល់របស់អ្នកមានអត្ថន័យល្អបាន អ្នកគប្បីអនុវត្តតាមគម្រោងខាងក្រោមនេះ :

### គម្រោងតែង

## ១ . សេចក្ដីផ្ដើម

- លំនាំបញ្ហា : និយាយឱ្យទាក់ទងនឹងប្រធានបទ ។
- ចំណូលបញ្ហា : បញ្ចូលប្រធានបទ ។
- ចំណោទបញ្ហា : បំផុសជាបញ្ហាចោទ ។

## ២ . តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី : ជាការភ្ជាប់ឃ្លា ឬល្បះពីផ្ដើមសេចក្ដី មកតួសេចក្ដី ។
- ពន្យល់ពាក្យ : ជាពាក្យគន្លឹះសំខាន់ៗ ។
- បកស្រាយ : លើកយកប្រធានបទមកធ្វើការបកស្រាយ ដោយមានគំនិតសំខាន់គាំទ្រ ។

- គំនិតសំខាន់ទី ១
- គំនិតសំខាន់ទី ២
- គំនិតសំខាន់ទី ៣
- គំនិតសំខាន់ទី ៤
- គំនិតសំខាន់ទី ................................. ។

ឧទាហរណ៍បញ្ជាក់ ៖ គាំទ្រទៅលើគំនិតសំខាន់ខាងលើ ។

- ក្នុងសង្គម
- ក្នុងអក្សរសិល្ប៍ ។
- ................. ។

• សរុប ៖ បូកសរុបទៅលើការបកស្រាយរួចមកហើយនេះ ។

## ៣ . សេចក្ដីបញ្ចប់

• សន្និដ្ឋានលើទស្សនៈប្រធាន ៖ ជាការឆ្លុះចេញពីការសិក្សាថា តើប្រធានមានឥទ្ធិពល ឬមានតម្លៃយ៉ាងណាខ្លះចំពោះសង្គម ?

• មតិផ្ទាល់ខ្លួន ៖ ជាបទពិសោធនៃប្រធានបទ ក្នុងការផ្ដល់ដំបូន្មាន ឬការអប់រំ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# បទានុក្រមភាសាខ្មែរ

## ថ្នាក់ទី ១០

### ក

- កង្វេរ [កង់វេ] ន : ប្រដាប់មានផ្លែក្ងក់ធ្វើដោយដែកមានដងធ្វើពីឈើសម្រាប់ការជីរ ។
- កតញ្ញុតាធម៌ [កៈតាញ់-ញុ-តា-] (បាសំ) ន : សេចក្ដីដឹងឧបការគុណដែលអ្នកដទៃធ្វើដល់ខ្លួន ។
- កណ្ហាជិនា [កាន់ ណាជិនា] ន : ឈ្មោះព្រះរាជធីតានៃព្រះវេស្សន្តរមានក្នុងមហាវេស្សន្តរជាតក ។
- កិត្យានុភាព (បាសំ) ន : អានុភាពនៃកេរ្តិ៍ឈ្មោះ ភាពល្បីល្បាញ ។
- កៅទ័ណ្ឌសហស្សថាម [កៅទាន់សៈហ័សថាម] ន : ធ្នូដែលមានទម្ងន់បុរស ១០០០នាក់ទើបលើករួច ។
- ក្ទម្ព [ខ្ទុម] ន : ឈ្មោះឈើមួយប្រភេទដែលមានផ្កាចេញមកសណ្ឋានដូចផ្លែតែម្ដងដូចផ្កាថ្កូវ... ។ ឈើនេះច្រើនដុះនៅដីទំនាប ឬទីត្រពាំងអ្នកស្រុកច្រើនយកត្រួយវាធ្វើជាថ្នាំទាស់ ។
- ក្រសាល (រ.ស) កិ : លេង លំហើយ ។
- ក្រចៅ ន : ឈ្មោះឈើមួយប្រភេទមានផ្លែបរិភោគបាន ។
- ក្រវាន់ [ក្រវ៉ាន់] ន: ឈ្មោះឈើមួយប្រភេទមានផ្កាក្រអូបឈ្ងុយស្រដៀងក្លិនផ្កាចេកនួនទុំ ។
- កប់ក្ដោង [កប់ក្ដោង] គុ : សន្ធឹកសន្ធាប់ ច្រើនហួសពីការស្មាន ។
- ក្ដួច ន : ឈ្មោះវល្លិមើមមួយប្រភេទដើមមានបន្លា មើមមានពិសពុលហើយរមាស់ផង តែបើបន្សាបចេញបរិភោគបាន ។
- កណ្ដោលបាត ន : ឈ្មោះឈើមួយប្រភេទស្លឹក ផ្លែ និងក្លិនប្រហែលគ្នានឹងកណ្ដោលធំ តែដើមតូចទាបកំពស់ស្មើដើមស្ពៃ ។
- ក្រូម៉ាញ៉ុង (បា រ) ន : ឈ្មោះតំបន់មួយដែលគេរកឃើញគ្រោងឆ្អឹងមនុស្ស មានរូបរាងដូចគ្នានឹងមនុស្សបច្ចុប្បន្ន ។
- ក្សេមក្សាន្ត [ក្សេម ក្សាន] គុ : ដែលមានសេចក្ដីសុខសាន្ត ។
- ក្លស់ ន : ឆត្រមានកំពូលនិងរំភាយ ឬមានតែកំពូលអត់រំភាយក៏មាន ។
- កា (អង់គ្លេស gear) ន : លេខ ស្ពឺចក្រ ។

facebook.com/moeys.gov.kh youtube.com/moeys krou.moeys.gov.kh

- កាសិកព័ស្ត្រ [កាសិកៈព័ស] ន : សំពត់ជ្រលក់ទឹកអម្ចត់ពណ៌លឿងសម្រាប់សមណៈក្នុងព្រះពុទ្ធសាសនាប្រើប្រាស់ ។
- កោមល [កោម៉ល់] ន : (ក្លាយមកពីពាក្យកមល) ផ្កាឈូក ដួងចិត្ត បេះដូង ។

ខ

- ខ្ទឹង ន : ឈ្មោះឈើមួយប្រភេទសម្បកនិងផ្លែវាធ្វើជាប្រេងបានផ្កាពណ៌សក្រអូប ។
- ខ្លោះ ពាក្យបុរាណ កំលោះ ។

គ

- គម្ពីរ [គុមពី] ន : សាស្ត្រា ច្បាប់ ធម្មវិន័យ ដែលរួបរួមដោយពួក ដោយប៉ែក ដោយផ្នែក ។
- គម្ពីរព្រះត្រៃបិដក [ត្រៃបីដក់] ន : ឈ្មោះគម្ពីរទាំងបីនៃពុទ្ធសាសនាគឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ។
- គោចរ ន : ដំណើរត្រាច់ចរ ។
- គោបុរៈ ន : ខ្លោងទ្វារ ។
- គីរីវង្កត [គីរីវង់កត់] ន : ឈ្មោះភ្នំមួយក្នុងពួកភ្នំហិមពាន្ត ភ្នំវង្កត (ភ្នំមានសណ្ឋានវៀច) ។
- គុលិកា [គុ លិកា] ន : ដុំមានសណ្ឋានមូលតូចៗ ដុំថ្នាំរម្ងាប់រោគដែលគេលញ់ជាគ្រាប់មូលតូចៗសម្រាប់លេប ។
- គុណធម៌ ន : ធម៌ដែលមានដំណើរចម្រើននិងធម៌ដែលមានសេចក្ដីសុខ ។
- គុយ [គុយ] ន : ឈ្មោះឈើតូចមួយប្រភេទ មានដើមជាវល្លិ ផ្លែមានរសផ្អែមលាយជូរ ប្រើជាអាហារ ។
- គូទឹក ន : ស្នាមភ្លោះព័ទ្ធជុំវិញបន្ទាយឬវាំង ។
- គ្រលរ គុ : ដែលនិយាយមិនច្បាស់ វិលវល់នៅដើមក ។

ច

- ចងសម្ព័ន្ធមេត្រី កិ : ចងភ្ជាប់គ្នា ទាក់ទងគ្នាជាមិត្ត ។
- ចរន្ត ន : ដំណើររត់ ឬហូរ ។
- ចរ [ច] កិ : ដើរ ត្រាច់ ទៅ ប្រព្រឹត្ត ។
- ចតុរង្គ [ចៈតុរ៉ង់ ឬ-រ៉ុង] គុ ឬ ន : ដែលមានអង្គ៤ កងទ័ពមានអង្គ៤គឺ កងទ័ពដំរី កងទ័ពសេះ កងទ័ពរថ ឬរទេះ កងទ័ពថ្មើរជើង ។
- ចង្ហាន់ [ចង់ ហាន់] ន : អាហារសម្រាប់បព្វជិតក្នុងពុទ្ធសាសនា ។

- ចក្ខុ [ចាក់ខុ] ន : អាយតនៈសម្រាប់មើល សម្រាប់ឃើញរូបផ្សេងៗ (ភ្នែក) ។
- ចក្រ [ចាក់] ន : អ្នកមានចក្រ អ្នកទ្រទ្រង់ចក្រ ងារសេនាបតីក្នុងកម្ពុជរដ្ឋ ។
- ចង្ក្រនាត [ចង់អ្រូត្នាត] ន : ឈ្មោះឈើមួយប្រភេទ មានសាច់រឹងប្រើជាសសរផ្ទះជាប់ល្អ ប៉ុន្តែពិបាកអារនិងពិបាកឈូស ។
- ចារបុរស ន : អ្នកស៊ើបការណ៍សម្ងាត់ ។
- ចិត្តយក្សយង់ ន : ចិត្តកំណាចឃោរឃៅ ។
- ចិញ្ចឹមឆ្នាំង [ចិញចឹមឆ្នាំង] ន : មុខរបរមួយពេលសម្រាប់តែមួយពេល ។
- ចុងបូព៌ា ន ប៉ែកខាងកើត ។
- ចុល្លព្រឹក្ស (បាសំ) ន : ដើមឈើតូចៗ ។
- ចេស្តា [ចេស ស្តា] ន : ការសំដែងឬកពាឱ្យឃើញតេជៈអំណាច ការប្រើអំណាចបញ្ចេញតេជៈ ។
- ច្រកែងទួយ [ច្រកែង តួយ] ន : ឈ្មោះឈើព្រៃម៉្យាងសម្រាប់ធ្វើឧសដុត ។

**ឆ**

- ឆព្វណ្ណរង្សី [ឆ័ព-ព័ណ-ណៈរ័ងសី] ន : រស្មី ៦ ពណ៌ខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេក ។
- ឆន្ទៈ [ឆ័នទៈ] ន : សេចក្តីប្រាថ្នា បំណង គំនិត ការយល់ព្រម ។
- ឆ្កែស្រែង ន : ឈ្មោះឈើមួយប្រភេទសម្បកក្រាស់សាច់ធូរជ្រោកច្រើនប្រើជាថ្នាំបង្កុយដំបៅ ឬរបួស កោសលាយនឹងថ្នាំឯទៀត ឬជក់កែរោគរឹស ឬសដូងខ្យល់ ។

**ជ**

- ជង្ឃ (បាសំ) ន : ស្មងជើង ជង្គង់ ។
- ជ្រៃ ន : ឈ្មោះឈើមួយប្រភេទពួកទ្រាំង ពួកត្នោត សាច់ក្នុងដើមគេបុកច្រោះយកជាម្សៅប្រើការជានំបានច្រើនយ៉ាង នំលតម្សៅជ្រៃ ។
- ជ្រៃ ន : ឈ្មោះឈើមានជ័រពពួកដើមពោធិ៍ ពួកល្វាមានពួររយឹករយាកឬសព័ទ្ធព័ន្ធ ហើយមានច្រើនប្រភេទដូចជា ជ្រៃពោធិ៍ ជ្រៃក្រឹម ជ្រៃលៀប ជ្រៃត្រាង ជ្រៃវល្លិ ។

**ឈ**

- ឈើស្ទន់ ន : ឈើចាក់ធ្មេញ ឬប្រដាប់សម្រាប់ជម្រះធ្មេញ ។

ដ

- ដង្កោ [ដង់ កោ] ន : ឈ្មោះឈើមួយប្រភេទ ផ្លែមូលៗមានរសជាតិចត់សម្រាប់ប្រើជាគ្រឿងជ្រលក់ ឬយកមកផ្សំជាអាហារក៏បាន ។
- ដកព [ដក ព] ន : ឈ្មោះឈើមួយប្រភេទមានសាច់ស្វិត ហៅក្លាយដក់ពក៏មាន ។
- ដីសណ្ដ ន ដែនដីដុះ ។

ឌ

- ឌ្រីយ៉ូពីតែក ន : អង់ត្រូប៉ូម័ពដែលបង្កើតជាភីលូម ៣ ដែលបន្តមកស្វាកូរី ស្វាឌី មនុស្ស ។

ត

- តបៈ [តៈប៉ៈ] ន : ការប្រព្រឹត្តកាន់វត្តយ៉ាងតឹង ដើម្បីធ្វើកាយនិងចិត្តឱ្យស្ងប់ ។
- តេជះ [ដែកជៈ] ន : អំណាច អានុភាព ។
- តិចសាស (អង់គ្លេស) ន : ឈ្មោះរដ្ឋមួយនៃសហរដ្ឋអាមេរិក ។
- តុសិត [ដុះសិត] ន : ឈ្មោះឋានកាមាវចរសួគ៌ ជាន់ទី៤ ។
- តុបតិន ន : ការពាក់ព័ន្ធ ណែងណង ។
- តូរ្យតន្ត្រី [ដូរដន់ត្រី] ន : គ្រឿងភ្លេងដេញ ដំ ផ្លុំ កូត ។
- ត្រៀល ន : ឈ្មោះឈើព្រៃមានផ្លែប្រើជាអាហារបាន ត្រៀលមានពីរប្រភេទ : ត្រៀលដោះក្របី មានដើមជាវល្លិឡើងតោងនឹងឈើឯទៀត ផ្លែមានទំនងស្រដៀងដោះក្របី ផ្លែជាចង្កោម ។ ត្រៀលល្វាដុះជាគុម្ពមានដើមតូចៗផ្លែជាចង្កោមតែតូចៗ ។
- ត្របែក ន : ឈ្មោះឈើពួកមួយប្រភេទផ្លែមានរសជាតិជូរផ្អែម ជាដំណាំ ឬដុះឯងតាមព្រៃក្បែរភូមិ ។
- ត្រែស័ង្ខ [ត្រែសាំង] ន : គ្រឿងភ្លេងធ្វើពីខ្យងស័ង្ខ ។
- ត្រឹកៗ គុ : ដែលមានលំនាំជ្រំៗតិច ។
- ត្រស់ ន : ឈ្មោះឈើរនាមមួយប្រភេទត្រួយមានរសជាតិចត់ ប្រើជាថ្នាំរមាស់កមក៏បាន ។
- ត្រៀក ន : ឈ្មោះឈើម្យ៉ាងច្រើនដុះនៅមាត់សមុទ្រឬព្រៃភ្នំ ។

ថ

- ថាមពលអគ្គិសនី (បា) ន : កម្លាំងដ៏លើសលប់ដើរដោយកម្ដៅឬភ្លើង ។
- ថ្វាន់ ន : ឈ្មោះឈើមួយប្រភេទសណ្ឋានទន្លា តែដុះនៅដីគោក ដំបូកទួល ត្រួយនិងផ្កាជ្រក់ធ្វើជាអាហារបាន ។

- ថែវ ន : រោងជួរមានសណ្ឋានវែងបរិវេណ ។

**ទ**

- ទស្សនវិស័យ [ទះសះនះវិសៃ] ន : ដំណើរគំនិតដែលយល់ឃើញ ។
- ទសទិសា [ទោះទិសា] ន : ទិសទាំង ១០ ។
- ទត [ទត] កិ : មើល (រ.ស) ។
- ទានបារមី [ទានបារះមី] ន : ឈ្មោះបារមីទី ១ ក្នុងបារមីទាំង ១០ ។
- ទិវា [ទិវា] ន : ថ្ងៃ ។
- ទិន (បាសំ) ន : ថ្ងៃ ។
- ទិព្វ [ទិព] គុ : ដែលជារបស់ទេវតា ដែលទាក់ទងពួកទេវតា ដែលមានក្នុងញាណទេវតា ដូចជា : ត្រចៀកទិព្វ ឱសថទិព្វ ។
- ទឹកដៃ (បាសំ) ន : ស្នាដៃល្អ ទេពកោសល្យល្អ ការប៉ិនប្រសប់ ។
- ទុរភិក្ស (បាសំ) ន : ការអត់ឃ្លាន ។
- ទុរគតភាព ន : ភាពក្រខ្សត់ ។
- ទុរគត (បាសំ) គុ : ដែលក្រលំបាក ។
- ទូរគម [ទូរះគំ] ន : ឆ្ងាយ ផ្លូវឆ្ងាយ ។
- ទូរវេទន៍ (បាសំ) ន : អារម្មណ៍ឆ្ងាយ ដឹងពីចម្ងាយ ។
- ទូន្មាន [ទូនមៀន] ន : ការអប់រំ ការប្រៀនប្រដៅ ។
- ទេសចរណ៍ (បាសំ) ន : ការធ្វើដំណើរកម្សាន្តលំហែចិត្តកាយ ។
- ទេពនិករ [ទេបនិ.ក] ន : ពពួកទេវតា ។
- ទេពទសសហស្សា [ទេបទោះសះហះសា] ន : ទេវតាទាំងពាន់ ទេវតាទាំងម៉ឺន ។
- ទោម្នេញ ន : សេចក្ដីតូចចិត្ត សេចក្ដីអន់ចិត្ត ។
- ទ្រុស្តមិត្ត (បាសំ) ន ឬ គុ : អ្នកធ្វើអាក្រក់ចំពោះមិត្ត ដែលធ្វើអាក្រក់ចំពោះមិត្ត ។
- ទ្រគោះ គុ : គំរោះគំរើយបោះបោកឥតគួរសម ។
- ទ្រយឹង ន ឈ្មោះឈើមួយប្រភេទពួកឈើខ្មៅ ផ្លែទុំមានក្លិនក្រអូបឆ្ងាញ់ប្រើជាចំណីបាន ។
- ទ្វារបាល (បាសំ) ន ឆ្មាំទ្វារ អ្នកយាមទ្វារ ។

## ធ

- ធនុ [ធៈនុ] ន : អាវុធធ្វើដោយឈើ ឫស្សី ឬដែកទ្រាំងមានដង មានបន្លោះសម្រាប់បាញ់ដោយព្រួញ ។
- ធ្មេញត្រី ន : ឈ្មោះឈើតូចមួយប្រភេទ ច្រើនដុះនៅទំនាបមាត់បឹង មាត់ត្រពាំង ។
- ធ្វើកាល កិ : ស្លាប់ ។
- ធម្មវិន័យ ន : ច្បាប់សម្រាប់បព្វជិតពុទ្ធសាសនា ។
- ធម៌ចន្ទបរិត្ត ន : ធម៌សម្រាប់សូត្រការពារព្រះចន្ទឱ្យគេចផុតពីអន្តរាយ ។
- ធម្មមន្ទីរ ន : កន្លែងពិភាក្សាអំពីធម៌ ។

## ន

- នរបតី [នៈរៈប៉ៈដី ឬ នរប់ប៉ៈដី] ន : ម្ចាស់នៃពពួកមនុស្ស ។
- នរក [ន៏រក់] ន : ឈ្មោះទីអបាយភូមិ ឬអធោលោក ដែលមានរណ្ដៅជាលំនៅនៃសត្វមានបាប នៅរងតាមកម្លាំងកម្មដែលខ្លួនធ្វើ ។
- នទី [នៈទី] ន : ស្ទឹង ទន្លេ ។
- នមស្ការ [នៈម៉ុស ស្កា] ន : កិរិយាថ្វាយបង្គំ ការបង្អោនកាយក្រាបប្រណិប័តន៍ គំនាប់ ។
- នាយសារថី [នាយសារៈថី] ន : អ្នកបររាជរថ រទេះ ។
- និស្ស័យ [និស-សៃ] ន : ការនៅអាស្រ័យក្រោមឱវាទនិងក្រោមការគ្រប់គ្រងអ្នកដទៃ ការប្រាស្រ័យទាក់ទង ។
- និគមជនបទ [និគំជន់បត់] ន : ទីប្រជុំភូមិ ឬតំបន់នៅតាមខេត្ត ។
- និរោធ [និរោត] ន : សេចក្ដីរលត់ ព្រះនិព្វាន ។
- និមន្ត [និមន់] កិ : អញ្ជើញ សូមឱ្យទៅ ឬសូមឱ្យមក ។
- និន្ទា [និនទា] ន : ការរិះគន់ ដំណើរតិះដៀល ។
- នីតិន័យ ន : ន័យឬខ្លឹមសាររបស់ច្បាប់ ។

## ប

- បរិច្ចាគ [បរិចចាក] ន : ការលះបង់ ការលះទ្រព្យ ការចំណាយទ្រព្យធ្វើជាទាន ។
- បណ្ដាជន [បន់ដាជន់] ន : មនុស្សទាំងអស់ មនុស្សទូទៅ ។
- បរលោក [ប-ល៉ោក ឬប៉ៈរ៉ៈលោក] ន : លោកខាងមុខ លោកឯនាយ ។
- បសុសត្វ [ប៉ៈសុ-ស័ត] (បាសំ) ន : សត្វចិញ្ចឹម ។

- បពិត្រ  ន : ពាក្យសម្រាប់បព្វជិតក្នុងពុទ្ធសាសនា ហៅក្សត្រិយ ឬសេនាបតី ។
- បព្វជា [ប័ប ព័ច ជា]  ន : ការបួស ផ្នួស ។
- បង្អុរ [បង់អុល]  កិ : ធ្លាក់ភ្លៀង ។
- បរិវារ [បរិវ៉ា]  ន : អ្នកបម្រើ អ្នកចោមរោមកំដរ ។
- បញ្ជា [ប៉ាញ់ ចា]  ន : គ្រឿងរចនាមានថ្នាក់ មានជាន់សម្រាប់តម្កល់កោដ្ឋដាក់សព ។
- បន្ទោបង់ [បន់ទោបង់]  កិ : បន្ថយចេញ នាំបង់ បត់ជើងធំ ។
- បទសរភញ្ញ [សៈរ៉ៈភ័ញ] (បាសំ)  ន :  ការសូត្រតាមលំនាំ ឬលើកដាក់សំឡេងទៅតាមឃ្លាសង្កាត់របស់គាថា ឬពាក្យរាយ ។
- បញ្ញត្តិ [ប័ញ-ញ៉ាត់]  (បា) ន : សេចក្តីហាមប្រាម បម្រាម ។
- បព្វជិត [ប័ប ពៈ ជិត]  ន : អ្នកបួស ។
- បដិមា  ន : រូបប្រៀប រូបសំណាក រូបតំណាង ។
- បទបាឋ [បទ-បាត]  (បាសំ)  ន : តាមដំណើររឿងរ៉ាវ ។
- បច្ចេកទេស [ប៉ុច-ចេកៈទេស]  (បា)  ន : ចំណេះវិជ្ជាពិសេស ជាចំណែកមួយដាច់មុខផ្សេងដោយឡែកខាងសិល្បៈ ឬខាងវិទ្យាសាស្ត្រនីមួយៗ ។
- បាយម៉ាត  ន : ឈ្មោះឈើមួយប្រភេទ ស្លឹកមានក្លិនក្រអូបប្រហើរ ។
- បាបកម្ម  (បា)  ន : អំពើអាក្រក់ ។
- ប្លាត  កិ : ជ្រុលជ្រួស ជ្រលួស ខ្វាត ។
- បិយវាចា  (បាសំ)  ន : វាចាជាទីស្រលាញ់ ។
- បិណ្ឌបាត  [បិនឌៈបាត]  កិ : អាហារដែលប្រមូលឱ្យជាដុំដាក់ក្នុងបាត្រ ។
- បីទ្រ  កិ : កាន់ត្រកង ឱប ឬទ្រដោយដៃទាំងពីរ ។
- បូព្វទិស  (បាសំ)  ន : ទិសខាងកើត ។
- បុរី  [បុរ៉ី]  ន : ក្រុង ខេត្តធំ រដ្ឋ មណ្ឌល ។
- បុសនាគ  ន : ឈើមួយប្រភេទស្លឹកស្រដៀងរំដួល ផ្កាស្រដៀងផ្កាសុរភីតែធំៗជាង មានក្លិនក្រអូបល្អហើយប្រើការជាគ្រឿងផ្សះរាយរងក៏បាន ។
- បើកភ្នែក  គុ : ស្វែងយល់ពីការពិត ។
- បេង  ន : ឈ្មោះឈើខ្លឹមមួយប្រភេទ ពួកគ្រញូង ពួកធ្នង់ ។
- បោក្ខរពស៌ [ប៉ោកខៈរៈព័ស]  (ន) : ភ្លៀងមានអាការៈដូចជាទឹកធ្លាក់លើស្លឹកឈូក ។

- បាតុភូត (បាសំ) (ន) : ហេតុដែលកើតឡើងប្រាកដជាក់ស្តែង ។
- បាក់តេរី (បារាំង) (ន) : ឈ្មោះមេរោគ ។
- ប៉ារ៉ាពីតែក (ន) : ជាអង់ត្រូប៉ូម័ពដើមដែលបានបង្កើតបុព្វមនុស្ស ។
- ប៉ោឡៃ (គុ) : ដែលព្រហើន ច្រឡោងខាម ។
- បំភាយ (កិ) : ធ្វើឱ្យសាយចេញ ឬភាយចេញ ។
- បំលែង (ន) : ធ្វើឱ្យឃ្លាត របូតចេញ ។
- ប្រតិព័ទ្ធ [ប្រតិពាត់] (កិ) : ស្រលាញ់ជាប់ចិត្ត ។
- ប្រណិប័តន៍ [ប្រណិបាត់] (កិ) : ការសម្តែងសេចក្តីគោរព ការគំនាប់ ។
- ប្រសូត (កិ) : កើត សម្រាលកូន ។
- ប្រទក្សិណ [ប្រទៈសិន] (កិ) : ដើរព័ទ្ធជុំវិញ ។
- ប្រតិកម្ម (បាសំ) ន : អំពើប្រឆាំងតប អំពើតទល់ ។
- ប្រគេន (កិ) : ឱ្យ លើកឱ្យដល់ដៃក្នុងហត្ថបាស ។
- ប្រថាប់ (រ.ស) កិ : គង់នៅ (ឈប់ ឈរ អង្គុយ) ។
- ប្រត្យក្ស [ប្រត្យ៉ក] គុ : ច្បាស់ ដែលជាក់ប្រាកដ មែន ពិត ។
- ប្រតិស្នូឬប្រតិដ្ឋ [ ប្រដឹសឬប្រដិត] (កិ) : បង្កើត ។
- ប្រទក្សិណ (បា.សំ) (ន) : ការសម្តែងសេចក្តីស្រឡាញ់ដោយដើរព័ទ្ធជុំវិញបុគ្គល ឬវត្ថុអ្វីៗឱ្យបុគ្គល ឬវត្ថុនោះនៅខាងស្តាំដៃ ។
- ប្រជាធិបតេយ្យ (បា.សំ) (ន) : ភាពនៃប្រទេស ឬរដ្ឋបាលដែលមានប្រជាជនជាធំក្នុងការជ្រើសរើសតំណាងរបស់ខ្លួនឱ្យជាអ្នកសម្រេចកិច្ចការប្រទេសជាតិ ។
- ប្រិមប្រិយ (គុ) : ដែលគួរឱ្យស្រឡាញ់ ដែលជាទីស្រឡាញ់ ។
- ប្រសិទ្ធភាព (ន) : ភាពសក្តិសិទ្ធិ ពូកែឆុតឆាប់ ។
- ប្រេងកំញាន (ន) : ប្រេងចម្រាញ់ពីជ័រឈើកំញាន.
- ប្រារព្ធ [ ប្រា-រប់] (កិ) : តាំងផ្តើម ផ្តួចផ្តើមផ្តងជាមុន ។
- ប្រណីត (បា.សំ) (គុ) : ដែលថ្លៃថ្លាឧត្តុង្គឧត្តមឆើតឆាយ ។
- បរាមុខ (ន) : ការធ្វើឱ្យអាប់មុខមាត់ ការវិនាស ។
- ប្រផេញ (ន) : ឈ្មោះឈើតូចស្លឹកល្អិតស្រដៀងស្លឹកអំពិលមានផ្កាផ្លែចេញពីស្លឹក ។ ប្រផេញញីមានផ្កាពណ៌ស ប្រផេញឈ្មោលមានផ្កាពណ៌ក្រហម ។

- ប៉ម (ន) ៖ គ្រឹហាខ្ពស់ស្រឡះមានសណ្ឋានមូល ឬកាច់ជ្រុងមានជញ្ជាំងចោះជាប្រហោងព័ទ្ធជុំវិញធ្វើទុកនៅត្រង់មុមកំពែងបន្ទាយ ឬទីណាមួយសម្រាប់ពួនយាមឃ្លាតឃ្លាំ ឬលាក់ខ្លួនពួនចាំបាញ់តយុទ្ធនឹងខ្មាំងសត្រូវ ។

**ផ**

- ផលានិសង្ស [ ផៈ-ល៉ា-និ-សង់ ] ៖ អានិសង្សនៃផល ការហូរមកនៃផល គឺសេចក្ដីសុខសេចក្ដីចម្រើន ដែលកើតមកអំពីផលនៃអំពើល្អ ។
- ផលានុផល [ ផៈ-ល៉ា-នុ-ផល ] (ន) ៖ ផ្លែមុននិងផ្លែក្រោយ ផ្លែតូចនិងផ្លែធំ ។
- ផាហ៊ុម (ន) ៖ សម្រាប់ដណ្ដប់ ខ្មែរយើងហៅតែចំពោះសំពត់ព្រែសូត្រ សម្រាប់ប្រើពានា ឬដណ្ដប់ពេលត្រជាក់ ។
- ផ្ដន្ទា [ ផ្ដន់-ទា ] (កិ) ៖ ផ្ដាលធ្វើទោស ឬចង់ឱ្យគេវិនាស ។
- ផលកម្ដៅ (ន) ៖ កម្ដៅដែលភាយចេញពីភ្លើង ឬចរន្តអគ្គិសនី ។
- ផូស៊ីល (ន) ៖ សំណល់ភាវៈរសដែលនៅគង់វង្សរកប់ជាប់ក្នុងស្រទាប់សិលា ។

**ព**

- ពនិតា [ ពៈនិតា ] (បា.សំ) (ន) ៖ ភរិយា ។
- ពនេចរ (បា.សំ) (ន) ៖ អ្នកត្រាច់ទៅក្នុងព្រៃ ឬព្រានព្រៃ ។
- ពសុធា [ ព័រសុធា ] (ន) ៖ ដី ផែនដី ។
- ពណ្ណរាយ [ ពន់-ណៈ-រាយ ] (គុ) ៖ ភ្លឺថ្លា ល្អប្រពៃ ។
- ពពេច (ន) ៖ ឈ្មោះសត្វស្លាបម្យ៉ាងមាឌតូច ពពួកចាប ។
- ពង្រ (ន) ៖ ឈ្មោះឈើធំមួយប្រភេទមានសាច់រឹង មានផ្លែប្រើជាម្ហូប ។
- ពាជី (ន) ៖ សេះ ។
- ពានា (កិ) ៖ យកសំពត់គ្របដណ្ដប់ ព័ទ្ធឆៀងស្មាម្ខាង ។
- ពិសុទ្ធសន្ធរ [ ពិសុតសន់ធ ] (គុ) ៖ ស្អាតវិសេស ម៉ត់ហ្មង ឥតមន្ទិល ។
- ពិពិធ [ ពិពិត ] (គុ) ៖ ច្រើនបែប ច្រើនយ៉ាង ។
- ពិពិធពិពណ៌ [ ពិពិតពិព័រ ] (គុ) ៖ ច្រើនបែប ច្រើនពណ៌ ។
- ពីតេកង់ត្រូប (ន) ៖ មនុស្សស្វាជារូបរាងជំនាន់ទីមួយរបស់មនុស្ស ។
- ពុទ្ធបាទ (ន) ៖ ជើងព្រះពុទ្ធ ។
- ពុទ្ធបរិស័ទ [ ពុត-បរិស័ត ] (បា.សំ) (ន) ៖ ជនអ្នកចូលទៅជិតស្ដាប់ឱវាទព្រះពុទ្ធ ។

- ពុទ្ធបដិមា (ន) : រូបសំណាក ឬរូបតំណាងព្រះពុទ្ធ ។
- ព្រៃព្រហ្មចារីយ៍ (ន) : ព្រៃដែលមិនធ្លាប់មានមនុស្សចូលដល់ ។
- ពុំជួកាល (គុ) : ដែលខុសកាល ដែលកើតមានក្នុងកាលដ៏ប្លែកខុសធម្មតា ។
- ព្រាច [ ព្រៀច ] (កិ) : សាចរាចទៅ ចាប់បាចរាចទៅ ។
- ព្រឹទ្ធាចារ្យ [ ព្រឹត-ធាចា ] (ន) : អាចារ្យដែលមានអាយុច្រើន អាចារ្យដែលចាស់ទុំ ។
- ព្រឹត្តិន័យ (បា.សំ) (ន) : ន័យរបស់អំពើ ។
- ព្រះសវនីយ៍ [ -សៈវៈនី ] (គុ) : ដែលគួរស្ដាប់ ដែលត្រូវស្ដាប់ ។ ខ្មែរប្រើជា រ.ស ចំពោះតែព្រះបន្ទូលរបស់សម្ដេចព្រះវររាជជនី ឬសម្ដេចព្រះអគ្គមហេសី ។
- ព្រះរាជសុណិសា (ន) : កូនប្រសាស្រី ។
- ព្រះសសុរៈ [ -សៈសុរៈ ] (ន) : ព្រះបិតាក្មេក ឪពុកក្មេក ។
- ព្រះព្រហ្មចរិយ [ -ព្រំចរិយៈ ] (ន) : បែបបទ ឬសណ្ដាប់ធ្នាប់របស់ព្រហ្មចារី ឬព្រហ្មចារិនី ការប្រព្រឹត្តធម៌ដ៏ប្រសើរ ។
- ព្រះភិរុណ [ ព្រះភិរុន ] (ន) : ភ្លៀង ។
- ព្រះភក្ត្រ [ ព្រះភ័ក ] (ន) : មុខ (រ.ស) ។
- ព្រះកន្សែង [ ព្រះកន់សែង ] (កិ) : យំ (រ.ស) ។
- ព្រះហស្ត [ ព្រះហ័ស ] (ន) : ដៃ ។
- ព្រះពោធិវង្ស [ ព្រះពោធិវង់ ](ន) : ឋានន្តរទីរាជាគណៈសម្រាប់ឯកថ្នាក់ខ្ពស់ក្នុងកម្ពុជប្រទេស សម្រាប់បព្វជិតជាមហាថេរ រូបណាមួយ អ្នកចេះចាំធម៌វិន័យស្ទាត់ប្រាកដ ដែលព្រះករុណាជាម្ចាស់ជីវិតទ្រង់ព្រះមេត្តាប្រោស ។
- ព្រះបាទា (ន) : ជើង (ស.រ) ។
- ព្រះពោធិសត្វ [ -ពោធិស័ត ] (ន) : អ្នកដែលមានចិត្ត ឬមានសេចក្ដីប្រាថ្នាជាប់នៅក្នុងពោធិ គឺអ្នកដែលកំពុងខំប្រឹងបំពេញបារមីបម្រុងនឹងត្រាស់ជាព្រះពុទ្ធសម្មាសម្ពុទ្ធ ។
- ព្រះជន្ម [ ព្រះជន់ ] (ន) : អាយុ (រ.ស).
- ព្រះក្បៀរ [ -ក្បឿ ] (ន) : ទឹកដោះ (រ.ស) ។
- ព្រះសន្ធិយា [ -សន់ធិយា ] (ន) : វាំងនន ឡប់ខ្មៅ រនាំង ឆាក ។
- ព្រះពលំ [ -ពល់-លាំង ] (ន) : កម្លាំង (រ.ស) ។

- ព្រះបច្ចេកពុទ្ធ [ -ប៉ុច-ចេក-ពុត] (ន) : លោកអ្នកត្រាស់ដឹង ចំពោះបានតែខ្លួនមួយសម្ដែងធម៌ប្រៀនប្រដៅអ្នកដទៃផងមិនកើត ។
- ព្រះនិវេសន៍ (បា.សំ) (ន) : ព្រះរាជដំណាក់ ។
- ព្រះវិស្ណុ (សំ) (ន) : ឈ្មោះទេវៈមួយអង្គនៅក្នុងព្រហ្មញ្ញសាសនា ។
- ព្រះសិវៈ (សំ) (ន) : ឈ្មោះទេវៈក្នុងព្រហ្មញ្ញសាសនា ។
- ព្រះពុទ្ធ (បា.សំ) (ន) : ឈ្មោះអ្នកដឹកនាំពុទ្ធសាសនា ។
- ព្រះត្រៃបិដក [ -ត្រៃ-បី-ដក់] (បា.សំ) (ន) : ឈ្មោះច្បាប់គម្ពីរធម្មវិន័យពុទ្ធសាសនា គឺព្រះវិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ។
- ព្រះអាល័ក្ស (ន) : ឈ្មោះក្រុមអ្នករាជការមួយក្រុមក្នុងរាជវាំងមានមុខងារជាអ្នកកត់ត្រាព្រះរាជទ្រព្យ ។
- ព្រះទីន័ងឬទីនាំង (ន) : យានជំនិះ ទីអង្គុយ ឬទីសម្រាប់ក្សត្រិយទ្រង់ប្រថាប់ ។
- ព្រះទែន (ន) : ទីសម្រាប់ស្ដេចគង់ ។
- ព្រះឱស្ឋ (ន) : មាត់ ។
- ព្រះសិរ [ -សេរ] (រ.ស) (ន) : ក្បាល ។

ភ

- ភាជន៍ [ ភាច] (បា) (ន) : ចាន ប្រដាប់សម្រាប់ដាក់ភោជនអាហារមានបាយជាដើម ។
- ភាពអន្ធការ [ ភាប-អន់-កា] (ន) : ភាពងងឹតសូន្យសុង ។
- ភិក្ខុ (ន) : អ្នកបួសក្នុងព្រះពុទ្ធសាសនាមានថ្នាក់ខ្ពស់ជាងសាមណេរ ។
- ភិយ្យោភាព [ ភិ-យោភាប] (ន) : ដំណើរច្រើនក្រៃលែង ភាវៈលើសលែង ។
- ភីលូម (ន) : ការវិវឌ្ឍមួយសេរីនៃទម្រង់សត្វ ឬរុក្ខជាតិ ។
- ភុល : ឧទាហរណ៍ ស្ងួរព្នដោយបក្សីស្មុះហើរព្រមគ្នា ឬស្ងួរទឹកខ្ពុរចេញជាដើម ។
- ភុជ [ ភុជៈ] (ន) : ភែ្នន ដៃ តែក្នុងទីនេះយកដៃ ។
- ភូធរ (ន) : អ្នកទ្រទ្រង់ដែនដី ស្ដេច ។
- ភ្លេង (ន) : គ្រឿងដេញ ដំ ផ្លុំ កូតផ្សេងៗសម្រាប់កម្សាន្តចិត្ត ដូចជា ភ្លេងខ្មែរ ភ្លេងចិន ភ្លេងការ ។ល ។
- ភោជន [-ជន់] (ន) : វត្ថុសម្រាប់បរិភោគ អាហារ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

- ភ្លូង (ន) ៖ ឈ្មោះឈើម្យ៉ាងសាច់រឹងស្អិទ្ធមានពីរប្រភេទ គឺភ្លូងជូរ ស្លឹកជូរៗបន្តិចប្រើស្ងោរលាងសំពត់បាននិងភ្លូងក្អែកស្លឹកធំៗក្រាស់ជាងភ្លូងជូរ ។
- ភ្លូ (ន) ៖ រុក្ខជាតិព្រៃម្យ៉ាង ស្លឹកមានមមីសគ្រើមៗផ្លែមានសណ្ឋានមូលមានត្របកជាស្រទាប់រុំជុំវិញ បណ្តូលមានរសជាតិជូរបរិភោគបាន ។ ភ្លូមានពីរប្រភេទ គឺភ្លូធំនិងភ្លូបាត ។
- ភ្លាំង (ន) ៖ ឈ្មោះឈើតូចៗមួយប្រភេទដើមតូចទាបៗ ផ្លែតូចៗមូលៗជាចង្កោម ។ ផ្លែទុំមានពណ៌សរលោង ។

## ម

- មហិទ្ធិឫទ្ធិ [ មៈហិត-ធឹរិត ] (បា. សំ) (ន) ៖ ឫទ្ធិធំ ឬរឹទ្ធខ្លាំងក្រៃលែង ឬរឹទ្ធិសម្បើម ។
- មគ្គុទ្ទេសក៍ [ ម័កគុតទេស ] (ន) ៖ អ្នកដឹកនាំ ។
- មធុបាយាស (បា) (ន) ៖ បាយចម្អិនលាយទឹកដោះគោព្រមទាំងគ្រឿងផ្សំមានតម្លៃផ្សេងៗជាច្រើន ។
- មជ្ឈិមបូព៌ា (បា. សំ) (ន) ៖ ភាគកណ្តាលផ្នែកខាងកើត ។
- មយូរៈ [ មៈយូ ] (ន) ៖ ក្ងោក ។
- មធុរៈ ឬមធូរ [ មៈធូ ] (គុ) ៖ ផ្អែម ពីរោះ ឆ្ងាញ់ ។
- មហាធិបតិន្ទ [ មហាធិបតិន ] (ន) ៖ ទេវតាជាអធិបតីធំលើសគេ ។
- មានលក្ខណ៍ (បា. សំ) (ន) ៖ មានភ័ព្វ មានសំណាង មានបុណ្យ ។
- មាតុគ្រាម (ន) ៖ អ្នកដែលមានលំអានដូចជាមាតា ។
- មាលា (ន) ៖ ផ្កាកម្រង កម្រងផ្កា ។
- ម្រឹគ [ ម្រឹក ] (ន) ៖ សត្វចតុប្បាទព្រៃទូទៅមានសីហៈ ខ្លា ឈ្លូស ប្រើស ក្តាន់ រមាំងជាដើម ។
- មុសា (បា. សំ) (កិ) ៖ កុហក ។
- មិុកស៊ិកូ (អង់គ្លេស) (ន) ៖ ឈ្មោះរដ្ឋមួយនៃសហរដ្ឋអាមេរិក ។
- មូល (បា. សំ) (ន) ៖ ជុំគ្នា ។
- មេដ្យាទ័រ (បារ) (ន) ៖ របាំងកណ្តាល ។
- មេសង្វៀន (ន) ៖ មេខ្លោង អ្នកការពារព្រំប្រទល់បឹង ឬការពារឡូត៍នេសាទ ។
- មហិមា [ មហិមា ] (គុ) ៖ ធំ សម្បើម អស្ចារ្យ ។

## យ

- យមុនា [ យៈមុនា ] (ន) ៖ ឈ្មោះទន្លេមួយក្នុងប្រទេសឥណ្ឌាមានចេញឈ្មោះច្រើនអន្លើក្នុងគម្ពីរពុទ្ធសាសនា ។
- យមរាជ [ យៈមៈ-ឬយំរាជ ] (ន) ៖ សេចក្តីស្លាប់ អធិបតីនរក ច្រើនហៅថា ព្រះយម ។
- យុត្តិធម៌ (ន) ៖ សេចក្តីទៀងត្រង់ មិនលំអៀង ។

## រ

- រចនាបថ [ រ៉ាច់-ចៈន៉ា-បត់ ] (បា.សំ) (ន) ៖ របៀប ឬលំនាំក្នុងការតុបតែង ឬសរសេរ ។
- រថ [ រត់ ] (ន) ៖ យាន ឬរទេះ ។
- រកា (ន) ៖ ឈ្មោះឈើព្រៃមួយប្រភេទ សណ្តាននឹងដើមគ ដើមវាមានបន្លាធំៗ ហើយមានផ្លែតូចៗខ្លីជាង ។
- រហោឋាន (បា.សំ) (ន) ៖ ទីស្ងាត់កំបាំង ។
- របកគំហើញ (បា.សំ) (ន) ៖ ការរកឃើញ ។
- រតន៍ [ រ័ត ] (បា.សំ) (ន) ៖ វត្ថុ ឬរបស់ដែលញ៉ាំងចិត្តឱ្យរីករាយមានកែវកងត្បូងពេជ្រគ្រប់ប្រភេទ ។
- រាជនី (រ.ស) (ន) ៖ ស្តេចស្រី ។
- រូបមន្ត (ន) ៖ ក្បួនខ្នាតក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ។
- រូ រូហាន (ន) ៖ ដូច ដូចជា បីដូច ស្មើនឹង ។
- រេហ៍ពល [ រេពល់ ] (ន) ៖ កម្លាំងបៀតបៀន អ្នកពិឃាត ពួកយោធា ពួកទាហាន ។
- រាំង (ន) ៖ ឈ្មោះឈើមានពីរប្រភេទ គឺរាំងភ្នំឈើធំដុះក្នុងព្រៃភ្នំ ឬទួលធំៗជាឈើមានខ្លឹមជាប់ធន់បានយូរជាគូនឹងថ្នឹក ។ រាំងអន្លក់ គឺឈើរនាមមួយប្រភេទស្លឹកខ្ចីប្រើអន្លក់ ឬរបោយមាន ជាតិចត់ ។
- រំពៃ (កិ) ៖ គន់មើលរឿយៗ រំពៃមើល ។

## ល

- លិង្គម [ លិង-គៈមៈ [ (បា) ៖ គ្រឿងសម្គាល់របស់បុរសភេទ ។
- លេច (កិ) ៖ អណ្តែតឡើង ផ្សាយចេញ ។
- លេណ [ ឡេន ] (ន) ៖ គុហាដែលកើតឯងក្នុងភ្នំ រូង រូងភ្នំ ។

- លោកិយ [ លោកិយៈ ឬកី ] (គុ) : ដែលមានក្នុងលោក ដែលជាប់ទាក់ទងដោយលោក សម្រាប់លោក ។
- លាំង (ន) : ឈ្មោះឈើធំមួយប្រភេទ ស្លឹកស្រដៀងស្លឹកច្រេស ខ្លឹមស្រដៀងនាងនួន ខ្លឹមវាប្រើបានដោយលាយនឹងខ្លឹមនាងនួន ។
- លាំងដៃឬលាំង (ន) : ឈ្មោះឈើពីរប្រភេទ គឺមួយប្រភេទស្លឹកតូចៗជាសំណុំៗ មួយប្រភេទទៀតស្លឹកធំៗរាយៗ ច្រើនកើតមានដង្កូវដួង ស៊ីដើម ចេញជ័រជ្រាយគគុល ដង្កូវដួងនោះហៅថា ដួងលាំងជ័យ ។
- លាំងសាត (ន) : ឈ្មោះឈើមួយប្រភេទផ្លែជាប់គ្នារដឹកចេញពីស្នែង សម្បកផ្លែស្តើងសម្បុរសសាច់ជាក្លែបដូចបង្គោ តែជ្រាយជាងបន្តិច មានរសផ្អែមលាយជូរបន្តិច បរិភោគបាន គ្រាប់មានរសជាតិល្វីង ។

វ

- វរនារី (ន) : ឋានន្តរសក្តិនាយទាហាននាវាចរណ៍ចាប់ពីសក្តិ៤ ឡើងទៅ ។
- វប្បធម៌ (ន) : ការផ្សាំបណ្តុះចំណេះវិជ្ជាឱ្យបានលូតលាស់ចម្រើន ។
- វឌ្ឍនភាព [វ័ធ នះ ភាព] (ន) : សេចក្តីចម្រើនលូតលាស់ ។
- វង្សា (ន) : ពូជ ត្រកូល អំបូរ ។
- វាយនភណ្ឌ [-យ-ភ័ន] (ន) : គ្រឿងតម្បាញ ឬកី ។
- វិកល (គុ) : ដែលខ្វះខាត មិនគ្រប់គ្រាន់ ពិការ ។
- វិតក្ក [ វិត័ក-កៈ ឬ -តក់] (បា.សំ) (ន) : សេចក្តីត្រិះរិះ ឬសេចក្តីសញ្ជឹងគិត ។
- វិញ្ញាណ (ន) : ធម្មជាតិដឹងច្បាស់នូវអារម្មណ៍ ។
- វិបត្តិ (ន) : សេចក្តីវិនាស អន្តរាយ ដំណើរទទួលគ្រោះថ្នាក់ ការរងទុក្ខ សេចក្តីប្រែប្រួល ។
- វិទ្យាសាស្ត្រ (សំ) (ន) : វិជ្ជាមួយប្រភេទដែលរកឃើញដោយការលៃផ្សំ មានការផ្សំធាតុជាដើម ។
- វិសាលភាព (បា) (ន) : ភាពធំទូលាយ ។
- វិវត្តន៍ (បា) (ន) : ការប្រែប្រួល ការផ្លាស់ប្តូរ បម្រែបម្រួល ។
- វេហាស៍ [ វេហា ] (ន) : អាកាស ។
- វេស្សន្តរ [ វេស សន់ តះរ៉ះ ឬ-សន់ដ] (ន) : រវាង ឬទីពាក់កណ្តាលផ្លូវពួកវេស្សៈ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ស

- សក្ការបូជា [ សៈការៈបូជា ] (ន) : ការគោរព ការធ្វើបដិសណ្ឋារកិច្ច តង្វាយ ជំនូន គ្រឿងបូជាដោយគោរព ។
- សន្តិភាព (ន) : ភាពសុខសាន្ត ភាពស្ងប់ស្ងាត់ ភាពសាន្តត្រាណ ។
- សណ្តាន់ (ន) : ឈើនាមមួយប្រភេទ ស្លឹក និងផ្លែមានរសជូរ សម្រាប់ធ្វើជាម្ជូរ ជ្រក់ក៏បាន ។
- សត្យ [ សាត់ ] (ន) : សេចក្តីពិត ដំណើរទៀង ទៀងទាត់ ទៀងត្រង់ ។
- សត្តសតកមហាទាន [ សាត់តៈស័តតៈកៈ-] (ន) : ទានដ៏ធំអស្ចារ្យ មានក្នុងមួយមុខៗ ៧០០ ។
- សមិទ្ធផល (ន) : ផលប្រយោជន៍ដែលបានសម្រេចហើយ ។
- សច្ចាអធិដ្ឋាន (ន) : ការតាំងចិត្តទៀងទាត់ ការតាំងប្រកាសពាក្យសច្ចៈ ។
- សប្បុរស (ន) : អ្នកមិនធ្វើអំពើអាក្រក់ ដោយកាយវាចាចិត្ត អ្នកប្រព្រឹត្តល្អ អ្នកត្រឹមត្រូវ ។
- សង្កែ (ន) : ឈ្មោះឈើមួយប្រភេទសាច់សរឹង គេច្រើនដាំតាមភ្លឺស្រែ ស្លឹកជ្រុះនាំឱ្យដីមានជីជាតិល្អជាដើម គឺងាយកើត ងាយដាំ ទោះជាកាប់សល់តែគល់ក៏ដោយចាប់ដុះបានល្អ ។
- សង្ឃ័រ [ សង់ យ័រ ] (ន) : ឈ្មោះឈើមួយប្រភេទមានបន្លាខុបៗ ផ្លែតូច ពេលទុំឡើង សម្បុរក្រមៅ មានរសជូរអែម បរិភោគបាន ។
- សត្វចតុប្បាទ [ ចៈតុប-បាត ] (បា) (ន) : សត្វមានជើងបួន ។
- សរីរៈ [ សៈរ៉ិរ៉ៈ ] (ន) : រាងកាយ ខ្លួនប្រាណ ។
- សហករណ៍ [ សៈហៈក ] (ន) : ក្រុមហ៊ុន ឬអង្គការដែលប្រមូលផ្តុំ ជនអ្នកបង្កើតផលផ្សេងៗ ។
- សារពាង្គកាយ (ន) : សរីរាង្គ រូបរាង រូបរាងកាយទាំងមូល ។
- សាយណ្ហកាល [ សាយ-យ័ន-ហៈកាល ] (ន) : វេលារសៀល ពេលល្ងាច ។
- សិប្បកម្ម (ន) : ការងារជំនាញ ។
- សិរសា [ សិរៈសា ] (ន) : ក្បាល ។
- សីមា (ន) : រដ្ឋ ប្រទេស ។
- សីហនាទ [ សីហៈនាទ ] (គុ) : បន្លឺសូរសៀងដូចសីហៈ ។
- សុភតិត្ថិ [ សុ-ភៈ-តិ-ថិ ] (គុ) : វេលាដែលជាសុភាឫក្ស ថ្ងៃដែលល្អ ។
- សុបវរ [ សុបវ៉ ] (គុ) : ល្អប្រសើរ ។

- សុខដុម [ សុ-ខៈ-ដុំ ] (បា) (ន) : សុខក្រៃលែង ឬការរស់នៅដោយសុខស្រួលឥតមានមោះហ្មង ។
- សុន្ទរកថា (បា. សំ) (ន) : ពាក្យសម្ដីសម្រាប់សូត្រថ្លែងសេចក្ដីក្នុងទីប្រជុំជន ។
- សុពណ៌ (ន) : មាស ។ (គុ) : ដែលមានពណ៌ ឬសម្បុរល្អ ។
- សុភមង្គល (ន) : មង្គលល្អ សេចក្ដីសុខ សេចក្ដីចម្រើន ។
- សោភ័ណ (បា. សំ) (គុ) : ល្អហ្មត់ហ្មង ។
- សោមនស្ស [ សោមៈន័ស ] (គុ) : ត្រេកអរ សប្បាយរីករាយ ។
- ស្នាច់ (ន) : ឈ្មោះឈើមួយប្រភេទសម្បកពុកៗ សកៗជាស្រទាប់ សកត្រាំក្នុងជ័រទឹក ហើយស្រង់ពូតធ្វើជាចន្លុះ ហៅចន្លុះស្នាច់ គេច្រើនប្រើឧស ឬធ្វើជាឫសបុករណ្ដៅសង់គ្រឹហា ។
- ស្ថាបត្យកម្ម [ ស្ថាបៈតៈយៈកាំ ] (ន) : ការសាងសង់ ឬការស្ថាបនា ។
- ស្វាធ្យាយជយន្តោ [ ស្វា-ធ្យាយជៈ-យ័ន-តោ ] (បា. សំ) (ន) : ការសូត្រធម៌ប្រោះព្រំសិរីមង្គលសួស្ដី ។
- ស្រឡៅ (ន) : ឈ្មោះឈើធំមួយប្រភេទ សណ្ឋានស្រដៀងនឹងត្របែកព្រៃ តែដើមធំជាងសាច់ស្អិតស្អាត ប្រើការបានច្រើនយ៉ាងដូចជា ក្ដារស្រឡៅ ទូកស្រឡៅ តុស្រឡៅ ។

## ហ

- ហទយវត្ថុ [ ហៈទៈយៈ-] (បា) (ន) : បេះដូង ។
- ហឫទ័យ [ ហៈរិទ័យ ] (បា) (ន) : ចិត្ត ដួងចិត្ត ទឹកចិត្ត ។
- ហិង្សាកិច្ច (បា. សំ) (ន) : ការបៀតបៀន ការធ្វើអាក្រក់ចំពោះគ្នា ។
- ហេដ្ឋារចនាសម្ព័ន្ធ [ ហេត-ថា-រ៉ាត់-ចៈន៉ា-សំពាន់ ] (បា) (ន) : រចនាសម្ព័ន្ធជាន់ទាប ។
- ហៃដែលប៊ែរ (បារ) (ន) : រូបរាងជំនាន់ទី៣នៃមនុស្សស្វាដែលគេរកឃើញឆ្អឹងថ្គាមរបស់វាដូចថ្គាមមនុស្ស ។

## អ

- អង្រ្កង (ន) : សុខុមសត្វពួកស្រមោច សម្បុរក្រហម ជើងវែងៗនៅអាស្រ័យនឹងរុក្ខជាតិ ឬលតាវល្លិ ប្រមូលស្លឹកឈើជាសម្បុក ខាំឈឺផ្សា ហើយពេលខាំវាមាននោមផង ។
- អភិសេក (ន) : ការប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរថ្វាយជ័យចំពោះព្រះពុទ្ធ ឬក្សត្រីយ៍ឱ្យពេញលក្ខណៈ ។
- អនេក (គុ) : ច្រើន ។

- អញ្ជលី [ អាញ់ជៈលី ] (ន) : ការផ្គុំប្រមាមដៃទាំង១០គោរព ។
- អមរនាគេន្ទ្រ [ អំមៈរៈនាគេន ] (ន) : ដំរីរបស់ទេវតា ។
- អម្ពរ [ អំព ] (ន) : សំពត់ ។
- អធិដ្ឋាន ឬអធិស្ឋាន (ន) : ការតាំងចិត្តនឹកតំរង់ចំពោះ ។
- អនុទិស (បា) (ន) : ទិសបន្ទាប់ពីទិសធំ ទិសតូច ។
- អបលក្ខណ៍ (បា) (ន) : គ្មានភ័ព្វ អាក្រក់គ្មានបុណ្យវាសនា ប្រាសចាកសេចក្ដីល្អអាក្រក់ ។
- អតិសេដ្ឋ (បា) (ន) : ដ៏ប្រសើរក្រៃលែង ។
- អព្ភូតហេតុសូរ្យគ្រាស (បា.សំ) (ន) : សូរ្យគ្រាសជាហេតុភេទដ៏អស្ចារ្យ ។
- អង់ត្រូប៉ូម័ត (បារ) (ន) : សត្វស្វារាងមនុស្ស ។
- អរញ្ញប្រទេស [ អៈរ៉ាញ់-] (ន) : ទីកន្លែងព្រៃ ។
- អត្ថា [ អ័ត-ថា ] (បា.សំ) (ន) : ដងផ្លូវ ។
- អហិង្សា (បា.សំ) (ន) : ការមិនបៀតបៀន មិនធ្វើទុក្ខគ្នា ។
- អង្គកបិ (បា.សំ) (ន) : ស្វា ។
- អរុណោទ័យ (បា.សំ) (ន) : ពេលថ្ងៃរះ ។
- អន្ធការ (បា.សំ) (ន) : ភាពងងឹត ។
- អយ្យកា [ អៈយៈកា ] (ន) : ជីដូន (រ.ស) ។
- អយ្យកោ [ អៈយៈកោ ] (ន) : ជីតា (រ.ស) ។
- អរិយធម៌ (បា) (ន) : ភាពនាំឱ្យមានសេចក្ដីសុខចម្រើនសម្បូររុងរឿង ។
- អរិយធម៌ហិណ្ឌូ (បា.សំ) (ន) : ភាពរីកចម្រើន ភាពរុងរឿងរបស់ហិណ្ឌូ ។
- អស្សពាហ៍ [ អ័ស-សៈ-ពា ] (ន) : សេះ ពាជី ។
- អាជានេយ្យ [ អាជាន័យ ] (ន) : សេះ ។
- អាជីវកម្ម (បា.សំ) (ន) : ការប្រកបមុខរបរចិញ្ចឹមជីវិត ។
- ឧបសម្បទា [ អ៊ុ-ប៉ះស័ម-ប៉ះទា ] (ន) : ការបួសជាភិក្ខុ ។
- ឧត្តម (បា.សំ) (ន) : ភាពខ្ពង់ខ្ពស់រុងរឿងប្រសើរថ្លៃថ្លា ។
- ឧបាសក (បា.សំ) (ន) : បុរសអ្នកបម្រើ ឬកាន់ពុទ្ធសាសនាស៊ប់ ។
- ឧរូ [ អ៊ុរូ ] (ន) : ភ្លៅ ។
- ឧណ្ហា [ អ៊ុនហា ] (គុ) : កម្ដៅ ឬក្ដៅបន្តិចៗ ។

facebook.com/moeys.gov.kh krou.moeys.gov.kh youtube.com/moeys

- ឯករាជ្យ (បា.សំ) (ន) ៖ ភាពនៃរដ្ឋ ឬប្រទេសដែលមានសិទ្ធិសេរីភាពពេញលេញបរិបូរក្នុងការគ្រប់គ្រងខ្លួនឯងមិនចំណុះប្រទេសដទៃ ។
- ឰយុធ្យា [ អៃយុធ្យា ] (ន) ៖ ជាឈ្មោះប្រទេសព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរ ។
- អំឡុង (ន) ៖ កាលដ៏យូរ ។
- អំបែង (ន) ៖ ឈ្មោះឈើមួយប្រភេទជាពួកសារព្រឹក្ស ស្លឹកទ្រវែងៗស្រួចៗពីខាងខ្នង ស្លឹកមានសម្បុរប្រផេះ សម្បកមានសរសៃ បើដើមខ្ចីគេយកសម្បកវាវេញជាខ្សែបានខ្លះ បើដើមធំមានខ្លឹម សម្បុរក្រហមប្រឿងជាប់ស្វិត គេច្រើនយកទៅធ្វើជាទូករទេះ ។
- ឱភា ឬ ឧភា (បា.សំ) (ន) ៖ ទ្រូង ។
- អ្នកលេង (ន) ៖ ក្រុមអ្នកដៃដល់ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh